

# ការរៀបចំសម្រាប់ អាពាហ៍ពិពាហ៍ ក្នុងព្រះអម្ចាស់

Gregory Brown



រក្សាសិទ្ធគ្រប់យ៉ាង © ២០១៥ ដោយលោក ហ្គ្រេកហ្គ័រី ប្រោន

Copyright © 2015 by Gregory Brown

បោះពុម្ពដោយក្រុម៖ BTG Publishing

"A special thanks to LATM for helping to print and distribute this material"

# មាតិកា

មូលដ្ឋានគ្រឹះទី១៖ ផែនការរបស់ព្រះសម្រាប់អាពាហ៍ពិពាហ៍ . . . . . . . . . . . . . . . . . . . . ៨
មូលដ្ឋានគ្រឹះទី២៖ ការប្ដេជ្ញានៅក្នុងអាពាហ៍ពិពាហ៍ . . . . . . . . . . . . . . . . . . . . . . . . ២០
មូលដ្ឋានគ្រឹះទី៣៖ ការប្រាស្រ័យទាក់ទងនៅក្នុងអាពាហ៍ពិពាហ៍ . . . . . . . . . . . . . . . ៣២
មូលដ្ឋានគ្រឹះទី៤៖ តួនាទីយេនឌ័រនៅក្នុងអាពាហ៍ពិពាហ៍ . . . . . . . . . . . . . . . . . . . . . ៤៤
មូលដ្ឋានគ្រឹះទី៥៖ ការដោះស្រាយទំនាស់នៅក្នុងអាពាហ៍ពិពាហ៍ . . . . . . . . . . . . . . . ៥៨
មូលដ្ឋានគ្រឹះទី៦៖ ភាពស្មោះត្រង់ផ្នែកហិរញ្ញវត្ថុនៅក្នុងអាពាពិពាហ៍ . . . . . . . . . . . . ៧២
មូលដ្ឋានគ្រឹះទី៧៖ ភាពស្និទ្ធស្នាលនៅក្នុងអាពាហ៍ពិពាហ៍ . . . . . . . . . . . . . . . . . . . . ៩០

# សេចក្ដីផ្ដើម

សូមស្វាគមន៍! ជាការពិតអ្នកបានជ្រើសរើសយកការសិក្សានេះមានន័យថា អ្នកយកចិត្តទុកដាក់អំពីការមានអាពាហ៍ពិពាហ៍នៅក្នុងព្រះជាម្ចាស់ ដែលជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ការផ្ដោតអារម្មណ៍ទៅលើការសិក្សានេះ គឺជាការប្រឹក្សាយោបល់មុនពេលរៀបអាពាហ៍ពិពាហ៍តាមបទគម្ពីរ ប៉ុន្តែគោលការណ៍ដែលបានបង្រៀននឹងល្អសម្រាប់គូអាពាហ៍ពិពាហ៍ផងដែរ។ ការសិក្សានេះខុសពីការសិក្សាព្រឹក្សាយោបល់ផ្សេងៗ ដោយយើងនឹងមិនផ្ដោតលើចិត្តវិទ្យានោះទេ ប៉ុន្តែផ្ដោតលើព្រះគម្ពីរវិញ។ យើងនឹងបង្រៀនការនេះ ពីព្រោះយើងជឿលើភាពគ្រប់គ្រាន់នៃបទគម្ពីរ។ កណ្ឌគម្ពីរ ២ធីម៉ូថេ ៣:១៦-១៧ ចែងថា: *«គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្ដាលឲ្យតែងទេ ក៏មានប្រយោជន៍សម្រាប់ការបង្រៀន ការរំឭកឲ្យដឹងខ្លួន ការប្រដៅដំរង់ និងការបង្ហាត់ខាងឯសេចក្ដីសុចរិត ដើម្បីឲ្យអ្នកសំណប់របស់ព្រះបានគ្រប់លក្ខណ៍ ហើយមានគ្រប់ទាំងចំណេះ សម្រាប់នឹងធ្វើការល្អគ្រប់មុខ»*។

«ធ្វើការល្អ» បទគម្ពីរនឹងរៀបចំអ្នកឲ្យឆ្លងកាត់ការសិក្សានេះគឺអាពាហ៍ពិពាហ៍។ ព្រះទ្រង់បានបង្កើតអាពាហ៍ពិពាហ៍(លោកុប្បត្តិ១:២៧) ទ្រង់បានរៀបចំវា គឺមានអត្ថន័យឆ្លុះបញ្ចាំងទ្រង់ (១កូរិថូស ១:១៣ អេភេសូ៥:២២-២៧) ហើយទ្រង់ប្រទាននូវសេចក្ដីណែនាំនៅក្នុងព្រះបន្ទូលទ្រង់ពីរបៀបដែលគួរតែបានអភិវឌ្ឍន៍និងថែរក្សា។

នៅក្នុងការសិក្សានេះ យើងនឹងពិចារណាពីមូលដ្ឋានគ្រឹះទាំងប្រាំពីរសម្រាប់អាពាហ៍ពិពាហ៍នៅក្នុងព្រះអម្ចាស់ ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ការប្ដេជ្ញាចិត្ត ការប្រាស្រ័យទាក់ទង តួនាទីយេនឌ័រ ការដោះស្រាយទំនាស់ ផ្នែកហិរញ្ញវត្ថុ និងភាពស្និទ្ធស្នាល។ដូចជាមូលដ្ឋានគ្រឹះនៃការសាងសង់នានា ប្រសិនបើមានស្នាមប្រេះខាងរចនា ផ្ទះនឹងមានបញ្ហានិងមិនស្ថិតស្ថេរឡើយ។ ដូចដែលបានរៀបរាប់រួចមកហើយថា គ្រប់មូលដ្ឋានគ្រឹះនីមួយៗនឹងបានសង់ឡើងឬស្ដារឡើងវិញដោយប្រើព្រះបន្ទូលរបស់ព្រះ។ នៅក្នុងការនិយាយអំពីជីវិតជាគ្រីស្ទបរិស័ទ ព្រះគ្រីស្ទបានមានព្រះបន្ទូលពីផ្ទះដែលបានសង់នៅលើថ្មនៃព្រះបន្ទូលទ្រង់នឹងឈរមាំ(ម៉ាថាយ៧:២៤-២៥) ប្រាកដណាស់ នេះក៏ដូចទៅនឹងអាពាហ៍ពិពាហ៍ផងដែរ។

**ទិដ្ឋភាពទូទៅ**

នេះនឹងជាការទាមទារឲ្យសិក្សា សម្រាប់គោលបំណងប្រឹក្សាយោបល់ ការនេះគឺបានបញ្ចប់យ៉ាងល្អបំផុតជាមួយដៃគូរបស់អ្នកក្រោមការណែនាំឬប្តីប្រពន្ធអ្នកណែនាំ។ ទោះជាយ៉ាងណាក៏ដោយការសិក្សានេះក៏នឹងជាព្រះពរសម្រាប់អ្នកណាដែលសិក្សាលក្ខណបុគ្គលឬជាក្រុមតូចៗផងដែរ។ ការរំពឹងទុកសម្រាប់វគ្គនីមួយៗមានដូចខាងក្រោមៈ

- អានមេរៀននិងបំពេញកិច្ចការផ្ទះនីមួយៗ
- ពិភាក្សាចម្លើយអំពីកិច្ចការផ្ទះជាមួយដៃគូរបស់អ្នក(និង/ឬក្រុមតូច)
- ពិភាក្សាចម្លើយជាមួយការណែនាំ ឬប្តីប្រពន្ធអ្នកណែនាំដើម្បីទទួលបានការយល់ដឹង និងការប្រឹក្សាប្រសិនបើអាចធ្វើទៅបាន។

ការសិក្សានេះគឺមានប្រាំពីរវគ្គ។ អ្នកគួរតែមានបំណងចិត្តដើម្បីបំពេញឬបញ្ចប់យ៉ាងហោចណាស់ឲ្យបានមួយវគ្គក្នុងមួយសប្តាហ៍។

# មូលដ្ឋានគ្រឹះទី១៖ ផែនការរបស់ព្រះសម្រាប់អាពាហ៍ពិពាហ៍

ព្រះជាម្ចាស់ទ្រង់បានមានបន្ទូលថា «ទ្រង់ក៏មានបន្ទូលថា ចូរយើងធ្វើមនុស្សឲ្យដូចជារូបយើង ឲ្យមានភាពដូចយើង ហើយឲ្យមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស នឹងសត្វជើង៤ដែលនៅលើផែនដីទាំងមូល ព្រមទាំងសត្វលូនវារដែលវារនៅផែនដីផង»។ ទ្រង់ក៏បង្កើតមនុស្សឲ្យដូចរូបអង្គទ្រង់ គឺបានបង្កើតគេឲ្យចំនឹងរូបអង្គទ្រង់នោះឯង ក៏បង្កើតគេឡើងជាប្រុសជាស្រី។ ទ្រង់ប្រទានពរដល់គេ ហើយមានបន្ទូលថា ចូរបង្កើតកូនឲ្យចំរើនជាច្រើនឡើង ឲ្យមានពេញពាសលើផែនដីចុះ ត្រូវបង្ក្រាបផែនដី ហើយមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស នឹងជីវិតផងទាំងឡាយដែលកំរើកនៅផែនដីផង។ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់មានព្រះបន្ទូលថា ដែលមនុស្សនេះនៅតែម្នាក់ឯង នោះមិនស្រួលទេ អញនឹងធ្វើឲ្យមានម្នាក់ជាជំនួយសំរាប់ជួយវា។ដោយហេតុនោះ បានជាមនុស្សប្រុសនឹងលាចេញពីឪពុកម្តាយខ្លួនទៅនៅជាប់នឹងប្រពន្ធវិញហើយអ្នកទាំង២នោះនឹងត្រឡប់ជាសាច់តែ១សុទ្ធ (លោកុប្បត្តិ ១:២៦-២៨ ២:១៨, ២៤) ។

នៅក្នុងផ្នែកនេះ យើងនឹងពិចារណាពីគម្រោងផែនការរបស់ព្រះជាម្ចាស់សម្រាប់ អាពាហ៍ពិពាហ៍ ដូចដែលយើងបានឃើញសាច់រឿងនៅក្នុងព្រះគម្ពីរលោកុប្បត្តិរួចមកហើយ។ គូអាពាហ៍ពិពាហ៍ភាគច្រើនបានភ្លេចពីផែនការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ពីព្រោះតែពួកគេមិនបានដឹងអ្វីដែលជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់អាពាហ៍ពិពាហ៍។ ប្រសិនបើអ្នកមិនបានដឹងពីគោលបំណងនៃរបស់អ្វីមួយ នោះយើងនឹងប្រើប្រាស់របស់នោះខុសជាមិនខានឡើយ។ ហេតុនោះបានជាជាង៥០%នៃអាពាហ៍ពិពាហ៍បានបញ្ចប់ដោយការលែងលះ ហើយអ្នកដែលបន្តនៅក្នុងអាពាហ៍ពិពាហ៍មួយចំនួនធំនៅតែមិនដឹងពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ការរួបរួមរបស់ពួកគេដែរ។

ថ្ងៃនេះយើងនឹងជួយជម្រុញអាពាហ៍ពិពាហ៍របស់អ្នកឬក៏អាពាហ៍ពិពាហ៍នៅពេលអនាគតរបស់អ្នកទៅក្នុងព្រះហឫទ័យរបស់ព្រះជាម្ចាស់តាមរយៈការសិក្សាព្រះបន្ទូលរបស់ទ្រង់។ នៅក្នុងផ្នែកនេះ យើងនឹងពិចារណាអំពីទស្សនៈ៥នៃផែនការរបស់ព្រះជាម្ចាស់សម្រាប់អាពាហ៍ពិពាហ៍។

### ផែនការរបស់ព្រះជាម្ចាស់សម្រាប់អាពាហ៍ពិពាហ៍ គឺសម្រាប់ឆ្លុះបញ្ចាំងពីរូបអង្គទ្រង់

*ទ្រង់ក៏មានបន្ទូលថា ចូរយើងធ្វើមនុស្សឲ្យដូចជារូបយើង ឲ្យមានភាពដូចយើង ហើយឲ្យមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស នឹងសត្វជើង៤ដែលនៅលើផែនដីទាំងមូល ព្រមទាំងសត្វលូនវារដែលវារនៅផែនដីផង ទ្រង់ក៏បង្កើតមនុស្សឲ្យដូចរូបអង្គទ្រង់ គឺបានបង្កើតគេឲ្យចំនឹងរូបអង្គទ្រង់នោះឯង ក៏បង្កើតគេឡើងជាប្រុសជាស្រី (លោកុប្បត្តិ១:២៦-២៧)។*

ព្រះគម្ពីរបានបង្រៀនពីអ័ដាមនិងអេវ៉ាប្រៀបដូចជាប្តីនិងប្រពន្ធដែលត្រូវបានបង្កើតនៅក្នុងរូបអង្គ

របស់ព្រះជាម្ចាស់ ហេតុនោះគឺមានន័យថា ពួកគេត្រូវបានបំពាក់រូបអង្គទ្រង់ ដើម្បីឲ្យបានដូចជារូបអង្គរបស់ព្រះជាម្ចាស់។ អាពាហ៍ពិពាហ៍នោះមានន័យថា ជាគំរូនិងសម្ដែងឲ្យឃើញពីសិរីល្អរបស់ព្រះជាម្ចាស់ទៅដល់ស្នាព្រះហស្ដរបស់ទ្រង់ទាំងអស់។

តើនៅក្នុងវិធីណាដែលរូបអង្គទ្រង់ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការរួបរួមនៃអាពាហ៍ពិពាហ៍?

យើងឃើញរូបអង្គទ្រង់នៅក្នុងភាពជាពហុវចនៈ (ព្រះវបិតា ព្រះរាជ្យបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ) និងការរួបរួមនៃអាពាហ៍ពិពាហ៍។ *ទ្រង់ក៏មានបន្ទូលថាចូរយើងធ្វើមនុស្សឲ្យដូចជារូបយើង* ហើយអត្ថបទបន្តទៀតថា *ទ្រង់ក៏បង្កើតគេឡើងជាប្រុសជាស្រី* (ខ២៦-២៧)។ នៅពេលដែលព្រះអង្គទ្រង់បង្កើតមនុស្សប្រុស ទ្រង់បានបង្កើតជាពហុវចនៈ  ពោលគឺបីរួមមកតែមួយ។ ទ្រង់បានបង្កើតមនុស្សប្រុស មនុស្សស្រី និងក្រោយមកនៅក្នុងសាច់រឿង  ទ្រង់មានបន្ទូលទៀតថា ពួកគេនឹងក្លាយជា «សាច់តែមួយ» (លោកុប្បត្តិ ២:២៤)។

ព្រះត្រៃឯកគឺមាន ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ទ្រង់ទាំង៣អង្គគឺតែមួយ និងជាអង្គបុគ្គលដាច់ដោយឡែកពីគ្នា។ នៅពេលដែលគូស្នេហ៍រៀបអាពាហ៍ពិពាហ៍ ពួកគេគឺជាគំរូពីការនេះ។ អាពាហ៍ពិពាហ៍ជាគំរូបុគ្គល២ផ្សេងគ្នាត្រឡប់ជារូបកាយតែមួយពេញមួយជីវិតរបស់ពួកគេក្នុងកំឡុងពេលដែលពួកគេជាបុគ្គលផ្សេងគ្នា។

ការនេះក៏អាចនិយាយបានដែរថា ព្រះត្រៃឯកគឺជាគំរូនៃការរួបរួមរបស់អាពាហ៍ពិពាហ៍។ នៅក្នុងព្រះត្រៃឯក ព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រាទ្រង់ចុះចូលគ្រប់កិច្ចការទាំងអស់ទៅចំពោះព្រះវរបិតា (យ៉ូហាន ៥:១៩; ១កូរិនថូស១៥:២៧) ហើយព្រះវិញ្ញាណបរិសុទ្ធទ្រង់ចុះចូលចំពោះអង្គទាំង២ (យ៉ូហាន ១៤:២៦; ១៥:២៦) ទាំងនេះជាការចុះចូលចំពោះគ្នាដ៏ល្អឥតខ្ចោះនៅក្នុងព្រះជាម្ចាស់។ ក្នុងរបៀបដូចគ្នានេះដែរ នៅពេលដែលព្រះជាម្ចាស់ទ្រង់បានបង្កើតមនុស្សប្រុសនិងមនុស្សស្រី នៅក្នុងរូបអង្គទ្រង់ នោះគឺមានន័យថា ដើម្បីឲ្យតាមលំដាប់លំដោយនៅក្នុងទំនាក់ទំនង។ ១កូរិនថូស ១១:៣ ចែងថា *«តែខ្ញុំចង់ឲ្យអ្នករាល់គ្នាដឹងថា ព្រះគ្រីស្ទជាសិរសានៃបុរសទាំងអស់ ឯបុរសវិញ នោះជាក្បាលនៃស្ត្រី ហើយសិរសានៃព្រះគ្រីស្ទ គឺជាព្រះ» ។*

សាវ័កប៉ុលនិយាយថា ព្រះសិរសានៃព្រះគ្រីស្ទគឺជាព្រះ ដូច្នេះ ក្បាលរបស់ស្ត្រី (ពាក្យដែលល្អជាងគឺប្រពន្ធ) គឺជាបុរស។ ព្រះទ្រង់បានបង្កើតទំនាក់ទំនងរវាងប្ដីនិងប្រពន្ធ ដើម្បីជាកញ្ចក់ឆ្លុះបញ្ចាំងពីព្រះជាម្ចាស់ ជាពិសេសនៅក្នុងសិទ្ធិអំណាចរបស់ទ្រង់។ ហេតុនេះ អេភេសូរ៥:១៤ ហៅឲ្យប្រពន្ធចុះចូលចំពោះប្ដីក្នុងគ្រប់ការទាំងអស់។

គំរូនៃព្រះត្រៃឯកមួយទៀត គឺសេចក្ដីស្រឡាញ់នៅក្នុងអាពាហ៍ពិពាហ៍។ ប្រពន្ធចុះចូលចំពោះប្ដី ហើយប្ដីស្រឡាញ់ប្រពន្ធរបស់ខ្លួន។ ចូរពិចារណានៅក្នុងអេភេសូរ៥:២៥-២៧៖

*២៥បុរសរាល់គ្នាអើយ ចូរស្រឡាញ់ប្រពន្ធខ្លួន ដូចជាព្រះគ្រីស្ទបានស្រឡាញ់ដល់ពួកជំនុំ ហើយបានប្រគល់ព្រះអង្គទ្រង់ជំនួសផង ២៦ដើម្បីឲ្យទ្រង់បានញែកពួកជំនុំចេញជាបរិសុទ្ធ ដោយបានលាងសំអាតនឹងទឹក គឺជាព្រះបន្ទូល ២៧ប្រយោជន៍នឹងថ្វាយពួកជំនុំនេះដល់ព្រះអង្គទ្រង់ទុកជាពួកជំនុំដ៏ឧត្ដម ឥតប្រឡាក់ ឥតជ្រួញ ឬមានអ្វីឲ្យដូចឡើយ គឺឲ្យបានបរិសុទ្ធ ហើយឥតកន្លែងបន្ទោសបានវិញ។*

ការចុះចូលរបស់ប្រពន្ធកើតឡើងនៅក្នុងទំនាក់ទំនងនៃសេចក្ដីស្រឡាញ់យ៉ាងល្អឥតខ្ចោះជាមួយប្ដីរបស់នាង។ ដូចគ្នានេះដែរជារៀងរហូត ព្រះជាម្ចាស់ទ្រង់តែងតែស្ថិតនៅក្នុងទំនាក់ទំនងនៃសេចក្ដីស្រឡាញ់ដ៏ល្អឥតខ្ចោះនិងសិទ្ធិអំណាចផងដែរ។ ព្រះវរបិតាទ្រង់ស្រឡាញ់ដល់ព្រះរាជបុត្រា ហើយព្រះរាជបុត្រាទ្រង់ចុះចូលចំពោះព្រះវរបិតា។ ព្រះវរបិតាមិនបានសង្កត់សង្កិនព្រះរាជបុត្រា ហើយបង្ខំឲ្យទ្រង់ចុះចូលនោះទេ។ ទ្រង់ស្រឡាញ់ព្រះរាជបុត្រានិងនៅក្នុងសេចក្ដីស្រឡាញ់ដ៏ល្អឥតខ្ចោះ ព្រះរាជបុត្រាចុះចូលចំពោះព្រះវរបិតា។ ព្រះវិញ្ញាណបរិសុទ្ធ ស្រឡាញ់ និងចុះចូលចំពោះអង្គទាំងពីរ។ នៅក្នុង ១យ៉ូហាន៤:១៨ និយាយយ៉ាងសាមញ្ញថា ព្រះទ្រង់ជាសេចក្ដីស្រឡាញ់។

ដូចគ្នានេះដែរ ភរិយាត្រូវបានហៅឲ្យចុះចូលចំពោះស្វាមីរបស់ខ្លួន និងស្វាមីត្រូវបានហៅឲ្យស្រឡាញ់ដល់ភរិយារបស់ខ្លួន។ មិនមែនមានន័យថា ប្រពន្ធមិនចាំបាច់ស្រឡាញ់ប្ដី ហើយប្ដីមិនចាំបាច់ចុះចូលចំពោះប្រពន្ធរបស់ខ្លួននោះទេ (អេភេសូរ៥:១២)។ វាគ្រាន់តែបង្ហាញពីអត្តចរិករបស់ប្រពន្ធក្នុងការបម្រើដល់ប្ដីរបស់ខ្លួនដោយការចុះចូល ហើយបង្ហាញពីអត្តចរិករបស់ប្ដីក្នុងការបម្រើដល់ប្រពន្ធរបស់ខ្លួនដោយសេចក្ដីស្រឡាញ់។ នេះគឺជាផ្នែកមួយដែលយើងអាចមើលឃើញពីរូបអង្គរបស់ព្រះជាម្ចាស់នៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍។

អេភេសូរ៥:២៥ ផ្ដល់ឲ្យយើងនូវរូបភាពនៃសេចក្ដីស្រឡាញ់របស់ប្ដីគួរតែមាន។ វាគួរតែឆ្លុះបញ្ចាំងពីព្រះគ្រីស្ទ។ ស្វាមីគ្រប់រូបត្រូវបានហៅឲ្យស្រឡាញ់ភរិយារបស់ខ្លួន ដូចជាព្រះគ្រីស្ទបានស្រឡាញ់ដល់ពួកជំនុំដែរ។ តើព្រះគ្រីស្ទស្រឡាញ់ដល់ពួកជំនុំដោយរបៀបណា? គឺទ្រង់បានសុគតសម្រាប់ពួកជំនុំ និងប្ដីត្រូវបង្រៀនប្រពន្ធរបស់ខ្លួនពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ស្វាមីគ្រប់រូបត្រូវតែស្រឡាញ់ភរិយារបស់ខ្លួនដោយលះបង់ និងដឹកនាំប្រពន្ធរបស់ខ្លួនឲ្យមានការរីកចម្រើនខាងឯព្រលឹងវិញ្ញាណ។

នៅពេលដែលលោកីយ៍សម្លឹងមើលទៅអាពាហ៍ពិពាហ៍គ្រីស្ទបរិស័ទ ពួកគេគួរតែសម្លឹងមើលឃើញពីស្វាមីដែលលះបង់ចំពោះប្រពន្ធរបស់ខ្លួនជាប្រចាំនិងសកម្មភាពដឹកនាំផ្ទះខាងព្រលឹងវិញ្ញាណ។ ស្វាមីជាអ្នកនាំគ្រួសាររបស់ខ្លួនទៅរកការអធិប្បាយព្រះបន្ទូលនៅក្នុងពួកជំនុំ។ ស្វាមីដឹកនាំនៅក្នុងការថ្វាយបង្គំផ្ទាល់ខ្លួន។ ស្វាមីបម្រើប្រពន្ធរបស់ខ្លួន និងកែតម្រូវនាងដោយពាក្យសម្ដីសមរម្យ។ ស្វាមីលះបង់ដើម្បីធ្វើឲ្យប្រពន្ធរបស់ខ្លួនរីករាយ និងស្អាងនាងឡើង។ ភរិយាផ្ដល់កិត្តិយសដល់ប្ដីរបស់ខ្លួនក្នុងនាមជាក្បាលរបស់នាង និងចុះចូលក្នុងគ្រប់កិច្ចការទាំងអស់ (កូល៉ុស៣:១៨)។ នេះគឺជារូបភាពនៃការសង្គ្រោះរបស់ដំណឹងល្អ។

អាពាហ៍ពិពាហ៍គួរតែជាគំរូពីសេចក្ដីស្រឡាញ់ដ៏ល្អឥតខ្ចោះនិងការចុះចូលចំពោះព្រះជាម្ចាស់។ វាគួរតែឆ្លុះបញ្ចាំងពីការលះបង់ដោយសេចក្ដីស្រឡាញ់ដ៏ល្អឥតខ្ចោះរបស់ព្រះគ្រីស្ទសម្រាប់ពួកជំនុំ និងពួកជំនុំចុះចូលចំពោះព្រះគ្រីស្ទ។ មនុស្សគួរតែលើកទឹកចិត្ត និងជម្រុញគ្នាដោយមើលពីអាពាហ៍ពិពាហ៍របស់គ្រីស្ទបរិស័ទ។ ពួកគេគួរតែមើលឃើញសិរីល្អ និងភាពអស្ចារ្យរបស់ព្រះជាម្ចាស់។

ហេតុយ៉ាងដូច្នេះ នៅពេលដែលអាពាហ៍មិនបានដើរតួនាទីត្រឹមត្រូវ វាបង្ហាញពីរូបអង្គរបស់ព្រះជាម្ចាស់ និងធ្វើឲ្យខូចអត្ថន័យដើមរបស់អាពាហ៍ពិពាហ៍។ ជាមួយនឹងអាពាហ៍ពិពាហ៍ជាច្រើន ដែលបញ្ចប់ដោយការលែងលះគ្នា និងបន្តក្នុងភាពច្របូកច្របល់ នោះធ្វើឲ្យសិរីល្អរបស់ព្រះត្រូវបានស្រអាប់

យ៉ាងខ្លាំង។ វាមិនមែនជារឿងភ្ញាក់ផ្អើលនោះទេ ដែលមានមនុស្សជាច្រើនបានសង្ស័យពីព្រះវត្តមានរបស់ព្រះជាម្ចាស់ និងឃ្លាតឆ្ងាយពីព្រះអង្គ។ ពន្លឺនៅក្នុងអាពាហ៍ពិពាហ៍ក្លាយទៅជាងងឹត ដែលជម្រុញឲ្យមនុស្សចេញឆ្ងាយពីព្រះជាម្ចាស់។ នៅក្នុងអាពាហ៍ពិពាហ៍ បំណងចិត្តរបស់យើងគួរតែឆ្លុះបញ្ចាំងពីព្រះជាម្ចាស់ និងថ្វាយសិរីល្អដល់ទ្រង់ ដែលនេះគឺជាគំរោងផែនការដើមរបស់ព្រះអង្គ។

**ផែនការរបស់ព្រះជាម្ចាស់សម្រាប់អាពាហ៍ពិពាហ៍គឺ ចម្រើនកូនរបស់ព្រះជាម្ចាស់**

*ទ្រង់ប្រទានពរដល់គេ ហើយមានបន្ទូលថា ចូរបង្កើតកូនឲ្យចំរើនជាច្រើនឡើង ឲ្យមានពេញពាសលើផែនដីចុះ (លោកុប្បត្តិ១:២៨)។*

ចំណុចមួយទៀត ការចិញ្ចឹមកូនត្រូវបានពិចារណាជាធំ ឬជាចំណុចខ្ពស់បំផុតនៃអាពាហ៍ពិពាហ៍ និងជារឿងគួរឲ្យគោរពបំផុត។ ទោះជាយ៉ាងនេះក៏ដោយ បច្ចុប្បន្ននេះ កូនបានក្លាយជាបន្ទុក និងជាឧបករណ៍ដែលសម្លាប់សេចក្តីអំណររបស់គូស្វាមីភរិយា ហើយពេលខ្លះសង្គមក៏បានគិតយ៉ាងដូច្នោះដែរ។ ចំណុចគន្លឹះមួយដែលមានភាពខុសគ្នារវាងទេវតានិងចិត្តមនុស្ស នោះគឺជាក់ស្តែងដែលព្រះជាម្ចាស់បង្កើតមនុស្ស ដើម្បីឲ្យមនុស្សអាចបន្តពូជពង្សបាន (អាចបង្កើតមនុស្សថ្មី) ដូចជាព្រះទ្រង់បានបង្កើតមនុស្សមកដែរ។ នៅពេលដែលគូស្វាមីភរិយាសុខចិត្តលះបង់ចោលលទ្ធភាពដែលអាចមានកូនបាន ដោយព្រោះ ការងារ ទម្លាប់ សេរីភាព ជាដើម នោះពួកគេបាត់បង់នូវចំណុចខ្ពស់បំផុត និងអស្ចារ្យបំផុតរបស់ព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់អាពាហ៍ពិពាហ៍។ ការនេះត្រូវបានគាំទ្រដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់តាមរយៈហោរា ម៉ាឡាគី។

*តើទ្រង់មិនបានបង្កើត ឲ្យមានតែ១ទេឬ ទោះបើទ្រង់មានព្រះវិញ្ញាណសល់នៅក៏ដោយ ហើយហេតុអ្វីបានជាបង្កើតតែមួយដូច្នេះ គឺពីព្រោះទ្រង់ស្វែងរកចង់បានពូជបរិសុទ្ធ ដូច្នេះ ចូរប្រយ័ត ចំពោះវិញ្ញាណរបស់ឯងចុះ កុំឲ្យប្រព្រឹត្តដោយមានចិត្តក្បត់ ចំពោះប្រពន្ធដែលបានគ្នា ពីកាលនៅក្រមុំកំឡោះនោះឡើយ (ម៉ាឡាគី២:១៥)។*

អត្ថបទគម្ពីរនេះប្រកាសពីសេចក្តីបង្គាប់របស់ព្រះជាម្ចាស់សម្រាប់ឲ្យមនុស្សបង្កើតផលផ្លែ ឬបង្កើតផលឲ្យចម្រើនឡើង ដូចជានៅក្នុងកណ្ឌគម្ពីរលោកុប្បត្តិ១:២៨ដែរ។ មិនមែនគ្រាន់តែជាកូនទេ ដែលទ្រង់ចង់បាន ប៉ុន្តែជាកូនរបស់ព្រះ។ ទ្រង់ចង់បានកូនដែលជាមនុស្សបរិសុទ្ធ និងត្រូវបាននាំឲ្យឃើញនគររបស់ព្រះជាម្ចាស់។ គោលបំណងមួយដែលខ្ពស់បំផុតរបស់ឪពុកម្តាយ គឺបង្រៀនព្រះគម្ពីរដល់កូនរបស់ខ្លួននិងជួយឲ្យពួកគេរីកចម្រើនផ្នែកអត្តចរិកនិងជួយពួកគេឲ្យស្វែងរកឃើញនូវអំណោយទានខាងឯព្រលឹងវិញ្ញាណរបស់ពួកគេ និងការត្រាស់ហៅ ដើម្បីបម្រើដល់ព្រះជាម្ចាស់។

ឥឡូវនេះ យើងត្រូវតែកំណត់ចំណាំថា វាមិនមែនជាព្រះហឫទ័យរបស់ព្រះសម្រាប់គ្រប់គ្នាត្រូវមានកូននោះទេ បញ្ហាខាងរូបកាយនាំឲ្យយើងមិនអាចមានកូនបានដែរ ហើយសម្រាប់អ្នកខ្លះ ព្រះបានត្រាស់ហៅមិនឲ្យពួកគេមានគូស្រករតែម្តង។ ប៉ុន្តែជាទូទៅ វាគឺជាព្រះហឫទ័យរបស់ព្រះជាម្ចាស់តាំងពីការចាប់ផ្តើមសម្រាប់មនុស្សមក ដើម្បីបង្កើតផលផ្លែ និងបង្កើតផលឲ្យបានចម្រើនឡើងជាពហុគុណ

(លោកុប្បត្តិ១:២៨)។ ការមានកូនគួរតែពិចារណាដូចជារបៀបមួយដែលយើងស្ដាប់បង្គាប់ព្រះជាម្ចាស់ និងសាងសង់នគររបស់ទ្រង់ឡើង។ ថ្វីបើយ៉ាងនោះក៏ដោយ យើងគួរតែអធិស្ឋានសម្រាប់ការនេះ និងរៀបគម្រោងដូចជាយើងធ្វើព័ន្ធកិច្ចផ្សេងៗទៀតដែរ។

**ផែនការរបស់ព្រះសម្រាប់អាពាហ៍ពិពាហ៍ គឺដើម្បីបង្កើត និងសាងសង់នគរព្រះឡើង**

*ទ្រង់ប្រទានពរដល់គេ ហើយមានបន្ទូលថា ចូរបង្កើតកូនឲ្យចំរើនជាច្រើនឡើង ឲ្យមានពេញពាសលើផែនដីចុះ ត្រូវបង្ក្រាបផែនដី ហើយមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស នឹងជីវិតផងទាំងឡាយដែលកំរើកនៅផែនដីផង (លោកុប្បត្តិ១:២៨)។*

ក្រោយដែលទ្រង់បានប្រាប់ដល់អ័ដាម និងអេវ៉ាឲ្យបង្កើតផល និងចម្រើនផលឡើង ព្រះជាម្ចាស់បានប្រាប់អ័ដាមឲ្យបង្ក្រាប និងគ្រប់គ្រងលើផែនដី។ ពួកគេត្រូវគ្រប់គ្រងការបង្កើតរបស់ព្រះជាម្ចាស់ និងបម្រើព្រះជាម្ចាស់រួមគ្នា។ ការនេះត្រូវបានពង្រីកដល់អាពាហ៍ពិពាហ៍នៅក្នុងសញ្ញាថ្មី ដែលត្រូវបានពណ៌នាថា ជាអំណោយទានខាងឯវិញ្ញាណក្នុងការសាងសង់រូបកាយរបស់ព្រះគ្រីស្ទឡើង និងពង្រីកនគររបស់ព្រះជាម្ចាស់។ ពិចារណាអ្វីដែលសាវ័កប៉ុលបាននិយាយនៅក្នុង ១កូរិនថូស៧:៧៖

*ពេលខ្លះ ខ្ញុំចង់ឲ្យគ្រប់មនុស្សទាំងអស់នៅលីវដូចជាខ្ញុំ ជីវិតសាមញ្ញមានច្រើនរបៀបណាស់! តែការមិនរួមភេទរីកាពនៅលីវមិនមែនសម្រាប់គ្រប់គ្នានោះទេ គឺដូចគ្នានិងការរៀបការក៏មិនសម្រាប់គ្រប់គ្នាដែរ អ្នកខ្លះនឹងត្រូវនៅលីវរហូត ហើយអ្នកខ្លះរៀបការ។ ព្រះជាម្ចាស់បានប្រទានអំណោយទាននៃជីវិតនៅលីវដល់អ្នកខ្លះ ហើយខ្លះទៀតមានអំណោយទាននៃជីវិតអាពាហ៍ពិពាហ៍។*

នៅទីនេះសាវ័កប៉ុលបានបង្រៀនថាអាពាហ៍ពិពាហ៍គឺជាអំណោយទានខាងឯវិញ្ញាណ ដូចជាការនៅតែឯងដែរ (នៅលីវ)។ ហើយតាំងពីអំណោយទានទាំងអស់បានផ្ដល់ឲ្យសាងសង់រូបកាយរបស់ព្រះគ្រីស្ទ និងនគររបស់ព្រះជាម្ចាស់ឡើង (១កូរិនថូស១២:៧) អាពាហ៍ពិពាហ៍ដែលតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺជាអាវុធដ៏មានថាមពលសម្រាប់នគរព្រះ។ ពួកគេសាងសង់នគរព្រះជាម្ចាស់ឡើងតាមរយៈការបង្កើតពូជពង្សរបស់ព្រះជាម្ចាស់ រួមគ្នាក្នុងសេចក្ដីអធិស្ឋាន បម្រើព្រះជាម្ចាស់នៅក្នុងពួកជំនុំ និងផ្សាយដំណឹងល្អទៅដល់ពិភពលោកទាំងមូល។

ជាការពិត គ្រប់ដៃគូអាពាហ៍ពិពាហ៍ទាំងអស់សុទ្ធតែមានអំណោយទានពិសេស និងរបៀបយ៉ាងពិសេសរបស់ព្រះជាម្ចាស់ក្នុងការត្រាស់ហៅពួកគេឲ្យសាងសង់នគររបស់ព្រះជាម្ចាស់។ គូខ្លះអាចបម្រើនៅក្នុងការដឹកនាំការថ្វាយបង្គំ គូខ្លះបម្រើតាមរយៈការបង្រៀន ហើយគូខ្លះទៀតខាងបដិសណ្ឋារកិច្ច ឬទទួលរាក់ទាក់ ហើយខ្លះទៀតក៏បម្រើនៅក្នុងបេសសកម្មជាដើម។ ដៃគូនីមួយៗត្រូវតែសម្លឹងមើលពីរបៀបពិសេសតែមួយដែលព្រះជាម្ចាស់ត្រាស់ហៅពួកគេចូលមក ដើម្បីសាងសង់នគររបស់ព្រះជាម្ចាស់។

តើអ្វីខ្លះដែលព្រះជាម្ចាស់ត្រាស់ហៅអ្នក និងដៃគូរបស់អ្នកឲ្យសាងសង់នគរព្រះឡើង?

**ផែនការរបស់ព្រះជាម្ចាស់សម្រាប់អាពាហ៍ពិពាហ៍ គឺភាពជាដៃគូជីវិត**

*ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់មានបន្ទូលថា ដែលមនុស្សនេះនៅតែម្នាក់ឯង នោះមិនស្រួលទេ អញ*

*នឹងធ្វើឲ្យមានម្នាក់ជាជំនួយសំរាប់ជួយវា (លោកុប្បត្តិ២:១៨)។*

ព្រះជាម្ចាស់បានដាក់បំណងចិត្តយ៉ាងជ្រៅនៅក្នុងចិត្តមនុស្សសម្រាប់ដៃគូជីវិតស្និទ្ធស្នាល។ ហេតុនេះបានជាមនុស្សនៅលីវភាគច្រើនគិតថាពួកគេមានគ្រួសារ និងមិត្តភក្តិ ពួកគេនៅតែចង់បានអ្វីបន្ថែម ដើម្បីមកបំពេញភាពឯកការបស់ពួកគេ។ ព្រះជាម្ចាស់បង្កើតបុរសមក ដើម្បីឲ្យរៀបការជាមួយស្ត្រី ហើយឲ្យស្ត្រីរៀបការជាមួយបុរស។

ទោះជាយ៉ាងណាក៏ដោយ នៅមានអ្នកខ្លះនៅក្នុងពិភពលោកយើងនេះមានអំណោយទានឲ្យនៅតែឯងដែរ ដែលជាអំណោយទានយ៉ាងពិសេសដែលបានផ្តល់មកសម្រាប់អនុញ្ញាតឲ្យពួកគេចូលជ្រៅក្នុងការថ្វាយបង្គំផ្ទាល់ខ្លួននៅចំពោះព្រះជាម្ចាស់ និងបម្រើព័ន្ធកិច្ចរបស់ទ្រង់ (១កូរិនថូស៧:៣២)។ អំណោយទាននៃភាពនៅលីវ គឺជាតម្រូវការ ដើម្បីស្តារពួកជំនុំឡើង ដោយព្រោះអ្នកដែលនៅលីវអាចនឹងធ្វើការងារអស្ចារ្យជាច្រើនសម្រាប់នគររបស់ព្រះ (ដូចជាព្រះយេស៊ូវ និងសាវ័កប៉ុលជាដើម)។ ប៉ុន្តែដូចដែលបាននិយាយរួចមកហើយ អំណោយទាននេះមិនមែនសម្រាប់មនុស្សគ្រប់គ្នានោះទេ។ ព្រះទ្រង់ចង់ឲ្យមនុស្សជាច្រើនមានដៃគូ ជាម្នាក់ដែលអាចប្រកបជាមួយគ្នា មានក្តីស្រម៉ៃជាមួយគ្នា បម្រើព្រះជាមួយគ្នានិង ដើម្បីទទួលមរតកជីវិតជាមួយគ្នា នេះគឺជាបទពិសោធយ៉ាងស្រស់ស្អាត និងជាអំណោយទានយ៉ាងអស្ចារ្យ។

ស្តេចសាឡូម៉ូនបានផ្តល់ហេតុផលមួយចំនួនដែលបង្ហាញពីភាពជាដៃគូជីវិតគឺល្អ (សាស្តា ៤:៩-១២)។ *មានគ្នា២នាក់ នោះវិសេសជាងនៅតែឯង ពីព្រោះគេមានរង្វាន់យ៉ាងល្អកើតពីការនឿយហត់របស់ខ្លួន ដ្បិតបើដួល នោះម្នាក់នឹងជ្រោងគ្នាឡើងវិញ តែវរហើយ អ្នកណាដែលដួលក្នុងកាលដែលនៅតែម្នាក់ឯង ឥតមានគ្នានឹងជួយជ្រោងឡើងវិញ មួយទៀត បើដេកមានគ្នា២នាក់ នោះក៏បានកក់ក្តៅ តែបើដេកតែម្នាក់ឯង នោះធ្វើដូចម្តេចឲ្យកក់ក្តៅបាន ហើយបើមានខ្មាំងណាមក ដែលមានកំឡាំងជាងនោះ២នាក់នឹងអាចទប់ទល់បាន ឯពួរ៣ធ្លុងមិនងាយដាច់ទេ។*

គំនិតទាំងនេះអាចអនុវត្តទៅកាន់គ្រប់ដៃគូជីវិត ភាគច្រើនពួកគេច្បាស់ជាអនុវត្តទៅកាន់អាពាហ៍ពិពាហ៍បានដែរ។ ស្តេចសាឡូម៉ូនមានបន្ទូលថា មានគ្នា២នាក់ នោះវិសេសជាងនៅតែឯង *ពីព្រោះគេមានរង្វាន់យ៉ាងល្អកើតពីការនឿយហត់របស់ខ្លួន។* មានដៃគូជាច្រើនដែលមើលឃើញខ្លួនថាមានរង្វាន់ពីការបញ្ចប់ការសិក្សា ការធ្វើការនៅក្នុងមុខជំនួញរីកចម្រើនក្នុងព្រះជាម្ចាស់ បម្រើព័ន្ធកិច្ចជាដើម ដោយព្រោះតែការរួបរួមនៃអាពាហ៍ពិពាហ៍។ ព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺចម្រើនផលពីមួយទៅជាច្រើនតាមរយៈអាពាហ៍ពិពាហ៍។

ស្តេចសាឡូម៉ូនក៏បានមានបន្ទូលទៀតដែរថា ដៃគូជីវិតគឺ មានប្រយោជន៍នៅពេលដែលមានម្នាក់ដួល ដោយព្រោះនឹងមានម្នាក់ទៀតជ្រោងឲ្យឡើងវិញបាន។ ជីវិតមានការឡើងចុះច្រើន មានការបាក់ទឹកចិត្ត ឧបសគ្គនិង បទពិសោធន៍ដែលលំបាកបំផុត។ ទោះជាយ៉ាងណាក៏ដោយ ជាច្រើនដង ជីវិតយើងមានការធ្លាក់ចុះជាងការដែលឡើង។ នៅពេលដែលអាពាហ៍ពិពាហ៍មានដំណើរការល្អនោះវានឹងជួយសម្រួលដល់ការលំបាក និងការបាក់ទឹកចិត្តដែលកើតឡើងនៅក្នុងជីវិត។

ប្រពន្ធដែលល្អនឹងនិយាយពាក្យល្អដែលលើកទឹកចិត្ត និងសេចក្ដីជំនឿទៅដល់ដៃគូរបស់នាង ដើម្បីលើកទឹកចិត្តស្វាមីរបស់ខ្លួនឲ្យក្រោកឡើងនៅពេលដែលជីវិតធ្លាក់ចុះ។ ប្រពន្ធនោះនឹងជួយដល់ប្ដីរបស់នាងឲ្យរឹងមាំឡើង នៅពេលដែលគាត់ចុះខ្សោយ និងធ្វើឲ្យស្ថានការណ៍ផ្លាស់ប្ដូរពីអាក្រក់មកល្អវិញ។

គួរឲ្យសោកស្ដាយ អាពាហ៍ពិពាហ៍ដែលមិនដំណើរការបានត្រឹមត្រូវ ជាការពិតនឹងធ្វើឲ្យមានសង្គ្រាមនៃការធ្លាក់ចុះជាមួយគ្នាជាជាងសាងសង់គ្នាឡើង។ សូមប្រុងប្រយ័ត្ន ការនិយាយពាក្យដែលមិនលើកទឹកចិត្តទៅលើប្រពន្ធរបស់អ្នក។ សូមសម្រេចចិត្តថា នឹងត្រូវនិយាយតែពាក្យដែលល្អទៅកាន់ជីវិតពួកគេ ដើម្បីឲ្យរីកចម្រើនឡើងដល់គ្នាទៅវិញទៅមក ទោះបើជាពេលដែលអ្នកគ្មានអារម្មណ៍ក្នុងការធ្វើបែបនោះក៏ដោយ ឬក៏អ្នកមានអារម្មណ៍ថា ពួកគេមិនសក្ដិសមក្នុងការទទួលពាក្យល្អទាំងនោះក៏ដោយ។ អេភេសូរ៤:២៩ ចែងថា *«មិនត្រូវឲ្យមានពាក្យអាក្រក់ណាមួយ ចេញពីមាត់អ្នករាល់គ្នាឡើយ ចូរបញ្ចេញតែពាក្យណាដែលល្អៗសំរាប់នឹងស្អាងចិត្តតាមត្រូវការ ដើម្បីឲ្យបានផ្ដល់ព្រះគុណដល់អស់អ្នកដែលស្ដាប់»*។

តើអ្នកបានអនុវត្តក្នុងការនិយាយពាក្យដែលពេញដោយសេចក្ដីជំនឿ និងការលើកទឹកចិត្តដល់ដៃគូរបស់អ្នកដែរឬទេ?

អាពាហ៍ពិពាហ៍ក៏មានផលប្រយោជន៍ផ្សេងទៀតដែរ ដូចជាផ្ដល់ភាពកក់ក្ដៅដល់គ្នា និងផ្គត់ផ្គង់ដល់តម្រូវការប្រចាំថ្ងៃ ប៉ុន្តែមួយក្នុងចំណោមផលប្រយោជន៍ដែលល្អជាងគេនោះគឺ ការការពារ។ ស្ដេចសាឡូម៉ូនបានមានបន្ទូលថា ២នាក់នោះអាចការពារគ្នាបាន (សាស្ដា៤:១២)។ នេះគឺជាសារៈសំខាន់យ៉ាងពិសេសនៅក្នុងអាពាហ៍ពិពាហ៍របស់គ្រីស្ទបរិស័ទ ដោយព្រោះតែការវាយប្រហារពីខ្មាំងសត្រូវនៅក្នុងសង្គ្រាមខាងឯព្រលឹងវិញ្ញាណ។ សាតាំងដឹងអំពីសក្ដានុពលយ៉ាងខ្លាំងក្លានៅក្នុងគ្រប់អាពាហ៍ពិពាហ៍ និងលទ្ធផលនៃអាពាហ៍ពិពាហ៍ នោះវាតែងតែវាយប្រហារទៅលើក្រុមគ្រួសាររបស់ពួកគេ។

ចូររំពឹងទុកថានឹងមានសង្គ្រាមនៅក្នុងអាពាហ៍ពិពាហ៍។ សាតាំងនឹងធ្វើគ្រប់បែបយ៉ាងដែលវាអាចធ្វើបាន ដើម្បីបញ្ចៀសប្ដី និងប្រពន្ធចេញពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ចេញពីសេចក្ដីអធិស្ឋាន ចេញពីការប្ដេជ្ញាចិត្តសម្រាប់បម្រើពួកជំនុំ នឹងបង្កឲ្យមានទំនាស់រវាងគ្នានិងគ្នានៅក្នុងក្រុមគ្រួសារ។ សាតាំងព្យាយាមធ្វើការទាំងនេះដោយព្រោះវាដឹងថា ការដែលមនុស្ស២នាក់រួមគ្នា នោះនគររបស់ព្រះនឹងរីកចម្រើនជាជាងមានតែម្នាក់។

ហេតុយ៉ាងដូច្នេះ វាជារឿងសំខាន់សម្រាប់ដៃគូក្នុងការប្រើប្រាស់អាវុធខាងឯព្រលឹងវិញ្ញាណ ដើម្បីការពារគ្នាទៅវិញទៅមក។ អាវុធទាំងនេះ គឺសេចក្ដីអធិស្ឋានសម្រាប់គ្នាទៅវិញទៅមកជាប្រចាំ ពិចារណាព្រះបន្ទូលរបស់ព្រះ និយាយពីព្រះបន្ទូលរបស់ព្រះទៅដល់គ្នាទៅវិញទៅមក ប្ដេជ្ញាចិត្តក្នុងការបម្រើរូបកាយរបស់ព្រះគ្រីស្ទ និងមានទំនួលខុសត្រូវជាមួយនឹងគ្រីស្ទបរិស័ទដទៃទៀត។

តើអ្នកធ្លាប់បានគិតអំពីសង្គ្រាមដែលអាចនឹងកើតឡើងនៅក្នុងការរួបរួមនៃអាពាហ៍ពិពាហ៍ដែរឬទេ? មានមនុស្សជាច្រើនរកឃើញថា ពួកគេឲ្យអំណាចទៅលើអាពាហ៍ពិពាហ៍ច្រើនពេកដែលធ្វើឲ្យខ្វះការយល់ដឹងពីធម្មជាតិនៃសង្គ្រាមថ្មីរបស់ពួកគេ។

## ផែនការរបស់ព្រះជាម្ចាស់សម្រាប់អាពាហ៍ពិពាហ៍ គឺសម្រាប់បង្កើតការរួបរួមនៃគ្រួសារថ្មី

*ដោយហេតុនោះ បានជាមនុស្សប្រុសនឹងលាចេញពីឪពុកម្តាយខ្លួន ទៅនៅជាប់នឹងប្រពន្ធវិញ ហើយអ្នកទាំង២នោះនឹងត្រឡប់ជាសាច់តែ១សុទ្ធ។*

ក្រោយពេលដែលព្រះជាម្ចាស់បានបង្កើតស្ត្រីសម្រាប់អ័ដាមមកនោះ ទ្រង់បានមានបន្ទូលថា បុរសនឹងត្រូវចាកចេញពីឪពុកនិងម្តាយ ដើម្បីទៅរួមរស់ជាមួយនឹងប្រពន្ធរបស់ខ្លួន។ នេះមានន័យថា នៅក្នុងអាពាហ៍ពិពាហ៍ គូស្វាមីភរិយានឹងត្រូវចាប់ផ្តើមការរួបរួមគ្រួសារថ្មី។

នេះមិនមែនមានន័យថា ពួកគេមិនមែនជាកូនរបស់ឪពុកម្តាយរបស់ពួកគេទៀតនោះទេ ប៉ុន្តែមិនមែនមានន័យថា អទិភាព(ភាពសំខាន់)របស់បុរស និងស្ត្រីក្រោយដែលរៀបការរួចមានការផ្លាស់ប្តូរនោះដែរ។ អទិភាព(ភាពសំខាន់)របស់ពួកគេឥឡូវនេះ គឺជាអាពាហ៍ពិពាហ៍។ ការនេះគឺសំខាន់ខ្លាំងណាស់ បុព្វហេតុដែលនាំឲ្យមានការលែងលះខ្ពស់នោះ គឺសាច់ថ្លៃ។ ប្តីប្រពន្ធដែលរស់នៅជាមួយឪពុកម្តាយច្រើនឈ្លោះទាស់ទែងគ្នាត្រង់ថា ពួកគេធ្វើតាមតែក្តីរំពឹងទុករបស់ឪពុកម្តាយខ្លួនជាជាងប្តីប្រពន្ធខ្លួនឯងវិញ។ គ្រប់ពេលដែលប្តីប្រពន្ធឈ្លោះគ្នា ម្តាយរបស់ប្តីឬឪពុករបស់ប្រពន្ធតែងតែមានរឿងនិយាយគ្នា។

គូអាពាហ៍ពិពាហ៍ដែលរៀបការរួចត្រូវប្រុងប្រយ័ត្នពីការនេះ។ ពួកគេតែងតែត្រូវបានប្រាប់ឲ្យគោរពដល់ ឪពុកម្តាយរបស់ខ្លួន និងថែរក្សាពួកគាត់នៅពេលដែលមានវ័យចាស់ (១ធីម៉ូថេ៥:៤,៨) ប៉ុន្តែពួកគេត្រូវតែគោរពដល់ប្តីប្រពន្ធរបស់ខ្លួនឯងជាមុនសិន។

ការពិតដែលបុរសត្រូវបានត្រាស់ហៅឲ្យចាកចេញពីផ្ទះឪពុកខ្លួនក៏បង្កប់ន័យថា គាត់ត្រូវតែអាចផ្គត់ផ្គង់ខ្លួនគាត់ហើយនិងផ្នែកហិរញ្ញវត្ថុដល់ប្រពន្ធរបស់ខ្លួនដែរ។ វាបង្កប់ន័យឯករាជ្យភាព។ គូស្វាមីភរិយាវ័យក្មេងដែលនៅពឹងផ្អែកលើហិរញ្ញវត្ថុឪពុកម្តាយរបស់ពួកគេ ជាញឹកញាប់វាអនុញ្ញាតឲ្យភាពស្មុគស្មាញដែលមិនចាំបាច់ចូលមកក្នុងអាពាហ៍ពិពាហ៍របស់ពួកគេ។ ហិរញ្ញវត្ថុរបស់ឪពុកម្តាយជាធម្មតាផ្គត់ផ្គង់ជាមួយចំនួនជាក់លាក់នៃការគ្រប់គ្រងឬការរំពឹងទុកដែលអាចប៉ះពាល់ដល់អាពាហ៍ពិពាហ៍របស់ពួកគេ។ គូស្នេហ៍ដែលត្រៀមខ្លួន ដើម្បីរៀបការគួរតែពិចារណាពីការរៀបចំផ្នែកហិរញ្ញវត្ថុសម្រាប់អាពាហ៍ពិពាហ៍។ ពួកគេគួរតែពិចារណាថា ពួកគេបានត្រៀមខ្លួន ដើម្បីចាកចេញពីគ្រួសាររបស់ពួកគេ និងច្បាស់លាស់ជាមួយនឹងដៃគូរបស់ខ្លួន ហើយពួកគេត្រូវត្រៀមខ្លួនរួចជាស្រេចក្នុងការដាក់ដៃគូរបស់ពួកគេជាអទិភាពបន្ទាប់ពីព្រះជាម្ចាស់។

## សរុបសេចក្តី

នៅក្នុងការសរុបសេចក្តី វាជាការសំខាន់ក្នុងការចងចាំពីមូលហេតុដែលព្រះបានបង្កើតអាពាហ៍ពិពាហ៍មក ដោយព្រោះថា ប្រសិនបើយើងភ្លេចពីមូលហេតុនោះ វាធ្វើឲ្យអាពាហ៍ពិពាហ៍ក្លាយទៅជារឿងដែលបំពានគ្នា។ ជំនួសឲ្យការសាងសង់នគរព្រះ ចិញ្ចឹមកូនរបស់ព្រះ ឬក៏ផ្តល់ឲ្យដៃគូជីវិតគូអាពាហ៍ពិពាហ៍បែរជាព្រងើយកន្តើយចំពោះការខិតខំប្រឹងប្រែងទាំងនេះ ហើយទីបំផុតដេញតាមអ្វីដែលធ្វើឲ្យអាពាហ៍ពិពាហ៍បែកបាក់ទៅវិញ។ សូមឲ្យយើងតែងតែចងចាំពីផែនការរបស់ព្រះជាម្ចាស់

សម្រាប់ការរួបរួមនៃអាពាហ៍ពិពាហ៍ ដូច្នេះ យើងអាចនឹងគោរពគ្នា និងបំពេញផែនការរបស់ព្រះជាម្ចាស់នៅក្នុងអាពាហ៍ពិពាហ៍បាន។

១. ផែនការរបស់ព្រះជាម្ចាស់សម្រាប់អាពាហ៍ពិពាហ៍ គឺឆ្លុះបញ្ចាំងពីរូបអង្គរបស់ទ្រង់

២. ផែនការរបស់ព្រះជាម្ចាស់សម្រាប់អាពាហ៍ពិពាហ៍ គឺបង្កើតកូនរបស់ព្រះជាម្ចាស់

៣. ផែនការរបស់ព្រះជាម្ចាស់សម្រាប់អាពាហ៍ពិពាហ៍ គឺបំពេញសម្រេច និងសាងសង់នគររបស់ទ្រង់ឡើង

៤. ផែនការរបស់ព្រះជាម្ចាស់សម្រាប់អាពាហ៍ពិពាហ៍ គឺភាពជាដៃគូជីវិត

៥.ផែនការរបស់ព្រះជាម្ចាស់សម្រាប់អាពាហ៍ពិពាហ៍ គឺសម្រាប់គូស្វាមីភរិយាបង្កើតការរួបរួមនៃគ្រួសារថ្មី

**កិច្ចការផ្ទះ នៃមេរៀនផែនការរបស់ព្រះសម្រាប់អាពាហ៍ពិពាហ៍**

ឆ្លើយសំនួរខាងក្រោម បន្ទាប់មកពិភាក្សាជាមួយគ្នា

១. តើមានអ្វីថ្មីដែលលេចចូលមកក្នុងគំនិតអ្នកនៅក្នុងជំពូកនេះ? តើអ្នកទទួលបានការជម្រុញចិត្ត និងលើកទឹកចិត្តដោយវិធីណាខ្លះ? តើមានចំណុច ឬគំនិតណាដែលអ្នកមិនយល់ស្របដែរឬទេ?

២. ហេតុអ្វីបានជាអ្នកចង់រៀបការជាមួយមនុស្សម្នាក់នេះ? សូមផ្តល់ហេតុផល៥ក្រៅពីការស្រឡាញ់។

៣. ប្រសិនបើអាពាហ៍ពិពាហ៍ គឺជាអំណោយទានខាងឯព្រលឹងវិញ្ញាណ ដើម្បីជាប្រយោជន៍ដល់នគរព្រះ សូមវាយតម្លៃខ្លួនឯង និងអំណោយទានខាងឯព្រលឹងវិញ្ញាណរបស់អ្នក។ តើព្រះទ្រង់បានប្រទានអំណោយទានដល់អ្នក ដើម្បីសាងសង់ពួកជំនុំទ្រង់ឡើងដោយរបៀបណា (ការបង្រៀន លើកទឹកចិត្ត ការបម្រើ អ្នកជំនួយ ចិត្តមេត្តាជាដើម)? ប្រសិនបើអ្នកមិនច្បាស់ទេ សូមសួរដៃគូរបស់អ្នក ឬមិត្តភក្តិរបស់អ្នក តើពួកគេយល់ថា អំណោយទានខាងឯព្រលឹងវិញ្ញាណរបស់អ្នកជាអ្វី?

៤. តើអ្វីជាអំណោយទានរបស់ដៃគូរបស់អ្នក? តើអ្វីដែលអ្នកមើលឃើញថា ព្រះទ្រង់កំពុងតែប្រើដៃគូរបស់អ្នក ដើម្បីសាងសង់នគររបស់ទ្រង់ឡើង ឬបម្រើដល់ពួកជំនុំ? តើអ្នកអាចជួយគាត់ឲ្យបន្តធ្វើការនេះយ៉ាងដូចម្ដេច?

៥. ស្ដេចសាឡូម៉ូនបានផ្ដល់យោបល់ពីអត្ថប្រយោជន៍ខ្លះៗសម្រាប់ដៃគូជីវិតដែលយើងអាចរកឃើញនៅក្នុងអាពាហ៍ពិពាហ៍ដូចជា៖ ការបង្កើតផលបានល្អនៅក្នុងការងារ ជួយគ្នានៅពេលដែលមានបញ្ហា និងការពារគ្នាទៅវិញទៅមក។ តើអ្វីដែលជាឧបសគ្គ ឬកាលៈទេសៈដែលអ្នករកឃើញខ្លួនឯងងាយបាក់ទឹកចិត្ត ឬធ្វើបាប? តើអ្វីដែលធ្វើឲ្យអ្នកធ្លាក់ចុះ (បញ្ហាការងារ គ្រួសារ ធ្លាក់ទឹកចិត្ត ការថប់បារម្ភជីវិតខាងឯព្រលឹងវិញ្ញាណជាដើម)? តើអ្នកអាចឆ្លងផុតបញ្ហានេះដោយរបៀបណា ហើយតើប្ដីឬប្រពន្ធរបស់អ្នកធ្វើដូចម្ដេចហើយដើរតួជាអ្វី ដើម្បីជួយដល់អ្នក?

៦. អាវុធដែលយើងប្រើនៅក្នុងសង្គ្រាមខាងឯព្រលឹងវិញ្ញាណ និងការសាកល្បងនៃជីវិតគឺជាព្រលឹងវិញ្ញាណចម្បង។ ចូរពិភាក្សាអំពីវិន័យខាងវិញ្ញាណ (ការអធិស្ឋាន ការអានព្រះបន្ទូល ទំនួលខុសត្រូវ ការអធិស្ឋានតម ការចូលរួមក្នុងពួកជំនុំ ការបម្រើជាដើម)។ តើអ្នកអនុវត្តការទាំងនេះជាប្រចាំថ្ងៃ ឬប្រចាំ  សប្ដាហ៍ហើយឬនៅ? តើអ្នកគិតយ៉ាងម៉េចពីវិន័យខាងឯព្រលឹងវិញ្ញាណរបស់ដៃគូរបស់អ្នក តើអ្នកអាចលើកទឹកចិត្តគ្នាយ៉ាងដូចម្ដេច ដើម្បីឲ្យដៃគូរបស់អ្នកមានឥទ្ធិពលជាងសត្រូវរបស់អ្នក?

៧. ព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់អាពាហ៍ពិពាហ៍ គឺបង្កើតផល និងចម្រើនផលឡើង បង្កើតកូនរបស់ព្រះ។ តើអ្នកចង់បានកូនប៉ុន្មាននាក់? តើដៃគូរបស់អ្នកចង់បានប៉ុន្មាន? តើអ្នកបានពិភាក្សាពីផែនការគ្រួសារឬទេ? តើអ្នកនឹងប្រើប្រាស់វិធីពន្យាកំណើត? បើមានមែន តើប្រភេទណា? វាជាការល្អដែលធ្វើការស្រាវជ្រាវពីការនេះមុនរៀបអាពាហ៍ពិពាហ៍ ដោយព្រោះមានវិធីខ្លះអាចធ្វើឲ្យគ្មានកូនឬខុសក្រមសីលធម៌។

៨. តើទំនាក់ទំនងប្រភេទណាដែលអ្នកមានជាមួយឪពុកម្ដាយរបស់អ្នក? តើអ្នកមានប្រមើលមើលពីគ្រួសាររបស់អ្នកមានបញ្ហាជាមួយអាពាហ៍ពិពាហ៍របស់អ្នកឬទេ? (ដូចជា មិនទទួលស្គាល់ប្ដីឬប្រពន្ធរបស់អ្នក បញ្ហាវប្បធម៌ គម្លាតជាដើម)។

៩. តើទំនាក់ទំនងប្រភេទណាដែលអ្នកមានជាមួយនឹងមិត្តភក្តិឪពុកម្ដាយរបស់អ្នក? តើមានវិធីណាដែលអ្នកគិតថា អ្នកអាចមានទំនាក់ទំនងល្អឬស្គាល់មិត្តភក្តិរបស់ឪពុកម្ដាយអ្នកបន្ថែមដើម្បីផ្ដល់កិត្តិយសដល់ពួកគាត់ (អេភេសូរ៦:២)?

១០. តើអ្នកអាចមើលឃើញបញ្ហាផ្សេងៗនៅក្នុងអាពាហ៍ពិពាហ៍អ្នកដោយការដាក់ការរួបរួមរបស់អ្នកជាអទិភាពជាងឪពុកម្ដាយទាំងសងខាង?

១១. តើឪពុកម្ដាយរបស់អ្នកឬមិត្តភក្តិរបស់ពួកគាត់មានជំងឺធ្ងន់ធ្ងរដែរឬទេ? ព្រះទ្រង់បង្គាប់ឲ្យដៃគូទាំងអស់មើលថែរឪពុកម្ដាយរបស់ខ្លួននៅពេលដែលពួកគាត់មានវ័យចំណាស់ (១ធីម៉ូថេ៥:៤,៨)។ តើអ្នកមានបានពិភាក្សាពីភាពដែលអាចទៅរួចក្នុងការមើលថែរឪពុកម្ដាយនៅក្នុងវ័យចំណាស់ដែរឬទេ? តើអ្នកនឹងដោះស្រាយដោយរបៀបណា? ចែកចាយពីគំនិតរបស់អ្នកឬការបារម្ភរបស់អ្នក?

១២. ក្រោយពេលដែលបញ្ចប់ផ្នែកនេះ តើនៅក្នុងរបៀបណាដែលអ្នកយល់ថាព្រះកំពុងតែត្រាស់ហៅអ្នកឲ្យអធិស្ឋានអំពីអាពាហ៍ពិពាហ៍របស់អ្នកនៅពេលអនាគត? សូមចំណាយពេលអធិស្ឋាន។

# មូលដ្ឋានគ្រឹះទី២៖ ការប្ដេជ្ញានៅក្នុងអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ជាច្រើនមានបញ្ហាពីការប្រកាសពាក្យថា «ខ្ញុំយល់ព្រម»។ នៅពេលដែលគូអាពាហ៍ពិពាហ៍ប្រកាសជាសាធារណៈថា «ខ្ញុំយល់ព្រម» ពួកគេមិនបានយល់ពិតប្រាកដពីអ្វីដែលពួកគេបានប្ដេជ្ញាចិត្តនោះទេ។ ពួកគេពុំបានយល់ពីអ្វីដែលហៅថា ការប្ដេជ្ញាចិត្តពិតប្រាកដនោះទេ។ ពួកគេឈានចូលក្នុងអាពាហ៍ពិពាហ៍ដោយគិតថា ការលែងលះ គឺជាជម្រើសមួយដែលអាចទៅរួច ដើម្បីដេញតាមការបំពេញចិត្តខ្លួនឯងនិងសុភមង្គលខ្លួនឯង ឬក៏ពួកគេគិតថា ការលែងលះជារឿងមួយដែលមិនអាចកើតឡើងបាននោះទេចំពោះពួកគេ។ ដៃគូជាច្រើនមិនមានភាពខុសគ្នាប៉ុន្មានទេរវាងការប្ដេជ្ញាចិត្តរបស់ពួកគេនៅក្នុងការសេពគប់គ្នាជាសង្សារនិងការប្ដេជ្ញាចិត្តនៅក្នុងអាពាហ៍ពិពាហ៍ពួកគេ។ អាពាហ៍ពិពាហ៍គ្រាន់តែជាការបង្ហាញថា តើពួកគេស្រឡាញ់នណាម្នាក់ខ្លាំងប៉ុណ្ណាប៉ុណ្ណោះទេ។

នៅក្នុងវប្បធម៌ជាច្រើន រួមទាំងវប្បធម៌នៅក្នុងព្រះគម្ពីរ ពួកគេអនុវត្តការរៀបការបែបរៀបចំដែលជាទូទៅមានអត្រានៃការលែងលះទាប។ នៅក្នុងវប្បធម៌ទាំងនោះ សេចក្ដីស្នេហា គឺលើសពីអារម្មណ៍ វាមានន័យថា ជាការប្ដេជ្ញាចិត្ត។ សេចក្ដីស្រឡាញ់ដូចជា អារម្មណ៍មួយដែលនឹងមានពេលមានកម្លាំងខ្លាំង និងមានពេលខ្លះដែលដូចជាបាត់បង់ទាំងស្រុង។ ជីវិតអាពាហ៍ពិពាហ៍ដែលផ្អែកទៅលើអារម្មណ៍ជាចម្បង នោះវានឹងប្រៀបដូចជាកម្រិតទឹកសមុទ្រដែលមាននាចមានជោរ (ឡើងចុះៗ) ដូច្នេះអាពាហ៍ពិពាហ៍បែបនោះមិនស្ថិតស្ថេរទេ ពីព្រោះមានតែអារម្មណ៍ ប៉ុន្តែខ្វះការប្ដេជ្ញាចិត្ត។ ហេតុនេះហើយបានជាយើងតែងឮមនុស្សនិយាយថា «យើងអស់សេចក្ដីស្រឡាញ់» នៅពេលដែលពួកគេលែងលះគ្នា ដែលមានន័យថា ពួកគេបាត់បង់អារម្មណ៍ដែលពួកគេធ្លាប់មានដូចកាលដែលពួកគេទើបរៀបការដំបូង។

នៅក្នុងផ្នែកនេះ យើងនឹងពិចារណាទៅលើសេចក្ដីស្រឡាញ់ដែលមានទម្រង់ជា ការប្ដេជ្ញាចិត្ត។ អត្ថន័យនៃសេចក្ដីស្រឡាញ់ដែលខ្ញុំចូលចិត្តជាងគេនោះគឺ«ការឲ្យដល់ដៃគូដោយមិនរំពឹងទុកថានឹងបានត្រឡប់មកវិញ។ មានមនុស្សជាច្រើនហៅ សេចក្ដីស្រឡាញ់នេះថា អាហ្កាប៉េ (Agape) ជាភាសាក្រិកដែលមានន័យថា សេចក្ដីស្រឡាញ់របស់ព្រះសម្រាប់យើង។ អាហ្កាប៉េមានន័យស្មើនឹងពាក្យសម្ដីដែលគូអាពាហ៍ពិពាហ៍និយាយទៅកាន់ដៃគូរបស់គេ «ទោះបីជាពេលខ្លះខ្ញុំមិនមានអារម្មណ៍ថាស្រឡាញ់អ្នក នោះខ្ញុំនឹងនៅតែស្រឡាញ់អ្នក។ ប្រសិនបើអ្នកឈឺ ហើយអ្នកមិនអាចឆ្លើយតបដោយសេចក្ដីស្រឡាញ់ចំពោះខ្ញុំវិញ នោះក៏ខ្ញុំនឹងនៅតែស្រឡាញ់អ្នកដែរ។ ប្រសិនបើអ្នកប្រព្រឹត្តមិនគួរឲ្យស្រឡាញ់ ក៏ខ្ញុំនឹងនៅតែឆ្លើយតបទៅអ្នកដោយសេចក្ដីស្រឡាញ់ដែរ»។ សេចក្ដីស្រឡាញ់ប្រភេទនេះគឺជាសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ហើយនេះគឺជាសេចក្ដីស្រឡាញ់ដើមរបស់ទ្រង់ ដែលមានន័យដើម្បីជាបទពិសោធន៍នៃសេចក្ដីស្រឡាញ់នៅក្នុងអាពាហ៍ពិពាហ៍។

## ការតាំងសញ្ញាដ៏ស្មោះត្រង់របស់ព្រះទៅចំពោះអ័ប្រាហាំ

ដើម្បីពិចារណាពីសេចក្តីស្រឡាញ់ដូចជាការប្តេជ្ញាចិត្ត សូមយើងមើលទៅកាន់ព្រះដូចជាគំរូមួយនៅក្នុងទំនាក់ទំនងស្នេហាដែលប្រកបដោយការប្តេជ្ញាចិត្ត។ យើងនឹងមើលឃើញនៅក្នុងការតាំងសញ្ញារវាងព្រះជាម្ចាស់ និងអ័ប្រាហាំនៅក្នុង លោកុប្បត្តិ១៥ និងលោកុប្បត្តិ១៥:៧-២១៖

*៧ នោះទ្រង់មានបន្ទូលទៅគាត់ថា អញជាព្រះយេហូវ៉ា ដែលនាំឯងចេញពីស្រុកអើររបស់*
*សាសន៍ខាល់ដេមក ដើម្បីនឹងឲ្យស្រុកនេះដល់ឯងទុកជាកេរ្តិ៍អាករ ៨ រួចគាត់ទូលសួរថា ឱព្រះយេហូវ៉ា*
*ជាព្រះអម្ចាស់អើយ តើទូលបង្គំនឹងដឹងដោយសារអ្វីថា ទូលបង្គំនឹងបានស្រុកនេះជាកេរ្តិ៍អាករពិត ៩ នោះ*
*ទ្រង់មានបន្ទូលថា ចូរយកគោញី១អាយុ៣ខួប ពពែញី១អាយុ៣ខួប ចៀមឈ្មោល១អាយុ៣ខួប ហើយ*
*លលក១នឹងព្រាបជំទើរ១មកឲ្យអញ ១០ គាត់ក៏យកសត្វទាំងនោះមកពុះជា២ភាគ រួចដាក់ចំហៀង*
*ប្រទល់គ្នា តែសត្វស្លាបគាត់មិនពុះទេ ១១ ឯពួកសត្វហើរក៏ចុះមកលើខ្មោចនៃសត្វទាំងនោះ តែអាប់រ៉ាម*
*ដេញវាទៅ ។ ១២ លុះដល់វេលាថ្ងៃកំពុងតែលិច អាប់រ៉ាមក៏ដេកលក់យន់ទៅ នោះឃើញមានងងឹតយ៉ាង*
*ខ្លាំងគួរស្ញែងខ្លាចចុះមកគ្របលើគាត់ ១៣ រួចទ្រង់មានបន្ទូលប្រាប់អាប់រ៉ាមថា ចូរដឹងជាប្រាកដថា ពូជ*
*ឯងនឹងត្រូវទៅជាអ្នកដទៃនៅស្រុក១ដែលមិនមែនជាស្រុករបស់ផងខ្លួន ហើយត្រូវបំរើពួកស្រុកនោះ*
*ដែលគេនឹងសង្កត់សង្កិនឯងអស់រវាង៤០០ឆ្នាំ ១៤ តែអញនឹងជំនុំជំរះសាសន៍ដែលឯងត្រូវបំរើនោះរួច*
*ពីនោះមក ពូជឯងនឹងចេញមកទាំងមានទ្រព្យសម្បត្តិជាច្រើនវិញ ១៥ ឯឯងនឹងទៅឯពួកឰយុកោឯង*
*ដោយសុខសាន្ត ហើយគេនឹងកប់ឯង ក្រោយដែលឯងមានអាយុវែងល្អហើយ ១៦ ដល់ដំណទី៤ នោះ*
*គេនឹងវិលមកឯណេះវិញ ដ្បិតសេចក្តីទុច្ចរិតរបស់ពួកសាសន៍អាម៉ូរីមិនទាន់ពោរពេញនៅឡើយ ១៧*
*រួចកាលថ្ងៃលិចទៅ បានងងឹតហើយ នោះឃើញមានគុកភ្លើងហុយផ្សែង នឹងចន្លុះដែលឆេះទៅមកនៅ*
*កណ្តាលដុំសាច់ទាំងនោះ ១៨ នៅថ្ងៃនោះឯង ព្រះយេហូវ៉ាទ្រង់តាំងសញ្ញានឹងអាប់រ៉ាមថា អញឲ្យស្រុក*
*នេះដល់ពូជឯង ចាប់តាំងពីទន្លេស្រុកអេស៊ីព្ទរហូតដល់ទន្លេធំ គឺជាទន្លេអើប្រាត។»*

តើអ្នកមានដឹងអ្វីខ្លះអំពីការតាំងសញ្ញាលោហិតដែរឬទេ? ការតាំងសញ្ញា គឺជាការយល់ព្រមចូលរួមរវាងមនុស្ស២នាក់ ឬលើសពីនេះ។ ប៉ុន្តែ ជាញឹកញាប់នៅសម័យដើម ពួកគេនឹងបានបោះត្រាការតាំងសញ្ញាជាមួយនឹងឈាម។ ជាការពិតពាក្យថា «តាំងសញ្ញា» មានន័យថា «កាត់»។ ពួកគេនឹងយកសត្វខ្លះ ដូចជា គោ ក្របី និងសត្វស្លាប ហើយកាត់វាពាក់ជាកណ្តាល។ ហើយមនុស្សម្នាក់នឹងដើរកាត់បំណែកនៃសត្វនោះ ហើយនិយាយថា សូមឲ្យការនេះកើតឡើងចំពោះខ្ញុំចុះ ប្រសិនបើខ្ញុំក្បត់ការតាំងសញ្ញានេះ។ ហើយបន្ទាប់មកមានអ្នកផ្សេងទៀតនឹងធ្វើដូចគ្នាដែរ។

នៅក្នុងសាច់រឿងនេះ ព្រះជាម្ចាស់ទ្រង់បានសន្យាជាមួយនឹងអ័ប្រាហាំ
ហើយនិងពូជពង្សរបស់គាត់ថា នឹងឲ្យទឹកដីកាណានដល់គាត់។ អ័ប្រាហាំឆ្លើយនៅក្នុងខ៨ថា *តើទូលបង្គំនឹងដឹងដោយសារអ្វីថា ទូលបង្គំនឹងបានស្រុកនេះជាកេរ្តិ៍អាករពិត* ព្រះជាម្ចាស់ទ្រង់បានឆ្លើយតបតាមរយៈការផ្តើមតាំងសញ្ញាដោយឈាមជាមួយនឹងអ័ប្រាហាំ។ ទោះជាយ៉ាងណាក៏ដោយ អ្វីដែលធ្វើឲ្យការតាំងសញ្ញានេះចាប់អារម្មណ៍នោះ គឺនៅក្នុងខ១៧ ព្រះជាម្ចាស់ដើរកាត់បំណែកដោយអង្គទ្រង់ផ្ទាល់ជាមួយអ័ប្រាហាំ។ ទ្រង់ស្ទើរតែនិយាយថា «សូមឲ្យការនេះកើតឡើងមកយើង ប្រសិនបើយើងមិនបានបំពេញសេក្តីសញ្ញានេះ» ព្រះទ្រង់បានដាក់ភាពជាព្រះរបស់ទ្រង់ចុះ ដើម្បីបំពេញផែនការនេះទាំងស្រុង

ទៅលើអង្គទ្រង់ផ្ទាល់ ក្រៅពីការអនុវត្តរបស់អ័ប្រាហាំ។

ដូចដែលបានបញ្ជាក់កាលពីវគ្គមួយរួចមកហើយថា អាពាហ៍ពិពាហ៍គឺដើម្បីឆ្លុះបញ្ចាំងពីព្រះជាម្ចាស់ (លោកុប្បត្តិ១:២៦-២៧)។ ព្រះទ្រង់បានបង្កើតអ័ដាម និងអេវ៉ានៅក្នុងរូបអង្គរបស់ទ្រង់ផ្ទាល់។ បាទ! ពួកគេត្រូវបានបង្កើតមកដោយមានភាពឯករាជ្យ ប៉ុន្តែក៏ដើម្បីត្រូវការគ្នាដែរ ដូចជាសាច់តែមួយ (លោកុប្បត្តិ២:២៤)។ ហេតុយ៉ាងដូច្នោះ នៅក្នុងអាពាហ៍ពិពាហ៍ ពួកគេត្រូវឆ្លុះបញ្ចាំងពីសេចក្តីស្រឡាញ់របស់ព្រះអង្គ ការប្តេជ្ញារបស់ព្រះអង្គ។ ព្រះគម្ពីរបានបង្រៀនថា ព្រះទ្រង់ជាសេចក្តីស្រឡាញ់ (១យ៉ូហាន៤:៨) ហើយទោះបីជាយើងមិនមាន អធិបតេយ្យភាព ឬបរិសុទ្ធដូចជាទ្រង់ យើងនៅតែទទួលបានការត្រាស់ហៅឲ្យត្រាប់តាមព្រះអង្គនៅក្នុងគ្រប់ទាំងទំនាក់ទំនងទាំងអស់ ហើយពិសេសនៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍ (អេភេសូរ៥:២២-២៣)។ *អេភេសូរ៥:១-២ចែងថា «ដូច្នេះ ចូរត្រាប់តាមព្រះ ដូចជាកូនស្ងួនភ្ងា ហើយដើរក្នុងសេចក្តីស្រឡាញ់ ដូចជាព្រះគ្រីស្ទបានស្រឡាញ់យើង ព្រមទាំងប្រគល់ព្រះអង្គទ្រង់ជំនួសយើងផង ទុកជាដង្វាយ ហើយជាយញ្ញបូជា សំរាប់ជាក្លិនឈ្ងុយថ្វាយដល់ព្រះ»។*

វាសមហេតុផលដែលយើងត្រូវមានប្រភេទនៃការប្តេជ្ញាចិត្តដូចគ្នាជាមួយដៃគូរបស់យើង ដូចជាព្រះទ្រង់មានជាមួយលោកអ័ប្រាហាំដែរ។ អ័ប្រាហាំមានបំណងចិត្តក្នុងការប្តេជ្ញាដើរតាមព្រះអង្គ និងបំពេញព្រះហឫទ័យរបស់ព្រះជាម្ចាស់។ នៅក្នុងលោកុប្បត្តិ១២:១-៣ អ័ប្រាហាំលះបង់អ្វីទាំងអស់ ដើម្បីដើរតាមព្រះអម្ចាស់ គាត់បានប្តេជ្ញានៅចំពោះព្រះ។ ប៉ុន្តែការប្តេជ្ញារបស់ព្រះជាម្ចាស់ទៅចំពោះលោកអ័ប្រាហាំ គឺឯកតោភាគី ដែលមានន័យថា ព្រះជាម្ចាស់ទ្រង់នឹងបំពេញការតាំងសញ្ញារបស់ទ្រង់ ទោះបីជាអ័ប្រាហាំបរាជ័យមិនអាចសម្រេចតាមការតាំងសញ្ញាក៏ដោយ។ ស្រដៀងគ្នានេះដែរ នៅក្នុងអាពាហ៍ពិពាហ៍ យើងនឹងនិយាយថា «ខ្ញុំនឹងខំប្រឹងឲ្យអស់ពីលទ្ធភាពរបស់ខ្ញុំ ដើម្បីស្រឡាញ់អ្នក មិនថាពេលដែលអ្នកធ្វើឲ្យខ្ញុំខូចចិត្ត ក៏ខ្ញុំនឹងនៅតែស្រឡាញ់អ្នក ទោះបីជាអ្នកមិនស្រឡាញ់ខ្ញុំក៏ដោយ។ ខ្ញុំនឹងស្រឡាញ់អ្នកដូចជាព្រះទ្រង់បានស្រឡាញ់ខ្ញុំដែរ។ ខ្ញុំមានការប្តេជ្ញាចិត្តក្នុងការស្រឡាញ់អ្នក។» ដោយគ្មានការសង្ស័យនោះទេ ការនេះគឺពិបាកណាស់ ប៉ុន្តែនេះគឺជា របៀបដែលព្រះទ្រង់ស្រឡាញ់យើង ហើយនេះក៏ជារបៀបដែលយើងគួរស្រឡាញ់ដល់ប្តីប្រពន្ធរបស់យើងដែរ។

## ភាពស្មោះត្រង់របស់ព្រះក្នុងការតាំងសញ្ញាជាមួយនឹងពួកអ៊ីស្រាអែលពូជពង្សរបស់លោកអ័ប្រាហាំ

គំរូមួយផ្សេងទៀតអំពីការប្តេជ្ញារបស់ព្រះចំពោះរាស្ត្ររបស់ទ្រង់ និងគំរូពីការប្តេជ្ញាចិត្តរបស់យើងគួរតែមានដូចគ្នាគឺ ដែលមានចែងនៅក្នុងព្រះគម្ពីរហូសេ។ ព្រះជាម្ចាស់ទ្រង់បានប្រាប់ដល់ហោរា ហូសេ ឲ្យរៀបការជាមួយនឹងស្ត្រីម្នាក់ដែលពេលក្រោយនឹងប្រែជាស្ត្រីសំផឹង ហើយនឹងក្បត់លោក។ ព្រះទ្រង់បានប្រើប្រាស់អាពាហ៍ពិពាហ៍របស់ហូសេ ដើម្បីបង្ហាញពីការប្តេជ្ញា និងសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះពួកអ៊ីស្រាអែលដែលពួកគេធ្លាប់មិនស្មោះត្រង់ចំពោះព្រះជាម្ចាស់ដោយថ្វាយបង្គំដល់ព្រះដទៃ។ សូមមើល ហូសេ៣:១-៥៖

*១ រួចព្រះយេហូវ៉ា ទ្រង់មានបន្ទូលមកខ្ញុំថា ចូរឲ្យឯងទៅស្រឡាញ់ស្រីមួយទៀតចុះ គឺជាស្រីដែលមានអ្នកដទៃស្រឡាញ់ហើយ ក៏ជាស្រីសំផឹងផង ដូចជាព្រះយេហូវ៉ាទ្រង់ក៏ស្រឡាញ់ ដល់ពួកកូនចៅអ៊ីស្រាអែលដែរ ទោះបើគេបែរទៅប្រព្រឹត្តតាមព្រះដទៃ ហើយគេចូលចិត្តនឹងផែនទំពាំងបាយជូរក៏ដោយ ២ ដូច្នេះ ខ្ញុំក៏ទិញនាងមកសំរាប់ខ្លួន ដោយប្រាក់១៥ដួង នឹងស្រូវឱក១ថាំងកន្លះ ៣ រួចខ្ញុំនិយាយនឹងនាងថា ត្រូវឲ្យឯងនៅសំរាប់អញ ជាយូរលង់មិនត្រូវឲ្យក្បត់អញ ឬទៅជាប្រពន្ធរបស់អ្នកដទៃណាឡើយ អញក៏នឹងប្រព្រឹត្តចំពោះឯងដូច្នោះដែរ ៤ នេះពីព្រោះពួកកូនចៅអ៊ីស្រាអែលនឹងនៅឥតមានស្តេច ឬចៅហ្វាយ ឥតការថ្វាយយញ្ញបូជា ឬបង្គោលគោរព ឥតអេផូឌ ឬរូបព្រះ ជាយូរអង្វែង ៥ ក្រោយនោះ ពួកកូនចៅអ៊ីស្រាអែលនឹងវិលមកវិញ ហើយនឹងស្វែងរកព្រះយេហូវ៉ា ជាព្រះនៃគេ នឹងដាវីឌ ជាស្តេចរបស់គេនៅជាន់ក្រោយបង្អស់ គេនឹងមកពឹងជ្រកនឹងព្រះយេហូវ៉ា ហើយនឹងសេចក្តីសប្បុរសនៃទ្រង់ ដោយញាប់ញ័រ ។*

ក្រោយពេលប្រពន្ធរបស់ហូសេចាកចេញពីលោក និងក្បត់លោកមក គាត់ខំប្រឹងស្តារទំនាក់ទំនងរបស់ពួកគេក្នុងការស្តាប់បង្គាប់តាមព្រះជាម្ចាស់។ នៅក្នុងកំឡុងពេលដែលនាងធ្វើជាស្ត្រីសំផឹង នាងបានក្លាយទៅជាទាសករ។ លោកហូសេបានទិញនាងចេញពីទាសភាព(ភាពជាទាសករ) និងយកនាងត្រឡប់មកវិញក្នុងនាមជាប្រពន្ធរបស់លោក (៣២)។ សេចក្តីស្រឡាញ់របស់លោកហូសេ គឺឆ្លុះបញ្ចាំងពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់សម្រាប់រាស្ត្រអ៊ីស្រាអែល។ អ៊ីស្រាអែលបានផិតក្បត់ចំពោះព្រះអង្គ ប៉ុន្តែព្រះអង្គនៅតែយកពួកគេត្រឡប់មកវិញ ដែលឆ្លុះបញ្ចាំងពីការប្តេជ្ញារបស់ទ្រង់ក្នុងការស្រឡាញ់ដល់ពួកគេ។

មានទេវវិទូជាច្រើនជឿថា ស្ថានភាពរបស់អ៊ីស្រាអែលសព្វថ្ងៃនេះ គឺជាទំនាយតាមរយៈខគម្ពីរទាំងនេះ។ ពួកគេឥឡូវនេះគ្មានពួកសង្ឃ គ្មានហោរា គ្មានការថ្វាយយញ្ញបូជា ដូចជាពួកគេបានបដិសេធព្រះជាម្ចាស់ដែរ ប៉ុន្តែនៅពេលដែលព្រះគ្រីស្ទត្រឡប់មកវិញ នោះពួកគេនឹងបានស្តារឡើងវិញជាមួយនឹងព្រះជាម្ចាស់ជាដៃគូនៃការតាំងសញ្ញាស្មោះត្រង់របស់ពួកគេ (៣៤,៥)។

ជាថ្មីម្តងទៀត នៅទីនេះយើងមើលឃើញពីភាពស្មោះត្រង់នៃការតាំងសញ្ញារបស់ព្រះជាម្ចាស់។ ថ្ងៃមួយទ្រង់នឹងយកប្រពន្ធរបស់ទ្រង់មកវិញ ជារាស្ត្រអ៊ីស្រាអែល ទោះបីជានាងបានប្រព្រឹត្តការកំផិតខាងឯព្រលឹងវិញ្ញាណក៏ដោយ។ ការតាំងសញ្ញារបស់ព្រះជាម្ចាស់ជាមួយលោកអ័ប្រាហាំនិងពូជពង្សរបស់លោក នោះទ្រង់នឹងស្មោះត្រង់ក្នុងការបំពេញការតាំងសញ្ញានោះ។

ក្នុងនាមជាគ្រីស្ទបរិស័ទ យើងត្រូវបានហៅឲ្យឆ្លុះបញ្ចាំងពីរូបអង្គរបស់ទ្រង់ យើងត្រូវស្វែងរកគំរូនៃការប្តេជ្ញារបស់ទ្រង់ទៅចំពោះរាស្ត្រទ្រង់ ជាកូនក្រមុំរបស់ទ្រង់។ គឺជាប្រភេទនៃការប្តេជ្ញាដែល ហូសេមានជាគំរូនៅក្នុងអាពាហ៍ពិពាហ៍របស់លោក។ គាត់បានយកប្រពន្ធរបស់គាត់មកវិញ ទោះបីជានាងក្បត់គាត់ក៏ដោយ។ ដោយសារការធ្វើបៀបនេះ គាត់បង្ហាញពីគំរូនៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ និងការប្តេជ្ញាទៅចំពោះពួកអ៊ីស្រាអែល។ អាពាហ៍ពិពាហ៍ គឺដើម្បីជាគំរូនៃព្រះនិងសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះរាស្ត្ររបស់ទ្រង់ (អេភេសូរ៥:២២-២៧)។

វាពិបាកណាស់ក្នុងការស្រម៉ៃឃើញអំពីដៃគូអាពាហ៍ពិពាហ៍របស់យើងដែលមិនស្មោះត្រង់ឬធ្វើ

ឲ្យយើងខកចិត្ត ប៉ុន្តែវាជាការល្អដែលយើងគួរគិតពីការឆ្លើយតបទៅចំពោះភាពមិនស្មោះត្រង់មុនពេលដែលយើងឈានដល់ការតាំងសញ្ញានៃអាពាហ៍ពិពាហ៍។ ប្រសិនបើគោលបំណងមួយក្នុងចំណោមគោលបំណងទាំងអស់នៃអាពាហ៍ពិពាហ៍គឺ ដើម្បីឆ្លុះបញ្ចាំងពីទំនាក់ទំនងរបស់ព្រះជាម្ចាស់ទៅចំពោះរាស្រ្តរបស់ទ្រង់ នោះយើងមិនក្បត់គ្នានោះទេ ប៉ុន្តែសូមពិចារណារឿងនេះ។ ក្នុងនាមជាអ្នកជឿ អាពាហ៍ពិពាហ៍មិនមែន ដើម្បីបំពេញបំណងចិត្តរបស់ខ្លួនឬសុភមង្គលរបស់ខ្លួនឯងនោះទេ គឺដើម្បីថ្វាយសិរីល្អដល់ព្រះជាម្ចាស់តាមរយៈការដែលយើងឆ្លុះបញ្ចាំងពីព្រះអង្គ។

លើសពីនេះទៅទៀត យើងត្រូវតែពិចារណាពីការប្ដេជ្ញាប្រភេទនេះ ពីព្រោះយើងកំពុងតែរៀបការជាមួយនឹងមនុស្សដែលទទួលឥទ្ធិពលដោយអំពើបាប និងងាយស្រួលក្នុងការធ្លាក់ទៅក្នុងអំពើបាប។ ប្រសិនបើយើងនឹងសម្ដែងពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ និងការប្ដេជ្ញារបស់ទ្រង់នៅក្នុងអាពាហ៍ពិពាហ៍ យើងត្រូវតែសួរខ្លួនឯងថា « តើយើងពិតជាស្ម័គ្រចិត្តប្ដេជ្ញាស្រឡាញ់ដល់ដៃគូរបស់យើង ទោះបើគាត់ល្អ ឬអាក្រក់ក៏ដោយ ទោះបើជោគជ័យឬបរាជ័យក៏ដោយដែរឬ?»

នៅក្នុងអាពាហ៍ពិពាហ៍ភាគច្រើនដៃគូអាពាហ៍ពិពាហ៍ប្ដេជ្ញាចំពោះគ្នានៅពេលដែលអ្នកម្ខាងទៀតរក្សាផ្នែកនៃការតាំងសញ្ញារបស់ខ្លួនតែប៉ុណ្ណោះ។ ទោះបីជា វាមើលទៅមិនដូចជាសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ក៏ដោយ។ អាពាហ៍ពិពាហ៍វាខុសពីការណាត់ជួបគ្នាជាសង្សារ។ អាពាហ៍ពិពាហ៍គួរតែបង្ហាញពីការស្រឡាញ់ដោយប្ដេជ្ញាចិត្ត ស្រឡាញ់ដោយអត់ធ្មត់ ស្រឡាញ់ដោយសេក្ដីសង្ឃឹម ជាពិសេសនៅពេលដែលទំនាក់ទំនងមានបញ្ហា។ ម្ដងទៀត យើងគួរតែសួរខ្លួនឯងមួយសំនួរថា ទោះបីជាពីមុនរៀបការប្រសិនបើ «តើគាត់ពិតជាស្ម័គ្រចិត្តបង្ហាញពីការប្ដេជ្ញាប្រភេទនេះឬទេ?»។

## ព្រះជាម្ចាស់ស្អប់ការលែងលះ

ដូចដែលបាននិយាយកាលពីមុនរួចមកហើយ អាពាហ៍ពិពាហ៍ដែលបានរៀបចំ នោះមានអត្រាលែងលះទាប ការនេះប្រហែលជាការពិត ប៉ុន្តែមួយផ្នែកទៀត ពីព្រោះតែទំហំនៃភាពអាម៉ាស់ដ៏ធំដែលបានមកពីការលែងលះនៅក្នុងវប្បធម៌នោះ។ វាគួរឲ្យចាប់អារម្មណ៍ក្នុងការពិចារណាពីការនេះ តាំងពីមានវប្បធម៌ជាច្រើនដែលការលែងលះមានភាពអាម៉ាស់តិចតួច ជាពិសេសនៅលោកខាងលិច។ វាស្ទើរតែក្លាយទៅជារឿងដែលមានប្រជាប្រិយភាពទៅហើយ។ ខ្ញុំអានពាក្យស្លោកដែលមាននៅស្ទីកយើឡានកាលពីប៉ុន្មានថ្ងៃមុន ដែលបាននិយាយថា «ខ្ញុំតែងតែត្រូវជានិច្ច! សួរអតីតប្រពន្ធរបស់ខ្ញុំទាំង២មើលទៅដឹងហើយ»។ ការលែងលះក្លាយទៅជារឿងដែលរំពឹងទុកមុន ដែលធ្វើឲ្យមនុស្សជាច្រើនជ្រើសរើសមិនរៀបការ ហើយគ្រាន់តែរស់នៅជាមួយគ្នា។ ហើយប្រសិនបើពួកគេរៀបការ ពួកគេដឹងថា ខ្លួនគេដូចបានរួចចេញពីគុក គឺមានសេរីភាពដែលពួកគេអាចធ្វើអ្វីតាមតែអំពើចិត្តរបស់ពួកគេបាន។ ឥរិយាបថបែបនេះគឺខុសពីទស្សនៈរបស់ព្រះជាម្ចាស់នៅក្នុងការលែងលះ។ ចូរពិចារណាអំពីកំហឹងរបស់ព្រះជាម្ចាស់ទៅលើការលែងលះនៅក្នុង ម៉ាឡាគី២:១៦ ចែងថា៖

*ឯងរាល់គ្នានាំឲ្យព្រះយេហូវ៉ារំខានព្រះហឫទ័យ ដោយពាក្យសំដីរបស់ឯង ទោះបើយ៉ាងនោះ ក៏ឯងរាល់គ្នាសួរថា យើងបាននាំឲ្យទ្រង់រំខានព្រះទ័យឯណា គឺដោយឯងរាល់គ្នាថា អស់អ្នកណាដែល*

*ប្រព្រឹត្តអំពើអាក្រក់ នោះល្អនៅចំពោះព្រះនេត្រនៃព្រះយេហូវ៉ាហើយ ទ្រង់ក៏សព្វព្រះហឫទ័យនឹងគេ ឬថាតើព្រះនៃសេចក្ដីយុត្តិធម៌ទ្រង់នៅឯណា»។*

នៅក្នុងអត្ថបទនេះ ព្រះទ្រង់សម្ដុតឲ្យដល់ពួកអ៊ីស្រាអែល ពីព្រោះតែការលះលែង គឺជារឿងធម្មតានៅក្នុងវប្បធម៌របស់ពួកគេ។ ព្រះទ្រង់មានបន្ទូលថា ទ្រង់ស្អប់អំពើហឹង្សានៃការលែងលះដែលបានបង្កើតនៅក្នុងចង្កោមក្រុមគ្រួសារ ហើយទ្រង់បានបង្រៀនដល់ពួកអ៊ីស្រាអែលឲ្យពិនិត្យមើលខ្លួនឯងនិងមិនត្រូវបំបែកបំបាក់សេចក្ដីជំនឿជាមួយនឹងប្រពន្ធរបស់ខ្លួននោះឡើយ។ លើសពីនេះទៅទៀត សូមមើលពីរបៀបដែលព្រះគ្រីស្ទទ្រង់ដោះស្រាយជាមួយនឹងការលែងលះនៅក្នុងសញ្ញាថ្មី។ នៅក្នុងម៉ាថាយ១៩:៩ ព្រះគ្រីស្ទទ្រង់មានបន្ទូលថា *«ហើយខ្ញុំប្រាប់អ្នករាល់គ្នាថា អ្នកណាដែលលែងប្រពន្ធ មិនមែនដោយព្រោះនាងនោះផិត ហើយទៅយកប្រពន្ធមួយទៀត អ្នកនោះឈ្មោះថាប្រព្រឹត្តសេចក្ដីកំផិតហើយ ឯអ្នកណាដែលយកប្រពន្ធ ជាស្រីដែលប្ដីដើមលែង នោះក៏ប្រព្រឹត្តសេចក្ដីកំផិតដែរ»។*

នៅក្នុងម៉ាថាយ១៩ ព្រះយេស៊ូវបានផ្ដល់ការលើកលែង២យ៉ាងដែលអាចបំបែកការតាំងសញ្ញានៃអាពាហ៍ពិពាហ៍បាន។ ទី១គឺការកំផិត។ នៅក្នុងអាពាហ៍ពិពាហ៍ នៅកន្លែងណាដែលមិនមានភាពស្មោះត្រង់ ប្រសិនបើប្ដីឬប្រពន្ធផ្អមតាចេញពីការរួបរួមដោយខ្លួនពុំមានកំហុស នោះគាត់ឬនាងមានសេរីភាពរៀបការម្ដងទៀតបាន។ ទោះជាយ៉ាងនេះក៏ដោយ ព្រះយេស៊ូវទ្រង់មានបន្ទូលថា ប្រសិនបើអ្នកណារៀបការជាមួយនឹងអ្នកដែលលែងលះហើយ ដោយមិនបានប្រព្រឹត្តអំពើកំផិត នោះពួកគេនឹងនៅតែបន្តរស់នៅក្នុងរូបភាពជាអ្នកកំផិតដដែល។ ហេតុអ្វីបានជាគេនៅតែរស់នៅក្នុងរូបភាពកំផិតបន្តទៀត? នេះព្រោះតែព្រះទ្រង់ទតមើលឃើញមនុស្សម្នាក់លែងលះនោះនៅតែជាប់ចំណងអាពាហ៍ពិពាហ៍ជាមួយនឹងប្ដីឬប្រពន្ធដើមរបស់គាត់ដដែល។ ដូច្នេះ ករណីលើកលែងទី១ដែលអាចបំបែកបំបាក់ការតាំងសញ្ញាអាពាហ៍ពិពាហ៍នោះ គឺការកំផិត។

ជាមួយនឹងការនិយាយដូច្នោះ យើងត្រូវតែនៅចងចាំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ទោះបីជាការកំផិតអាចបំបែកបំបាក់ការតាំងសញ្ញានៃអាពាហ៍ពិពាហ៍ ហើយអនុញ្ញាតឲ្យប្ដី ឬប្រពន្ធដែលមិនមានកំហុសអាចលែងលះ ហើយអាចរៀបការម្ដងទៀតបានក៏ពិតមែន ប៉ុន្តែការនោះនៅតែមិនមែនជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ដូចដែលបានឃើញនៅក្នុងខណ្ឌគម្ពីរហូសេ ពួកអ៊ីស្រាអែលបានផិតក្បត់ក្នុងទំនាក់ទំនងរបស់ពួកគេជាមួយនឹងព្រះជាម្ចាស់ជាច្រើនដង ប៉ុន្តែព្រះអង្គទ្រង់នៅតែបន្តលោះគេឲ្យត្រឡប់មកវិញ។ ដូចដែលហោរាហូសេបានបង្ហាញពីគំរូនៃការប្ដេជ្ញាក្នុងការស្រឡាញ់របស់ព្រះជាម្ចាស់ ដោយគាត់បានយកប្រពន្ធដែលផិតក្បត់គាត់ត្រឡប់មកវិញផងដែរ។ ទោះបីជាករណីលើកលែងក៏ពិតមែន ព្រះហឫទ័យរបស់ព្រះជាម្ចាស់គឺសម្រាប់ឲ្យស្វាមីភរិយាស្តារទំនាក់ទំនងឡើងវិញ ហើយការដែលស្តារឡើងវិញនេះ ពួកគេបានបង្ហាញពីការស្រឡាញ់ដោយប្ដេជ្ញាចិត្ត។ សូមមើលទៅអ្វីដែលលោក ប៉ុលបាននិយាយអំពីការលែងលះ នៅក្នុង១កូរិនថូស៧:១០-១១ គាត់បាននិយាយថា៖

*១០ ឯខាងអ្នកដែលមានប្ដីប្រពន្ធហើយ នោះខ្ញុំនឹងបង្គាប់ដែរ តែមិនគឺខ្ញុំ គឺជាព្រះអម្ចាស់វិញ ទ្រង់បង្គាប់ថា កុំឲ្យប្រពន្ធលែងប្ដីឡើយ ១១ឬបើបានលែងប្ដីហើយ នោះចូរនៅជាឥតប្ដីទៅចុះ ឬឲ្យជានឹងប្ដីខ្លួនវិញទៅ ហើយឯប្ដី ក៏កុំឲ្យលែងប្រពន្ធខ្លួនដែរ។*

អ្នកណាដែលលែងលះដោយមូលហេតុផ្សេងៗខុសពីការកំផិត នោះត្រូវតែបន្តនៅជាឥតប្តី ប្រពន្ធ ឬក៏ផ្សះផ្សារជាមួយនឹងដៃគូរបស់ពួកគេវិញ។ នេះគឺរាប់បញ្ចូលស្ថានភាពណាដែលមានការរំលោភបំពានទំនាស់ដែលមិនអាចផ្សះផ្សារគ្នាជាដើម។ *អាពាហ៍ពិពាហ៍គឺគួរតែជាទំនាក់ទំនងពេញមួយជីវិត ហើយប្រសិនបើមានការលែងលះ នោះព្រះគម្ពីរប្រាប់ថា ឲ្យគាត់ ឬក៏នាងនៅបន្តជា ឥតប្តី ឬប្រពន្ធទៅ។*

នៅក្នុងការណីដែលមានការលែងលះដោយព្រោះភាពមិនស្មោះត្រង់ ប្តីប្រពន្ធដែលផិតក្បត់គ្នានោះគួរលើកទឹកចិត្តឲ្យស្វែងរកការផ្សះផ្សារ។ ប្រសិនបើមិនអាចទៅរួចទេ នោះពួកគេត្រូវដឹងថា ការបាកបញ្ចេតជាអំពើមិនអាចលើកទោសឲ្យបាននោះទេ។ ព្រះយេស៊ូវគ្រីស្ទបានសុគតនៅលើឈើឆ្កាងសម្រាប់អំពើបាបរបស់យើងទាំងអស់គ្នា ហើយអាចមានការអត់ទោសបាបឲ្យផង (១យ៉ូហាន១:៩)។ ទោះជាយ៉ាងណាក៏ដោយ ការអត់ទោសមិនមែនដកចេញនូវលទ្ធផលនោះទេ។ ប្រសិនបើការផ្សះផ្សារមិនអាចទៅរួចនោះទេ នោះប្តីប្រពន្ធដែលប្រព្រឹត្តអំពើកំផិតត្រូវតែទទួលយកការអត់ទោសរបស់ព្រះជាម្ចាស់ ហើយថ្វាយជីវិតទៅកាន់ការបម្រើដល់ព្រះជាម្ចាស់ ក្នុងភាពជាអ្នកនៅលីវ។ ព្រះទ្រង់នឹងផ្តល់នូវព្រះគុណដើម្បីបំពេញការត្រាស់ហៅនោះ និងធ្វើឲ្យពួកគេបង្កើតផលច្រើន ប្រសិនបើពួកគេស្មោះត្រង់។ ដូចដែលប្តីឬប្រពន្ធដែលមិនបានប្រព្រឹត្តកំហុសឆ្គងនោះ ព្រះហឫទ័យរបស់ព្រះគឺសម្រាប់ឲ្យនាងស្វែងរកការផ្សះផ្សារទំនាក់ទំនងអាពាហ៍ពិពាហ៍ឡើងវិញ។ ប្រសិនបើការនោះមិនអាចទៅរួច នោះនាងមានសេរីភាពអាចរៀបការម្តងទៀតបាន។

ហេតុអ្វីបានជាយើងពិចារណាអំពីការលែងលះ និងការរៀបការម្តងទៀតនៅក្នុងការសិក្សាប្រឹក្សាយោបល់មុនពេលរៀបការ? គឺពីព្រោះសម្រាប់អ្នកដែលចង់ដើរតាមគំរូរបស់ព្រះជាម្ចាស់ត្រូវល់ពីការតាំងសញ្ញានៅក្នុងអាពាហ៍ពិពាហ៍សំខាន់យ៉ាងណា គឺដើម្បីព្រះជាម្ចាស់។ សម្រាប់ព្រះជាម្ចាស់ អាពាហ៍ពិពាហ៍ គឺជាការប្តេជ្ញានៃទំនាក់ទំនងដែលមិនគួរមានអ្វីមកបំបែកបំបាក់បាន។ ហើយអ្នកណាដែលបំបែកបំបាក់អាពាហ៍ពិពាហ៍នោះ លើកលែងការកំផិត គឺត្រូវបន្តរស់នៅលីវហើយស្វែងរកព្រះជាម្ចាស់វិញ។

បទប្បញ្ញត្តិទាំងនេះសម្រាប់អាពាហ៍ពិពាហ៍ គឺតឹងរឹងនិងត្រូវបានប្រទានដោយព្រះជាម្ចាស់ដែលពិបាកក្នុងការលែងលះ។ នៅក្នុងសង្គមមួយដែលគ្មានបទប្បញ្ញត្តិ ហើយគ្មានភាពអាម៉ាស់ជាមួយការគោរពទៅកាន់ ការលែងលះនោះទេ វាក្លាយទៅជារឿងថោកទាបនិងជាជម្រើសដែលអាចទៅរួចនៅក្នុងអាពាហ៍ពិពាហ៍ដែលមានការលំបាក។ ព្រះគម្ពីរបានបង្រៀនថា អាពាហ៍ពិពាហ៍គឺជាការតាំងសញ្ញាដែលគួរតែឆ្លុះបញ្ចាំងពីសេក្តីសញ្ញារបស់ព្រះជាម្ចាស់ជាមួយនឹងយើងរាល់គ្នា។ ទោះបីជានៅពេលយើងធ្វើឲ្យព្រះអង្គខកព្រះទ័យ ហើយយើងបែរចេញពីព្រះអង្គ ក៏ទ្រង់នៅតែបន្តស្មោះត្រង់ ដោយព្រោះតែការតាំងសញ្ញារបស់ទ្រង់គឺត្រូវបានបោះត្រាដោយព្រះលោហិតរបស់ព្រះរាជបុត្រាទ្រង់។

តើអ្វីជាករណីលើកលែងទី២ដែលអាចបំបែកបំបាក់ការតាំងសញ្ញានៃអាពាហ៍ពិពាហ៍បាន? នៅក្នុងរ៉ូម៧:១-៣ ប៉ុលបាននិយាយថា៖ *១ឯសេចក្តីដែលអ្នករាល់គ្នាបានផ្ញើទៅសួរខ្ញុំ នោះខ្ញុំយល់ឃើញថា បើមនុស្សប្រុសមិនដែលប៉ះពាល់នឹងស្រីសោះ នោះល្អជាជាង ២តែ ដោយព្រោះមានការសហាយស្មន់កើតឡើង បានជាគួរឲ្យគ្រប់គ្នាមានប្រពន្ធជារបស់ផងខ្លួនវិញ ហើយគ្រប់ទាំងស្រីក៏ត្រូវមានប្តីជា*

*របស់ផងខ្លួនដែរ ៣ត្រូវឲ្យប្តីប្រព្រឹត្តនឹងប្រពន្ធដោយចិត្តសប្បុរស ហើយត្រូវឲ្យប្រពន្ធប្រព្រឹត្តនឹងប្តីក៏ដូច្នោះដែរ។*

នៅទីនេះសាវ័កប៉ុលបានបង្រៀនពីមូលហេតុទី២ ដែលអាចអនុញ្ញាតឲ្យរៀបការម្តងទៀតបាននោះ គឺសេចក្តីស្លាប់។ សេក្តីស្លាប់អាចបំបែកបំពាក់កិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍បាន។ អាពាហ៍ពិពាហ៍គឺជាការតាំងសញ្ញាខាងឯរូបកាយដែលធ្វើឲ្យគូអាពាហ៍ពិពាហ៍ក្លាយទៅជាសាច់តែមួយ (លោកុប្បត្តិ ២:២៤)។ ពួកគេក្លាយទៅជារូបកាយតែមួយ ព្រលឹងតែមួយ និងវិញ្ញាណតែមួយ។ មានតែរូបកាយប៉ុណ្ណោះដែលអាចបំបែកបំបាក់ការតាំងសញ្ញានេះបាន គឺការកំផិតនិងការស្លាប់។ ជាការពិតនៅក្នុងសញ្ញាចាស់ ការផិតក្បត់ប្តីឬប្រពន្ធ គឺត្រូវតែដាក់ទោសដល់ស្លាប់ ហើយប្តីប្រពន្ធដែលស្មោះត្រង់ នោះអនុញ្ញាតឲ្យរៀបការម្តងទៀតបាន (លេវីវិន័យ២០:១០)។ នៅក្នុងសញ្ញាថ្មី ការនេះលែងក្លាយទៅជាការពិតទៀតហើយ ប៉ុន្តែប្តីឬប្រពន្ធដែលប្រព្រឹត្តអំពើផិតក្បត់ នោះត្រូវបានហៅឲ្យរស់នៅម្នាក់ឯង (នៅលីវ) វិញ។

ម្តងទៀត យើងគួរតែបានឮហើយថា ការលែងលះមិនមែនជាអំពើបាបដែលមិនអាចអត់ទោសឲ្យបាននោះទេ។ សេចក្តីស្រឡាញ់និងព្រះគុណរបស់ព្រះជាម្ចាស់ ត្រូវបានពិសោធ៍នៅក្នុងរបៀបមួយយ៉ាងអស្ចារ្យទោះបីជាយើងឆ្លងកាត់ការបរាជ័យដ៏ធំក្នុងជីវិតក៏ដោយ។ កន្លែងណាដែលអំពើបាបបានចម្រើនឡើង នោះព្រះគុណក៏ចម្រើនលើសទៅទៀត(រ៉ូម៥:២០)។ ព្រះទ្រង់សព្វព្រះហឫទ័យប្រទានព្រះគុណ ដើម្បីឲ្យគូអាពាហ៍ពិពាហ៍ដែលលែងលះអាចនឹងស្តារទំនាក់ទំនងជាមួយនឹងគ្នាឡើងវិញ ហើយសំខាន់ជាងសម្រាប់ខ្លួនពួកគេផ្ទាល់។ ក្នុងនាមជាពួកជំនុំ ជារូបកាយរបស់ព្រះគ្រីស្ទយើងត្រូវតែស្រឡាញ់ហើយកំសាន្តចិត្តដល់អស់អ្នកដែលរងការឈឺចាប់ដោយព្រោះការលែងលះ។ ការមកដល់នៃអំពើបាប អាពាហ៍ពិពាហ៍ត្រូវបានបំផ្លាញជាច្រើន ហើយគួរឲ្យសោកស្តាយ ភាគច្រើននៅក្នុងរបៀបខ្លះឬផ្សេងទៀត អាពាហ៍ពិពាហ៍ត្រូវបានជះឥទ្ធិលដោយការលែងលះគ្នា។ ប៉ុន្តែកន្លែងណាដែលមានអំពើបាបនិងការបែកបាក់ យើងជាពួកជំនុំរបស់ព្រះ យើងត្រូវតែបន្តស្វែងរកការដឹកនាំរបស់ព្រះជាម្ចាស់ដែលមានពេញដោយព្រះគុណដ៏បរិបូរណ៍ ដូច្នេះ នៅទីនោះអាចមានការព្យាបាលនិងស្តារឡើងវិញសម្រាប់អស់អ្នកដែលរងទុក្ខ។

តើអាពាហ៍ពិពាហ៍មិនទាមទារឲ្យមានការប្តេជ្ញាទេឬអី ជាពិសេសអាពាហ៍ពិពាហ៍ដែលមិនល្អស្តាប់ទៅវាគួរឲ្យខ្លាច? វាដូចជាមិនអាចទៅរួចនោះទេ។ អាពាហ៍ពិពាហ៍រួបរួមគឺសន្មត់ថា ជាការប្តេជ្ញាពេញមួយជីវិតដោយគ្មានពាក្យថា «រួចចេញពីគុក»នោះទេ។ វាមានន័យថាដើម្បីអ្វីម៉្យាងដែលបានសម្រេចតាមរយៈអំណាចរបស់ព្រះជាម្ចាស់តែប៉ុណ្ណោះ។ ជាការពិត នៅពេលដែលពួកសិស្សបានឮពីបទប្បញ្ញត្តិតឹងរឹងទាំងនេះ ពួកគេបានឆ្លើយតបស្រដៀងគ្នាដែរ។ ពួកគេបាននិយាយថា បើរបៀបនៃមនុស្សដែលមានប្រពន្ធត្រូវជាយ៉ាងនេះ នោះស៊ូកុំយកគ្នាជាជាង (ម៉ាថាយ១៩:១០)។ ទាំងនោះជារបៀបដែលពួកសិស្សមើលឃើញពីភាពតឹងរឹងនៃបទប្បញ្ញត្តិ ហើយវាគួរតែជម្រុញយើងឲ្យពិចារណាពីកិច្ចព្រមព្រៀងពេញមួយជីវិតនេះដែរ។ ម្តងទៀត តើអ្នកគិតថា ហេតុអ្វីបានជាព្រះទ្រង់បានបង្កើតការតាំងសញ្ញានៃអាពាហ៍ពិពាហ៍តឹងរឹងយ៉ាងនេះ?

ជាធម្មតា ព្រះនៃយើងទ្រង់ស្អប់ការលែងលះណាស់ ហើយទ្រង់មានព្រះហឫទ័យសម្រាប់មនុស្ស

ឲ្យរៀបការ ហើយនៅជាមួយគ្នាជារៀងរហូត។ ប្រព័ន្ធច្បាប់របស់យើងផ្តល់នូវលទ្ធផលដ៏វិបាក ដើម្បីបង្អាក់មនុស្ស ពីការលួចប្លន់ ការសម្លាប់ ឬរំលោភជាដើម។ អំពើឃាតកម្មដ៏សាហាវឃោរឃៅអាចនឹងដាក់ទោសក្នុងគុកមួយជីវិត ឬក៏ដាក់ទោសប្រហារជីវិតបាន។ ផលវិបាកឬការដាក់ទោសដ៏ធ្ងន់ធ្ងរអាចរារាំងមនុស្សពីការប្រព្រឹត្តអំពើបាបនៅក្នុងសង្គម។ ហើយនេះគឺជាអ្វីដែលព្រះទ្រង់បានធ្វើដូចគ្នាទៅនឹងអាពាហ៍ពិពាហ៍ដែរ។

ទ្រង់ចង់ឲ្យមនុស្សដឹងថា អាពាហ៍ពិពាហ៍គឺជាការគ្រាស់ហៅពេញមួយជីវិត។ វាគឺជាការប្តេជ្ញាចិត្តនៃការតាំងសញ្ញាហើយដំណោះស្រាយសំខាន់តែមួយគត់នៃបញ្ហានេះ គឺបន្តភាពនៅលីវ។ ពីព្រោះនៅក្នុងពួកជំនុំមិនដែលបានទទួលការបង្រៀន ឬពិចារណាពីការសេក្តីពិត ពួកគេបានចម្លងវប្បធម៌របស់លោកីយ៍ ដែលមើលឃើញការលែងលះជាជម្រើសដែលអាចទៅរួច ឬការលែងលះជាលទ្ធផលដ៏ចាំបាច់សម្រាប់ស្វែងរកការបំពេញចិត្តនិងសុភមង្គលរបស់ខ្លួនឯង។ ប្រសិនបើការលែងលះ គឺជាការចាំបាច់ក្នុងការស្វែងរកសុភមង្គលដល់ខ្លួនឯងដូចដែលពួកគេនិយាយ បន្ទាប់មកកើតឡើងមែន ដូច្នេះ ការលែងលះបានកើនឡើងជារឿងធម្មតានៅក្នុងចំណោមគ្រីស្ទបរិស័ទ។ តាមស្ថិតិបានបង្ហាញថា គ្មានអត្រាខុសគ្នាក្នុងការលែងលះនៅក្នុងពួកជំនុំប្រៀបធៀបទៅនឹងអ្នកនៅក្រៅពួកជំនុំ(អ្នកមិនជឿ)នោះឡើយ។ ទោះជាយ៉ាងណាក៏ដោយ តាំងពីអាពាហ៍ពិពាហ៍មានន័យឆ្លុះបញ្ចាំងពីព្រះជាម្ចាស់ និងសេចក្តីស្រឡាញ់របស់ទ្រង់សម្រាប់រាស្ត្ររបស់ទ្រង់ វាមានន័យ ដើម្បីឲ្យមានការរួបរួម នោះផ្អែកលើការប្តេជ្ញាចិត្ត។ គឺជាការរួបរួមដែលអាចនិយាយបាន២របៀបថា « ខ្ញុំនឹងស្រឡាញ់អ្នក ទោះបីជានៅពេលដែលអ្នកមិនគួរឲ្យស្រឡាញ់ក៏ដោយ ហើយទោះបីជាពេលដែលខ្ញុំមិនមានអារម្មណ៍ថា ស្រឡាញ់អ្នក គង់តែខ្ញុំនៅស្រឡាញ់អ្នកដូចដែលព្រះទ្រង់ស្រឡាញ់ខ្ញុំសម្រាប់សិរីល្អរបស់ទ្រង់ និងសម្រាប់ព្រះកិត្តិនាមរបស់ទ្រង់ ដែលនេះគឺជាគោលបំណងពេញមួយជីវិតរបស់ខ្ញុំ»។

### សរុបសេចក្តី

តើអ្នកធ្លាប់មើលទៅអាពាហ៍ពិពាហ៍ក្នុងរបៀបជាការប្តេជ្ញាបែបនេះឬទេ?

ដូចជាការតាំងសញ្ញារបស់ព្រះជាម្ចាស់ជាមួយនឹងរាស្ត្ររបស់ទ្រង់ទោះបីជាពួកគេល្អ អាក្រក់ មិនស្អាត ដូច្នេះយើងក៏ត្រូវពិចារណាចំពោះអាពាហ៍ពាហ៍ជាការតាំងសញ្ញាពេញមួយជីវិតបែបយ៉ាងដូច្នេះឯង។ វាជាការតាំងសញ្ញាដែលផ្អែកលើការប្តេជ្ញាចិត្ត មិនមែនគ្រាន់តែជាអារម្មណ៍នោះទេ ព្រោះអារម្មណ៍តែងតែមក ហើយទៅវិញ។ យើងចូលទៅជិតការតាំងសញ្ញានេះដោយទទួលស្គាល់ពីសក្តានុពលនៃលទ្ធផលដែលមិនអាចនឹងបំពេញសម្រេចវាបាន ដូចជារាស្ត្ររបស់ព្រះបានធ្វើនៅចំពោះការតាំងសញ្ញាពីសម័យបុរាណមកដែរ។ យើងត្រូវតែចូលមកកាន់ការតាំងសញ្ញានេះដោយស្វែងរកនូវការសម្គាល់និងឆ្លុះបញ្ចាំងពីការតាំងសញ្ញានៃសេចក្តីស្រឡាញ់របស់ព្រះចំពោះយើង។ តើអ្នកគិតថា ការយល់ដឹងពីសេចក្តីពិតនៃការតាំងសញ្ញាបរិសុទ្ធនឹងជះឥទ្ធិពលដល់គូស្នេហ៍ ឬអ្នកដែលរៀបការរួចដោយរបៀបណា?

ជាការពិត យ៉ាងហោចណាស់ក៏វាអាចជួយឲ្យដៃគូស្នេហាវាយតម្លៃលើការប្តេជ្ញារបស់ពួកគេម្តងទៀត។ ពួកគេគួរតែសួរខ្លួនឯងថា «តើខ្ញុំពិតជាស្ម័គ្រចិត្តស្រឡាញ់ដៃគូរបស់ខ្ញុំ ដូចជាព្រះអង្គស្រឡាញ់ខ្ញុំ

ដែរ និងប្ដេជ្ញា ដូចជាព្រះអង្គទ្រង់ប្ដេជ្ញាសម្រាប់សិរីល្អ និងសេចក្ដីអំណាររបស់ព្រះដែរឬទេ?»

**កិច្ចការផ្ទះ៖ អំពីការប្ដេជ្ញាចិត្តនៅក្នុងអាពាហ៍ពិពាហ៍**

ឆ្លើយនឹងសំនួរ ហើយពិភាក្សាជាមួយគ្នា

១.តើមានអ្វីថ្មីឬលេចចូលមកក្នុងគំនិតអ្នកនៅក្នុងជំពូកនេះឬទេ? តើតាមរយៈអ្វីដែលអ្នកទទួលបានការលើកទឹកចិត្ត និងជម្រុញចិត្ត? តើមានចំណុច ឬគំនិតណាដែលអ្នកមិនយល់ស្របជាមួយការនេះដែរឬទេ?

២.តើវិន័យអ្វីដែលអ្នកបន្តអនុវត្ត ដើម្បីជួយដល់ភាពស្មោះត្រង់ និងការប្ដេជ្ញារបស់អ្នកនៅក្នុងអាពាហ៍ពិពាហ៍? តើជំហ៊ានអ្វីដែលអ្នកឈានទៅប្រសិនបើ អាពាហ៍ពិពាហ៍របស់អ្នកជួបការលំបាក? តើអ្នកនឹងជួយស្ដារការរួបរួមរបស់អ្នកវិញដោយរបៀបណា? (រួមបញ្ចូលអ្នកដែលអ្នកនឹងសុំជំនួយ)។

៣.ចូរសរសេរចុះពីចំណុចខ្លាំងរបស់ដៃគូរបស់អ្នកដែលអាចជួយដល់ការប្ដេជ្ញា និងជួយឲ្យអាពាហ៍ពិពាហ៍របស់អ្នកបានជោគជ័យ។

៤.ចូរសរសេរចុះពីចំណុចខ្សោយដៃគូរបស់អ្នកដែលអាចធ្វើឲ្យមានការឈឺចាប់ដល់ការប្ដេជ្ញាចិត្ត និងអាពាហ៍ពិពាហ៍របស់អ្នកជោគជ័យ?

៥.ចូរសរសេរចុះនូវចំណុចខ្លាំងរបស់អ្នកដែលអាចជួយដល់ការប្ដេជ្ញា និងអាពាហ៍ពិពាហ៍របស់អ្នកបានជោគជ័យ។

៦. ចូរសរសេរចុះនូវចំណុចខ្សោយរបស់អ្នកដែលធ្វើឲ្យមានការឈឺចាប់ដល់ការប្ដេជ្ញាចិត្ត និងអាពាហ៍ពិពាហ៍របស់អ្នកជោគជ័យ។

៧. ពិភាក្សាជាមួយដៃគូរបស់អ្នក។ តើជំហ៊ាននៃសកម្មភាពអ្វីដែលអ្នកគួរឈានក្នុងនាមជាដៃគូអាពាហ៍ពិពាហ៍ដើម្បីកែតម្រូវនៅលើចំណុចខ្សោយផ្សេងៗ។

៨. (ប្រសិនបើដៃគូរបស់អ្នកមិនមានបំណងចិត្តក្នុងការកែតម្រូវលើចំណុចខ្សោយ ដូច្នេះអ្នកគួរតែពិចារណា តើចំណុចខ្សោយទាំងនេះមានគ្រោះថ្នាក់ប៉ុណ្ណា តើអ្នកអាចរស់នៅជាមួយនឹងវាបានទេ ឬតើការមិនយល់ព្រមរបស់នាង ឬគាត់ប្រហែលជាសញ្ញាសម្គាល់ពីការដែលមិនយល់ស្របគ្នានៅពេលអនាគតដែរឬទេ។ ការនេះគួរតែនិយាយបន្ថែមជាមួយគ្នា ឬក៏លើកយកនិយាយជាមួយគ្រូគង្វាល ឬគ្រូរបស់អ្នកដើម្បីដោះស្រាយនិងវាយតម្លៃ។)

៩. បន្ទាប់ពីបញ្ចប់ជំពូកនេះ តើក្នុងរបៀបណាដែលអ្នកមានអារម្មណ៍ថា ព្រះទ្រង់កំពុងតែត្រាស់ហៅអ្នក ដើម្បីអធិស្ឋានសម្រាប់អាពាហ៍ពិពាហ៍នៅពេលអនាគតរបស់អ្នក? សូមចំណាយពេលអធិស្ឋាន។

# មូលដ្ឋានគ្រឹះទី៣៖ ការប្រាស្រ័យទាក់ទងនៅក្នុងអាពាហ៍ពិពាហ៍

ចំណុចស្នូលនៃគ្រប់អាពាហ៍ពិពាហ៍ទាំងអស់ដែលមានជាសុខភាពនោះ គឺជាសមត្ថភាពដែលស្វាមីភរិយាអាចមានការប្រាស្រ័យទាក់ទងជាមួយគ្នាបានយ៉ាងជោគជ័យ។ ការប្រាស្រ័យទាក់ទងអាចនឹងមានភាពលំបាក ពីព្រោះបុគ្គលម្នាក់ៗអាចមានប្រវត្តិខុសៗគ្នា ទម្លាប់ខុសៗគ្នា និងពេលខ្លះវប្បធម៌ខុសគ្នាផងដែរ ដែលទាំងអស់នេះអាចជះឥទ្ធិពលដល់ការប្រាស្រ័យទាក់ទងគ្នា។ លើសពីនេះទៅទៀតពី៦០% ទៅ ៩០%ការប្រាស្រ័យទាក់ទងទាំងអស់បង្ហាញតាមរយៈ ភាសារកាយវិការ ភ្នែក ការបង្ហាញតាមរយៈទឹកមុខ និងសម្លេងជាជាងពាក្យសម្ដី។ ការប្រាស្រ័យទាក់ទង គឺជាជំនាញដែលត្រូវតែបានរៀនហើយអនុវត្ត ដើម្បីឲ្យក្លាយជាអាពាហ៍ពិពាហ៍ដែលជោគជ័យ។

ព្រះគម្ពីរបង្រៀនយើងពីដំណោះស្រាយដ៏អស្ចារ្យអំពីការប្រាស្រ័យទាក់ទងគ្នា តាំងពីព្រះជាម្ចាស់ទ្រង់ជាអ្នកនិពន្ធនៃព្រះគម្ពីរមកម្ល៉េះ ទ្រង់គឺជាអ្នកប្រាស្រ័យទាក់ទង។ នៅពេលដែលទ្រង់បានបង្កើតផ្ទៃមេឃនិងផែនដី ទ្រង់បានធ្វើវាឡើងដោយមានការប្រាស្រ័យទាក់ទង។ ព្រះទ្រង់មានបន្ទូលថា ចូរឲ្យមានពន្លឺឡើង ជាការពិតតាមរយៈធម្មជាតិ ព្រះទ្រង់មានបន្ទូលមកកាន់យើងជារៀងរាល់ថ្ងៃ។ ស្ដេចដាវីឌបានមានបន្ទូលថា៖ *១ ផ្ទៃមេឃសំដែងពីសិរីល្អនៃព្រះ ហើយលំហអាកាសក៏បង្ហាញការដែលព្រះហស្តទ្រង់ធ្វើ ២ ថ្ងៃ១ពោលប្រាប់តដល់ថ្ងៃ១ទៀត ហើយយប់១ក៏សំដែងចំណេះដល់យប់១ទៀតដែរ ៣ ឯពាក្យសំដី ឬភាសា នោះគ្មានឮឡើយ គ្មានអ្នកណាដែលឮសំឡេងនៃរបស់ទាំងនោះទេ ៤ ប៉ុន្តែដំណឹងដែលរបស់ទាំងនោះផ្សាយមក ក៏បានចេញទៅគ្រប់លើផែនដី ហើយសេចក្តីនោះបានឮទៅដល់ទីបំផុតលោកីយ នៅលើមេឃ ទ្រង់បានដំឡើងត្រសាលសំរាប់ព្រះអាទិត្យ(ទំនុកដំកើង១៩:១-៤)។*

ព្រះទ្រង់មានបន្ទូលមកកាន់យើងតាមរយៈធម្មជាតិ ទ្រង់ប្រាប់យើងពីសិរីល្អដ៏អស្ចារ្យ និងភាពរុងរឿងរបស់ទ្រង់។ ទ្រង់ក៏មានបន្ទូមកកាន់យើងតាមរយៈព្រះរាជបុត្រាទ្រង់ផងដែរ ជាអង្គដែលយាងមកផែនដីមិនមែន ដើម្បីតែសុគតសម្រាប់អំពើបាបរបស់យើងតែប៉ុណ្ណោះទេ ប៉ុន្តែទ្រង់មកដើម្បីនឹងប្រទានឲ្យយើងនូវព្រះបន្ទូលរបស់ព្រះវរបិតាផងដែរ។ ជាការពិតណាស់ លោកយ៉ូហានបាទីស្ទបានហៅ ព្រះយេស៊ូវថា ជាព្រះបន្ទូល (យ៉ូហាន១:១) ទ្រង់គឺជាស្ពានមេត្រីនៃព្រះជាម្ចាស់។ ព្រះយេស៊ូវទ្រង់មានព្រះបន្ទូលពីសេចក្ដីបង្រៀនរបសទ្រង់ថា *«ព្រះយេស៊ូវមានបន្ទូលឆ្លើយថា សេចក្តីដែលខ្ញុំបង្រៀននេះ មិនមែនជារបស់ខ្ញុំទេ គឺជារបស់ផងព្រះ ដែលចាត់ឲ្យខ្ញុំមកនោះវិញ»* (យ៉ូហាន៧:១៦)។ ហើយទីបំផុតព្រះ ទ្រង់មានបន្ទូលមកកាន់យើងតាមរយៈអត្ថបទគម្ពីរដោយព្រះវិញ្ញាណបរិសុទ្ធ(២ធីម៉ូថេ៣:១៦-១៧)។ ព្រះទ្រង់ជាអ្នកប្រាស្រ័យទាក់ទង ហើយមនុស្សក៏ត្រូវបានបង្កើតមកក្នុងរូបអង្គទ្រង់ យើងក៏ជាអ្នកដែលប្រាស្រ័យទាក់ទងគ្នាដែរ។

សុភាសិត១៨:២១និយាយថា *«ទោះទាំងសេចក្តីស្លាប់ ហើយនឹងជីវិតក៏នៅក្នុងអំណាចនៃ*

*អណ្តាតដែរ អ្នកណាដែលចូលចិត្តប្រើ នោះនឹងស៊ីផលនៃអណ្តាតនោះឯង»។*

តើអ្នកគិតថា ស្តេចសាឡូម៉ូនចង់មានន័យដូចម្តេចនៅពេលដែលទ្រង់មានបន្ទូលថា អំណាចនៃជីវិត និងសេចក្តីស្លាប់ គឺនៅលើអណ្តាត?

ស្តេចសាឡូម៉ូនយល់ឃើញថា មនុស្សត្រូវបានបង្កើតមកនៅក្នុងរូបអង្គរបស់ព្រះជាម្ចាស់ ដូចគ្នាដែរ យើងមានអំណាចស្ថិតនៅលើអណ្តាត។ យើងមានអំណាចក្នុងការបង្កើតនិងនៅក្នុងការបំផ្លាញ។ យើងអាចនឹងលើកទឹកចិត្តមនុស្ស ហើយលើកគេឡើងជាមួយពាក្យសម្តីរបស់យើង ឬក៏អាចនឹងបំផ្លាញពួកគេជាមួយពាក្យសម្តីរបស់យើងបានដែរ។

មានគេនិយាយថា ដំបងនិងដុំថ្មអាចបំបាក់ឆ្អឹងខ្ញុំបាន ប៉ុន្តែពាក្យសម្តីនឹងមិនធ្វើឲ្យខ្ញុំឈឺចាប់នោះទេ ការនិយាយបែបនេះគឺជាកំហុសឆ្គង។ មានមនុស្សជាច្រើនដែលស្គាល់ការឈឺចាប់ និងការរងទុក្ខដោយសារពាក្យសម្តីទៅលើពួកគេជាច្រើនឆ្នាំ។ ការដែលថាឲ្យពួកគេ អាក្រក់ ស្គម ធាត់ មិនឆ្លាតគ្រប់គ្រាន់ មិនមានកម្លាំងគ្រប់គ្រាន់ មិនចូលសង្គមជាដើម ហើយការម៉ាកងាយទាំងនោះ (ស្នាមរបួស) នៅជាប់ជិតដាមជាមួយពួកគេជាច្រើនឆ្នាំ។ នៅក្នុងនិមិត្តសញ្ញាតែមួយអ្នកដែលមានមិត្តភក្តិដែលចេះលើកទឹកចិត្ត គ្រួសារដែលល្អ និងសហគមន៍ដែលផ្តល់នូវទំនុកចិត្តនិងក្តីសង្ឃឹម នោះនឹងនៅដក់ជាប់ក្នុងចិត្តរបស់ពួកគេ។ ជាការពិត ពាក្យសម្តីដែលនិយាយចេញទៅអាចនឹងមានឥទ្ធិពលទៅលើជោគវាសនារបស់ពួកគេ។ លោកយ៉ាកុបដែលជាប្អូនរបស់ព្រះយេស៊ូវបានបង្រៀនថា ទោះបីជាអណ្តាតជាផ្នែកមួយតូចនៃរាងកាយ ប៉ុន្តែវាគ្រប់គ្រងលើរាងកាយទាំងមូល។ វាគ្រប់គ្រងរាងកាយដូចជាបង្ហារសេះ ឬក៏ជាអ្នកកាច់ចង្កូតនៃកប៉ាល់ដ៏ធំ (យ៉ាកុប៣:១-៦)។ វាមានអំណាចដ៏មហិមានៅក្នុងពាក្យសម្តីដែលអាចផ្តល់ជីវិតហើយក៏ឲ្យមានសេក្តីស្លាប់ផងដែរ ។

អំណាចនៃការប្រាស្រ័យទាក់ទងគ្នា គឺមានសារៈសំខាន់ជាពិសេសនៅក្នុងបរិបទនៃអាពាហ៍ពិពាហ៍។ ដោយសារពាក្យសម្តីរបស់យើង យើងអាចអភិវឌ្ឍអាពាហ៍ពិពាហ៍មួយដ៏ស្រស់ស្អាតនិងរុងរឿងដែលលើកតម្កើងសិរីល្អដល់ព្រះជាម្ចាស់។ ហើយដោយសារពាក្យសម្តីនោះ យើងក៏អាចបំផ្លាញអំណោយទាននិងបេសសកកម្មដែលព្រះជាម្ចាស់ទ្រង់ប្រទានឲ្យយើងនៅក្នុងអាពាហ៍ពិពាហ៍បានដែរ។

នៅក្នុងផ្នែកនេះ យើងនឹងពិចារណាអំពីគោលការណ៍ដែលនឹងធ្វើឲ្យការប្រាស្រ័យទាក់ទងនៅក្នុងអាពាហ៍ពិពាហ៍មានការរីកចម្រើនឡើង។ យើងនឹងរៀនអំពីសារៈសំខាន់នៃការលូតលាស់នៅក្នុងចំណេះដឹងនៃដៃគូរបស់អ្នក ការផ្តល់កិត្តិយស និងទទួលយកនូវសមភាពនៃភាពខុសគ្នា តែងតែនិយាយពាក្យសម្តីដែលស្ថាបនាដល់គ្នា ស្តាប់ដៃគូរបស់អ្នក និងរៀនឲ្យនៅជាប់ជាមួយនឹងព្រះគ្រីស្ទ។

### ស្គាល់ដៃគូរបស់អ្នក

គោលការណ៍ទី១ ដែលនឹងធ្វើឲ្យការប្រាស្រ័យទាក់ទងគ្នាមានការរីកចម្រើនឡើងនោះ ជាទូទៅគឺត្រូវចាប់ផ្តើមស្គាល់ដៃគូរបស់អ្នក។ លោកពេត្រុសនិយាយនៅក្នុង ១ពេត្រុស៣:៧ *«ឯពួកប្រុសៗ នោះក៏ត្រូវនៅជាមួយនឹងប្រពន្ធដោយប្រាជ្ញាដែរ ដូចនឹងគ្រឿងភាជនៈដែលខ្សោយជាង គឺជាមនុស្សស្រី ព្រម*

*ទាំងរាប់អាននាង ទុកដូចជាអ្នកគ្រងព្រះគុណនៃជីវិត ទុកជាមរដកជាមួយគ្នា ដើម្បីកុំឲ្យមានអ្វីបង្អាក់ដល់សេចក្ដីអធិស្ឋានរបស់អ្នករាល់គ្នាឡើយ»។*

តើចំណេះដឹងអ្វីដែលស្វាមីត្រូវតែអភិវឌ្ឍនៅក្នុងទំនាក់ទំនងរបស់គាត់ជាមួយនឹងប្រពន្ធរបស់ខ្លួន ដើម្បីផ្ដល់ការគោរពនិងផ្ដល់កិត្តិយសដល់ប្រពន្ធរបស់ខ្លួនបាន? ស្វាមីត្រូវតែអភិវឌ្ឍចំណេះដឹងប្រពន្ធរបស់ខ្លួន។ មនុស្សគ្រប់គ្នាត្រូវបានបង្កើតឲ្យមានលក្ខណៈខុសប្លែកពីគ្នា។ ការខ្លះដែលរំខានដល់ប្រពន្ធ ប៉ុន្តែវាប្រហែលមិនរំខានដល់ស្វាមីនោះទេ។ អ្វីដែលធ្វើឲ្យស្វាមីសប្បាយចិត្ត ប្រហែលជាមិនមែនជាអ្វីដែលធ្វើឲ្យប្រពន្ធសប្បាយចិត្តផងដែរ ហើយការនេះកើតឡើងទៅវិញទៅមក។ ជារឿយៗការយល់ច្រឡំនៅក្នុងអាពាហ៍ពិពាហ៍អាចកើតមានឡើងជាធម្មតា ដោយព្រោះតែគូស្វាមីភរិយាមិនទាន់ស្គាល់ពីគ្នាច្បាស់លាស់។

ស្វាមីត្រូវរៀនពីអ្វីដែលធ្វើឲ្យប្រពន្ធរបស់ខ្លួនសប្បាយចិត្ត អ្វីដែលធ្វើឲ្យនាងមិនសប្បាយចិត្ត និងអ្វីដែលធ្វើឲ្យនាងខឹង ហើយប្រើប្រាស់ព័ត៌មានទាំងនេះ ដើម្បីស្អាងនាងឡើង ហើយមានការប្រាស្រ័យទាក់ទងគ្នាបានល្អប្រសើរទៀតផង។ ទោះបីជា លោកពេត្រុសនិយាយទៅកាន់ស្វាមីក៏ពិតមែន ប៉ុន្តែការនេះក៏ត្រូវសម្រាប់ប្រពន្ធផងដែរ។ នៅក្នុងភាសាក្រិក ពាក្យថា «ដឹង» មិនមែនគ្រាន់តែសំដៅទៅលើចំណេះដឹងនោះទេ ប៉ុន្តែក៏សម្ដៅទៅលើចំណេះដឹងនៃបទពិសោធន៍។ ស្វាមីនិងភរិយាត្រូវតែស្គាល់គ្នាឲ្យស្និទ្ធស្នាលបំផុត នោះពួកគេអាចមានការប្រាស្រ័យទាក់ទងជាមួយគ្នាបានល្អប្រសើរជាងមុន។

តើពួកគេគួរតែអភិវឌ្ឍចំណេះដឹងនេះដោយរបៀបណា? ដូចជាពេត្រុសបាននិយាយថា ពួកគេអាចអភិវឌ្ឍវាបានដោយការចំណាយពេលជាមួយគ្នាទៅវិញទៅមក(ឧទាហរ៍ រស់នៅជាមួយគ្នា)។ នៅកំឡុងពេលដែលមានការណាត់ជួប គូសង្សារតែងចំណាយពេលវេលាជាមួយគ្នាតាមដែលអាចទៅរួច ប៉ុន្តែគួរឲ្យសោកស្ដាយ ក្រោយពេលរៀបការរួច ការចំណាយពេលជាមួយគ្នាកាន់តែរសាត់ទៅៗ។ ប្ដីត្រូវមានការងារធ្វើ ប្រពន្ធត្រូវថែរក្សាផ្ទះសម្បែង និងកូនៗ ហើយក៏អាចមានការងារធ្វើផងដែរ។

នៅពេលដែលកូនកាន់តែធំឡើង ប្ដីប្រពន្ធនិងចំណាយពេលច្រើនផ្ដោតទៅលើកូនៗ ហើយមានពេលវេលាតិចតួចណាស់ផ្ដល់ឲ្យគ្នា។ ប្រសិនបើការនេះនៅតែបន្តដូចនេះ ពួកគេនឹងទៅដល់ចំណុចមួយដែលពួកគេលែងស្គាល់គ្នាទៀតហើយ។ ដើម្បីឲ្យគូស្វាមីភរិយាផ្លាស់ប្ដូរជារៀងរាល់ថ្ងៃ ហើយនៅតែបន្តស្គាល់គ្នាយ៉ាងស្និទ្ធស្នាលបាន នោះពួកគេត្រូវតែចំណាយពេលវេលាជាមួយគ្នា។ ពេលវេលានោះរួមមានដំណើរកម្សាន្តលក្ខណៈប្ដីប្រពន្ធរៀងរាល់ឆ្នាំ ការណាត់ជួបគ្នារៀងរាល់សប្ដាហ៍ និងការប្រាស្រ័យទាក់ទងគ្នាយ៉ាងស្និទ្ធស្នាលប្រចាំថ្ងៃផងដែរ។ ខ្ញុំនិងប្រពន្ធរបស់ខ្ញុំព្យាយាមចំណាយពេលយ៉ាងហោចណាស់ម៉ោងចុងក្រោយរៀងរាល់ថ្ងៃជាមួយគ្នា ដោយគ្មានទូរទស្សន៍ ឬកុំព្យូទ័រឡើយ។ យើងធ្វើបែបនេះ ពីព្រោះយើងមានបំណងចិត្តចង់ស្គាល់គ្នាកាន់តែប្រសើរឡើង។

គម្លាតរវាងប្ដីប្រពន្ធកាន់តែឃ្លាតឆ្ងាយ បញ្ហានៃទំនាក់ទំនងកាន់តែធ្ងន់។ ការនេះក៏កើតឡើងចំពោះអ្នកបម្រុងនឹងរៀបការផងដែរ។ ការចែចង់និងការភ្ជាប់ពាក្យ គឺជារដូវកាលយ៉ាងពិសេសដែលជួយចាក់គ្រឹះសម្រាប់សាងសង់គ្រួសារនាពេលអនាគត។ គូស្នេហ៍ដែលមានការប្រាស្រ័យទាក់ទងល្អនោះស្គាល់គ្នាបានច្បាស់ ហើយអ្នកណាដែលមិនស្គាល់គ្នាបានច្រើន នោះក៏មិនអាចមានការប្រាស្រ័យ

ទាក់ទងល្អនោះដែរ។

តើព្រះជាម្ចាស់កំពុងត្រាស់ហៅអ្នកឲ្យរៀបយុទ្ធសាស្ត្រលូតលាស់ក្នុងភាពស្និទ្ធស្នាលជាមួយដៃគូរបស់អ្នកដោយរបៀបណា?

### ផ្តល់កិត្តិយសនិងទទួលយកភាពខុសគ្នា

គោលការណ៍ចាំបាច់បន្ទាប់នៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍ គឺមិនមែនគ្រាន់តែស្គាល់ដៃគូរបស់អ្នកប៉ុណ្ណោះទេ ប៉ុន្តែគឺទទួលស្គាល់និងផ្តល់កិត្តិយសដល់ដៃគូរបស់អ្នក ក្នុងនាមគាត់ជាបុរស ឬស្ត្រីដែលព្រះទ្រង់បានបង្កើតគាត់មកក្នុងរបៀបជាគាត់។ ជាទូទៅប្រភពនៃការមិនមានការប្រាស្រ័យទាក់ទងល្អឬមានការយល់ច្រឡំនៅក្នុងអាពាហ៍ពិពាហ៍នោះ គឺជាការពិតដែលមនុស្សប្រុស និងមនុស្សស្រីមានភាពខុសគ្នានោះជារឿងធម្មតាទេ។ មិនមែនគ្រាន់តែភេទផ្ទុយគ្នាមានរាងកាយខុសគ្នានិងមានអារម្មណ៍ឬមនោសញ្ចេតនាខុសគ្នាប៉ុណ្ណោះទេ ប៉ុន្តែសូម្បីតែរបៀបក្នុងការប្រាស្រ័យទាក់ទងគ្នាក៏ខុសគ្នាដែរ ហើយភាពខុសគ្នាទាំងនេះជារឿយៗពង្រីកនៅក្នុងសហភាព(ភាពរួបរួម)អាពាហ៍ពិពាហ៍។ ចំនួននៃការឈ្លោះទាស់ទែងគ្នាខ្លាំងនៅក្នុងអាពាហ៍ពិពាហ៍មកពីមិនយល់ចិត្តគ្នានិងមិនទទួលយកនូវភាពខុសគ្នាទាំងនេះ។

មានមនុស្សស្រីជាច្រើនដែលលូតលាស់ឡើងជាមួយមិត្តភក្តិស្រីដូចគ្នា ដែលពួកគេអាចចែករំលែកអារម្មណ៍របស់ពួកគេទាំងអស់ជាមួយបាន ហើយទទួលបានមកវិញនូវមិត្តសម្លាញ់ដែលផ្តល់នូវការគាំទ្រដល់គ្នា។ មនុស្សប្រុសជាធម្មតា គឺជាអ្នកដែលមានទំនាក់ទំនងផ្តោតលើគោលដៅច្រើនជាងពេលគឺការប្រាស្រ័យទាក់ទងរបស់ពួកគេ គឺដើម្បីបំពេញសម្រេចនូវអ្វីមួយ។ ជារឿយៗការប្រាស្រ័យទាក់ទងរបស់មនុស្សប្រុស គឺត្រូវបានប្រើ ដើម្បីសម្រេចនូវគោលដៅមួយបន្តទៀត ឬអាចឈានទៅដល់គោលដៅដោយរបៀបណា ហើយត្រូវធ្វើអ្វីទៀតបន្ទាប់ពីសម្រេចបានគោលដៅនោះហើយ។ ការប្រាស្រ័យទាក់ទង គឺមានគោលដៅនៅក្នុងគំនិតរួចហើយ ចំណែកឯមនុស្សស្រីវិញ គឺមានគោលបំណងខុសគ្នាពីមនុស្សប្រុស។ ជាធម្មតាគោលដៅអាចដូចជាការបង្ហាញពីអារម្មណ៍ ការទទួលបានអារម្មណ៍និងការទទួលស្គាល់។

ជារឿយៗមនុស្សស្រីស្រែកឡើងថា «ដោយសារមនុស្សប្រុស» ហើយមនុស្សប្រុសក៏ស្រែកឡើងដែរថា «ដោយសារមនុស្សស្រី»។ ទាំងពីរនាក់ស្រែកឡើងព្រមគ្នា ពីព្រោះតែពួកគេមិនអាចស្វែងរកដំណោះស្រាយក្រៅពីនេះបាន។ ព្រះគម្ពីរបានបង្រៀនយើងថា ព្រះទ្រង់ជ្រើសរើសមនុស្សប្រុស និងមនុស្សស្រីសម្រាប់គ្នាទៅវិញទៅមក។ ទោះបីជាអេវ៉ាត្រូវបានដកចេញពីឆ្អឹមជំនីរបស់អ័ដាមហើយត្រូវបានបង្កើតមកឲ្យសមគ្នាជាមួយនឹងអ័ដាមយ៉ាងឥតខ្ចោះក៏ដោយ ទោះបីជាមានភាពខុសគ្នាក៏ពិតមែនក៏បុរស ហើយនិងស្ត្រីត្រូវបានបង្កើតមកសម្រាប់គ្នាទៅវិញទៅមក ហើយជាពិសេស នៅពេលដែលមានការរួបរួមនៅក្នុងអាពាហ៍ពិពាហ៍នៃព្រះអម្ចាស់ នោះប្រហែលជាគ្មានវិធីផ្សេងទៀតដែលអស្ចារ្យជាងនេះនៅក្នុងការបង្ហាញពីរូបអង្គរបស់ព្រះជាម្ចាស់នោះទេ(លោកុប្បត្តិ១:២៧)។ នៅក្នុងការបង្កើតបុរសនិងស្ត្រីយើងអាចដឹងយ៉ាងប្រាកដថា ព្រះជាម្ចាស់ទ្រង់ជ្រាបពីភាពខុសគ្នាយ៉ាងធំដែលអាចបង្កជាបញ្ហានៅក្នុង

អាពាហ៍ពិពាហ៍របស់ពួកគេ។ ហេតុយ៉ាងដូច្នោះ ទ្រង់បានប្រទាននូវការណែនាំយ៉ាងច្បាស់នៅក្នុងព្រះបន្ទូលរបស់ទ្រង់អំពីរបៀបដោះស្រាយពីចន្លោះខ្វះខាតនៅក្នុងការប្រាស្រ័យទាក់ទងដើម្បីឲ្យទទួលបានអាពាហ៍ពិពាហ៍ជោគជ័យ។

ជាថ្មីម្តងទៀត សាវ័កពេត្រុសជាបុរសដែលរៀបការរួចបាននិយាយនៅក្នុងសំបុត្ររបស់លោកថា៖ *ឯពួកប្រុសៗ នោះក៏ត្រូវនៅជាមួយនឹងប្រពន្ធដោយប្រាជ្ញាដែរ ដូចនឹងគ្រឿងភាជនៈដែលខ្សោយជាង គឺជាមនុស្សស្រី ព្រមទាំងរាប់អាននាង ទុកដូចជាអ្នកគ្រងព្រះគុណនៃជីវិត ទុកជាមរដកជាមួយគ្នា ដើម្បីកុំឲ្យមានអ្វីបង្អាក់ ដល់សេចក្តីអធិស្ឋានរបស់អ្នករាល់គ្នាឡើយ (១ពេត្រុស៣:៧)*។

លោកពេត្រុសបានហៅប្រពន្ធថា ជាដៃគូដែលខ្សោយជាង (ជាភាជនៈដែលខ្សោយជាង) ហើយបង្គាប់ដល់ប្តីឲ្យប្រព្រឹត្តចំពោះប្រពន្ធខ្លួនដោយប្រាជ្ញា ដោយការគោរព(ផ្តល់កិត្តិយស)។ តើគាត់ចង់មានន័យដូចម្តេចចំពោះស្ត្រីដែលជាភាជនៈដែលខ្សោយជាង? ន័យត្រង់គឺសម្តៅលើរូបកាយដែលខ្សោយជាង ប៉ុន្តែច្បាស់ណាស់វាមានន័យជាងនោះទៅទៀត។ មានការបកស្រាយមួយចំពោះភាជនៈខ្សោយជាង គឺមានន័យអាចំកំបាំងដែលមានតម្លៃជាង ឬជាភាជនៈដ៏ប្រណិត។ ពីព្រោះស្ត្រីមានភាពប្រណិតជាងបុរស មនុស្សប្រុសងាយនឹងធ្វើឲ្យនាងឈឺចាប់ទាំងខាងឯរូបកាយ អារម្មណ៍ ហើយជាការពិតណាស់ថែមទាំងពាក្យសម្តីទៀតផង។ សម្រាប់ហេតុផលនេះ សាវ័កប៉ុលបានបង្គាប់ដល់ស្វាមី កុំឲ្យធ្វើបាបដល់ប្រពន្ធរបស់ខ្លួនឡើយ (កូល៉ុស៣:១៩)។ ជាច្រើនដងដែលមនុស្សប្រុសតែងតែធ្វើបាបដល់ប្រពន្ធរបស់ខ្លួន ពីព្រោះតែភាពខុសគ្នានិងរបៀបខុសគ្នាដែលព្រះបានបង្កើតពួកគេមក។ ហេតុយ៉ាងដូច្នោះ លោកពេត្រុសបានហៅពួកមនុស្សប្រុស មិនមែនគ្រាន់តែប្រព្រឹត្តនឹងប្រពន្ធខ្លួនដោយពិចារណាពីភាពខុសគ្នាប៉ុណ្ណោះទេ ប៉ុន្តែត្រូវផ្តល់កិត្តិយសដល់ពួកគេថែមទៀតផង (១ពេត្រុស៣:៧)។ ទោះបីជាលោកពេត្រុសនិយាយទៅកាន់ប្តី ប៉ុន្តែជាការពិតណាស់ប្រពន្ធក៏ត្រូវស្តាប់បង្គាប់ការនេះដូចគ្នាដែរ។ នាងត្រូវតែពិចារណាចំពោះប្តីរបស់ខ្លួន និងពីរបៀបដែលព្រះបានបង្កើតគាត់មក ហើយផ្តល់កិត្តិយសដល់ភាពខុសគ្នាទាំងនោះផងដែរ។

ដូចដែលបានបញ្ជាក់ពីមុនថា មានមនុស្សប្រុសនិងមនុស្សស្រីជាច្រើនមិនបានផ្តល់កិត្តិយដល់ភាពខុសគ្នាដែលព្រះបានបង្កើតមកដោយភេទខុសគ្នា ផ្ទុយទៅវិញ ពួកគេបែរជាមិនផ្តល់កិត្តិយឲ្យគ្នាថែមទាំងកំណត់ឲ្យមានការផ្លាស់ប្តូរទៅវិញ។ មនុស្សប្រុសចង់ឲ្យមនុស្សស្រីមានភាពទៀងត្រង់ជាងហើយបញ្ឈប់ការធ្វើឬកម៉្ងិកម៉្ងក់ និងងាយប៉ះពាល់ផ្លូវអារម្មណ៍ទៀត។ មនុស្សស្រីវិញចង់ឲ្យមនុស្សប្រុសឆាប់យល់ចិត្តខ្លួន និងស្តាប់តាមខ្លួនបានប្រសើរជាងមុន។ ជាការពិតណាស់ មានការជាច្រើនដែលយើងអាចធ្វើនិងគួររៀនបានពីភេទខុសគ្នា។ ការនិយាយដូច្នេះ យើងត្រូវតែនិយាយពី «ការផ្តល់កិត្តិយស ឬការគោរព» ភាពខុសប្លែកពីគ្នាដែលជាឫសគល់ក្នុងរបៀបដែលព្រះបានបង្កើតពួកគេមក។ ព្រះទ្រង់បានបង្កើតមនុស្សប្រុស និងមនុស្សស្រីដោយភាពខុសគ្នាហើយសម្រាប់គ្នាទៅវិញទៅមក។

ប្រាកដណាស់ មានមនុស្សប្រុសដែលបានរៀបការរួចជាច្រើននាក់ចង់ធ្វើដូចពេត្រុសដែលព្យាយាមផ្លាស់ប្តូរប្រពន្ធរបស់ខ្លួនឲ្យដូចជារូបលោកកាន់តែច្រើនឡើង។ ប៉ុន្តែពេត្រុសរៀនបានថា ព្រះទ្រង់បានបង្កើតមនុស្សស្រីយ៉ាងពិសេស និងភាពខុសគ្នាទាំងនោះគឺ ដើម្បីឲ្យបានផ្តល់កិត្តិយសដល់គ្នា។

ហេតុយ៉ាងដូច្នោះ នេះគឺជាគោលការណ៍ដ៏សំខាន់ដែលគួរចងចាំនៅក្នុងអាពាហ៍ពិពាហ៍ និងជាការបង្គាប់របស់ព្រះជាម្ចាស់។ ការផ្ដល់កិត្តិយសដល់ចរិកលក្ខណៈពិសេសនៃភាជនៈដែលព្រះបានបង្កើតមកសម្រាប់អ្នក។

នៅក្នុងអាពាហ៍ពិពាហ៍របស់ខ្ញុំ ការនេះបានជួយខ្ញុំជាច្រើន កាលពីមុនខ្ញុំធ្លាប់ចង់ឲ្យប្រពន្ធរបស់ខ្ញុំមានការផ្លាស់ប្ដូរ ខ្ញុំមិនអាចយល់ឬមិនអាចទទួលយកការគិតរបស់នាងបាននោះទេ។ ខ្ញុំបានរៀនពីការទទួលយកនិងផ្ដល់កិត្តិយសដល់នាង ដូចជាភាជនៈដ៏មានតម្លៃ។ ព្រះទ្រង់បានបង្កើតនាងឲ្យមានលក្ខណៈខុសពីខ្ញុំ ហើយខ្ញុំសរសើរដម្កើងដល់ព្រះសម្រាប់ភាពខុសគ្នាទាំងនោះ។ ជំនួសឲ្យការដែលព្យាយាមកែប្រែនាង ខ្ញុំកំពុងតែរៀនជារៀងរាល់ថ្ងៃពីការទទួលយកនិងផ្ដល់កិត្តិយសដល់នាងបន្ថែមទៀត។ ខ្ញុំចង់ឲ្យនាងទទួលបានអារម្មណ៍ពីការទទួលស្គាល់ និងមានអំណរដែលព្រះបានបង្កើតនាងឲ្យមានលក្ខណៈខុសប្លែកពីគេយ៉ាងដូច្នេះ។ លើសពីនេះទៅទៀត ខ្ញុំក៏កំពុងតែរៀនពីការដែលខ្ញុំត្រូវការគ្រប់ចំណុចខុសគ្នាៗទាំងនោះ។

គូស្នេហ៍បម្រុងរៀបការគួរតែរៀនទទួលស្គាល់ពីភាពខុសគ្នានៅក្នុងដៃគូរបស់ខ្លួន ដើម្បីនឹងផ្ដល់កិត្តិយសដល់ភាពខុសគ្នាទាំងនោះ ហើយរៀនពីការនោះ។ តាំងពីព្រះទ្រង់បានបង្កើតមនុស្សស្រី ដើម្បីជួយដល់មនុស្សប្រុស ហើយមនុស្សប្រុសដើម្បីជួយដល់មនុស្សស្រី នោះពួកគេត្រូវការរៀនពីគ្នាទៅវិញទៅមក។ រៀនពីរបៀបដែលផ្ដល់កិត្តិយសដល់ភាពខុសគ្នាទាំងនោះ ហើយធ្វើឲ្យប្ដីឬប្រពន្ធរបស់អ្នកទទួលបានអារម្មណ៍ទទួលស្គាល់ និងផ្ដល់កិត្តិយសសម្រាប់ពួកគេឲ្យក្លាយទៅជាមនុស្សដែលព្រះបានបង្កើតពួកគេមកយ៉ាងពិសេស។ ការផ្ដល់កិត្តិយសនេះនឹងជួយឲ្យការប្រាស្រ័យទាក់ទងមានភាពរីកចម្រើនឡើង។

**តែងតែនិយាយពាក្យដែលកែតម្រូវគ្នា**

ទាក់ទងទៅនឹងការផ្ដល់កិត្តិយសដល់ប្ដីឬប្រពន្ធ ព្រះទ្រង់បានធ្វើឲ្យឃើញយ៉ាងច្បាស់ដែលយើងមិនគួរមិនផ្ដល់កិត្តិយសដល់គ្នាតាមរយៈពាក្យសម្ដីរបស់យើងនោះឡើយ។ យើងមើលឃើញនៅក្នុងទូរទស្សន៍ និងក្នុងរឿងផ្សេងៗ ហើយអ្នកនឹងមើលឃើញពីមនុស្សដែលមិនគោរពនិងមិនផ្ដល់កិត្តិយសដល់គ្នាទៅវិញទៅមក។ គួរឲ្យសោកស្ដាយ ការនេះតែងកើតឡើងនៅក្នុងអាពាហ៍ពិពាហ៍ ដែលមានបញ្ហាជាមួយបទបញ្ញារបស់ព្រះដោយផ្ទាល់។ សាវ័កប៉ុលបាននិយាយពីការនេះនៅក្នុង អេភេសូ៤:២៩-៣០ *«មិនត្រូវឲ្យមានពាក្យអាក្រក់ណាមួយ ចេញពីមាត់អ្នករាល់គ្នាឡើយ ចូរបញ្ចេញតែពាក្យណាដែលល្អៗសំរាប់នឹងស្អាងចិត្តតាមត្រូវការ ដើម្បីឲ្យបានផ្តល់ព្រះគុណដល់អស់អ្នកដែលស្តាប់។ កុំធ្វើឲ្យព្រះវិញ្ញាណបរិសុទ្ធនៃព្រះបានព្រួយព្រះហឫទ័យ ដែលទ្រង់ដៅចំណាំអ្នករាល់គ្នាទុកសំរាប់ដល់ថ្ងៃប្រោសលោះនោះឡើយ»*។

តាមរយៈសាវ័កប៉ុល ព្រះបានបង្គាប់ដល់យើងមិនឲ្យមានពាក្យសម្ដីណាមិនសមរម្យចេញពីមាត់របស់ពួកយើងឡើយ។ ការនេះរាប់បញ្ចូលទាំងការប្រទេចផ្ដាសា ការស្ដីបន្ទោស ការចោទប្រកាន់ ការនិយាយដើម ការកុហកជាដើម។ ការទាំងអស់ទាំងនេះមិនសក្ដិសមជាមួយនឹងគ្រីស្ទបរិស័ទក្នុងការ

និយាយនោះឡើយ ជាពិសេសនៅក្នុងបរិបទនៃអាពាហ៍ពិពាហ៍។

សាវ័កប៉ុលក៏បានបន្ថែមចំណុចវិជ្ជមាននៃការនិយាយដែរថា ត្រូវនិយាយតែពាក្យណាដែលស្អាងគ្នាឡើង យោងទៅតាមសេចក្តីត្រូវការរបស់ពួកគេ (ខ២៩)។ នៅក្នុងបរិបទនៃអាពាហ៍ពិពាហ៍ អទិភាពនៃជម្លោះនឹងមិនដែលកើតមានឡើងឡើយ ប្រសិនបើ ប្តីប្រពន្ធនិយាយពាក្យដែលលើកគ្នាឡើង ជាជាងបន្ទោសដល់គ្នាវិញ។

អ្នកចិត្តសាស្ត្របានផ្តល់នូវការអះអាងអំពីវិធីសាស្ត្រដ៏មានប្រយោជន៍ ដើម្បីជួយក្នុងដំណើរការនេះហៅថា ការប្រើប្រាស់ «ប្រយោគខ្ញុំ» ជំនួសឲ្យ «ប្រយោគអ្នក»។ នៅពេលដែលប្រពន្ធនិយាយថា «អ្នកមិនដែលស្តាប់ខ្ញុំទេ!» ហើយ«អ្នកមិនដែលខ្វល់ពីខ្ញុំទេ!» ការនេះជាស្វ័យប្រវត្តិធ្វើឲ្យប្តីមានអារម្មណ៍ រងការវាយប្រហារភ្លាមៗ ហើយឈានដល់ការការពារខ្លួនឯង។ ជំនួសឲ្យការនេះ វាត្រូវបានស្នើឲ្យយើងប្រើ «ប្រយោគខ្ញុំ» ដូចជា «នៅពេលដែលអ្នកចាប់ផ្តើមនិយាយ ដោយខ្ញុំមិនទាន់បញ្ចប់ការចែកចាយរបស់ខ្ញុំនោះខ្ញុំមានអារម្មណ៍ថា អ្នកមិនស្តាប់ខ្ញុំទេ»។ «នៅពេលដែលអ្នកមើលទូរទស្សន៍ពេញមួយយប់ ខ្ញុំមានអារម្មណ៍ថា អ្នកមិនខ្វល់ពីខ្ញុំទេ» ។ នេះជាការផ្តល់ពត៌មានយ៉ាងសមរម្យ ជំនួសឲ្យការចោទប្រកាន់ថាបុគ្គលនោះខុស។ ហើយការនេះបើកទ្វារឲ្យមានការវាយតម្លៃនូវអារម្មណ៍ទាំងនេះជំនួសឲ្យមានការឈ្លោះទាស់ទែង។ នេះគឺជាឧបករណ៍មួយដ៏អស្ចារ្យដែលនឹងជួយដល់ដៃគូនិយាយតែពាក្យកែតម្រូវគ្នា ជាពិសេសនៅពេលដែលដោះស្រាយជាមួយរឿងងាយប៉ះទង្គិចគ្នា។

**អនុវត្តសិល្បៈនៃការស្តាប់**

ភ្ជាប់ជាមួយនឹងការនិយាយតែពាក្យដែលកែតម្រូវគ្នា ព្រះគម្ពីរក៏បានផ្តល់ឲ្យយើងនូវការបង្រៀនបន្ថែមទៀតផងដែរ អំពីការប្រាស្រ័យទាក់ទងដែលមានផាសុខភាព។ លោកយ៉ាកុបជាប្អូនព្រះយេស៊ូវបាននិយាយថា «ដូច្នេះ បងប្អូនស្ងួនភ្ងាអើយ ចូរឲ្យគ្រប់គ្នាបានឆាប់នឹងស្តាប់ ក្រនឹងនិយាយ ហើយយឺតនឹងខឹងដែរ (យ៉ាកុប១:១៩)»។ ដើម្បីឲ្យមនុស្សអាចនិយាយតែពាក្យសម្តីកែតម្រូវគ្នាបាន ពួកគេត្រូវតែគ្រប់គ្រងការស្តាប់របស់ពួកគេ។ ទាំងនេះជាចំណុចមួយចំនួន ដើម្បីជួយអ្នកឲ្យក្លាយជាអ្នកស្តាប់ដ៏ប្រសើរ៖

**១. អនុវត្តការស្តាប់អ្វីដែលប្តីឬប្រពន្ធរបស់អ្នកកំពុងនិយាយ**

មានឃ្លាមួយនិយាយជាញឹកញាប់ថា ព្រះទ្រង់ប្រទានឲ្យយើងមានត្រចៀក២និងមាត់មួយ ដូច្នេះយើងនឹងបានស្តាប់ទ្វេរដងច្រើនជាងយើងនិយាយ។ នេះគឺជាគោលការណ៍ដ៏ឈ្លាសវៃនៅក្នុងការប្រាស្រ័យទាក់ទងគ្នា យើងត្រូវតែអនុវត្តការស្តាប់។ ការខ្លះដែលនឹងជួយជាមួយអនុវត្តដល់ការស្តាប់នោះគឺ «ការស្តាប់ដោយសកម្ម»។ យើងធ្វើការនេះដោយការនិយាយបញ្ជាក់ម្តងទៀតពីអ្វីដែលប្តី ឬប្រពន្ធរបស់យើងបាននិយាយរួច ដើម្បីទទួលបានការបញ្ជាក់ឲ្យច្បាស់ពីការនោះ។ ឧទាហរណ៍ យើងអាចសួរគាត់ថា ទាំងនេះជាអ្វីដែល «ខ្ញុំឮអ្នកនិយាយថា អ្នកមានអារម្មណ៍ថា ខ្ញុំព្រងើយកន្តើយនឹងអ្នកនៅពេលដែលខ្ញុំមើលទូរទស្សន៍ពេញមួយយប់ តើត្រូវទេ?» ការធ្វើរបៀបនេះ ដើម្បីប្រាកដប្រជាពីពាក្យសម្តី និងចេតនារបស់ប្តីឬប្រពន្ធរបស់អ្នក។ ហើយការនេះក៏បង្ហាញគាត់ឬនាងថា អ្នកកំពុងតែព្យាយាមស្វែងយល់ពីអ្វីដែលសំខាន់ក្នុងការប្រាស្រ័យទាក់ទងគ្នាផងដែរ។

**២. អនុវត្តការស្តាប់អ្វីដែលប្តីឬប្រពន្ធរបស់អ្នកមិនបាននិយាយ**

ជាច្រើនដង មានការប្រាស្រ័យទាក់ទងគ្នាច្រើនជាងតាមរយៈអ្វីដែលបុគ្គលម្នាក់មិនបាននិយាយ នោះច្រើនជាងអ្វីដែលគេបាននិយាយទៅទៀត។ កាប្រាស្រ័យទាក់ទងគ្នាចន្លោះពី 60% ទៅ90% គឺជាការប្រាស្រ័យទាក់ទងដោយគ្មានពាក្យសម្តី។ ពេលខ្លះវាជាការពិតប្តីឬប្រពន្ធដែលស្ងៀមស្ងាត់អាចនិយាយចេញមកដោយមានប្រសិទ្ធិភាព។ អាចនិយាយបានថា គាត់មិនមានអារម្មណ៍ល្អ ឬគាត់មានអ្វីច្រើននិយាយ។ នេះគឺជាអ្វីមួយល្អដែលប្តីឬប្រពន្ធនឹងរៀនឲ្យបានយល់ដឹងពីគ្នាផងដែរ។ សូមរៀនយល់ពីភាសាកាយវិការរបស់ប្តីឬប្រពន្ធរបស់អ្នក ហើយនិងចេតនារបស់គាត់ ដើម្បីឲ្យមានការរីកចម្រើនក្នុងការប្រាស្រ័យទាក់ទងគ្នា។

**៣. អនុវត្តការស្តាប់សម្លេងព្រះវិញ្ញាណបរិសុទ្ធ**

ព្រះទ្រង់សព្វព្រះហឫទ័យប្រទានឲ្យយើងមានប្រាជ្ញា ដើម្បីនឹងគ្រប់គ្រងភាពខុសប្លែករបស់ប្តី ឬប្រពន្ធរបស់យើង។ ព្រះទ្រង់ស្គាល់ពីប្តីឬប្រពន្ធរបស់យើងជាជាងយើងស្គាល់ពួកគេទៅទៀត។ ហេតុយ៉ាងដូច្នោះ យើងគួរតែអនុវត្តការអធិស្ឋាន ទោះបីជាពេលខ្លះនៅកំឡុងពេលសន្ទនា ដូច្នេះ យើងអាចឮនូវអ្វីដែលព្រះទ្រង់ចង់ឲ្យយើងឮ និងនិយាយនូវអ្វីដែលទ្រង់ចង់ឲ្យយើងនិយាយ (នេហេមា២:៤-៥)។ យ៉ាកុប១:៥ និយាយថា *«តែបើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះ ដែលទ្រង់ប្រទានដល់មនុស្សទាំងអស់ដោយសទ្ធា ឥតបន្ទោសផង នោះទ្រង់នឹងប្រទានឲ្យ»*។

**៤. អនុវត្តការនិយាយតិច**

ជាការពិតណាស់ ដើម្បីឲ្យមនុស្សម្នាក់អាចស្តាប់ប្តីឬប្រពន្ធរបស់គាត់ និងស្តាប់ព្រះបានច្បាស់ក្នុងពេលតែមួយ គាត់ត្រូវតែរៀនពីរបៀបក្នុងការនិយាយតិច។ ស្តេចសាឡូម៉ូនបានមានបន្ទូលនៅក្នុងសុភាសិតថា *«អ្នកណាដែលនិយាយច្រើន នោះមិនខាននឹងមានបាបឡើយ (១០:១៩)»* នៅក្នុងទំនាក់ទំនងជាច្រើន មនុស្សចូលចិត្តនិយាយច្រើនរបៀបណាស់ ហេតុយ៉ាងដូច្នោះ ធ្វើឲ្យគាត់ស្តាប់បានតិចវិញដែលនាំឲ្យមានជម្លោះកើតឡើង។ លោកយ៉ាកុបបានប្រាប់យើងថា យើងគួរតែឆាប់នឹងស្តាប់ ហើយក្រនឹងនិយាយវិញ។

**រៀននៅជាប់ជាមួយនឹងព្រះគ្រីស្ទ**

ដូចដែលបាននិយាយរួចមកហើយថា ព្រះគម្ពីរបានផ្តល់ឲ្យយើងនូវគោលការណ៍ជាច្រើនអំពីការប្រាស្រ័យទាក់ទងគ្នា តាំងតែពីព្រះនៃយើងទ្រង់គឺជាព្រះទំនាក់ទំនងមកម្ល៉េះ។ ទោះបីយ៉ាងជាណាក៏ដោយជាមួយនឹងការនិយាយដូច្នេះ យើងគួរតែដឹងហើយថា ការយល់ដឹងពីគោលការណ៍ទាំងនោះ នោះវាស្រួលជាជាងការដែលធ្វើឆ្ងាយណាស់។ ព្រះគម្ពីរបានបង្រៀនថា យើងមិនត្រឹមតែត្រូវការប្រាជ្ញាមកពីព្រះប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ត្រូវការព្រះចេស្តារបស់ព្រះ ដើម្បីអាចធ្វើការប្រាស្រ័យទាក់ទងគ្នាឲ្យបានប្រសើរឡើង ពីព្រោះយើងជាប់មាននិស្ស័យបាប។ ព្រះយេស៊ូវបានមានព្រះបន្ទូលនៅក្នុង យ៉ូហាន១៥:៥ ថា *«ខ្ញុំជាគល់ អ្នករាល់គ្នាជាខ្នែង អ្នកណាដែលនៅជាប់នឹងខ្ញុំ ហើយខ្ញុំជាប់នឹងអ្នកនោះ នោះទើបនឹងបង្កើតផលឡើងជាច្រើន ដ្បិតបើដាច់ពីខ្ញុំចេញ នោះអ្នករាល់គ្នាពុំអាចនឹងធ្វើអ្វីបានទេ»*។

គោលការណ៍ទាំងនេះអាចអនុវត្តជោគជ័យបានតែចំពោះអ្នកបម្រុងរៀបការឬទំនាក់ទំនងអាពាហ៍ពិពាហ៍ប៉ុណ្ណោះ ប្រសិនបើមនុស្សចូលរួមដើរយ៉ាងជិតស្និទ្ធជាមួយនឹងព្រះសង្គ្រោះរបស់ពួកគេ ហើយនៅជាប់ក្នុងព្រះវត្តមានរបស់ទ្រង់។ នៅពេលដែលអ្នកនៅជាប់នឹងព្រះគ្រីស្ទ ព្រះទ្រង់នឹងប្រទានដល់អ្នកនូវផលផ្លែដែលយើងត្រូវការ ដើម្បីភាពជោគជ័យ។ ផលផ្លែទាំងនោះរួមបញ្ចូលទាំង ភាពអត់ធ្មត់ ដឹងខ្នាត សេចក្តីស្រឡាញ់ ការអត់ទោស និង ថែមទាំងពាក្យនិយាយដែលត្រឹមត្រូវគួរនិយាយទៀតផង។ ការនៅជាប់ជាមួយនឹងព្រះគ្រីស្ទគឺជាអាថ៌កំបាំង ដើម្បីផលផ្លែនៃការប្រាស្រ័យទាក់ទងគ្នា សម្រាប់ទាំងពីរប្តីឬប្រពន្ធរបស់យើង។

តើយើងអាចនៅជាប់នឹងព្រះគ្រីស្ទដោយរបៀបណា? ការនៅជាប់ជាមួយនឹងព្រះគ្រីស្ទរួមមាន ប៉ុន្តែគ្មានដែនកំណត់ទេ គឺទាំងវិន័យក្នុងការអធិស្ឋាន ការសិក្សាព្រះគម្ពីរ ការចូលរួមក្នុងពួកជំនុំជាទៀតទាត់ ការបម្រើ ការប្រែចិត្តចេញពីអំពើបាប និងការនៅជាប់ជាមួយនឹងព្រះគ្រីស្ទជាប្រចាំ។ តាមរយៈការនៅជាប់ជាមួយនឹងព្រះគ្រីស្ទ យើងត្រូវទទួលស្គាល់ពីភាពអសមត្ថភាពរបស់យើងក្នុងការប្រាស្រ័យទាក់ទងគ្នាឲ្យបានល្អ ហើយតើការដែលយើងដាច់ចេញពីព្រះគុណរបស់ព្រះ យើងនឹងបំផ្លាញនូវអ្វីដែលទ្រង់បានប្រទានដល់យើងដោយរបៀបណា។ ហើយសម្រាប់អ្នកណាដែលបន្ទាបខ្លួនជាប្រចាំនៅចំពោះព្រះជាម្ចាស់ នោះពួកគនឹងរកឃើញនូវព្រះគុណដ៏អស្ចារ្យ ដើម្បីអាចនឹងប្រាស្រ័យទាក់ទងគ្នានៅក្នុងអាពាហ៍ពិពាហ៍របស់ពួកគេបាន (យ៉ាកុប៤:៦,១០)។

## សរុបសេចក្តី

ដូចដែលយើងបានពិចារណាអំពីការប្រាស្រ័យទាក់ទងគ្នានៅក្នុងអាពាហ៍ពិពាហ៍រួចមកហើយ យើងត្រូវតែចងចាំថា ព្រះជាម្ចាស់ទ្រង់គឺជាអ្នកប្រាស្រ័យទាក់ទង ហើយយើងត្រូវបានបង្កើតមកនៅក្នុងរូបអង្គទ្រង់។ ដូច្នេះ យើងត្រូវបានបង្កើតមក ដើម្បីឲ្យមានការប្រាស្រ័យទាក់ទង។ ដូចដែលយើងពឹងផ្អែកទៅលើព្រះជាម្ចាស់តាមរយៈការអនុវត្តនូវគោលការណ៍ទាំងនោះនៅក្នុងព្រះបន្ទូលរបស់ទ្រង់ យើងអាចចាប់ផ្តើមប្រើប្រាស់ការប្រាស្រ័យទាក់ទងរបស់យើង ដើម្បីសាងសង់អាពាហ៍ពិពាហ៍របស់យើងជំនួសឲ្យបែកបាក់គ្នា។ ហើយដោយព្រះគុណទ្រង់ យើងអាចចាប់ផ្តើមទទួលស្គាល់ពីផែនការដើមសម្រាប់អាពាហ៍ពិពាហ៍បាន គឺការរួបរួមដែលនាំមកនូវការថ្វាយសិរីល្អដល់ព្រះជាម្ចាស់ ហើយជាព្រះពរទៅកាន់មនុស្សគ្រប់គ្នា។

### កិច្ចការផ្ទះ ឆ្លើយសំនួរហើយពិភាក្សាជាមួយគ្នា

១. តើមានដែលអ្វីថ្មីឬចូលមកក្នុងគំនិតអ្នកនៅក្នុងជំពូកនេះឬទេ? នៅក្នុងរបៀបណាដែលអ្នកមានការលំបាក (ការជំរុញ) ឬទទួលបានការលើកទឹកចិត្ត តើមានចំណុចអ្វីឬគំនិតអ្វីដែលអ្នកមិនយល់ស្របដែរ ឬទេ?

២. លោកពេត្រុសបាននិយាយថា ឲ្យនៅជាប់ជាមួយនឹងប្តីឬប្រពន្ធរបស់អ្នកដោយមានចំណេះដឹង (១ពេត្រុស៣:៧) តើចំណេះដឹងអ្វីអំពីដៃគូរបស់អ្នកដែលអ្នករកឃើញថា ពិសេសមានប្រយោជន៍នៅពេល ប្រាស្រ័យទាក់ទងគ្នា? តើចំណេះដឹងអំពីខ្លួនរបស់អ្នកដែលនឹងជួយដល់ដៃគូរបស់អ្នកឲ្យមានការប្រាស្រ័យទាក់ទងគ្នាជាមួយអ្នកឲ្យបានប្រសើរជាងមុន? តើអ្នកនឹងបន្តការដាំដុះចំណេះដឹងនេះនៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍ដោយរបៀបណា នៅពេលដែលជីវិតកាន់តែរវល់ជាមួយនឹងការងារ កូនៗ និងព័ន្ធកិច្ចជាដើម។

៣. វាជាធម្មតាសម្រាប់គូស្វាមីភរិយាដែលមានបញ្ហាក្នុងការប្រាស្រ័យទាក់ទងគ្នានៅផ្នែកខ្លះដោយព្រោះតែបញ្ហានៃភេទខុសគ្នា និងការរំពឹងទុកផ្សេងគ្នា។ តើមានអ្វីខុសពីធម្មតាឬការយល់ច្រឡំណាមួយនៅក្នុងទំនាក់ទំនងរបស់អ្នកដែលជាផ្នែកមួយទាក់ទងនឹងបញ្ហាភេទខុសគ្នាដែរឬទេ? តើជារឿយៗការយល់ច្រឡំចាប់ផ្តើមដោយរបៀបណា ហើយអ្នកណាជាអ្នកចាប់ផ្តើមវា?

៤. តើមានការផ្លាស់ប្តូរអ្វីខ្លះនៅខាងអ្នក ដើម្បីធ្វើឲ្យប្រសើរឡើងនូវការរអាក់រអួលដោយយល់ច្រឡំទាំងនេះ? តើខាងឯព្រលឹងវិញ្ញាណឬការអនុវត្តបច្ចេកទេសអ្វីខ្លះដែលនឹងត្រូវប្រើ ដើម្បីបង្កើនទំនាក់ទំនង?

៥. តើវិធីណាខ្លះដែលអ្នកមានបទពិសោធន៍អំពីសារៈសំខាន់នៃការបន្តនៅជាប់ក្នុងព្រះគ្រីស្ទសម្រាប់ការប្រាស្រ័យទាក់ទង? តើអ្នកនឹងការពារនិងបណ្តុះទំនាក់ទំនងការនៅជាប់នឹងព្រះគ្រីស្ទយ៉ាងដូចម្តេច? តើអ្នកនឹងជួយការពារហើយលើកទឹកចិត្តដល់ទំនាក់ទំនងដៃគូរបស់អ្នកយ៉ាងដូចម្តេច?

៦. ចូរសរសេរសំបុត្រដល់ឪពុកម្តាយរបស់អ្នក ផ្ញើរអ៊ីម៉ែល ឬទូរស័ព្ទទៅ ដើម្បីសួរសំណួរពួកគាត់។ ចូរសួរថាតើអ្នកមានគុណសម្បត្តិអ្វីខ្លះដែលនឹងជួយដល់អាពាហ៍ពិពាហ៍។ ចូរសួរថាតើគុណវិបត្តិអ្វីខ្លះដែលអ្នកមានដែលធ្វើឲ្យប៉ះពាល់ដល់អាពាហ៍ពិពាហ៍របស់អ្នក ហើយស្វែងរកវិធីណាដែលអ្នកអាចកែវាបាន។ ចូរសួររកអ្នកចង្អុលបង្ហាញណាដែលនឹងជួយអ្នកក្នុងការសម្រេចបាននូវការប្រាស្រ័យទាក់ទងគ្នាប្រកបដោយជោគជ័យក្នុងអាពាហ៍ពិពាហ៍និងអាពាហ៍ពិពាហ៍ជោគជ័យទូទៅ។

៧. ចូរសរសេរសំបុត្រដល់អាណាព្យាបាលរបស់ដៃគូរបស់អ្នក ផ្ញើរអ៊ីម៉ែល ឬទូរស័ព្ទទៅពួកគាត់ហើយសួរនូវសំណួរ។ ចូរសួរថាតើដៃគូរបស់អ្នកមានគុណសម្បត្តិអ្វីខ្លះដែលនឹងជួយដល់អាពាហ៍ពិពាហ៍។ សួរថាតើដៃគូរបស់អ្នកមានគុណវិបត្តិអ្វីខ្លះដែលអាចធ្វើឲ្យប៉ះពាល់ដល់អាពាហ៍ពិពាហ៍របស់អ្នកនិងរកវិធីណាដែលអ្នកអាចកែវាបាន។ ចូរសួររកអ្នកចង្អុលបង្ហាញណាដែលនឹងជួយក្នុងការសម្រេចបាននូវការប្រាស្រ័យទាក់ទងគ្នាប្រកបដោយជោគជ័យក្នុងអាពាហ៍ពិពាហ៍ និងអាពាហ៍ពិពាហ៍ជោគជ័យទូទៅ។

៨.បន្ទាប់ពីបញ្ចប់វគ្គនេះតើអ្នកមានអារម្មណ៍ថា ព្រះកំពុងត្រាស់ហៅអ្នកឲ្យអធិស្ឋានសម្រាប់

អាពាហ៍ពិពាហ៍របស់អ្នកយ៉ាងដូចម្តេច? ចំណាយពេលខ្លះអធិស្ឋាន។

# មូលដ្ឋានគ្រឹះទី៤៖
# តួនាទីយេនឌ័រនៅក្នុងអាពាហ៍ពិពាហ៍

នៅក្នុងផ្នែកនេះ យើងនឹងពិភាក្សាអំពីតួនាទីរបស់ព្រះសម្រាប់ប្តីនិងប្រពន្ធនៅក្នុងអាពាហ៍ពិពាហ៍រួបរួម។ ហេតុអ្វីបានជាតួនាទីយេនឌ័រមានសារៈសំខាន់ក្នុងអាពាហ៍ពិពាហ៍? ព្រះបានរចនាអាពាហ៍ពិពាហ៍ ហើយនៅពេលដែលមនុស្សមិនធ្វើតាមការរចនារបស់ទ្រង់ នោះអាពាហ៍ពិពាហ៍គឺរចនាឡើងសម្រាប់បញ្ហាវិញ។ វាជាការសំខាន់សម្រាប់យើងឲ្យដឹងនិងធ្វើតាមការរចនារបស់ទ្រង់ ទោះបីជាវាមានវប្បធម៌ឬផ្ទុយពីអ្វីដែលយើងទំម្លាប់ធ្វើក៏ដោយ។

យើងអាចយល់អំពីសារៈសំខាន់នៃតួនាទីយេនឌ័រដោយពិចារណាអំពីអាពាហ៍ពិពាហ៍ដំបូងនៅសួនច្បារអេដែន។ តួនាទីយេនឌ័រ គឺជារឿងដំបូងដែលសាតាំងបានវាយប្រហារដែលនាំទៅដល់ការធ្លាក់ចុះ។ តាមរយៈការល្បួងអេវ៉ាជំនួសឲ្យអ័ដាម សាតាំងបានប្រើនាងដើម្បី ដណ្តើមអំណាចដែលព្រះបានបង្កើតមក។ ការធ្លាក់ចុះបានកើតឡើងនៅពេលដែលអ័ដាមធ្វើតាមអេវ៉ាដែលអ្នកត្រូវបានបោកបញ្ឆោតដោយសាតាំង (លោកុប្បត្តិ៣:១-៦)។

គោលបំណងដើមរបស់ព្រះ គឺសម្រាប់ឲ្យស្វាមីដឹកនាំអាពាហ៍ពិពាហ៍ដែលអាចយល់ច្បាស់ពីបទគម្ពីរ។ នៅក្នុងមេរៀននេះ យើងនឹងបង្កើតសិទ្ធិអំណាចដល់ស្វាមីដោយមើលទៅកាន់សាច់រឿងនៃការបង្កើត។ យើងនឹងពិចារណាអំពីការបង្វែរតួនាទីយេនឌ័រដែលជាលទ្ធផលនៃការធ្លាក់ចុះហើយបន្ទាប់មកយើងនឹងពិចារណាពីការបង្កើតឡើងវិញរបស់ព្រះនៃតួនាទីរបស់ស្វាមីនិងភរិយាដោយមើលអត្ថបទគម្ពីរសំខាន់ៗផ្សេងទៀត។

ចូរចាប់ផ្តើមដំបូងជាមួយមូលដ្ឋានគ្រឹះព្រះគម្ពីរសម្រាប់ភាពជាអ្នកដឹកនាំរបស់បុរស។ តើយើងមើលឃើញពីការបង្កើតឡើងនៅក្នុងរឿងការបង្កើតនេះយ៉ាងដូចម្តេច?

### ព្រះបានបង្កើតអ័ដាមជាមុន ដើម្បីបង្ហាញពីសិទ្ធិអំណាចរបស់គាត់

នៅក្នុងរឿងការបង្កើត ដំបូងព្រះជាម្ចាស់បានបង្កើតអ័ដាម ហើយបន្ទាប់មកអេវ៉ាជាជំនួយការរបស់គាត់។ កណ្ឌគម្ពីរលោកុប្បត្តិ ២:១៨ ចែងថា *«ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់មានបន្ទូលថា ដែលមនុស្សនេះនៅតែម្នាក់ឯង នោះមិនស្រួលទេ អញនឹងធ្វើឲ្យមានម្នាក់ជាជំនួយសំរាប់ជួយវា»* ។

នៅក្នុងធីម៉ូថេទី១ជំពូក២ សាវ័កប៉ុលបានប្រើលំដាប់លំដោយនៃការបង្កើតជាភស្តុតាងសម្រាប់បុរសជាអ្នកដឹកនាំ ឬគ្រូបង្រៀននៅក្នុងព្រះវិហារហើយមិនមែនជាស្ត្រីទេ។ សូមមើលពីអ្វីដែលគាត់បាននិយាយនៅក្នុងធីម៉ូថេទី១ជំពូក២:១២-១៣៖ *«ខ្ញុំមិនបើកឲ្យស្ត្រីណាបង្រៀន ឬមានអំណាចលើបុរសទេ ត្រូវឲ្យគេតែនៅដោយស្រគត់ស្រគំចុះ ពីព្រោះព្រះបានបង្កើតលោកអ័ដាមមកជាមុន រួចមកនាងអេវ៉ា»*។

អ្នកខ្លះព្យាយាមពន្យល់ឆ្ងាយពីការបង្រៀនរបស់លោកប៉ុល លើភាពជាអ្នកដឹកនាំរបស់បុរសនៅក្នុងព្រះវិហារដូចជាវប្បធម៌សាមញ្ញទៅហើយ ដូច្នេះមិនត្រូវអនុវត្តនៅក្នុងព្រះវិហារសព្វថ្ងៃនេះទេ។ ទោះជាយ៉ាងណាក៏ដោយ ការជំទាស់របស់លោកប៉ុលសម្រាប់ភាពជាអ្នកដឹកនាំរបស់បុរសមិនមែនគ្រាន់តែជាវប្បធម៌ជំទាស់ប៉ុណ្ណោះទេ។ សាវ័កប៉ុលបានប្រើការបង្កើតសម្រាប់ការបង្កើតភាពជាអ្នកដឹកនាំរបស់បុរស នោះមានន័យថា ព្រះបានបង្កើតការនេះឡើងជាលំដាប់នេះតាំងពីដំបូងមក។ ជាការពិតណាស់នៅក្នុងវប្បធម៌បុរាណ បទបញ្ញាកំណើតពិតជាសំខាន់ណាស់។ កូនច្បងនឹងទទួលមរតកមួយទ្វេជាពីរ។ លំដាប់កំណើតបង្ហាញពីឋានៈមួយ។ ស្រដៀងគ្នានេះដែរ សាវ័កប៉ុលបាននិយាយថា ការបង្កើតអ័ដាមដំបូងបង្អស់របស់ព្រះមិនមែនជារឿងចម្លែកនោះទេ ប៉ុន្តែគឺដោយសារតែការរចនាអធិបតេយ្យភាព។ វាគឺមានន័យដើម្បីបង្ហាញពីភាពជាអ្នកដឹកនាំរបស់គាត់នៅក្នុងទំនាក់ទំនងចំពោះភរិយារបស់គាត់។ ព្រះបានបង្កើតសិទ្ធិអំណាចរបស់ស្វាមីនៅក្នុងផ្ទះតាំងតែពីដើមដំបូងនៃការបង្កើតមកម្ល៉េះ ហើយការជំទាស់របស់ប៉ុល គឺថាសិទ្ធិអំណាចនេះគួរតែបន្តឆ្លុះបញ្ចាំងនៅក្នុងព្រះវិហាររបស់ព្រះ។ តើមានវិធីណាផ្សេងទៀតដែលយើងឃើញពីសិទ្ធិអំណាចរបស់ស្វាមីបានឆ្លុះបញ្ចាំងនៅក្នុងរឿងការបង្កើត?

## ការដាក់ឈ្មោះរបស់អ័ដាមឲ្យប្រពន្ធរបស់គាត់ នោះបង្ហាញពីសិទ្ធិអំណាចរបស់គាត់

ភស្តុតាងមួយទៀតនៃការរចនាដំបូងរបស់ព្រះ សម្រាប់ភាពជាអ្នកដឹកនាំរបស់បុរសនៅក្នុងផ្ទះត្រូវបានបង្ហាញដោយការពិតដែលអ័ដាមដាក់ឈ្មោះឲ្យប្រពន្ធរបស់គាត់។ យើងឃើញការដាក់ឈ្មោះរបស់អ័ដាមឲ្យប្រពន្ធគាត់មាននៅពីរផ្នែក។ ផ្នែកទីមួយនៅក្នុងលោកុប្បត្តិ ជំពូក២ ព្រះជាម្ចាស់បានត្រាស់ហៅអ័ដាមឲ្យដាក់ឈ្មោះសត្វទាំងអស់។ បន្ទាប់ពីដាក់ឈ្មោះសត្វទាំងអស់រួចហើយ ព្រះបានធ្វើឲ្យអ័ដាមដេកលក់ស៊ប់ទៅ នោះព្រះក៏ដកយកឆ្អឹងជំនីរបស់គាត់មក ដើម្បីបង្កើតបានជាប្រពន្ធរបស់អ័ដាម។ បន្ទាប់មកអ័ដាមបានដាក់ឈ្មោះនាងភ្លាម។ លោកុប្បត្តិ ២:២៣ និយាយថា បុរសនេះបាននិយាយថា *«នេះហើយជាឆ្អឹងពីឆ្អឹងអញ ជាសាច់ពីសាច់អញ នាងត្រូវបានហៅថា "ស្ត្រី" ពីព្រោះនាងត្រូវបានយកចេញពីបុរសមក» ។ ដូចជាអ័ដាមបានដាក់ឈ្មោះសត្វដំបូង បន្ទាប់មកគាត់បានដាក់ឈ្មោះប្រពន្ធរបស់គាត់ថា« ស្ត្រី»* ។ផ្នែកទី២បន្ទាប់ពីការធ្លាក់ចុះ គាត់បានហៅនាងថា«អេវ៉ា»ពីព្រោះនាងជាម្តាយនៃមនុស្សទាំងអស់ (លោកុប្បត្តិ ៣:២០)។

ស្រដៀងគ្នានឹងសម័យបុរាណដែរ ការដាក់ឈ្មោះនៅក្នុងវប្បធម៌របស់យើងនៅតែជាការឆ្លុះបញ្ចាំងពីសិទ្ធិអំណាចរបស់មនុស្សម្នាក់។ ឪពុកម្តាយដាក់ឈ្មោះកូនៗរបស់ពួកគេតាំងពីពួកគេមានសិទ្ធិអំណាចមកម្ល៉េះ។ ការរចនារបស់ព្រះសម្រាប់អ័ដាម ដើម្បីដឹកនាំប្រពន្ធរបស់គាត់ឲ្យអាចយល់ច្បាស់ពីរឿងការបង្កើត ទាំងពីរនៅក្នុងការបង្កើតតាមលំដាប់លំដោយនិងការដាក់ឈ្មោះឲ្យប្រពន្ធរបស់គាត់។

## តួនាទីយេនឌ័រត្រូវបានបំផ្លាញនៅក្នុងការធ្លាក់ចុះ

នៅក្នុងការធ្លាក់ចុះ សាតាំងបានល្បួងអេវ៉ាឲ្យបរិភោគផ្លែឈើពីដើមដែលហាមឃាត់។ បទគម្ពីរចែងយ៉ាងច្បាស់ថា អេវ៉ាបានចាញ់បញ្ឆោតតែមិនមែនអ័ដាមទេ។ កណ្ឌគម្ពីរ១ធីម៉ូថេ ២:១៤ បានចែងថា *«ហើយមិនមែនលោកអ័ដាមដែលចាញ់បញ្ឆោតទេ គឺជាស្ត្រីវិញទេតើ ដែលចាញ់បញ្ឆោត នោះព្រមទាំងរំលងច្បាប់ផង»*។ ហេតុអ្វីក៏និយាយថា អ័ដាមមិនមែនចាញ់បញ្ឆោតតែគឺស្ត្រីវិញ? សូមចាំនៅក្នុងបរិបទនៃកណ្ឌគម្ពីរធីម៉ូថេទី១និងទី២ សាវ័កប៉ុលកំពុងតែជជែកវែកញែកដែរថា ស្ត្រីមិនគួរធ្វើជាអ្នកដឹកនាំ ឬគ្រូបង្រៀននៅក្នុងព្រះវិហារនោះទេ (២ធីម៉ូថេ ២:១២) ។ គាត់ហាក់ដូចជាកំពុងតែជជែកវែកញែកដែរថា ការធ្លាក់ចុះបានកើតឡើងដោយសារតែអ័ដាមស្ម័គ្រចិត្តធ្វើតាមប្រពន្ធរបស់គាត់ជំនួសឲ្យធ្វើជាមេដឹកនាំដែលព្រះបានហៅគាត់ឲ្យធ្វើវិញ។ អេវ៉ាបានចាញ់បញ្ឆោតហើយអ័ដាមបានធ្វើតាមទោះបីជាគាត់ដឹងថាវាខុសក៏ដោយ។ ការល្បួងរបស់សាតាំងបានបង្អាក់ដល់សណ្តាប់ធ្នាប់ដើមរបស់ព្រះជាម្ចាស់។

ជាមួយការនិយាយបែបនេះ សូមពិចារណាអំពីផលប៉ះពាល់នៃការធ្លាក់ចុះទៅលើតួនាទីយេនឌ័រនៅក្នុងអាពាហ៍ពិពាហ៍។ ព្រះទ្រង់មានបន្ទូលអំពីផលប៉ះពាល់នេះ ទ្រង់បានមានបន្ទូលទៅកាន់ស្ត្រីវិញថា *«អញនឹងចំរើនឲ្យឯងមានសេចក្តីព្រួយលំបាកជាច្រើនឡើង ក្នុងវេលាដែលមានផ្ទៃពោះ ឯងនឹងបង្កើតកូនដោយឈឺចាប់ ចិត្តឯងនឹងប្រាថ្នាខាងឯប្តី ហើយប្តីនឹងត្រួតត្រាលើឯង»* (លោកុប្បត្តិ ៣:១៦) ។ តើព្រះជាម្ចាស់ចង់មានន័យដូម្តេចនៅពេលដែលទ្រង់មានបន្ទូលទៅកាន់ស្ត្រីថា «ចិត្តឯងនឹងប្រាថ្នាខាងឯប្តី ហើយប្តីនឹងត្រួតត្រាលើឯង»? អត្ថន័យគឺមិនច្បាស់ទេ ប៉ុន្តែវាត្រូវបានធ្វើឲ្យកាន់តែច្បាស់ដោយពិចារណាលើការប្រើប្រាស់ពាក្យហេព្រើរ «ប្រាថ្នា» នៅក្នុងអត្ថបទផ្សេងទៀត។

នៅក្នុងកណ្ឌគម្ពីរលោកុប្បត្តិ៤:៧ ព្រះជាម្ចាស់បានប្រើពាក្យដូចគ្នានេះ ដើម្បីពិពណ៌នាអំពី«អំពើបាប»ដែលព្យាយាមត្រួតត្រាលើកាអ៊ីន ហើយបានបង្កហេតុធ្វើឲ្យគាត់ខឹងនឹងទទួលយកដង្វាយរបស់អេបិល។ សូមស្តាប់នូវអ្វីដែលព្រះបានមានបន្ទូលទៅកាន់កាអ៊ីន៖ *ព្រះយេហូវ៉ាមានព្រះបន្ទូលសួរកាអ៊ីនថា៖ «ឯងខឹងធ្វើអី ហេតុអ្វីបានជាឯងធ្វើទឹកមុខក្រញូវដូច្នេះ បើឯងធ្វើល្អ តើមិនបានទឹកមុខរីករាយវិញទេឬអី បើឯងធ្វើមិនល្អ នោះមានដង្វាយលោះបាបដេកនៅមាត់ទ្វារស្រាប់ហើយ ចិត្តវានឹងបណ្តោយតាមឯង ហើយឯងមានអំណាចលើវាដែរ»*។

នៅត្រង់នេះពាក្យថា« សេចក្តីប៉ងប្រាថ្នា» មានន័យថាគ្រប់គ្រង ហើយដូច្នេះយើងអាចយល់ពីឥទ្ធិពលនៃអំពើបាបមកលើតួនាទីរបស់ប្តីនិងប្រពន្ធ (ឬបុរសនិងស្ត្រី) ។ ភរិយានឹងព្យាយាមគ្រប់គ្រងប្តី ហើយប្តីនឹងព្យាយាមគ្រប់គ្រងប្រពន្ធ។ សមរភូមិរបស់យេនឌ័រ គឺជាលទ្ធផលមួយនៃលទ្ធផលទាំងអស់នៃការធ្លាក់ចុះ។ យើងធ្លាប់បានឃើញផលប៉ះពាល់ទាំងនេះនៅទូទាំងប្រវត្តិសាស្ត្រតាមរបៀបជាច្រើន។ នៅក្នុងវប្បធម៌ខ្លះ ប្តីគឺមិនអើពើ ខ្ជិលខាងឯព្រលឹងវិញ្ញាណ ហើយពេលខ្លះក៏អវត្តមានដែរ ហេតុដូច្នេះលទ្ធផលភរិយាត្រូវដឹកនាំផ្ទះសម្បែង។ នៅក្នុងវប្បធម៌ផ្សេងទៀត ប្តីព្យាយាមត្រួតត្រាដោយកម្លាំង ហើយស្ត្រីមានសិទ្ធិតិចតួចណាស់។ ការត្រួតត្រារបស់បុរសត្រូវបានឃើញនៅក្នុងការប្រយុទ្ធប្រឆាំងដើម្បីសិទ្ធិរបស់ស្ត្រីនៅទូទាំងប្រវត្តិសាស្ត្រ។ នៅក្នុងសង្គមជាច្រើន ការរំលោភបំពានទៅលើស្ត្រី

ហើយចាត់ទុកពួកគេដូចជាទ្រព្យសម្បត្តិមួយអញ្ចឹង។ នេះមិនមែនជាការរចនាដើមរបស់ព្រះទេ។ នេះបានមកពីលទ្ធផលនៃអំពើបាប - បុរសនឹងព្យាយាមត្រួតត្រាលើស្ត្រីដោយកម្លាំង។

យើងប្រាកដជាឃើញពីផលប៉ះពាល់នៃអំពើបាបនៅក្នុងពិភពលោកជុំវិញយើង។ វាត្រូវបានបង្ហាញនៅក្នុងបុរសតណ្ហាដែលចង់ត្រួតត្រា ហើយដេកជាមួយស្ត្រីឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ វាក៏ត្រូវបានបង្ហាញនៅក្នុងស្ត្រីតណ្ហាដែលមានភាពទាក់ទាញដែលស្វែងរកការគ្រប់គ្រងបុរសជាមួយនឹងសម្រស់របស់នាង ហើយប្រើវាដើម្បីទទួលបាននូវបំណងប្រាថ្នាទាំងអស់របស់នាង។

អ្វីដែលសំខាន់បំផុត យើងឃើញការប្រយុទ្ធនេះនៅក្នុងផ្ទះ កន្លែងណាដែលប្ដីនិងប្រពន្ធខំប្រឹងរកអំណាច ពោលគឺធ្វើខុសពីការរចនាដើមរបស់ព្រះ។ ព្រះជាម្ចាស់ គឺជាព្រះដ៏មានសណ្ដាប់ធ្នាប់ ទ្រង់យល់ពីស្ថាប័នអាពាហ៍ពិពាហ៍មិនអាចដំណើរការបានត្រឹមត្រូវទេ ប្រសិនបើវាមិនមានភាពជាអ្នកដឹកនាំច្បាស់លាស់។ នេះជាការពិតជាមួយស្ថាប័នណាមួយៈ យោធា ជំនួញ សាលារៀន និងសូម្បីតែព្រះវិហារ។ ដូច្នេះ ព្រះមានគោលបំណងសម្រាប់ឲ្យស្វាមីធ្វើជាអ្នកដឹកនាំ ដើម្បីសម្រេចគោលបំណងដើមរបស់ទ្រង់តាមរយៈអាពាហ៍ពិពាហ៍។

ជាក់ស្ដែងការបង្រៀននេះ គឺមានការជំទាស់គ្នា។ មនុស្សហាក់ដូចជាជឿថា ការមានសណ្ដាប់ធ្នាប់និងភាពជាអ្នកដឹកនាំក្នុងអាពាហ៍ពិពាហ៍មានន័យមិនស្មើភាពគ្នាទេ។ ទោះជាយ៉ាងណាក៏ដោយនេះមិនមែនជាការពិតទេ។ ជាទូទៅ និងឯកជនគឺមានភាពស្មើគ្នាចំពោះមនុស្សម្នាក់ៗ ប៉ុន្តែមិនមែនតាមលំដាប់ស្មើគ្នាទេ។ ចំណាត់ថ្នាក់គឺចាំបាច់ ដើម្បីនាំមកនូវសណ្ដាប់ធ្នាប់ល្អនិងវិន័យល្អនៅក្នុងវិស័យយោធា។ ភាពជាអ្នកដឹកនាំគឺចាំបាច់ ដើម្បីសម្រេចបេសកកម្មដោយគ្មានការខ្វែងគំនិតគ្នា។ ស្រដៀងគ្នានេះដែរ ព្រះមានបេសកកម្មដ៏អស្ចារ្យសម្រាប់អាពាហ៍ពិពាហ៍ទាំងអស់។ នេះជាអង្គភាពមូលដ្ឋាននៃសង្គមទាំងអស់ហើយនៅពេលដែលគ្មានសណ្ដាប់ធ្នាប់ សង្គមទាំងអស់គ្មានសណ្ដាប់ធ្នាប់នោះឡើយ។ ដូច្នេះ ទ្រង់បានបង្កើតភាពជាអ្នកដឹកនាំយ៉ាងច្បាស់លាស់សម្រាប់គោលបំណងនេះ។

ឥឡូវនេះដោយនិយាយថា តើការដឹកនាំរបស់ប្ដីគួរតែមានលក្ខណៈបែបណា? តើការចុះចូលរបស់ប្រពន្ធគួរតែមានលក្ខណៈបែបណា? ប្ដីមិនត្រូវបានគេសន្មតថា ជាអ្នកកាន់អំណាចផ្ដាច់ការហើយប្រពន្ធមិនត្រូវបានហៅឲ្យធ្វើជាក្រណាត់ជូតជើងនៅមាត់ទ្វារនោះទេ។ នៅកាលដំបូងឡើយ ព្រះបានហៅអ័ដាមនិងអេវ៉ាឲ្យគ្រប់គ្រងនិងត្រួតត្រាលើការបង្កើតរបស់ព្រះជាមួយគ្នា។ ភាពជាដៃគូប្រកបដោយសេចក្ដីស្រឡាញ់និងមានរបៀបរៀបរយ នេះគឺដើម្បីសម្រេចបេសកកម្មរបស់ព្រះនៅលើផែនដីនេះ។ តើតួនាទីរបស់ស្វាមីនិងភរិយាគួរមានលក្ខណៈបែបណានៅក្នុងអាពាហ៍ពិពាហ៍? បុគ្គលិកលក្ខណៈនិងការចិញ្ចឹមបីបាច់ធ្វើឲ្យគ្រួសាររបស់ព្រះនីមួយៗមានលក្ខណៈខុសប្លែកពីគ្នា ប៉ុន្តែច្បាប់មូលដ្ឋានគួរតែដូចគ្នា។

### ប្ដីត្រូវតែស្រឡាញ់ប្រពន្ធរបស់ខ្លួន

ជំនួសឲ្យការប្រើប្រាស់ភាពជាអ្នកដឹកនាំរបស់គាត់ទៅគ្រប់គ្រងឬត្រួតត្រាលើប្រពន្ធរបស់គាត់ ព្រះបានត្រាស់ហៅប្ដីឲ្យប្រើការដឹកនាំរបស់គាត់ឲ្យស្រឡាញ់ដល់ប្រពន្ធរបស់គាត់។ ព្រះជាម្ចាស់

បានគ្រោងទុកការនេះតាំងតែពីដំបូងមក។ ស្វាមីនឹងដឹកនាំតាមរយៈការស្រឡាញ់ដល់ភរិយា។ តើសេក្តីស្រឡាញ់នេះគួរមានសក្ខណៈបែបណា? លោកប៉ុលបានបង្រៀនថា សេចក្តីស្រឡាញ់របស់ស្វាមីគួរតែឆ្លុះបញ្ចាំងពីសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទចំពោះក្រុមជំនុំ។ នៅក្នុងអេភេសូរ ៥: ២៥-២៨ គាត់បានមានប្រសាសន៍ថា៖

*បុរសរាល់គ្នាអើយ ចូរស្រឡាញ់ប្រពន្ធខ្លួន ដូចជាព្រះគ្រីស្ទបានស្រឡាញ់ដល់ពួកជំនុំ ហើយបានប្រគល់ព្រះអង្គទ្រង់ជំនួសផង ២៦ ដើម្បីឲ្យទ្រង់បានញែកពួកជំនុំចេញជាបរិសុទ្ធ ដោយបានលាងសំអាតនឹងទឹក គឺជាព្រះបន្ទូល ២៧ ប្រយោជន៍នឹងថ្វាយពួកជំនុំនេះដល់ព្រះអង្គទ្រង់ទុកជាពួកជំនុំដ៏ឧត្តម ឥតប្រឡាក់ ឥតជ្រួញ ឬមានអ្វីឲ្យដូចឡើយ គឺឲ្យបានបរិសុទ្ធ ហើយឥតកន្លែងបន្ទោសបានវិញ ២៨ ត្រូវឲ្យប្តីស្រឡាញ់ប្រពន្ធបែបយ៉ាងនោះឯង គឺដូចជាស្រឡាញ់រូបកាយរបស់ខ្លួនដែរ អ្នកណាដែលស្រឡាញ់ប្រពន្ធខ្លួន នោះក៏ឈ្មោះថាស្រឡាញ់ដល់ខ្លួនឯងហើយ។*

តើអ្វីដែលយើងអាចរៀនបានអំពីសេចក្តីស្រឡាញ់របស់ស្វាមីតាមរយៈគំរូរបស់ព្រះគ្រីស្ទ?

**១. សេចក្តីស្រឡាញ់របស់ស្វាមីត្រូវតែជាសេចក្តីស្រឡាញ់ពិត**

ប្តីមិនគួររវើរវាយអំពីស្ត្រីដែលគាត់កំពុងរៀបការនោះទេ (ខ ២៥) ។ ព្រះគ្រីស្ទទ្រង់ស្រឡាញ់ដល់ពួកជំនុំទោះបើដឹងថា នាងជាមនុស្សមានបាបហើយមិនស្តាប់បង្គាប់ក៏ដោយ។ ព្រះគ្រីស្ទបានលះបង់ព្រះជន្មរបស់ទ្រង់សម្រាប់ពួកជំនុំកំឡុងពេលដែលទ្រង់ដឹងពីកំហុសរបស់ពួកគេ។ សេចក្តីស្រឡាញ់របស់ទ្រង់គឺពិតប្រាកដ។

ក្នុងអាពាហ៍ពិពាហ៍គូទាំងពីរត្រូវតែស្វែងយល់ពីការពិតនេះ។ ជាក់ស្តែង ការប្រឹក្សាមុនរៀបការជាច្រើនគឺបំផ្លាញការរំពឹងទុកមិនពិតដែលបានរៀបចំឡើងតាមរយៈរឿងកំប្លែង ផ្អែមល្ហែមនិងហូលីវូដ។ ប្តីត្រូវស្រឡាញ់យ៉ាងពិតប្រាកដ។ ស្ត្រីនេះមិនដើរលើទឹកទេ នាងត្រូវបានឆ្លងដោយអំពើបាបដូចជាគាត់មានដែរ។ នាងត្រូវតែបានកែប្រែរាល់ថ្ងៃដោយព្រះគុណរបស់ព្រះ ហើយនាងត្រូវតែបានស្រឡាញ់តាមរយៈកំហុសរបស់នាង។ បទគម្ពីរចែងថា *«សេចក្តីស្រឡាញ់គ្របបាំងអំពើបាបជាច្រើន»* (១ពេត្រុស ៤: ៨)។ មានសេក្តីស្រឡាញ់ពិត គឺជារឿងសំខាន់សម្រាប់គូទាំងពីរ ពីព្រោះបើពួកគេមិនមានវាទេ នោះពួកគេនឹងក្លាយជាមានអារម្មណ៍ស្រងាកចិត្ត។ គ្មានអ្វីសង្ស័យនោះទេ នេះជាហេតុផលមួយក្នុងចំណោមហេតុផលទាំងអស់សម្រាប់ចំនួនខ្ពស់នៃការលែងលះគ្នាក្នុងឆ្នាំដំបូងនៃអាពាហ៍ពិពាហ៍ គឺដោយសារតែសេក្តីស្រឡាញ់ភាគច្រើនមិនប្រាកដប្រជា។

**២. សេចក្តីស្រឡាញ់របស់ស្វាមីត្រូវតែមានការលះបង់**

គាត់ត្រូវស្រឡាញ់ដល់នាងដូចជាព្រះគ្រីស្ទទ្រង់ស្រឡាញ់ដល់ក្រុមជំនុំដែរ ហើយសុខចិត្តស្លាប់ដើម្បីនាង (ខ ២៥)។ វាគួរតែយល់បានដែលថា ប្រសិនបើអ្នកណាម្នាក់មានអារម្មណ៍ចូលចិត្តតួនាទីរបស់ប្រពន្ធគឺអយុត្តិធម៌ នោះពួកគេគួរតែផ្តល់គំនិតបន្ថែមទៀតទៅកាន់តួនាទីរបស់បុរស។ នេះជាការងាយស្រួលជាងក្នុងការចុះចូលទៅកាន់អ្នកណាម្នាក់ជាជាងលះបង់ជីវិតមួយសម្រាប់បុគ្គលនោះ។ សេចក្តីស្រឡាញ់នេះប្តីត្រូវបានសន្មតថា អាចបង្កប់បានគឺមិនអាចទៅរួចនោះទេ ក្រៅពីព្រះគុណរបស់ព្រះជាម្ចាស់។ ការស្រឡាញ់ដោយការលះបង់គឺមានន័យថា ស្វាមីត្រូវលះបង់អ្វីផ្សេងៗទៀតជា

ញឹកញាប់ ដើម្បីបម្រើនិងផ្គាប់ចិត្តភរិយារបស់គាត់។ គាត់ត្រូវលះបង់ដើម្បីនាង។ គាត់ត្រូវតែលះបង់ពេលវេលា មិត្តភាព ការងារ ការកម្សាន្ត ចំណង់ចំណូលចិត្តជាដើម ដើម្បីស្រឡាញ់ដល់ភរិយារបស់គាត់ដូចជាព្រះគ្រីស្ទដែរ។

**៣. សេចក្តីស្រឡាញ់របស់ស្វាមីចាំបាច់ត្រូវតែមានគោលបំណង**

គោលបំណងនៃសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទ គឺដើម្បីធ្វើឲ្យពួកជំនុំបរិសុទ្ធសម្អាតនាងឲ្យស្អាតដោយព្រះបន្ទូលព្រះ (ខ ២៦-២៧)។ គោលបំណងរបស់ព្រះគ្រីស្ទ គឺធ្វើឲ្យក្រុមជំនុំក្លាយជាកូនក្រមុំដ៏ល្អឥតខ្ចោះ។ ស្រដៀងគ្នាដែរ ស្វាមីត្រូវស្រឡាញ់ភរិយារបស់ខ្លួនតាមរយៈបង្រៀនបទគម្ពីរដល់នាង នាំនាងឲ្យចូលរួមនៅក្នុងការអធិប្បាយព្រះបន្ទូលនៅព្រះវិហារនិងលើកទឹកចិត្តនាងឲ្យចូលរួមជាមួយនឹងព័ន្ធកិច្ចនៃព្រះវិហារ។

គាត់ត្រូវតែស្វែងរកការដាំដុះមិនត្រឹមតែចរិតរបស់នាងប៉ុណ្ណោះទេ ប៉ុន្តែការត្រាស់ហៅរបស់នាងផងដែរ ដូច្នេះ នាងអាចបំពេញផែនការរបស់ព្រះសម្រាប់ជីវិតរបស់នាងបានហើយ។ គាត់ត្រូវតែជួយនាងឲ្យយល់ពីអំណោយទានរបស់នាងនិងទេពកោសល្យរបស់នាង ហើយលើកទឹកចិត្តនាងក្នុងការប្រើប្រាស់អំណោយទានទាំងនោះសម្រាប់លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។ គោលបំណងរបស់សេចក្តីស្រឡាញ់ក៏មានន័យថា ពេលខ្លះដាស់តឿននាងជួយនាងឲ្យស្គាល់ព្រះគ្រីស្ទកាន់តែច្រើន។ បុរសគ្រប់រូបគួរតែពិចារណាប្រសិនបើគាត់ត្រៀមខ្លួននិងមានឆន្ទៈក្នុងការស្រឡាញ់ដល់នារីក្នុងរបៀបនេះសូម្បីតែមុនពេលរៀបការក៏ដោយ។ តើគាត់ត្រៀមខ្លួនធ្វើជាអ្នកដឹកនាំខាងឯវិញ្ញាណឬទេ?
តើគាត់ត្រៀមខ្លួនរួចជាស្រេច ដើម្បីអធិស្ឋានដល់ការអភិវឌ្ឍន៍ខាងឯវិញ្ញាណរបស់ភរិយាគាត់ឬទេ?

**៤. សេចក្តីស្រឡាញ់របស់ស្វាមីត្រូវតែផ្ទាល់ខ្លួន**

គាត់ត្រូវស្រឡាញ់ដល់នាងឲ្យដូចជាខ្លួនរបស់គាត់ដែរ (ខ២៨)។ ជារៀងរាល់ថ្ងៃស្វាមី ដុសធ្មេញរបស់គាត់ សិតសក់ ហើយស្លៀកពាក់ខ្លួនឯង។ ជារៀងរាល់ថ្ងៃគាត់តុបតែងខ្លួនរបស់គាត់ តែគួរឲ្យសោកស្តាយ ជារឿយៗស្វាមីតែងចាកចេញដោយមិនខ្វល់ពីការមើលថែរក្សាប្រពន្ធរបស់ខ្លួនឡើយ។ នេះវាងាយស្រួលណាស់ក្នុងការមមាញឹកជាមួយជីវិត ការងារ និងព័ន្ធកិច្ចដែលអាចធ្វើឲ្យភាពមមាញឹកទាំងនោះកើនឡើងកាន់តែច្រើនដោយចៃដន្យនៅក្នុងអាពាហ៍ពិពាហ៍របស់គាត់។ សេក្តីស្រឡាញ់ត្រូវតែមានលក្ខណៈផ្ទាល់ខ្លួន។ គាត់ត្រូវតែស្រឡាញ់នាងដូចជាខ្លួនរបស់គាត់ដែរ។ គាត់ត្រូវចំណាយពេលរាល់ថ្ងៃដើម្បីដាំដុះគ្រួសារប្រកបដោយសុភមង្គល។

នៅពេលដែលពិភពលោកព្យាយាថា «ភាពជាអ្នកដឹកនាំរបស់បុរស» វាច្រើនតែមានអត្ថន័យអវិជ្ជមានតែវាមិនគួរយល់បែបដូច្នោះទេ។ ចូរពិចារណាពីអ្វីដែលព្រះគ្រីស្ទបានបង្រៀនដល់ពួកសិស្សរបស់ទ្រង់អំពីភាពជាអ្នកដឹកនាំនៅក្នុងបទគម្ពីរលូកា ២២: ២៥-២៧ ៖

*២៥ តែទ្រង់មានបន្ទូលថា អស់ទាំងស្តេចនៃសាសន៍ដទៃ គេតែងសោយរាជ្យលើបណ្តារាស្ត្រ ហើយបណ្តាជនហៅពួកអ្នកមានអំណាចលើគេ ថាជាអ្នកមានគុណដែរ ២៦ ប៉ុន្តែ មិនត្រូវឲ្យមានដូច្នោះក្នុងពួកអ្នករាល់គ្នាឡើយ ឯអ្នកណាដែលធំជាងគេ ក្នុងពួកអ្នករាល់គ្នា នោះត្រូវប្រព្រឹត្តដូចជាតូចជាងគេវិញ ហើយអ្នកណាដែលនាំមុខគេ នោះដូចជាអ្នកបំរើដែរ ២៧ ដ្បិតតើអ្នកណាធំជាង អ្នកដែលអង្គុយនៅ*

*តុ ឬអ្នកដែលបំរើ តើមិនមែនជាអ្នកដែលអង្គុយនៅតុទេឬអី ប៉ុន្តែ ខ្ញុំនៅកណ្តាលពួកអ្នករាល់គ្នា ទុកដូចជាអ្នកបំរើវិញ។*

ដូចដែលបានពិពណ៌នានៅក្នុងកណ្ឌគម្ពីរលូកា២២ ភាពជាអ្នកដឹកនាំរបស់បុរសចម្បងមានន័យថា ការបម្រើច្រើន។ ព្រះគ្រីស្ទបានប្រាប់ដល់ពួកសិស្សទ្រង់ថា ដែលអ្នកណាចង់ធ្វើជាអ្នកធំជាងគេនោះត្រូវប្រព្រឹត្តដូចជា «តូចជាងគេ»។ វប្បធម៌ថ្វីហ្វមានឋានុក្រមខ្ពស់ណាស់ដោយមានន័យថាកូនប្អូននឹងតែងតែបម្រើដល់កូនបង។ ប៉ុន្តែព្រះយេស៊ូវទ្រង់មានបន្ទូលទៅកាន់វប្បធម៌នៃឋានានុក្រមនេះ ហើយមានបន្ទូលពីការដឹកនាំយ៉ាងពិតប្រាកដ គឺភាពជាអ្នកដឹកនាំបែបអ្នកបម្រើ។ ការដឹកនាំមានន័យដូចជាតូចជាងគេបំផុត ជាអ្នកបម្រើដល់គ្រប់គ្នា។ មេដឹកនាំពិតប្រាកដនឹងលះបង់សិទ្ធិរបស់ពួកគេក្នុងការបម្រើ ដើម្បីបម្រើដល់អ្នកដទៃ។ នេះជារបៀបដែលស្វាមីគួរតែធ្វើនៅក្នុងអាពាហ៍ពិពាហ៍ដែរ។ ពួកគេគួរតែបន្ទាបខ្លួនជានិច្ច ដើម្បីបម្រើដល់ភរិយារបស់ខ្លួន។

ព្រះគ្រីស្ទបានបង្ហាញពីភាពជាអ្នកដឹកនាំនេះនៅក្នុងយ៉ូហានជំពូក ១៣ នៅពេលដែលទ្រង់បានប្រព្រឹត្តដូចជាអ្នកបម្រើដោយការលាងជើងដល់ពួកសិស្សរបស់ទ្រង់។ ការនេះមិនមានអ្វីជាអវិជ្ជមានអំពីភាពជាអ្នកដឹកនាំប្រភេទនេះឡើយ។ ព្រះជាម្ចាស់តែងតែបម្រុងទុកនូវភាពជាអ្នកដឹកនាំប្រកបដោយសេចក្តីស្រឡាញ់ប្រភេទនេះ សម្រាប់ទំនាក់ទំនងអាពាហ៍ពិពាហ៍ហើយស្វាមីត្រូវតែខិតខំដាំដុះជារៀងរាល់ថ្ងៃ។

តើចរិតលក្ខណៈអ្វីខ្លះទៀតដែលគួរបញ្ជាក់ពីតួនាទីយេនឌ័រនៅក្នុងអាពាហ៍ពិពាហ៍?

## ស្វាមីត្រូវតែចុះចូលចំពោះការដឹកនាំរបស់ព្រះគ្រីស្ទ

*១កូរិនថូស ១១:៣ «តែខ្ញុំចង់ឲ្យអ្នករាល់គ្នាដឹងថា ព្រះគ្រីស្ទជាសិរសានៃបុរសទាំងអស់ ឯបុរសវិញ នោះជាក្បាលនៃស្ត្រី ហើយសិរសានៃព្រះគ្រីស្ទ គឺជាព្រះ»។*

នៅក្នុងខនេះ  យើងឃើញពីអភ័យឯកសិទ្ធិដ៏ជាលក្ខណៈទេវសាស្ត្រៈ ព្រះគ្រីស្ទបានចុះចូលចំពោះព្រះជាម្ចាស់ ហើយបុរសត្រូវចុះចូលចំពោះព្រះគ្រីស្ទ ហើយស្ត្រីត្រូវចុះចូលចំពោះបុរស។ ប្រសិនបើស្វាមីនឹងដឹកនាំភរិយារបស់គាត់តាមការរចនារបស់ព្រះ នោះគាត់ត្រូវតែចុះចូលចំពោះព្រះគ្រីស្ទជាមុនសិន។ វាគឺសម្រាប់ហេតុផលដែលភរិយាត្រូវតែចុះចូលចំពោះស្វាមីរបស់ខ្លួន ពីព្រោះនៅពេលនាងដើរតាមស្វាមីរបស់នាង នោះនាងពិតជាកំពុងចុះចូលចំពោះសិទ្ធិអំណាចរបស់ព្រះគ្រីស្ទមែន។

នេះនាំមកនូវការទទួលខុសត្រូវដ៏ធំដល់ស្វាមីម្នាក់ៗ ដើម្បីស្គាល់ពីការនាំមុខរបស់ព្រះគ្រីស្ទ។ គាត់ត្រូវតែជាមនុស្សម្នាក់ដែលគោរពតាមព្រះបន្ទូល ហើយអធិស្ឋានដល់ទ្រង់ ដូច្នេះគាត់អាចស្គាល់ព្រះសូរសៀងរបស់ព្រះជាម្ចាស់បានហើយ។ បុរសដែលពិចារណាអំពីអាពាហ៍ពិពាហ៍គួរតែសួរខ្លួនឯងថា «តើខ្ញុំកំពុងដេញតាមព្រះអម្ចាស់តាមរបៀបមួយដែលខ្ញុំអាចស្គាល់ព្រះសូរសៀងរបស់ទ្រង់ ដើម្បីដឹកនាំភរិយានិងគ្រួសារដោយសេចក្តីស្រឡាញ់ឬទេ? ជាទូទៅ គេនិយាយថា «មានតែអ្នកដែលនៅជិតព្រះទេបានឮ» ស្វាមីត្រូវតែនៅជិតព្រះគ្រីស្ទ នៅជិតព្រះសិរសាទ្រង់ ដើម្បីបានឮព្រះសូរសៀងរបស់ទ្រង់។ មានតែស្វាមីដែលនៅជិតព្រះគ្រីស្ទទេ ទើបនឹងអាចធ្វើជាគំរូរបស់ព្រះគ្រីស្ទហើយដឹកនាំបានត្រឹមត្រូវ។

ការនេះក៏សំខាន់ផងដែរសម្រាប់ស្ត្រីនៅលីវបានឮ ហើយពិចារណា ពីព្រោះមិនមែនបុរសគ្រប់រូប គឺសុទ្ធតែសក្តិសមខាងឯវិញ្ញាណសម្រាប់ភាពជាអ្នកដឹកនាំនោះទេ។ ពួកគេគួរតែសួរខ្លួនឯងអំពីស្វាមីដែលមានសក្តានុពលថា «តើបុរសនេះស្រឡាញ់ព្រះគ្រីស្ទឬទេ? តើបុរសនេះដើរតាមព្រះគ្រីស្ទឬទេ? តើគាត់សមនឹងដឹកនាំខាងឯវិញ្ញាណឬទេ?» មនុស្សម្នាក់អាចប្រាកដបានថា ប្រសិនបើបុរសនៅលីវមិនស្មោះត្រង់ក្នុងការដើរតាមព្រះគ្រីស្ទទេ គាត់នឹងមិនស្មោះត្រង់នៅពេលរៀបការដែរ។ បទគម្ពីរចែងថា *«ដែលអ្នកណាមិនស្មោះត្រង់ជាមួយនឹងការតូច អ្នកនោះក៏នឹងមិនស្មោះត្រង់ជាមួយការធំដែរ»* (លូកា ១៦:១០)។ ស្វាមីត្រូវតែបន្តចុះចូលទៅចំពោះការដឹកនាំរបស់ព្រះគ្រីស្ទ ដើម្បីដឹកនាំគ្រួសាររបស់ពួកគេឲ្យបានត្រឹមត្រូវ។

## ប្រពន្ធត្រូវតែចុះចូលចំពោះភាពជាអ្នកដឹកនាំរបស់ស្វាមីខ្លួន

ដូចដែលបានរៀបរាប់រួចមកហើយ ក្នុងការចុះចូលចំពោះព្រះគ្រីស្ទ ភរិយាត្រូវចុះចូលចំពោះស្វាមីរបស់ខ្លួនដែរ។ អេភេសូរ ៥:២២ និយាយថា *«ស្ត្រីរាល់គ្នាអើយ ចូរឲ្យចុះចូលចំពោះប្ដីខ្លួន ដូចជាចុះចូលនឹងព្រះអម្ចាស់ដែរ»* ។

បទគម្ពីរបានបង្គាប់ដល់ភរិយាឲ្យចុះចូលចំពោះស្វាមីរបស់ខ្លួនដូចជានាងកំពុងដើរតាមព្រះគ្រីស្ទដែរ។ ពាក្យថា « ចុះចូល» គឺជាពាក្យយោធាដែលមានន័យថា «ក្រោមបញ្ជា» ។ ដូចជាពលបាលម្នាក់ដែលចុះចូលនឹងវរសេនីយ៍ឯក ភរិយាត្រូវតែចុះចូលចំពោះប្ដីរបស់នាងនៅគ្រប់កិច្ចការទាំងអស់ លើកលែងតែវាធ្វើឲ្យនាងមិនស្ដាប់បង្គាប់មេបញ្ជាការនិងប្រធាន គឺជាព្រះគ្រីស្ទ។ ។ រាល់ការសម្រេចចិត្តរបស់ស្ត្រីត្រូវធ្វើតាមប្ដីរបស់នាងលើកលែងតែភាពជាអ្នកដឹកនាំរបស់គាត់នាំឲ្យនាងធ្វើបាប។ នៅក្នុងពាក្យបច្ចេកទេសយោធានេះ អាចត្រូវបានគេហៅថា «បទបញ្ជាខុសច្បាប់» ។ ភរិយាត្រូវតែយល់ពីរឿងនេះដោយប្រាជ្ញា។

ជាមួយនឹងការនិយាយបែបនេះ ពិតជាមិនរាប់បញ្ចូលសមត្ថភាពរបស់ប្រពន្ធក្នុងការសម្រេចចិត្តដោយខ្លួនឯងនោះទេ។ ព្រះគ្រីស្ទដឹកនាំយើងផ្តល់ឲ្យយើងនូវទំនួលខុសត្រូវជាច្រើន និងទម្រង់នៃស្វ័យភាពនៅក្រោមសិទ្ធអំណាចរបស់ទ្រង់។ ក្នុងការដើរតាមព្រះគ្រីស្ទ ទ្រង់ជារឿយៗមិនប្រាប់យើងឲ្យទៅខាងឆ្វេងឬទៅខាងស្តាំ ឬពេលណាត្រូវសម្រាកនោះឡើយ។ បទគម្ពីរអំពាវនាវឲ្យយើងធ្វើជាមនុស្សដែលមានប្រាជ្ញា ហើយប្រើគោលការណ៍ដែលបានចែងនៅក្នុងបទគម្ពីរ។ ស្រដៀងគ្នានេះដែរ ប្រពន្ធអាចមានផ្នែកជាច្រើននៃភាពជាអ្នកដឹកនាំក្រោមសិទ្ធអំណាចរបស់ស្វាមីនាង។

សម្រាប់អ្នកខ្លះ ភរិយានឹងពូកែក្នុងផ្នែកថែរក្សាផ្ទះសម្បែង ទោះបីជានាងស្ថិតក្រោមការដឹកនាំរបស់ស្វាមីក៏ដោយ។ សម្រាប់អ្នកផ្សេងទៀត ភរិយានឹងត្រួតពិនិត្យលើហិរញ្ញវត្ថុ។ អ្នកដឹកនាំល្អទទួលស្គាល់ចំណុចខ្លាំងរបស់អ្នកដទៃនិងពឹងផ្អែកលើពួកគេនូវចំណុចទាំងនោះ។ រឿងនេះនឹងក្លាយជាការពិតនៅរាល់អាពាហ៍ពិពាហ៍ ហើយវាអាចមើលទៅខុសគ្នាបន្តិចបន្តួចនៅរាល់អាពាហ៍ពិពាហ៍។

នេះប្រហែលជាគំនិតមួយដែលខុសប្លែកពីធម្មតា ពោលគឺគំនិតមួយដែលនាំឲ្យមានការផ្លាស់ប្ដូរដែលស្ត្រីទើបរៀបការថ្មីថ្មោងត្រូវតែចាប់យក។ វាមិនយូរទៀតទេថា« តើខ្ញុំបានផ្តល់កិត្តិយសដល់ព្រះ

ជាម្ចាស់ក្នុងទង្វើរបស់ខ្ញុំ និងការព្យាយាមរបស់ខ្ញុំឬទេ? ប៉ុន្តែក៏ «តើខ្ញុំបានផ្តល់កិត្តិយសដល់ស្វាមីរបស់ខ្ញុំដែលព្រះជាម្ចាស់បានត្រាស់ហៅខ្ញុំឲ្យដើរតាមឬទេ?»

សូមពិចារណានូវកិត្តិយសដែលបានផ្តល់ឲ្យសារ៉ាដោយសាររបៀបដែលនាងបានចុះចូលចំពោះស្វាមីរបស់នាង លោកអ័ប្រាហាំ។ ១ពេត្រុស៣: ៥-៦ និយាយថា៖

*៥ ដ្បិតពីដើម ពួកស្រីៗបរិសុទ្ធដែលសង្ឃឹមដល់ព្រះ ក៏បានតែងខ្លួនយ៉ាងដូច្នោះ ទាំងចុះចូលចំពោះប្តីខ្លួនដែរ ៦ ដូចជានាងសារ៉ា បានចុះចូលនឹងលោកអ័ប្រាហាំ ព្រមទាំងហៅលោកជាម្ចាស់ផង ឯអ្នករាល់គ្នា ក៏បានត្រឡប់ជាពូជនាងនោះ ដោយបានប្រព្រឹត្តល្អ ឥតភិតភ័យនឹងសេចក្តីស្ញែងខ្លាចណាឡើយ។*

សារ៉ាបានហៅស្វាមីរបស់នាងថា លោកម្ចាស់ ហើយបទគម្ពីរបានថែងថា នេះគឺជាអត្តចរិកមួយដែលធ្វើឲ្យស្ត្រីស្រស់ស្អាតនៅចំពោះព្រះជាម្ចាស់។ ស្ត្រីដែលកំពុងពិចារណារឿងរៀបការត្រូវតែសួរខ្លួនឯងថា «តើខ្ញុំត្រៀមខ្លួន ដើម្បីគោរពនិងចុះចូលចំពោះស្វាមីរបស់ខ្ញុំដូចជាព្រះអម្ចាស់ហើយឬនៅ? តើខ្ញុំស្ម័គ្រចិត្តចុះចូលនឹងផែនការរបស់គាត់ដូចដែលគាត់បានពមកពីព្រះជាម្ចាស់ឬទេ? មនុស្សម្នាក់ដែលស្ម័គ្រចិត្តចុះចូលគួតែពិចារណាប្រសិនបើនាងពិតជាត្រៀមខ្លួនរួចរាល់ ដើម្បីរៀបការមែន។

### ប្រពន្ធត្រូវតែចុះចូលចំពោះភាពជាអ្នកដឹកនាំរបស់ព្រះគ្រីស្ទ

ម្តងទៀត អេភេសូរ ៥:២២ ចែងថា *«ស្ត្រីរាល់គ្នាអើយ ចូរឲ្យចុះចូលចំពោះប្តីខ្លួន ដូចជាចុះចូលនឹងព្រះអម្ចាស់ដែរ»*។ នេះមិនត្រឹមតែបង្រៀនដល់ភរិយាត្រូវចុះចូលចំពោះស្វាមីរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែពោលគឺពួកគេត្រូវតែចុះចូលចំពោះព្រះជាម្ចាស់ជាមុនសិន។ ស្វាមីគ្រាន់តែជាតំណាងឲ្យភាពជាអ្នកដឹកនាំរបស់ព្រះគ្រីស្ទ មិនថាការតំណាងនោះទន់ខ្សោយយ៉ាងណាក៏ដោយ។ វាគឺស្ថិតនៅក្នុងការចុះចូលចំពោះព្រះគ្រីស្ទ ដោយគោរពតាមព្រះបន្ទូលរបស់ទ្រង់ ហើយស្រឡាញ់ទ្រង់ ដែលភរិយានឹងស្វែងរកនូវសមត្ថភាពក្នុងការចុះចូលចំពោះប្តីរបស់នាង។ នេះនឹងក្លាយជាការពិតយ៉ាងពិសេសក្នុងការដោះស្រាយជាមួយស្វាមីដែលមិនស្គាល់ព្រះអម្ចាស់ឬអ្នកដែលឃ្លាតឆ្ងាយពីទ្រង់។ ១ពេត្រុស៣:១-២ និយាយថា៖

*ភរិយាទាំងឡាយត្រូវចុះចូលនឹងស្វាមីរបស់អ្នកដែរដូច្នេះ បើមានអ្នកណាមិនជឿព្រះបន្ទូល គេអាចនឹងឈ្នះដោយគ្មានពាក្យសំដី គឺដោយអាកប្បកិរិយារបស់ប្រពន្ធគេពេលឃើញភាពបរិសុទ្ធ និងការគោរពនៃជីវិតរបស់អ្នក។*

ការដឹកនាំរបស់ស្វាមីប្រព្រឹត្តឡើងសូម្បីតែនៅពេលដែលគាត់មិនដើរតាមព្រះក៏ដោយ។ នៅក្នុងករណីនេះ ការចុះចូលរបស់ភរិយាចំពោះព្រះគ្រីស្ទ គឺសំខាន់ជាង។ តាមរយៈការចុះចូលចំពោះព្រះគ្រីស្ទ នាងនឹងរកឃើញនូវសមត្ថភាពក្នុងការស្រឡាញ់ និងចុះចូលចំពោះស្វាមីដែលពិបាក ហើយការចុះចូលនេះអាចនាំមកនូវការផ្លាស់ប្តូរ និងសូម្បីតែសេចក្តីសង្គ្រោះដល់ជីវិតរបស់គាត់។ទោះជាយ៉ាងណាក៏ដោយ ការនេះអាចទៅរួចបាននៅពេលដែលភរិយាកំពុងតែចុះចូលចំពោះព្រះជាម្ចាស់។ ព្រះយេស៊ូវបានមានបន្ទូលនៅក្នុងកណ្ឌគម្ពីរយ៉ូហាន ១៥:៥ ថា *«ចូរនៅជាប់នឹងខ្ញុំចុះនោះអ្នកនឹងបង្កើតផលបានច្រើន»* (ជាពាក្យពន្យល់) ។ សមត្ថភាពក្នុងការស្រឡាញ់ មានសន្តិភាព មានភាពអត់ធ្មត់មានការអភ័យទោស

ជាដើម។ ល។ ទាំងអស់សុទ្ធតែមកពីព្រះ។

ស្ត្រីនៅលីវដែលកំពុងពិចារណាអំពីរឿងរៀបការត្រូវតែសួរខ្លួនឯងថា «តើខ្ញុំកំពុងចុះចូលចំពោះការដឹកនាំរបស់ព្រះអម្ចាស់ ដូច្នេះ តើខ្ញុំអាចចុះចូលដោយស្មោះត្រង់ចំពោះភាពជាអ្នកដឹកនាំរបស់ប្ដីខ្ញុំបានឬទេ?» ការចុះចូលជារៀងរាល់ថ្ងៃទៅកាន់ព្រះជាម្ចាស់ នឹងរៀបចំស្ត្រីសម្រាប់រៀបអាពាហ៍ពិពាហ៍។ ដូចគ្នានេះដែរ បុរសនៅលីវដែលកំពុងពិចារណារឿងរៀបការជាមួយស្ត្រីត្រូវតែសួរខ្លួនឯងថា «តើការចុះចូលរបស់នាងយ៉ាងម៉េចដែរ? តើនាងចុះចូលចំពោះព្រះអម្ចាស់ដោយស្មោះត្រង់ឬទេ? តើនាងស្មោះត្រង់ក្នុងការចូលរួមនៅក្នុងព្រះវិហារ ការលះបង់ប្រចាំថ្ងៃនិងការបម្រើដល់ព្រះជាម្ចាស់ឬទេ? ប្រសិនបើនាងមិនចុះចូលទៅកាន់ព្រះដ៏ធំបំផុតទេ នោះនាងនឹងមិនចុះចូលទៅកាន់អ្នកតូចដែលជាប្ដីនាងដែរ។ បុរសដែលមានប្រាជ្ញានឹងពិចារណាពីការស្ដាប់បង្គាប់របស់ស្ត្រីម្នាក់ចំពោះព្រះជាម្ចាស់នៅពេលស្វែងរកប្រពន្ធ។ ព្រះជាម្ចាស់បានត្រាស់ហៅភរិយាឲ្យចុះចូលចំពោះព្រះគ្រីស្ទជាមុនសិន ដូច្នេះ នាងអាចគោរពនិងចុះចូលចំពោះស្វាមីរបស់ខ្លួនដោយស្មោះត្រង់ដែរ។

### ស្វាមីនិងភរិយាត្រូវតែបង្ហាត់កូនៗជាមួយគ្នា

អេភេសូរ ៦:៤ ចែងថា *«ឪពុករាល់គ្នាអើយ កុំឲ្យចាក់រុកកូនរបស់ខ្លួនឡើយ ចូរបង្រៀនវាទៅតាមដំបូន្មាន នឹងសេចក្ដីដាស់តឿនរបស់ព្រះអម្ចាស់វិញ»* «ឪពុក» ក៏អាចបកប្រែបានថា «ឪពុកម្ដាយ» (ប្រៀបធៀបនៅក្នុងព្រះគម្ពីរជាភាសាអារ៉ាប់ ពន្យល់ជាភាសាអង់គ្លេស)។

នេះមានន័យថា ឪពុកម្ដាយទាំងពីរត្រូវតែធ្វើការរួមគ្នា ដើម្បីបង្ហាត់កូនៗ និងមិនបណ្ដោយឲ្យពួកគេមានចិត្តរឹងរូសនាំឲ្យពួកគេមានចិត្តខ្លាំង មានសេរីភាពពេក ឬមានភាពជាអ្នកដឹកនាំអយុត្តិធម៌នោះឡើយ។ ឪពុកម្ដាយត្រូវបង្ហាញភាពជាអ្នកដឹកនាំដោយកោតខ្លាចដល់ព្រះជាម្ចាស់ដោយយកគំរូតាមព្រះគ្រីស្ទ បង្រៀនកូនៗអំពីព្រះបន្ទូលរបស់ព្រះ ហើយទាញនាំពួកគេឲ្យមានទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយនឹងព្រះជាម្ចាស់។

ការនេះជាកាតព្វកិច្ចដែលមិនមែនសម្រាប់តែឪពុកឬម្ដាយតែម្នាក់ឯងនោះឡើយ ហើយនោះជាមូលហេតុដែលព្រះបានប្រគល់ទំនួលខុសត្រូវខាងឯព្រលឹងវិញ្ញាណដល់ឪពុកម្ដាយទាំងពីរ។ នៅទីបំផុតស្វាមីគួរតែនៅត្រួតពិនិត្យការបណ្ដុះបណ្ដាលនេះ ប៉ុន្តែការទទួលខុសត្រូវគឺចែករំលែកគ្នា។ សម្រាប់ហេតុផលនេះ ឪពុកម្ដាយត្រូវតែឈានដល់កិច្ចព្រមព្រៀងអំពីរបៀបបណ្ដុះបណ្ដាលកូនៗ។ ប្រសិនបើគ្មានការសាមគ្គីគ្នាក្នុងការបណ្ដុះបណ្ដាលទេ នោះវានឹងមានផលប៉ះពាល់គ្រោះថ្នាក់ដល់កូនៗ។

គូស្វាមីភរិយាដែលកោតខ្លាចដល់ព្រះជាម្ចាស់ត្រូវអង្គុយចុះ ហើយពិភាក្សាគ្នាអំពីរបៀបណាដែលអាចធ្វើការបានសម្រេច។ នេះនឹងរួមបញ្ចូលនូវវិន័យ ការបណ្ដុះបណ្ដាលខាងវិញ្ញាណ ការបណ្ដុះបណ្ដាលការអប់រំ ការហ្វឹកហាត់កីឡា និងផ្នែកនៃការបម្រើក្នុងចំណោមកិច្ចការផ្សេងទៀត។ សម្រាប់ការបណ្ដុះបណ្ដាលខាងវិញ្ញាណ ឪពុកម្ដាយជាច្រើនបានប្រគល់កូនៗឲ្យទៅឯខាងកម្មវិធីរបស់កុមារ ការចងចាំព្រះគម្ពីរ ការថ្វាយបង្គំក្នុងគ្រួសារប្រចាំថ្ងៃក៏ដូចជាការចូលរួមនៅក្នុងការអធិប្បាយព្រះ

បន្ទូលនៅព្រះវិហារដែរ។

គួរឲ្យស្តាយ អ្វីដែលបានកើតឡើងនៅក្នុងគ្រួសារគ្រីស្ទបរិស័ទជាច្រើន គឺការអំពាវនាវសម្រាប់ឲ្យឪពុកម្តាយបង្ហាត់បង្រៀនកូនៗរបស់ពួកគេត្រូវបានចាកចេញពីព្រះវិហារ ចោលសាលារៀន ចេញពីជីដូនជីតា ចេញពីគ្រូបង្វឹកកីឡាជាដើម។ ព្រះទ្រង់មិនដែលមានបំណងព្រះហឫទ័យសម្រាប់ឲ្យមនុស្សទាំងនេះទៅចិញ្ចឹមកូនៗទាំងស្រុងនោះទេ ពួកគេគួរតែអាចបំពេញខ្លួនឯងឲ្យបានល្អបំផុត។ ជាលទ្ធផល ៧៥%នៃយុវជនគ្រីស្ទបរិស័ទបានឃ្លាតឆ្ងាយពីព្រះនៅពេលដែលពួកគេចូលរៀននៅមហាវិទ្យាល័យ ពីព្រោះឪពុកម្តាយជាច្រើនបានធ្វេសប្រហែសក្នុងការទទួលខុសត្រូវរបស់ពួកគេ។

គូដណ្តឹងគួរតែពិចារណាអំពីការបណ្តុះបណ្តាលកូនរបស់ពួកគេនាពេលអនាគតមុនពេលពួកគេរៀបការ តាំងពីការចិញ្ចឹមគ្រាប់ពូជដែលកោតខ្លាចដល់ព្រះ គឺជាបំណងចិត្តមួយដ៏ចម្បងរបស់ព្រះសម្រាប់អាពាហ៍ពិពាហ៍រួបរួម (ម៉ាឡាគី ១:១៥)។ តើអ្នកមានបានពិចារណាអំពីរបៀបណាដែលអ្នកនឹងបណ្តុះបណ្តាលកូនៗរបស់អ្នកឬនៅ?

### សរុបសេចក្តី

ការធ្លាក់ចុះបានធ្វើឲ្យខូចដល់ទ្រង់ទ្រាយនៃការរចនាដើមរបស់ព្រះជាម្ចាស់សម្រាប់ស្វាមីនិងភរិយា។ ដោយសារតែអំពើបាបប្តីមានទំនោរព្យាយាមត្រួតត្រាលើប្រពន្ធរបស់ខ្លួន ឬក្លាយជាអ្នកធ្វើឲ្យប្រពន្ធនៅក្រោមអំណាចរបស់គាត់។ ទំនោរសម្រាប់ភរិយាគឺដូចគ្នាដែរ។ ទោះយ៉ាងណាក៏ដោយផែនការរបស់ព្រះ គឺឲ្យស្វាមីស្រឡាញ់និងបម្រើដល់ភរិយារបស់ខ្លួន ហើយសម្រាប់ភរិយាត្រូវឲ្យចុះចូលចំពោះប្តីវិញ។ ពួកគេទាំងពីរមានទំនួលខុសត្រូវក្នុងការចិញ្ចឹមបីបាច់កូនៗតាមការដាស់តឿនរបស់ព្រះជាម្ចាស់។ ប៉ុន្តែនៅទីបំផុតស្វាមីនឹងត្រូវទទួលខុសត្រូវចំពោះព្រះចំពោះភាពជាអ្នកដឹកនាំរបស់គាត់ឬការខ្វះខាតក្នុងភាពជាអ្នកដឹកនាំលើគ្រួសាររបស់គាត់ដែរ។

### កិច្ចការផ្ទះ--តួនាទីយេនឌ័រ

ឆ្លើយនឹងសំនួរ ហើយពិភាក្សាជាមួយគ្នា

១. តើមានអ្វីថ្មីឬចូលមកក្នុងគំនិតអ្នកនៅក្នុងវគ្គនេះ? តើអ្នកត្រូវបានជំរុញឬលើកទឹកចិត្តក្នុងវិធីណាខ្លះ? តើមានចំណុច ឬគំនិតណាដែលអ្នកមិនយល់ស្របឬទេ?

២. ជារឿយៗ នៅពេលចាប់ផ្តើមអាពាហ៍ពិពាហ៍ប្តីប្រពន្ធនាំមានការរំពឹងទុកខុសគ្នាៗដោយមិន

មានការនិយាយគ្នា។ ទាំងនេះជាញឹកញាប់ក្លាយជាចំណុចនៃការបាក់ទឹកចិត្តនិងភាពតានតឹងក្នុងទំនាក់ទំនង។ ការពិភាក្សាអំពីការរំពឹងទុកជាមុននឹងជួយធ្វើឲ្យមានការផ្លាស់ប្តូរនៅក្នុងអាពាហ៍ពិពាហ៍ដោយរលូន។ តើអ្នកមានតួនាទីយេនឌ័រអ្វីខ្លះនៅក្នុងគេហដ្ឋានរបស់អ្នក? តើតួនាទីអ្វីដែលឪពុករបស់អ្នកបានបំពេញក្នុងការលះបង់សម្រាប់គ្រួសារ ក្នុងការដាក់វិន័យកូនៗ ហិរញ្ញវត្ថុ ការងារ ការសំអាតផ្ទះជាដើម។ តើតួនាទីអ្វីដែលម្តាយរបស់អ្នកបានបំពេញ?

៣. ចូរសរសេរចុះនូវការរំពឹងទុកចំនួនមួយម្ភៃ សម្រាប់ដៃគូរបស់អ្នកនៅក្នុងអាពាហ៍ពិពាហ៍ដូចជា៖ តើអ្នកណានឹងធ្វើកិច្ចការផ្ទះ? តើអ្វីជាក្តីរំពឹងរបស់អ្នកសម្រាប់ដៃគូរបស់អ្នកចំពោះការលះបង់ខាងឯព្រលឹងវិញ្ញាណ? តើអ្វីជាក្តីរំពឹងរបស់អ្នកសម្រាប់ប្តីប្រពន្ធរបស់អ្នកនៅក្នុងសម្លៀកបំពាក់ដែលគាត់ស្លៀក? តើអ្នកនឹងធ្វើអ្វីសម្រាប់ថ្ងៃឈប់សម្រាក? តើក្រុមគ្រួសារខាងណាដែលអ្នកនឹងចំណាយពេលជាមួយនៅពេលបុណ្យចូលឆ្នាំខ្មែរឬភ្ជុំបិណ្ឌជាមួយ។ ល។ តើអ្នករំពឹងថាលុយនិងការសម្រេចចិត្តសំខាន់ៗនឹងត្រូវដោះស្រាយយ៉ាងដូចម្តេច? តើអ្នកណានឹងដាក់វិន័យដល់កូនៗ?

៤. ចូរសរសេរការរំពឹងទុកចំនួនដប់ដែលអ្នកគិតថាដៃគូរបស់អ្នកនឹងមានសម្រាប់អ្នក។

៥. ចូរពិភាក្សារឿងទាំងនេះជាមួយដៃគូរបស់អ្នកហើយឈានដល់កិច្ចព្រមព្រៀងស្តីពីការរំពឹងទុកដែល ម្នាក់ៗនឹងបំពេញ។ ចូរសរសេរចុះពីការរំពឹងទុកដែលអ្នកបានព្រមព្រៀងគ្នា។ ចូរសរសេរវាជាមួយទម្រង់នេះ

«ខ្ញុំនឹងប្តេជ្ញាចិត្តថា.................................នៅក្នុងអាពាហ៍ពិពាហ៍របស់យើងជាមួយការគាំទ្រពីភរិយាឬ ស្វាមីរបស់ខ្ញុំ និងដោយព្រះគុណរបស់ព្រះជាម្ចាស់» ។

៦. បន្ទាប់ពីបញ្ចប់វគ្គនេះតើរបៀបណាដែលអ្នកគិតថា ព្រះកំពុងត្រាស់ហៅអ្នកឲ្យអធិស្ឋានសម្រាប់អនាគតអាពាហ៍ពិពាហ៍របស់អ្នក? សូមចំណាយពេលខ្លះអធិស្ឋាន។

# មូលដ្ឋានគ្រឹះទី៥៖ ការដោះស្រាយទំនាស់នៅក្នុងអាពាហ៍ពិពាហ៍

តើគូស្វាមីគួរតែដោះស្រាយទំនាស់នៅក្នុងអាពាហ៍ពិពាហ៍ដោយរបៀបណា?

ជាទូទៅទំនាស់គឺជាផ្នែកមួយនៃនិស្ស័យរបស់មនុស្ស។ ក្រោយដែលអ័ដាមធ្លាក់ទៅក្នុងអំពើបាបនៅក្នុងសួនច្បារអេដែនមកទំនាស់បានកើតឡើង។ នៅពេលដែលព្រះទ្រង់បានសួរអ័ដាមថា តើគាត់បានបរិភោគផ្លែឈើដែលបានហាមឃាត់នោះឬ គាត់មិនបានឆ្លើយតប"បាទ"ដោយសាមញ្ញនោះទេ គាត់បែរជាឆ្លើយថា ស្ត្រីដែលទ្រង់ប្រទានឲ្យទូលបង្គំ វាឲ្យផ្លែឈើនោះមកទូលបង្គំ ហើយទូលបង្គំក៏ទទួលទានទៅ។ គាត់បានបន្ទោសព្រះជាម្ចាស់ដោយប្រយោល ហើយក៏បន្ទោសស្ត្រីដោយត្រង់ៗផងដែរ។ បន្ទាប់មកស្ត្រីក៏បានបន្ទោសទៅសត្វពស់។ នៅពេលដែលអំពើបាបបានចូលមកក្នុងលោកីយ៍ ទំនាស់ក៏បានចូលមកជាមួយគ្នាដែរ។ ជាក់ស្តែងព្រះទ្រង់បានមានបន្ទូលដែរថា លទ្ធផលមួយក្នុងចំណោមលទ្ធផលនៃអំពើបាបដែលចូលមកក្នុងលោកីយ៍នឹងមានទំនាស់រវាងមនុស្ស ប្រុសហើយនិងមនុស្សស្រី។ ប្រពន្ធមានបំណងចិត្តក្នុងការគ្រប់គ្រងប្តី ហើយប្តីនិងព្យាយាមត្រួតត្រាប្រពន្ធដោយការបង្ខិតបង្ខំ (លោកុ៣:១៦)។

ដូចដែលយើងបានដឹងពីសាច់រឿងនៅក្នុងព្រះគម្ពីររួចមកហើយ យើងបន្តឃើញពីផលផ្លែនៃអំពើបាបដែលបានបង្ហាញនៅក្នុងទំនាស់។ នៅក្នុងលោកុប្បត្តិជំពូក៤ ការអ៊ីនបានសម្លាប់ប្អូនប្រុសរបស់គាត់អេបិល។ នៅក្នុងជំពូកដដែលនោះ ឡាមេកកូនប្រុសរបស់ការអ៊ីនបានសម្លាប់បុរសម្នាក់ ហើយបានអួតពីការនោះ។ នៅក្នុងលោកុប្បត្តិជំពូក៦ លោកីយ៍ទាំងមូលពោរពេញទៅដោយអំពើហិង្សា ហើយព្រះជាម្ចាស់បានសម្រេចព្រះហឫទ័យបោសសំអាតពួកគេដោយទឹកជំនន់។ ទោះជាយ៉ាងណាក៏ដោយ ទឹកជំនន់មិនបានផ្លាស់ប្តូរសារជាតិរបស់មនុស្សបាននោះទេ ហើយហេតុយ៉ាងដូច្នោះ ទំនាស់បានបន្តនៅទូទាំងប្រវត្តិសាស្ត្រ។ លោកីយ៍ទាំងមូលបានប្រឈមមុខនឹងសង្គ្រាមឬទំនាស់ដោយគ្មានពេលស្រាកស្រាន្ត ហើយជាអកុសល អាពាហ៍ពិពាហ៍មិនត្រូវបានលើកលែងនោះទេ។

សាវ័កប៉ុលបានបង្រៀនថា លទ្ធផលមួយនៃសាច់ឈាមដែលជានិស្ស័យបាបរបស់យើងនោះគឺ"ការមិនចុះសម្រុងគ្នា" (កាឡាទី ៥:២០)។ យើងងាយនឹងធ្វើឲ្យអ្នកដទៃអាក់អន់ចិត្ត ឆាប់អន់ចិត្តស្អប់ មិនងាយអត់ទោស ហើយមានការបែងចែក។ គួរឲ្យស្តាយ ផលផ្លែទាំងអស់នេះងាយនឹងចេញផ្កានៅក្នុងសហជីពអាពាហ៍ពិពាហ៍។ គូស្វាមីភរិយាគួរតែដឹងអំពីរឿងនេះ ដូច្នេះត្រូវត្រៀមលក្ខណៈដើម្បីដោះស្រាយ ទំនាស់នៅក្នុងអាពាហ៍ពិពាហ៍។ តើគូស្វាមីភរិយាគួរដោះស្រាយទំនាស់នៅក្នុងអាពាហ៍ពិពាហ៍ដោយរបៀបណា?

**នៅក្នុងទំនាស់ យើងត្រូវតែមានឥរិយាបថត្រឹមត្រូវ**

គោលការណ៍ទីមួយដែលចាំបាច់ ដើម្បីដោះស្រាយទំនាស់គឺត្រូវមានអាកប្បកិរិយាត្រឹមត្រូវ នេះជាការរំពឹងទុកដ៏រីករាយមួយនៅក្នុងព្រះជាម្ចាស់។ វាជាការល្អដែលត្រូវចងចាំថា ទំនាស់មិនចាំបាច់ធ្វើឲ្យខូចដល់ទំនាក់ទំនងអាពាហ៍ពិពាហ៍នោះទេ។ ទំនាស់ក៏ដូចជាការសាកល្បងទាំងអស់ដែរ គឺមានន័យថា ដើម្បីសាកល្បងសេក្តីជំនឿរបស់យើង បង្ហាញពីអំពើបាបនៅក្នុងដួងចិត្តរបស់យើង អភិវឌ្ឍចរិតលក្ខណៈនឹងនាំយើងឲ្យចូលទៅកាន់តែជិតព្រះ (រ៉ូម៥: ៣-៥, យូដាស ១: ២-៤) ។ លោកប៉ុលបាននិយាយថា៖ *មិនតែប៉ុណ្ណោះសោត យើងនៅតែអួតក្នុងកាលដែលមានទុក្ខលំបាកដែរ ដោយដឹងថា សេក្តីទុក្ខលំបាកបង្កើតឲ្យមានសេក្តីទ្រាំទ្រ សេក្តីទ្រាំទ្របង្កើតឲ្យមានសេក្តីស៊ាំថ្នឹក សេក្តីស៊ាំថ្នឹកបង្កើតឲ្យមានសេក្តីសង្ឃឹម* (រ៉ូម ៥: ៣-៤) ។ ស្រដៀងគ្នាដែរ យ៉ាកុបបាននិយាយថា *"បងប្អូនអើយ កាលណាអ្នករាល់គ្នាមានសេចក្ដីល្បួងផ្សេងៗ នោះត្រូវរាប់ជាសេចក្ដីអំណរសព្វគ្រប់វិញ ដោយដឹងថា ការល្បងលមើលសេចក្ដីជំនឿនៃអ្នករាល់គ្នា នោះនាំបង្កើតឲ្យមានសេចក្ដីខ្ជាប់ខ្ជួន"* (យ៉ាកុប ១:២-៣) ។ លោកប៉ុលបាននិយាយថា យើងគួរអរសប្បាយនៅក្នុងកាលដែលមានទុក្ខលំបាក ហើយយ៉ាកុបក៏បាននិយាយដែរថាយើងគួរតែរាប់វាជា "សេចក្ដីអំណរសព្វគ្រប់" នៅពេលយើងជួបប្រទះការលំបាកទាំងនោះដោយសារតែគោលបំណងរបស់ព្រះនៅក្នុងសេក្តីទាំងនោះ។ ព្រះមិនខ្វះខ្វាយពេលមានទុក្ខលំបាកទេ រួមទាំងទំនាស់ក្នុងអាពាហ៍ពិពាហ៍ដែរ។ ព្រះជាម្ចាស់ប្រើទំនាស់ ដើម្បីធ្វើឲ្យយើងរីកចម្រើនដូចអង្គព្រះគ្រីស្ទដែរ(រ៉ូម ៨: ២៨-២៩) ដែលគួរតែជាគោលដៅចុងក្រោយរបស់យើង។

ជាច្រើនលើកច្រើនសារដែលព្រះជាម្ចាស់ទ្រង់ប្រើប្ដីឬប្រពន្ធរបស់យើងដូចជាក្រដាសខ្សាច់ដែលគ្រើមយកមកដុសខាត់ផ្នែកណានៅក្នុងជីវិតយើងដែលមិនបានឆ្លុះបញ្ចាំងពីព្រះគ្រីស្ទឲ្យបានរាបស្មើរឡើង។ មានពាក្យមួយឃ្លាដែលតែងនិយាយថា អាពាហ៍ពិពាហ៍មិនមែននិយាយអំពីសុភមង្គលទេ ប៉ុន្តែនិយាយអំពីភាពបរិសុទ្ធ។ ហើយនៅពេលដែលយើងបរិសុទ្ធ បន្ទាប់មកយើងនឹងសប្បាយរីករាយពិតប្រាកដ។ នៅក្នុងអាពាហ៍ពិពាហ៍ យើងឈានចូលទៅក្នុងទំនាក់ទំនងមួយដែលមានទំនួលខុសត្រូវលើការសម្រេចចិត្តរបស់យើង ដែលមានន័យថា ជួយយើងឲ្យលូតលាស់ក្នុងនាមជាកូនរបស់ព្រះជាម្ចាស់ (អេភេសូរ៥:២៥-២៧)។

ហេតុយ៉ាងដូច្នេះ ដូចជាលោកយ៉ាកុបបានបង្រៀននៅ (យ៉ាកុប ១:២) និងលោកប៉ុលបានបង្រៀននៅ (រ៉ូម ៥:៣) យើងគួរតែជួបប្រទះនឹងទំនាស់នៅក្នុងអាពាហ៍ពិពាហ៍ (និងការសាកល្បងទាំងអស់) ដោយការរំពឹងទុកដ៏រីករាយមិនមែនដោយសារយើងរីករាយនឹងទុក្ខវេទនានោះទេ ប៉ុន្តែដោយសារតែយើងដឹងពីគោលបំណងរបស់ព្រះជាម្ចាស់នៅក្នុងទុក្ខលំបាកនោះ។ យើងថ្វាយបង្គំព្រះដែលបានដកយកអស់ទាំងអំពើបាបដ៏អាក្រក់បំផុតដែលកើតនៅក្នុងលោកីយ៍ទាំងមូល ជាកន្លែងដែលធ្វើគត់ព្រះរាជបុត្រារបស់ទ្រង់ ហើយធ្វើឲ្យវាក្លាយជារបស់ល្អបំផុត។ វាគឺសម្រាប់ហេតុផលនេះដែលយើងមានការរំពឹងទុកដ៏រីករាយសូម្បីតែនៅក្នុងទំនាស់ក៏ដោយ។ នេះមិនមែនជាការបដិសេធនៃការឈឺចាប់នោះទេ។ វាគឺទាំងពីរទទួលស្គាល់ពីការឈឺចាប់និងក្តីសង្ឃឹមនាពេលអនាគត។ វាដូចជាម្ដាយផ្ដល់កំណើតដល់កូនអញ្ចឹងដែរ។ ទោះបីជាមានការឈឺចាប់ខ្លាំងក៏ដោយ នោះគឺមានការរំពឹងទុកដ៏រីករាយដែរ។ គូស្វាមីភរិយាជាច្រើនដែលបានឆ្លងកាត់ទំនាស់ដ៏លំបាកបាន

បង្កើតចំណងអាពាហ៍ពិពាហ៍រឹងមាំបំផុតពេលគឺអាពាហ៍ពិពាហ៍ប្រើ ដើម្បីប្រឹក្សានិងផ្សះផ្សារអ្នកដទៃផង ដែរ។

តើអ្នកមានអាកប្បកិរិយាបែបណានៅពេលអ្នកជួបប្រទះនឹងទំនាស់ជាមួយដៃគូរបស់អ្នក? ប្រសិនបើយើងមិនមានអាកប្បកិរិយាត្រឹមត្រូវ ប្រសិនបើយើងខឹងនឹងដៃគូរបស់យើង ហើយខឹងនឹងព្រះ ប្រសិនបើយើងបាក់ទឹកចិត្ត មានភាពល្វីងជូរចត់ និងស្រងាកចិត្ត បន្ទាប់មកនោះវានឹងជះឥទ្ធិពល អវិជ្ជមានដល់អាកប្បកិរិយារបស់យើង ហើយប្តីប្រពន្ធរបស់យើងដែរ ហេតុដូច្នេះហើយ យើងនឹងទទួល បានផលអាក្រក់នៅក្នុងអាពាហ៍ពិពាហ៍។ ទំនាស់គ្រាន់តែជាឱកាសមួយ ដើម្បីឲ្យយើងរីកចម្រើនហើយ យើងគួរតែមើលវាក្នុងរបៀបនោះវិញ។

តើអ្នកមានអាកប្បកិរិយាបែបណាកំឡុងពេលមានទំនាស់? តើអ្នកមានការរំពឹងទុកដ៏រីករាយនឹង ការងារដែលព្រះសព្វព្រះហឫទ័យឲ្យធ្វើឬទេ? តើអ្នករំពឹងថាទ្រង់នឹងធ្វើឲ្យអ្នកកាន់តែបរិសុទ្ធឬទេ? តើអ្នក រំពឹងថាគាត់នឹងពង្រឹងសមត្ថភាពរបស់អ្នកក្នុងការស្រឡាញ់ឬទេ? នោះហើយជារបៀបដែលបទគម្ពីរ ប្រាប់យើងឲ្យមើលការសាកល្បងទាំងអស់។

### នៅក្នុងទំនាស់ យើងត្រូវតែអភិវឌ្ឍភាពទ្រាំទ្រ

ក្នុងការបន្តនូវអ្វីដែលលោកប៉ុលនិងយ៉ាកុបបានបង្រៀនអំពីការសាកល្បង ទាំងពីរបានបង្រៀន ថាការសាកល្បងបង្កើតសេក្តីទ្រាំទ្រ។ បន្ទាប់មកសាវ័កប៉ុលបាននិយាយថា សេក្តីទ្រាំទ្របង្កើតឲ្យមាន សេក្តីស៊ាំថ្នឹក ហើយសេក្តីស៊ាំថ្នឹកបង្កើតឲ្យមានសេចក្តីសង្ឃឹម (រ៉ូម ៥: ៣-៤) ។ យ៉ាកុបបាននិយាយថា យើងគួរតែ *«ចូរទុកឲ្យសេចក្តីខ្ជាប់ខ្ជួននោះ បានធ្វើការឲ្យសំរេចពេញលេញចុះ ដើម្បីឲ្យអ្នករាល់គ្នាបាន គ្រប់លក្ខណ៍ ហើយពេញខ្នាតឥតខ្វះអ្វីឡើយ»* (យ៉ាកុប ១: ៣-៤) ។ នៅក្នុងទំនាស់អាពាហ៍ពិពាហ៍ យើងត្រូវតែអភិវឌ្ឍសេក្តីទ្រាំទ្រ ដូច្នេះយើងអាចបង្កើតផលដែលព្រះសព្វព្រះហឫទ័យដាំដុះនៅក្នុង អាពាហ៍ពិពាហ៍របស់យើង។

ការនេះមិនមែនជារឿងងាយស្រួលនោះទេ ពីព្រោះជាធម្មតាការឆ្លើយតបរបស់យើងទៅនឹង បញ្ហានិងជម្លោះ នោះយើងចង់បោះបង់ចោលឬឈប់តែម្តង។ នោះហើយជាអ្វីដែលគូស្វាមីភរិយាជា ច្រើនធ្វើ។ នៅចំណុចខ្លះពួកគេនិយាយថា «វាគ្រប់គ្រាន់ហើយ»។ ខ្ញុំមិនអាចរស់នៅដូចនេះបានទេ» ហើយពួកគេក៏ឈប់។ អ្នកខ្លះធ្វើបែបនេះដោយការលែងលះគ្នា ឯអ្នកផ្សេងទៀតដាក់ឆ្ងាយខ្លួនរប ស់ពួកគេពីគ្នាទាំងអារម្មណ៍ និងរាងកាយពេលដែលពួកគេឈប់ធ្វើការផ្សះផ្សារអាពាហ៍ពិពាហ៍។ ទោះជាយ៉ាងណាក៏ដោយ ព្រះគម្ពីរបានបង្រៀនយើងឲ្យមានសេក្តីទ្រាំទ្រក្នុងការលំបាកឬការសាកល្ប ងនានាដែលរួមមានទាំងទំនាស់ផងដែរ។ អត្ថន័យនៃពាក្យ «ទ្រាំទ្រចំពោះទុក្ខលំបាក» ។ ព្រះទ្រង់បង្រៀន យើងឲ្យទុកចិត្តលើទ្រង់ថែមទៀត។ ទ្រង់ជួយយើងអភិវឌ្ឍន៍សន្តិភាព ភាពអត់ធ្មត់និងសេក្តីអំណរ ដោយមិនគិតពីកាលៈទេសៈរបស់យើងនោះឡើយ។ ទ្រង់ជួយយើងឲ្យលូតលាស់ក្នុងសេក្តីស៊ាំថ្នឹក ខណៈពេលដែលយើង «អនុញ្ញាតឲ្យការទ្រាំទ្របញ្ចប់កិច្ចការរបស់វា»។

ដើម្បីដោះស្រាយទំនាស់យើងត្រូវតែអភិវឌ្ឍសេក្តីទ្រាំទ្រ។ នោះគឺជាអ្វីសំខាន់ដែលយើងបាន

សន្យាថាធ្វើនៅក្នុងពាក្យសច្ចាក្នុងមង្គលការរបស់យើង។ យើងប្ដេជ្ញាថាស្រឡាញ់ប្ដីឬប្រពន្ធរបស់យើងនៅពេលមានជំងឺហើយនឹងសុខភាពល្អដែរ  ទោះបើកាន់តែប្រសើរឬកាន់តែអាក្រក់ទៅក៏ដោយ។ យើងគួរតែអរគុណនៅពេលដែលវា «ល្អប្រសើរ» និងទ្រាំទ្រនៅពេលវា »កាន់តែអាក្រក់« ។ សម្រាប់អ្នកណាដែលធ្វើនោះនឹងទទួលបានផលផ្លែ។ សាវ័កប៉ុលបាននិយាយថា «កុំឲ្យយើងណាយចិត្តនឹងធ្វើការល្អឡើយ ដ្បិតបើមិនរសាយចិត្តទេ នោះដល់កំណត់យើងនឹងច្រូតបានហើយ» (កាឡាទី ៦:៩) ។ តើអ្នកមានអារម្មណ៍ចង់បោះបង់ចោលដែរឬទេ? ឈប់សិន ពីព្រោះព្រះទ្រង់បានច្រូតសម្រាប់អ្នកប្រសិនអ្នកមិនបានបោះបង់ចោល។

### នៅក្នុងទំនាស់ យើងត្រូវតែសាបព្រោះគ្រាប់ពូជល្អ

យើងមិនត្រឹមតែត្រូវមានអាកប្បកិរិយាត្រឹមត្រូវនៅពេលជួបប្រទះទំនាស់ប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ត្រូវសាបព្រោះគ្រាប់ពូជត្រឹមត្រូវ ដើម្បីដោះស្រាយវាដែរ។ សាវ័កប៉ុលបានមានប្រសាសន៍ថាអ្វីក៏ដោយដែលយើងសាបព្រោះ នោះយើងនឹងច្រូតបានផងយ៉ាងនោះដែរ (កាឡាទី ៦:៧) ។ ការសាបព្រោះនិងការច្រូតកាត់ គឺជាគោលការណ៍មួយដែលព្រះបានបង្កើតនៅពាសពេញផែនដី ហើយវាក៏មាននៅក្នុងគ្រប់ពិធីមង្គលការផងដែរ។ ប្រសិនបើយើងសាបព្រោះគ្រាប់ពូជអវិជ្ជមាន នោះយើងនឹងទទួលបានផលអវិជ្ជមានដែរ។ ហើយប្រសិនយើងសាបព្រោះគ្រាប់ពូជវិជ្ជមាន  នោះយើងនឹងទទួលបានផ្លែវិជ្ជមានដែរ។

គួរឲ្យស្ដាយ ទោះបីជាយើងទាំងអស់គ្នាចង់បានការប្រមូលផលវិជ្ជមាននៅក្នុងអាពាហ៍ពិពាហ៍របស់យើងក៏ដោយ   ជាធម្មតាយើងឆ្លើយតបតាមរបៀបដែលផ្ទុយពីនោះវិញ។ ប្រពន្ធចង់ឲ្យប្ដីចំណាយពេលច្រើនជាមួយនាង ប៉ុន្តែដើម្បីឲ្យបានបែបនោះ នាងបែរជារិះគន់គាត់។ ផលផ្លែដែលនាងចង់បាន គឺផ្ទុយពីគ្រាប់ពូជដែលនាងកំពុងសាបព្រោះទៅវិញ។ គ្រាប់ពូជនៃការរិះគន់នឹងបង្កើតតែផលអវិជ្ជមាននៅក្នុងស្វាមីរបស់នាង។ ស្រដៀងគ្នានេះដែរ ស្វាមីដែលចង់បានភាពស្និទ្ធស្នាលជាមួយភរិយារបស់គាត់តាមពិតចាប់ផ្ដើមដកខ្លួនចេញពីនាង។ គាត់ដកខ្លួនដោយសង្ឃឹមថាការនេះនឹងធ្វើឲ្យនាងកាន់តែជិតស្និទ្ធ  ប៉ុន្តែតាមពិតវាផ្ទុយពីនេះ។ គ្រាប់ពូជអវិជ្ជមាននៃការដកខ្លួនមិនអាចបង្កើតផលវិជ្ជមាននៃភាពស្និទ្ធស្នាលបាននោះទេ។

នៅក្នុងទំនាស់ យើងត្រូវធ្វើផ្ទុយពីអ្វីដែលធម្មជាតិរបស់យើងចង់បាន។ យើងប្រហែលជាមានបំណងចិត្តចង់បញ្ចេញសំលេងឬក៏ធ្វើឲ្យអ្នកដទៃឈឺចាប់ ប៉ុន្តែគ្រាប់ពូជទាំងនេះនឹងបង្កើតតែផលអវិជ្ជមាននិងបំផ្លាញសក្ដានុពលនៅក្នុងអាពាហ៍ពិពាហ៍។ ដើម្បីដោះស្រាយទំនាស់យើងត្រូវសាបព្រោះគ្រាប់ពូជដែលត្រឹមត្រូវ។

ស្រដៀងគ្នាដែរ  សូមពិចារណាពីអ្វីដែលសាវ័កប៉ុលបានបង្រៀនអំពីរបៀបដែលយើងគួរឆ្លើយតបទៅនឹងសត្រូវ។ គាត់បាននិយាយថា៖

*ឱពួកស្ងួនភ្ងាអើយ កុំឲ្យសងសឹកឡើយ ចូរថយចេញពីសេចក្ដីកំហឹងទៅ ដ្បិតមានសេចក្ដីចែងទុកមកថា «ព្រះអម្ចាស់ ទ្រង់មានបន្ទូលថា ការសងសឹក នោះស្រេចនឹងអញ អញនឹងសងដល់គេ»*

*ដូច្នេះ បើសិនណាជាខ្មាំងសត្រូវអ្នកឃ្លាន នោះចូរឲ្យគេបរិភោគចុះ បើគេស្រេក ចូរឲ្យផឹកទៅ បើប្រព្រឹត្ត ដូច្នោះ នោះដូចជាអ្នកបានប្រមូលរងើកភ្លើង ដាក់លើក្បាលគេវិញ*
*កុំឲ្យសេចក្ដីអាក្រក់ឈ្នះអ្នកឡើយ ត្រូវឲ្យអ្នកឈ្នះសេចក្ដីអាក្រក់ ដោយសារសេចក្ដីល្អវិញ ( រ៉ូម ១២: ១៩-២១)។*

សាវ័កប៉ុលបានបង្រៀនក្នុងការឆ្លើយតបនឹងខ្មាំងសត្រូវ យើងត្រូវតែយកឈ្នះអំពើអាក្រក់ដោយសេចក្ដីល្អ។ ជំនួសឲ្យការឆ្លើយតបដោយកំហឹង ឬការសងសឹក យើងគួរតែសាបព្រោះសេចក្ដីសប្បុរស និងចិត្តសប្បុរសវិញ។ ប្រសិនបើគាត់ឃ្លានសូមផ្ដល់អាហារដល់គាត់។ ប្រសិនបើគាត់ស្រេកចូរឲ្យគាត់ផឹកទៅ។ ជំនួសឲ្យការយកឈ្នះអំពើអាក្រក់ យើងត្រូវតែយកឈ្នះអំពើអាក្រក់ដោយការសាបព្រោះអំពើល្អជានិច្ច។

តើព្រោះគ្រាប់ពូជល្អអ្វីខ្លះដែលយើងអាចសាបព្រោះនៅពេលយើងកំពុងមានទំនាស់? វាប្រហែលអាចជាគ្រាប់ពូជល្អនៃត្រចៀកដែលស្ដាប់។ វាអាចជាគ្រាប់ពូជនៃការបញ្ជាក់។វាអាចជាគ្រាប់ពូជនៃការបម្រើ។ ពិតប្រាកដណាស់ វាត្រូវតែជាគ្រាប់ពូជនៃសេចក្ដីស្រឡាញ់ដោយគ្មានលក្ខខណ្ឌ។ នៅក្នុងទំនាស់យើងត្រូវតែសាបព្រោះគ្រាប់ពូជល្អៗ ដើម្បីទទួលបានផលល្អ។

ជាមួយការនិយាយបែបនោះ យើងត្រូវតែចងចាំជានិច្ចថា ការដោះស្រាយទំនាស់ គឺពិតជាដូចជាការធ្វើកសិកម្មចឹងដែរ។ ពេលខ្លះវាអាចចំណាយពេលច្រើនខែឬច្រើនឆ្នាំ ដើម្បីទទួលបានផលដែលយើងចង់បាន។ មនុស្សជាច្រើនបាក់ទឹកចិត្តកំឡុងពេលរង់ចាំដៃគូរបស់ពួកគេផ្លាស់ប្ដូរឬ ដើម្បីឲ្យទំនាស់ត្រូវបានដោះស្រាយ។ ជាធម្មតានៅក្នុងការធ្លាក់ទឹកចិត្តបែបនោះ មនុស្សចាប់ផ្ដើមសាបព្រោះគ្រាប់ពូជអវិជ្ជមានដែលរារាំងដល់ការប្រមូលផលដែលពួកគេស្វែងរក។ ខគម្ពីរដែលស័ក្ដិសមនិយាយឡើងវិញកំឡុងពេលកំពុងពិចារណាអំពីការដោះស្រាយទំនាស់គឺ *«កុំឲ្យយើងណាយចិត្តនឹងធ្វើការល្អឡើយ ដ្បិតបើមិនរសាយចិត្តទេ នោះដល់កំណត់យើងនឹងច្រូតបានហើយ»* (កាឡាទី ៦: ៩) ។ យើងមិនត្រឹមតែត្រូវសាបព្រោះគ្រាប់ពូជល្អប៉ុណ្ណោះទេ តែយើងត្រូវតែធ្វើវាដោយស្មោះត្រង់រហូតដល់ពេលព្រះបានប្រមូលផល។ យើងដាំនិងស្រោចទឹក ប៉ុន្តែមានតែព្រះជាម្ចាស់ទេដែលធ្វើឲ្យគ្រាប់ពូជដុះឡើងតាមពេលវេលារបស់ទ្រង់ (១ កូរិនថូស ៣: ៦-៧) ។

តើពូជអវិជ្ជមានអ្វីខ្លះដែលអ្នកមានចេតនាសាបព្រួសនៅពេលមានទំនាស់? តើព្រះជាម្ចាស់ត្រាស់ហៅអ្នកឲ្យសាបព្រោះគ្រាប់ពូជវិជ្ជមាន ដើម្បីច្រូតផលវិជ្ជមានដោយរបៀបណា?

## នៅក្នុងទំនាស់ យើងត្រូវតែនិយាយទៅកាន់ស្វាមីឬភរិយារបស់យើងមុននឹងនិយាយទៅកាន់អ្នកដទៃ

គោលការណ៍សំខាន់មួយទៀតដែលត្រូវអនុវត្តន៍នៅក្នុងទំនាស់ គឺនិយាយជាមួយប្ដីឬប្រពន្ធរបស់យើងជាមុនសិនមុនពេលទៅនិយាយជាមួយអ្នកណាម្នាក់។ នេះគឺជាគោលការណ៍មួយដែលព្រះគ្រីស្ទបានបង្រៀនអំពីការដោះស្រាយអំពើបាបទូទៅ។ នៅក្នុងគម្ពីរម៉ាថាយ១៨:១៥ ទ្រង់បានមានបន្ទូលថា *«បើបងប្អូនធ្វើបាបនឹងអ្នក នោះឲ្យទៅបន្ទោសគាត់ ក្នុងកាលដែលមានតែអ្នកហើយនឹងគាត់ បើគាត់*

*ស្តាប់អ្នក នោះអ្នកនឹងបានបងប្អូននោះមកវិញ"។*

ការនេះមានសារៈសំខាន់សម្រាប់ហេតុផលជាច្រើន។ ទីមួយ វាបង្ហាញពីការគោរពចំពោះដៃគូរបស់យើង។ វាជាការមិនគោរពដែលទៅពិភាក្សាបញ្ហាជាមួយម្តាយរបស់យើង មិត្តភក្តិរបស់យើងឬនរណាម្នាក់ផ្សេងទៀតដោយមិនបានពិភាក្សាជាមួយប្តីឬប្រពន្ធរបស់យើងជាមុនសិន។ ប្រសិនបើប្តីប្រពន្ធរបស់យើងរកឃើញឬដឹង វាពិតជាអាចបង្កឲ្យមានទំនាស់កាន់តែខ្លាំង។ ទីពីរ រឿងនីមួយៗមានពីរភាគី ហើយអ្នកណាដែលនៅជិតយើង (ដូចជាគ្រួសារហើយនិងមិត្តភក្តិ) ប្រហែលជាមិនមានសមត្ថភាពផ្តល់ឲ្យយើងនូវដំបូន្មានមិនលំអៀងឡើយ។ សូម្បីតែសម្រាប់ខ្លួនខ្ញុំផ្ទាល់ ក្នុងនាមជាគ្រូគង្វាលប្រឹក្សាយោបល់ ខ្ញុំត្រូវតែខិតខំជាខ្លាំង ដើម្បីកុំឲ្យលោតទៅរកការសន្និដ្ឋានបញ្ចប់បន្ទាប់ពីឮតែផ្នែកម្ខាងនៃសាច់រឿង។ នេះមិនមែនមានន័យថា យើងមិនគួរនិយាយជាមួយអ្នកដែលនៅក្បែរយើងនោះទេ យើងគួរនិយាយ តែបន្ទាប់ពីព្យាយាមដោះស្រាយបញ្ហាជាមួយប្តីឬប្រពន្ធរបស់យើងជាមុនសិន។ ហើយនៅពេលយើងនិយាយជាមួយអ្នកដទៃ យើងគួរតែគោរពនិងផ្តល់កិត្តិយសដល់ប្តីឬប្រពន្ធរបស់យើង។

ព្រះគ្រីស្ទបានបង្រៀនថា នៅពេលនរណាម្នាក់ធ្វើបាបទាស់នឹងយើងយើងគួរតែចូលទៅរកបុគ្គលនោះជាមុនសិន (ម៉ាថាយ ១៨:១៥) ។ គូស្វាមីភរិយាជាច្រើនបង្កើនជម្លោះរបស់ពួកគេដោយការនាំអ្នកដទៃចូលរួមដែរ ដោយមិនស្វែងរកដំណោះស្រាយវាជាមួយប្តីឬប្រពន្ធរបស់ពួកគេជាមុនសិន។

**នៅក្នុងទំនាស់ យើងត្រូវតែស្វែងរកអ្នកប្រឹក្សាដែលឈ្លាសវៃ**

ទោះបីជាចំណុចនេះ វាហាក់បីដូចជាផ្ទុយទៅនឹងចំណុចមុនក៏ដោយគង់តែវាមិនដូច្នោះដែរ។ ព្រះគ្រីស្ទបានបង្រៀនថា យើងគួរតែប្រឈមមុខនឹងម្នាក់ដែលធ្វើបាបមួយទល់មួយ ហើយប្រសិនបើពួកគេមិនឆ្លើយតប បន្ទាប់មកអញ្ជើញអ្នកផ្សេងទៀតឲ្យចូលរួមក្នុងដំណើរការនេះរួមទាំងក្រុមជំនុំផងដែរ។ ម៉ាថាយ ១៨: ១៦-១៧ និយាយថា៖

*១៦ តែបើគាត់មិនព្រមស្តាប់ទេ នោះត្រូវយកមនុស្សម្នាក់ឬ២នាក់ទៅជាមួយ ដើម្បីនឹងបញ្ជាក់គ្រប់ទាំងពាក្យ ដោយសារស្មរបន្ទាល់២ឬ៣នាក់ ១៧ បើគាត់មិនព្រមស្តាប់អ្នកទាំងនោះទេ នោះត្រូវតែប្រាប់ដល់ពួកជំនុំ ហើយបើមិនព្រមស្តាប់ពួកជំនុំទៀត នោះត្រូវតែរាប់គាត់ទុកជាអ្នកក្រៅសាសន៍ ឬជាអ្នកយកពន្ធវិញ។*

ទោះបីជាការនេះ ត្រូវបានគេនិយាយដំបូងអំពីរឿងបងប្អូនប្រុសដែលបានប្រព្រឹត្តអំពើបាបក៏ដោយ វាពិតជាអាចអនុវត្តចំពោះអំពើបាប ឬទំនាស់នៅក្នុងអាពាហ៍ពិពាហ៍។ ព្រះបានបង្កើតយើងជាផ្នែកមួយនៃរូបកាយរបស់គ្រីស្ទដែលរួមបញ្ចូលអាពាហ៍ពិពាហ៍របស់យើងដែរ។ នៅពេលដែលរូបកាយធម្មជាតិឈឺ វាច្រើនតែធ្វើឲ្យក្តៅខ្លួន។ នៅក្នុងគ្រុនក្តៅ រូបកាយគ្រាន់តែជ្រើសរើសខ្លួនវាដើម្បីនាំទៅកាន់ការព្យាបាល។ នៅក្នុងរបៀបដូចគ្នានេះដែរ អាពាហ៍ពិពាហ៍គ្រីស្ទបរិស័ទត្រូវការជំនួយពីរូបកាយ ដើម្បីមានសុខភាពល្អ។ អាពាហ៍ពិពាហ៍គួរតែដំណើរការជាផ្នែកមួយនៃរូបកាយរបស់ព្រះគ្រីស្ទ ប៉ុន្តែនៅពេលមានការលំបាកពួកគេត្រូវការជំនួយពីរូបកាយផងដែរ។

សម្រាប់មនុស្សជាច្រើន នេះគឺជាវប្បធម៌របស់ពួកគេទៅហើយ។ នៅពេលមានទំនាស់ធ្ងន់ធ្ងរ គូស្វាមីភរិយាជាច្រើនស្ទាក់ស្ទើរក្នុងការអញ្ជើញអ្នកណាម្នាក់ចូលមក ដើម្បីជួយដល់អាពាហ៍ពិពាហ៍របស់ពួកគេ។ អំនួតរារាំងពួកគេពីការបង្ហាញខ្លួនឯងនិងទទួលបានជំនួយដែលពួកគេត្រូវការ។ នេះគឺពិតជាលទ្ធផលមួយទៀតនៃការធ្លាក់ចុះ។ នៅពេលដែលអ័ដាមនិងអេវ៉ាបានបរិភោគផ្លែឈើដែលត្រូវបានហាមឃាត់នោះ ពួកគេមើលគ្នាទៅវិញទៅមកឃើញភាពអាក្រាតរបស់ពួកគេ ហើយលាក់ខ្លួន។ បន្ទាប់មកពួកគេដាក់ស្លឹកល្វាបាំងកាយ។ នៅក្នុងការធ្លាក់ចុះមនុស្សបានបាត់បង់តម្លាភាពដែលបានគ្រោងទុក។ យើងលាក់ខ្លួនពីគ្នាទៅវិញទៅមក យើងពាក់ស្នាមញញឹមក្លែងក្លាយសូម្បីតែមានរឿងអាក្រក់ក៏ដោយ។ យើងលាក់ខ្លួននៅពីក្រោយសម្លៀកបំពាក់របស់យើង ផ្ទះរបស់យើង ការងារនិងចំណង់ចំណូលចិត្តរបស់យើង។ យើងខ្លាចស្លាប់ដែលមនុស្សស្គាល់យើង គឺអសន្តិសុខនិងបញ្ហារបស់យើង។ យើងថែមទាំងលាក់ខ្លួនពីព្រះដូចជាអ័ដាម ហើយនិងអេវ៉ាធ្វើដែរ។

ទោះជាយ៉ាងណាក៏ដោយ ដើម្បីធ្វើឲ្យអាពាហ៍ពិពាហ៍មានផាសុខភាពដែលព្រះមានន័យសម្រាប់យើង យើងត្រូវមានឆន្ទៈដើម្បីបង្ហាញខ្លួននិងស្វែងរកជំនួយ។ នៅក្នុងគម្ពីរម៉ាថាយជំពូក១៨ ព្រះគ្រីស្ទបានមានបន្ទូលថា ប្រសិនបើយើងចូលទៅជិតអ្នកដែលធ្វើបាបមិនមានប្រសិទ្ធិភាព យើងគួរតែនាំមនុស្សម្នាក់ពីរនាក់ទៀតឲ្យទទួលខុសត្រូវ។ បើជួយមិនបាន អញ្ជើញក្រុមជំនុំ។ ហើយបើសិនមិនអាចជួយបានទេ ក្រុមជំនុំគួរដាក់វិន័យដល់ដៃគូដែលធ្វើខុសដោយសេចក្តីស្រឡាញ់។ ការនេះគឺពិបាក ប៉ុន្តែប្រសិនបើយើងជាអ្នកដើរតាមព្រះគ្រីស្ទ យើងត្រូវតែជឿជាក់ថា ទ្រង់ស្គាល់យើងយ៉ាងច្បាស់បំផុត។ ព្រះជាម្ចាស់ចង់ប្រើមនុស្សរបស់ទ្រង់ផ្សេងទៀតឲ្យចូលទៅនិយាយ ឬដោះស្រាយនៅក្នុងអាពាហ៍ពិពាហ៍របស់យើង ហើយសម្លៀងវាដូចជាដែកដែលមុតអញ្ចឹង (សុភាសិត ២៧:១៧)។

តើអ្នកនឹងអញ្ជើញអ្នកណាឲ្យជួយដល់អាពាហ៍ពិពាហ៍របស់អ្នក? ពួកគេគួរតែជាមនុស្សមានប្រាជ្ញាដែលអាចយល់ពីអ្នកហើយជាម្នាក់ដែលកំពុងដើរជាមួយព្រះគ្រីស្ទ ជាដៃគូដែលរៀបការរួចហើយ។ ស្តេចសាឡូម៉ូនបានមានប្រសាសន៍ថា៖ *«ទីណាដែលឥតមានអ្នកប្រាជ្ញនាំមុខ នោះប្រជាជនរមែងដួលទៅ តែបើមានអ្នកប្រឹក្សាជាច្រើន នោះមានសេចក្តីសុខវិញ»* (សុភាសិត ១១:១៤) ។

គ្រប់ប្រធានាធិបតីឬស្តេចជ្រើសរើសគណៈរដ្ឋមន្ត្រីដែលមានទីប្រឹក្សាជាច្រើន។ គណៈរដ្ឋមន្ត្រីផ្តល់យោបល់ដល់ប្រធានាធិបតីអំពីគោលនយោបាយការណ៍បរទេស កំណែទម្រង់ការអប់រំ ការថែរក្សាសុខភាពជាដើម ហើយអ្នកប្រឹក្សាជាច្រើនជួយនាំឲ្យមានជ័យជំនះ។ ក្នុងរបៀបដូចគ្នានេះដែរ អាពាហ៍ពិពាហ៍ត្រូវការអ្នកប្រឹក្សាជាច្រើនជាពិសេសនៅពេលមានទំនាស់។ ពិតមែនហើយប្តីប្រពន្ធគួរតែព្យាយាមដោះស្រាយបញ្ហាជាមួយគ្នាជាមុនសិន ប៉ុន្តែបន្ទាប់ពីនោះពួកគេគួរតែស្វែងរកជំនួយ។ ការនេះគួរតែត្រូវបានពិចារណាសូម្បីតែមុនពេលរៀបការ។ តើអ្នកណានឹងក្លាយជាអ្នកប្រឹក្សាយោបល់ជាច្រើនរបស់អ្នកដែលធ្វើឲ្យមានភាពជោគជ័យ? វាអាចជាឪពុកម្តាយរបស់អ្នក ប្តីប្រពន្ធដែលមានប្រាជ្ញានៅក្នុងព្រះវិហារ គ្រូគង្វាលរបស់អ្នក ដឹកនាំក្រុមតូចរបស់អ្នកជាដើម។ ការជ្រើសរើសអ្នកប្រឹក្សាយោបល់ដ៏ឈ្លាសវៃទាំងនេះត្រូវការប្រាជ្ញាខ្ពស់ ពីព្រោះអ្នកប្រឹក្សាយោបល់ទាំងអស់មិនត្រូវបានបង្កើតឲ្យស្មើគ្នាទេ។ អ្នកផ្តល់យោបល់ទាំងនេះគួរតែប្រើព្រះគម្ពីរជាចម្បងព្រោះថា បទគម្ពីរគឺគ្រប់គ្រាន់ដើម្បីបណ្តុះ

បណ្ដាលពួកយើងនៅក្នុងភាពសុចរិតទាំងអស់។ ២ធីម៉ូថេ ៣: ១៦-១៧ និយាយថា៖

*១៦ គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្ដាលឲ្យតែងទេ ក៏មានប្រយោជន៍សំរាប់ការបង្រៀន ការរំឭកឲ្យដឹងខ្លួន ការប្រដៅដំរង់ នឹងការបង្ហាត់ខាងឯសេចក្តីសុចរិត ១៧ ដើម្បីឲ្យអ្នកសំណប់របស់ព្រះបានគ្រប់លក្ខណ៍ ហើយមានគ្រប់ទាំងចំណេះសំរាប់នឹងធ្វើការល្អគ្រប់មុខ។*

ព្រះបន្ទូលរបស់ព្រះ គឺមានប្រយោជន៍ក្នុងការបណ្ដុះបណ្ដាលនិងប្រដាប់យើងសម្រាប់រាល់ការល្អ ដែលរួមមានអាពាហ៍ពិពាហ៍ផងដែរ។ អ្នកណាដែលមិនគោរពដល់បទគម្ពីរ នោះនាំឲ្យខ្លួនធ្លាក់ក្នុងគ្រោះថ្នាក់ ព្រមទាំងអាពាហ៍ពិពាហ៍របស់ពួកគេផងដែរ។

ក្នុងការស្វែងរកអ្នកប្រឹក្សាយោបល់ តាមឧត្តមគតិ ប្ដីប្រពន្ធនឹងព្រមព្រៀងជ្រើសរើសយកនរណាដែលគួរទំនាក់ទំនង។ ប៉ុន្តែនៅពេលដែលដៃគូមួយមិនត្រូវការជំនួយ  ដៃគូឯទៀតប្រហែលនៅតែត្រូវស្វែងរកជំនួយក្នុងការគោរពប្រតិបត្តិតាមការបង្រៀនរបស់ព្រះគ្រីស្ទនៅក្នុងកណ្ឌគម្ពីរម៉ាថាយ១៨ ។ នេះជារបៀបមួយដែលព្រះគ្រីស្ទមានគោលបំណងឲ្យក្រុមជំនុំរបស់ទ្រង់ដំណើរការ។ យើងមិនត្រឹមតែពឹងផ្អែកលើព្រះប៉ុណ្ណោះទេ ប៉ុន្តែយើងគួរតែពឹងផ្អែកលើគ្នាទៅវិញទៅមក។ ភ្នែកមិនអាចនិយាយទៅដៃថា «ខ្ញុំមិនត្រូវការអ្នកទេ»(១កូរិនថូស១២:២១)។ ដោយមិនប្រើរូបកាយយើងធ្វើឲ្យខ្លួនយើងខ្សោយខាងឯព្រលឹងវិញ្ញាណ។   គូស្វាមីភរិយាឯករាជ្យអាចចំណាយពេលអាពាហ៍ពិពាហ៍ពេញមួយជីវិតរបស់ពួកគេឈឺចាប់ខាងឯព្រលឹងវិញ្ញាណឬសូម្បីតែធ្ងន់ធ្ងរជាងនេះ    នោះអាពាហ៍ពិពាហ៍ប្រហែលជាអាចបញ្ចប់ដោយការលែងលះ។

តើអ្នកណាជាអ្នកប្រឹក្សាដ៏ឈ្លាសវៃរបស់អ្នកដែលជួយអ្នកឲ្យឈានដល់ជ័យជំនះ? តើអ្នកនិងដៃគូរបស់អ្នកបានពិចារណាសំណួរនេះឬទេ? តើអ្នកសុខចិត្តអនុញ្ញាតឲ្យពួកជំនុំចូលរួមក្នុងអាពាហ៍ពិពាហ៍របស់អ្នកដូចជាព្រះគ្រីស្ទចង់បានដែរឬទេ?

## នៅក្នុងទំនាស់ យើងត្រូវតែស្វែងរកដំណោះស្រាយភ្លាមៗ

គោលការណ៍សំខាន់មួយទៀតដែលត្រូវអនុវត្តនៅក្នុងអាពាហ៍ពិពាហ៍ គឺត្រូវស្វែងរកដំណោះស្រាយឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។ ដៃគូទាំងពីរគួរតែយល់ស្របនឹងគោលការណ៍នេះមុនពេលមានទំនាក់ទំនង។ សាវ័កប៉ុលបាននិយាយនៅក្នុងអេភេសូរ ៤:២៦-២៧៖ *«២៦ ចូរខឹងចុះ តែកុំឲ្យធ្វើបាបឡើយ កុំឲ្យសេចក្ដីកំហឹងរបស់អ្នកនៅដរាបដល់ថ្ងៃលិចឡើយ ២៧ ក៏កុំឲ្យអារក្សមានឱកាសឲ្យសោះ»* ។

សាវ័កប៉ុលនិយាយថា ដើម្បីកម្ចាត់កំហឹងមុនពេលថ្ងៃលិច ពីព្រោះប្រសិនបើយើងមិនធ្វើនោះវានឹងផ្ដល់ឱកាសដល់សាតាំង។ តើនេះមានន័យថាម៉េច? «មានឱកាស» គឺជាពាក្យសង្គ្រាមវិទ្យាសាស្ត្រ។ វាមានន័យថា ការមិនអភ័យទោសហើយនិងកំហឹងនោះ នឹងបើកទ្វារឲ្យសាតាំង ដើម្បីបន្តវាយប្រហារដល់មនុស្សឬទំនាក់ទំនងផងដែរ។

យើងរៀនថែមទៀតអំពីការនេះពីរឿងប្រៀបប្រដូចរបស់អ្នកបម្រើដែលគ្មានមេត្តានៅកណ្ឌគម្ពីរម៉ាថាយ ១៨:២៣-៣៥។ នៅក្នុងរឿងនេះ អ្នកបំរើម្នាក់ជំពាក់ប្រាក់ចៅហ្វាយគាត់យ៉ាងច្រើន

សន្ទឹក ដូច្នេះគាត់បានសុំសេចក្តីមេត្តាករុណា។ ចៅហ្វាយបានអត់ទោសឲ្យគាត់នូវបំណុលទាំងអស់។ ទោះជាយ៉ាងណាក៏ដោយ អ្នកបំរើនេះមានអ្នករួមការងារម្នាក់ដែលជំពាក់បំណុលគាត់តិចជាង។ បាវបម្រើដែលបានជំពាក់បំណុលបានអង្វរសុំសេចក្តីមេត្តាករុណា ប៉ុន្តែអ្នកបំរើដែលត្រូវបានលើកលែងទោសនោះបានបោះគាត់ទៅក្នុងគុកទៅវិញ។ នៅពេលដែលចៅហ្វាយឮដំណឹងនេះលោកបានខឹងជាខ្លាំងណាស់ ហើយបានបោះអ្នកបំរើដែលលោកបានលើកលែងទោសឲ្យទាំងស្រុងនោះចូលទៅក្នុងគុកធ្វើទារុណកម្មដោយឆ្មាំគុក។ សូមស្តាប់នូវអ្វីដែលព្រះគ្រីស្ទបានមានបន្ទូលទៅកាន់ពួកសិស្សរបស់ព្រះអង្គអំពីរឿងប្រៀបប្រដូចនេះថា៖ *«យ៉ាងនោះ បើអ្នករាល់គ្នាមិនអត់ទោសការរំលងរបស់បងប្អូន ដោយស្ម័គ្រពីចិត្តទេ នោះព្រះវរបិតានៃខ្ញុំ ដែលគង់នៅស្ថានសួគ៌ ទ្រង់ក៏នឹងប្រព្រឹត្តនឹងអ្នករាល់គ្នាដូច្នោះដែរ»* (ម៉ាថាយ ១៨:៣៥)។

ព្រះគ្រីស្ទបានមានបន្ទូលទៅកាន់ពួកសិស្សថា ប្រសិនបើពួកគេមិនអភ័យទោសដល់អ្នកដទៃដោយចេញពីចិត្តទេ នោះព្រះជាម្ចាស់នឹងធ្វើដូចគ្នាចំពោះពួកគេដែរ។ តើអ្នកណាជាអ្នកធ្វើទារុណកម្មទាំងនេះ? គ្មានការសង្ស័យអ្វីទេ ពួកគេសំដៅទៅលើសាតាំងនិងបិសាចរបស់វា (១សាំយូអែល១៦:១៤, ១កូរិនថូស៥:៥, ១ធីម៉ូថេ១:២០) ។ នេះគឺជាផលវិបាកសម្រាប់ការខឹងនិងការមិនអភ័យទោសចំពោះអ្នកដទៃ។ ប្រសិនបើព្រះបានអភ័យទោសឲ្យរាល់អំពើបាបយើងទាំងអស់ដែលយើងបានប្រព្រឹត្ត ហើយនឹងប្រព្រឹត្ត តើយើងអាចធ្វើឲ្យមានការចោទប្រកាន់ចំពោះអ្នកដទៃទៀតជាពិសេសដៃគូរបស់យើងបានយ៉ាងដូចម្តេច? នៅពេលដែលយើងជ្រើសរើសកាន់កំហឹងនិងភាពជូរចត់ ព្រះជាម្ចាស់ប្រគល់យើងឲ្យខ្មាំងសត្រូវ ដើម្បីទទួលវិន័យ។

ចំពោះគូស្វាមីភរិយាជាច្រើនដោយសារតែការមិនស្តាប់បង្គាប់របស់ពួកគេទៅកាន់ព្រះក្នុងការកាន់ខ្ជាប់នូវភាពជូរចត់ហើយនិងកំហឹង អាពាហ៍ពិពាហ៍របស់ពួកគេបានក្លាយជាកន្លែងលេងសម្រាប់សត្រូវ។ វាកុហកពួកគេ វាចោទប្រកាន់ពួកគេ វាល្បួងពួកគេឲ្យចេញឆ្ងាយពីអាពាហ៍ពិពាហ៍ ហើយវាក៏អាចនាំមកនូវជំងឺ និងផលវិបាកផ្សេងៗទៀតសម្រាប់ការបះបោររបស់ពួកគេ (លូកា១៣:១១-១៦, យ៉ូប ២: ៤-៧)។

ដើម្បីធ្វើឲ្យស្ថានភាពនេះកាន់តែធ្ងន់ធ្ងរ បទគម្ពីរចែងថា
នៅពេលយើងកំពុងដើរដោយមិនអភ័យទោស ព្រះជាម្ចាស់នឹងមិនអត់ទោសឲ្យយើងទេ (ម៉ាថាយ ៦:១៥) ហើយទ្រង់នឹងមិនស្តាប់ការអធិស្ឋានរបស់យើងដែរ។ ពេត្រុសបានអំពាវនាវឲ្យស្វាមីទាំងឡាយត្រូវចេះគិតដល់ភរិយារបស់ពួកគេ ហើយប្រព្រឹត្តនឹងពួកគេជាមួយការគោរព ដូច្នេះគ្មានអ្វីនឹងរារាំងដល់សេចក្តីអធិស្ឋានរបស់ពួកគេ បានឡើយ(១ពេត្រុស៣:៧)។ អាពាហ៍ពិពាហ៍មួយដែលដៃគូកាន់ភាពជូរចត់និងកំហឹងចំពោះគ្នាទៅវិញទៅមក គឺជាអាពាហ៍ពិពាហ៍មួយដែលការអធិស្ឋានមានអំណាចតិចតួចដែលបើកទ្វារយ៉ាងធំឲ្យសត្រូវវាយប្រហារនិងនាំមកនូវសេចក្តីហិនវិនាសបាន។

នៅពេលមានទំនាស់ យើងត្រូវតែស្វែងរកដំណោះស្រាយភ្លាមៗ។ ពិតណាស់យើងមិនអាចបង្ខំឲ្យនរណាម្នាក់អភ័យទោសឲ្យយើងឬមានបំណងសម្រេចការងារបានទេ។ ទោះជាយ៉ាងណាក៏ដោយ យើងអាចធ្វើបានច្រើនតាមដែលអាចធ្វើទៅរួច ដើម្បីរស់នៅដោយសន្តិភាពជាមួយនឹងនរណាម្នាក់។ រ៉ូម១២:១៨ ចែងថា *«ប្រសិនបើអាចធ្វើទៅរួចដរាបណាវាអាស្រ័យលើអ្នកខ្លួនឯង រស់នៅដោយមេត្រីភាព*

*ជាមួយមនុស្សគ្រប់គ្នា»* ។

តើអ្នកកំពុងចងគំនុំទាស់នឹងដៃគូរបស់អ្នកមែនទេ? តើព្រះជាម្ចាស់ត្រាស់ហៅអ្នកឲ្យស្វែងរកដំណោះស្រាយដោយរបៀបណា?

**នៅក្នុងទំនាស់ យើងត្រូវតែមានបំណងចិត្តក្នុងការលះបង់**

ការចូលទៅក្នុងជីវិតគ្រីស្ទបរិស័ទគឺជាការលះបង់។ យើងដើរតាមព្រះអង្គសង្គ្រោះដែលបានចាកចេញពីស្ថានសួគ៌ ហើយការថ្វាយបង្គំទាំងអស់ត្រូវបានថ្វាយដល់ទ្រង់នៅទីនោះ ដើម្បីមកផែនដីក្នុងនាមជាអ្នកបម្រើ ហើយស្លាប់សម្រាប់អំពើបាបរបស់ពិភពលោក។ អ្នកដើរតាមព្រះគ្រីស្ទដ៏ពិតប្រាកដត្រូវបានស្គាល់តាមរយៈការលះបង់។ ជាការពិត ព្រះគ្រីស្ទបានមានបន្ទូលថា មនុស្សម្នាក់មិនអាចក្លាយជាសិស្សរបស់ទ្រង់បានទេ បើសិនមិនលីឈើឆ្កាងរបស់ទ្រង់រាល់ថ្ងៃ (លូកា ៩:២៣)។ ជីវិតនៃការលះបង់គួរតែបង្ហាញជាពិសេសនៅពេលមានទំនាស់។ សាវ័កប៉ុលបាននិយាយដូច្នេះទៅកាន់ក្រុមជំនុំនៅក្រុងភីលីពដែលកំពុងជួបប្រទះនិងបញ្ហាជាមួយទំនាស់ផ្ទៃក្នុង (ភីលីព៤: ១-៣)៖

*៣ កុំឲ្យធ្វើអ្វី ដោយទាស់ទែងគ្នា ឬដោយសេចក្ដីអំនួតឥតប្រយោជន៍ឡើយ តែចូររាប់អានគេឲ្យលើសជាងខ្លួនដោយចិត្តសុភាពវិញ ៤ កុំឲ្យគ្រប់គ្នាស្វែងរកតែប្រយោជន៍ផ្ទាល់ខ្លួនឡើយ ត្រូវស្វែងរកចំពោះអ្នកដទៃផង ៥ ត្រូវតែមានគំនិតគិតដូចជាព្រះគ្រីស្ទយេស៊ូវវិញ (ភីលីព ២: ៣-៥)*។

នៅក្នុងបរិបទនៃការអំពាវនាវឲ្យមានសាមគ្គីភាព (ភីលីព ២: ១-២) សាវ័កប៉ុលបាននិយាយថាភីលីពគួរតែ «មិនត្រូវធ្វើអ្វីដោយមហិច្ឆតាគិតតែប្រយោជន៍ផ្ទាល់ខ្លួនឡើយ»។ មូលហេតុចម្បងដែលគូស្វាមីភរិយាមានបញ្ហាក្នុងការមិនចុះសម្រុងគ្នា គឺដោយសារតែភាពអាត្មានិយម។ មនុស្សម្នាក់ចង់បាននេះ រីឯម្នាក់ទៀតចង់បានបែបនោះ។ ទោះជាយ៉ាងណា សាវ័កប៉ុលបាននិយាយថា កុំធ្វើអ្វីដោយមហិច្ឆតាអាត្មានិយមនោះឡើយ។ នៅក្នុងទំនាស់មនុស្សម្នាក់ត្រូវសួរថា “តើបំណងប្រាថ្នានេះជាអ្វីដែលព្រះសព្វព្រះហឫទ័យដូចដែលបានបង្ហាញនៅក្នុងព្រះបន្ទូលរបស់ព្រះអង្គ ឬជាចំណូលចិត្តខ្ញុំនេះទេ? ទំនាស់ភាគច្រើន គឺកើតឡើងដោយភាពអាត្មានិយមរបស់ខ្លួនជំនួសឲ្យអ្វីដែលជាការសំខាន់ពិតប្រាកដដូចជាការស្រឡាញ់ដល់ព្រះជាម្ចាស់និងស្រឡាញ់ដល់អ្នកដទៃដែលជាបទបញ្ញត្តិពីរធំបំផុត (ម៉ាថាយ ២២: ៣៦-៤០)។

ជំនួសឲ្យការជំរុញខ្លួនឯង សាវ័កប៉ុលបាននិយាយទៅ «ដោយចិត្តរាបទាប» ចាត់ទុកអ្នកដទៃប្រសើរជាងខ្លួនយើង និងស្វែងរកចំណាប់អារម្មណ៍របស់អ្នកដទៃ។ នៅក្នុងទំនាស់ មនុស្សម្នាក់ត្រូវសួរថា «តើខ្ញុំអាចស្វែងរកភាពប្រសើរជាងរបស់ប្ដីប្រពន្ធរបស់ខ្ញុំ ឬបំណងប្រាថ្នារបស់ខ្ញុំជាងខ្ញុំបានយ៉ាងដូចម្ដេច?» សំខាន់សាវ័កប៉ុលបានហៅក្រុមជំនុំភីលីពឲ្យរស់នៅក្នុងជីវិតនៃការលះបង់ ដើម្បីការរួបរួម (ខ២) ការលះបង់នេះត្រូវបានពង្រឹងថែមទៀតនៅពេលគាត់បាននិយាយថា “អាកប្បកិរិយារបស់អ្នកគួរតែដូចគ្នានឹងព្រះគ្រីស្ទយេស៊ូវដែរ” (ខ ៥) ។ នៅក្នុងអត្ថបទដែលនៅសល់គាត់បានពិពណ៌នាអំពីរបៀបដែលព្រះគ្រីស្ទលះបង់សិទ្ធិជាព្រះរបស់ទ្រង់ មកយករូបភាពជាអ្នកបម្រើព្រមទាំងសុគតនៅលើឈើឆ្កាង និងរបៀបដែលព្រះបានលើកតម្កើងទ្រង់សម្រាប់ការលះបង់របស់ទ្រង់

(ខ ៦-៩) ។ នេះគឺជាគំនិតដែលគួរតែមាននៅក្នុងគ្រីស្តបរិស័ទ ដើម្បីជួយពួកគេឲ្យដើរក្នុងសាមគ្គីភាពជាមួយបងប្អូនប្រុសស្រីរបស់ពួកគេ។ ហើយនេះគឺជាគំនិតដែលគួរតែត្រូវបានគេមើលឃើញនៅក្នុងគ្រប់អាពាហ៍ពិពាហ៍ដែលអាចឲ្យពួកគេដើរក្នុងសាមគ្គីភាពជំនួសឲ្យការមិនចុះសម្រុងគ្នាវិញ (អេភេសូរ ៥:២៥)។

គូស្វាមីភរិយាដែលជាគ្រីស្ទានគួរដោះស្រាយទំនាស់របស់ពួកគេដោយយកចិត្តទុកដាក់ចំពោះសេចក្តីប៉ងប្រាថ្នារបស់ប្តីប្រពន្ធជាជាងបញ្ហាផ្ទាល់ខ្លួន។ ពួកគេគួរតែបន្ទាបខ្លួនដូចជាព្រះគ្រីស្ទបានធ្វើដែរ។ ទ្រង់បានលះបង់ភាពសុខស្រួលរបស់ទ្រង់ និងសិទ្ធិរបស់ទ្រង់ ដើម្បីបម្រើយើង។

តើព្រះជាម្ចាស់ត្រាស់ហៅអ្នកឲ្យលះបង់អ្វីខ្លះ ដើម្បីដោះស្រាយទំនាស់ដែលមានសក្តានុពលនៅក្នុងអាពាហ៍ពិពាហ៍ដោយរបៀបណា? តើទ្រង់កំពុងត្រាស់ហៅអ្នកឲ្យបោះបង់ចោលមិត្តភាពដែលជាឥទ្ធិពលអាក្រក់ ឬបង្កឲ្យមានភាពមិនចុះសម្រុងគ្នាដែរឬទេ? តើទ្រង់កំពុងត្រាស់ហៅអ្នកឲ្យជួយបន្ថែមទៀតនៅជុំវិញផ្ទះ ដើម្បីថែរក្សាកូនៗបន្ថែមទៀត ដើម្បីចាប់ផ្តើមចូលរួមក្នុងអ្វីមួយដែលប្តីប្រពន្ធអ្នកពេញចិត្ត ប៉ុន្តែអ្នកមិនចង់ចំណាយពេលច្រើនជាមួយប្តីឬប្រពន្ធរបស់អ្នកជាជាងធ្វើអ្វីផ្សេងទៀតឬទេ? តើអ្នកអាចបង្ហាញពីការលះបង់របស់ព្រះគ្រីស្ទនៅក្នុងអាពាហ៍ពិពាហ៍របស់អ្នកដោយរបៀបណា? ការលះបង់គឺជាអាថ៌កំបាំងក្នុងការដោះស្រាយទំនាស់ រីឯភាពអាត្មានិយមគឺជាកត្តាជំរុញនៃទំនាស់។

**នៅក្នុងទំនាស់យើងត្រូវតែស្រឡាញ់ប្តីឬប្រពន្ធរបស់យើងយ៉ាងជ្រាវជ្រៅនិងគ្របបាំងអំពើបាបរបស់គ្នា**

ជាចុងក្រោយ នៅពេលមានទំនាស់យើងត្រូវតែស្រឡាញ់ប្តីឬប្រពន្ធរបស់យើងហើយបិទបាំងនូវអំពើបាបរបស់គ្នា។ ១ពេត្រុស ៤:៨ ចែងថា *«សំខាន់បំផុតត្រូវស្រឡាញ់គ្នាទៅវិញទៅមកពីព្រោះសេចក្តីស្រឡាញ់គ្របបាំងអំពើបាបជាច្រើន»*។ នៅក្នុងភាសាក្រិកពាក្យថា «ជ្រាវជ្រៅ» គឺពាក្យអត្ថពលកម្មត្រូវបានប្រើនៃការហាត់ពុតឬទាញសាច់ដុំ។

នេះគឺជារូបភាពមួយ ហើយក៏ជាពាក្យពេចន៍ដ៏សម្បូរបែបនៃសេចក្តីស្រឡាញ់របស់យើងកំឡុងពេលមានទំនាស់។ ក្នុងរបៀបដូចគ្នា សាច់ដុំត្រូវតែពុតនិងលាតសន្ធឹងដើម្បីអភិវឌ្ឍនិងកាន់តែរឹងមាំឡើង ព្រះតែងតែចម្រើនសេចក្តីស្រឡាញ់របស់យើងតាមរយៈទំនាស់ និងការលំបាកជាមួយដៃគូរបស់យើង។ ទោះបីជាការលាតសន្ធឹងនេះឈឺចាប់ក៏ដោយ វាពិតជានាំមកនូវសមត្ថភាពក្នុងការស្រឡាញ់កាន់តែខ្លាំង។ ដូច្នេះគូស្វាមីភរិយាដែលស្រឡាញ់និងបិទបាំងអំពើបាបរបស់គ្នាទៅវិញទៅមក ហើយនៅពេលមានទំនាស់កើតឡើង នោះបានចម្រើនសមត្ថភាពក្នុងការស្រឡាញ់ឲ្យកាន់តែជ្រាវជ្រៅបន្ថែមទៀត។ ប្រាកដណាស់នេះត្រូវតែបានលើកទឹកចិត្តដូចជានៅពេលដែលយើងលាតសន្ធឹងសេក្តីស្រឡាញ់របស់យើង ដើម្បីគ្របបាំងអំពើបាបរបស់ប្តីឬប្រពន្ធរបស់យើងកំឡុងពេលមានទំនាស់អញ្ចឹងដែរ។

ការលាតសន្ធឹងសេក្តីស្រឡាញ់របស់យើងច្រើនតែមានន័យថា ការមើលរំលងនិងបំភ្លេចភាពបរាជ័យរបស់ប្តីឬប្រពន្ធរបស់យើង។ ១កូរិនថូស១៣:៥ ចែងថា សេចក្តីស្រឡាញ់ *«មិនកត់ទុកអ្វីដែលខុសទេ»*។ ព្រះនឹងត្រាស់ហៅយើងមិនឲ្យលើកយកបញ្ហាខ្លះៗចេញមក។ ខណៈពេលដែលអ្នកផ្សេងទៀត ទ្រង់នឹងត្រាស់ហៅយើងឲ្យនិយាយការពិតដោយសេចក្តីស្រឡាញ់ (អេភេសូរ ៤:១៥)

ហើយធ្វើការឆ្ពោះទៅរកដំណោះស្រាយជាពិសេសនៅពេលវាទាក់ទងនឹងអំពើបាប។

តើព្រះជាម្ចាស់ត្រាស់ហៅអ្នកឲ្យស្រឡាញ់ដៃគូរបស់អ្នកយ៉ាងជ្រាវជ្រៅហើយគ្របបាំងអំពើបាបរបស់គ្នា ដើម្បីដោះស្រាយទំនាស់យ៉ាងដូចម្ដេច?

**សរុបសេចក្ដី**

ដោយសារតែអំពើបាបបានក្លាយជាផ្នែកមួយនៃធម្មជាតិរបស់មនុស្សនៅក្នុងការធ្លាក់ចុះ យើងងាយនឹងប៉ះទង្គិច សូម្បីតែមានទំនាស់ជាមួយអ្នកដែលយើងស្រឡាញ់បំផុត។ សម្រាប់ហេតុផលនោះ យើងត្រូវមានប្រាជ្ញានិងត្រៀមលក្ខណៈចំពោះទំនាស់ជាមុន ពីព្រោះវានឹងកើតមានឡើងនៅក្នុងអាពាហ៍ពិពាហ៍រួបរួម។ យើងអាចដោះស្រាយទំនាស់ដោយៈ

១. មានអាកប្បកិរិយាត្រឹមត្រូវៈ ជាការរំពឹងទុកដ៏រីករាយជំនួសឲ្យឥរិយាបទខុស។

២. អភិវឌ្ឍភាពអត់ធ្មត់ឬសេក្ដីទ្រាំទ្រជំនួសឲ្យការបញ្ឈប់រូបកាយឬផ្លូវចិត្ត។

៣. ការសាបព្រោះគ្រាប់ពូជល្អៗ ដើម្បីបង្កើតផលនៃសេចក្ដីសុចរិតនៅក្នុងអាពាហ៍ពិពាហ៍របស់យើង។

៤. និយាយជាមួយប្ដីឬប្រពន្ធរបស់យើងជាមុនសិន មុនពេលនិយាយជាមួយអ្នកដទៃ។

៥.ស្វែងរកអ្នកប្រឹក្សាដែលមានប្រាជ្ញា ដើម្បីជួយយើងក្នុងការដោះស្រាយទំនាស់។

៦.ស្វះស្វែងរកដំណោះស្រាយទំនាស់ភ្លាមៗ ដើម្បីការពារការការបើកទ្វារឲ្យអារក្ស។

៧. លះបង់សិទ្ធិរបស់យើងនិងបំណងប្រាថ្នារបស់យើងសម្រាប់ដៃគូរបស់យើង។

៨. ស្រឡាញ់ប្ដីឬប្រពន្ធរបស់យើងយ៉ាងជ្រាលជ្រៅ ហើយគ្របបាំងអំពើបាបរបស់គ្នា។

**កិច្ចការផ្ទះអំពី--ការដោះស្រាយទំនាស់ក្នុងអាពាហ៍ពិពាហ៍**

ឆ្លើយសំនួរទាំងនេះហើយពិភាក្សាជាមួយគ្នា

១. តើមានអ្វីថ្មីឬចូលមកក្នុងគំនិតអ្នកនៅក្នុងវគ្គនេះ? តើអ្នកត្រូវបានជំរុញឬលើកទឹកចិត្តដោយវិធីណាខ្លះ? តើមានចំណុចឬគំនិតអ្វីដែលអ្នកមិនយល់ស្របឬទេ?

២. គូស្វាមីភរិយាភាគច្រើនតែងតែឈ្លោះប្រកែកគ្នាលើរឿងស្រដៀងៗគ្នា។ ទាំងនេះហៅថា «ហេតុដែលនាំឲ្យមានទំនាស់»។ នេះអាចជាពេលដែលស្ត្រីដើរទិញឥវ៉ាន់ ឯបុរសវិញមើលទូរទស្សន៍ ឬក៏ញ៉ាំបាយហើយអត់លាងចានជាដើម។ ល។ ចូរសរសេរចុះរាល់មេបញ្ហាទាំងអស់ដែលនាំឲ្យមានការឈ្លោះប្រកែកគ្នានៅក្នុងទំនាក់ទំនងរបស់អ្នក។ ហេតុអ្វីបានជាអ្នកគិតថាមេបញ្ហាទាំងនេះជាទូទៅធ្វើឲ្យអ្នកឬដៃគូអ្នកខឹង?

៣. នៅក្នុងវគ្គនេះ យើងបាននិយាយអំពីការមិនសាបព្រោះគ្រាប់ពូជអរិជ្ជមាន។ តើគ្រាប់ពូជអវិជ្ជមានណាដែលអ្នកសាបព្រោះនៅពេលមានជម្លោះ (ឧទាហរណ៍ ការដកខ្លួន ការរិះគន់ ការត្អូញត្អែរ ការសងសឹក ការស្វែងរកការឈ្នះចាញ់ក្នុងការឈ្លោះប្រកែកជាដើម)? តើប្តីឬប្រពន្ធរបស់អ្នកយ៉ាងម៉េចដែរ? តើអ្នកបានឃើញគ្រាប់ពូជអវិជ្ជមានទាំងនេះបង្កើតផលអវិជ្ជមានយ៉ាងដូចម្តេច? តើអ្នកអាចសាបព្រោះគ្រាប់ពូជវិជ្ជមានជាជាង ដើម្បីទទួលផ្លែវិជ្ជមានវិញដោយរបៀបណា?

៤. ស្តេចសាឡូម៉ូនបាននិយាយនៅក្នុងទីប្រឹក្សាជាច្រើននោះមានជ័យជំនះ (សុភាសិត ១១:១៤) ។ តើអ្នកនឹងនិយាយជាមួយដៃគូមួយណាប្រសិនបើអ្នកមានបញ្ហាក្នុងអាពាហ៍ពិពាហ៍? ប្រសិនបើអ្នកជ្រើសរើសដៃគូណែនាំសម្រាប់អាពាហ៍ពិពាហ៍របស់អ្នក (នរណាម្នាក់ដើម្បីសួរសំណួរ និយាយអំពីបញ្ហាឬភាពជោគជ័យ  ឬសូម្បីតែជួបគ្នាជាទៀងទាត់) តើអ្នកនឹងជ្រើសរើសអ្នកណា?

៥. តើអ្នកនឹងដោះស្រាយទំនាក់ទំនងជាមួយភេទផ្ទុយគ្នាដោយរបៀបណា? តើមានអ្វីជាក់លាក់ដែលអ្នកនឹងធ្វើ ដើម្បីការពារអាពាហ៍ពិពាហ៍របស់អ្នកពីការបើកចំហ?

៦. តើអ្នកមានគំនិតផ្សេងឬកង្វល់អ្វីអំពីបញ្ហានេះឬទេ?

៧. បន្ទាប់ពីបញ្ចប់វគ្គនេះតើអ្នកមានអារម្មណ៍ថា ព្រះកំពុងត្រាស់ហៅអ្នកឲ្យអធិស្ឋានសម្រាប់

អាពាហ៍ពិពាហ៍របស់អ្នកយ៉ាងដូចម្ដេច? សូមចំណាយពេលខ្លះអធិស្ឋាន។

# មូលដ្ឋានគ្រឹះទី៦៖ ភាពស្មោះត្រង់ផ្នែកហិរញ្ញវត្ថុ នៅក្នុងអាពាហ៍ពិពាហ៍

តើគូស្វាមីភរិយាអាចអនុវត្តភាពស្មោះត្រង់ខាងឯហិរញ្ញវត្ថុក្នុងអាពាហ៍ពិពាហ៍បានដោយរបៀបណា? គូស្វាមីភរិយាគ្រិស្ទបរិស័ទជាច្រើនថ្វាយដង្វាយមួយភាគដប់របស់ពួកគេដល់ព្រះជាម្ចាស់ ប៉ុន្តែគិតថាអ្វីដែលនៅសល់ជារបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ នេះគឺជាការប្រើប្រាស់ហិរញ្ញវត្ថុមិនត្រឹមត្រូវទេ។ ទំនុកដំកើង ២៤: ១ ចែងថា *«ផែនដី នឹងសារពើនៅផែនដី ជារបស់ផងព្រះយេហូវ៉ា ព្រមទាំងលោកីយ នឹងបណ្តាអ្នកដែលនៅលោកីយផង»*។ ភាពចាំបាច់នៅក្នុងភាពស្មោះត្រង់ខាងឯផ្នែកហិរញ្ញវត្ថុគឺទទួលស្គាល់ថា ព្រះជាម្ចាស់ទ្រង់ជាម្ចាស់នៃគ្រប់របស់ទាំងអស់ ហើយយើងគ្រាន់តែជាអ្នកបម្រើដែលថ្ងៃណាមួយនឹងប្រគល់គណនីទៅកាន់ទ្រង់វិញ (លូកា១៩:១៥, ម៉ាថាយ ២៥: ១៩-២០)។ នៅពេលព្រះបានបង្កើតផែនដី បំណងរបស់ទ្រង់គឺចង់ឲ្យមនុស្សជាតិគ្រប់គ្រងលើផែនដីដោយនៅក្រោមការគ្រប់គ្រងរបស់ទ្រង់។ ការប្រើប្រាស់ធនធានរបស់ទ្រង់ដូចជារបស់យើងតែម្នាក់ឯងនឹងនាំឲ្យមានភាពមិនស្មោះត្រង់។ ដោយសារតែផ្នត់គំនិតដ៏លេចធ្លោនេះនៅក្នុងចំណោមគូស្វាមីភរិយា នោះមានការប្រើហិរញ្ញវត្ថុមិនត្រឹមត្រូវជាប្រចាំដែលនាំឲ្យមានភាពតានតឹងផ្នែកហិរញ្ញវត្ថុ។

ភាពតានតឹងផ្នែកហិរញ្ញវត្ថុ គឺជាហេតុផលមួយក្នុងចំណោមហេតុផលកំពូលសម្រាប់ទំនាស់នៅក្នុងអាពាហ៍ពិពាហ៍និងការលែងលះ។ នេះមិនមែនជាព្រះហឫទ័យរបស់ព្រះនោះទេ។ បំណងព្រះហឫទ័យរបស់ព្រះសម្រាប់ហិរញ្ញវត្ថុ គឺជាប្រភពនៃព្រះពរនិងជាទ្វារសម្រាប់ព្រះគុណដ៏ហូរហៀររបស់ទ្រង់នៅក្នុងអាពាហ៍ពិពាហ៍នីមួយៗ (១ កូរិនថូស ៩:៦-១១)។ ប៉ុន្តែដើម្បីស្មោះត្រង់ហើយទទួលបានព្រះពរពីព្រះអម្ចាស់ គូស្វាមីភរិយាត្រូវតែយល់ហើយធ្វើតាមផែនការរបស់ព្រះសម្រាប់ហិរញ្ញវត្ថុរបស់ពួកគេ។ តើគូស្វាមីភរិយាអាចអនុវត្តភាពស្មោះត្រង់ខាងហិរញ្ញវត្ថុក្នុងអាពាហ៍ពិពាហ៍បានដោយរបៀបណា?

### ដើម្បីឲ្យក្លាយជាស្មោះត្រង់ខាងឯផ្នែកហិរញ្ញវត្ថុ គូស្វាមីភរិយាត្រូវប្រើប្រាស់ទ្រព្យសម្បត្តិរបស់ពួកគេ ដើម្បីនាំព្រលឹងថ្វាយដល់ព្រះគ្រីស្ទ

នៅក្នុងលូកា ១៦ ព្រះគ្រីស្ទបានបង្រៀនរឿងប្រៀបប្រដូចមួយដល់ពួកសាវ័ករបស់ទ្រង់អំពីទ្រព្យសម្បត្តិ ដើម្បីជួយពួកគេឲ្យស្មោះត្រង់នឹងវា។ យើងនឹងពិចារណាពីរឿងប្រៀបប្រដូចនេះហើយអនុវត្តវាចំពោះគូស្វាមីភរិយា។ នេះជាអ្វីដែលព្រះគ្រីស្ទបានមានបន្ទូលនៅក្នុងលូកា ១៦: ១-១៣៖

*«១ ទ្រង់ក៏មានបន្ទូលទៅពួកសិស្សថា មានសេដ្ឋីម្នាក់ ដែលគេមកប្តឹងលោក ពីអ្នកត្រួតត្រាលើរបស់ទ្រព្យលោកថា គាត់ចាយបង្ហិនបង្ហោចទ្រព្យសម្បត្តិលោកជាច្រើន ២ លោកក៏ហៅអ្នកនោះមកសួរថា តើរឿងអ្វីដែលអញឮនិយាយពីឯង ចូររៀបរាប់ប្រាប់ពីការឯងត្រួតត្រានោះមកមើល ពីព្រោះឯងនៅត្រួតត្រាការទៀតពុំបានទេ ៣ អ្នកជំនួតនោះគិតក្នុងចិត្តថា តើអញនឹងធ្វើអ្វី ដ្បិតចៅហ្វាយអញគិតដកការ*

*ត្រួតត្រានេះពីអញចេញហើយ អញទៅកាប់ដីមិនកើតទេ នឹងទៅសូមទាន ក៏ខ្មាសគេដែរ ៤ អញដឹងការ*
*ដែលអញនឹងធ្វើហើយ ដើម្បីបើកាលណាលោកបណ្តេញអញ ពីការត្រួតត្រាចេញ នោះនឹងមានគេទទួល*
*អញ ឲ្យទៅនៅផ្ទះគេមិនខាន ៥ គាត់ក៏ហៅពួកកូនបំណុលរបស់ចៅហ្វាយគាត់មក គាត់សួរអ្នកដែល*
*មកមុនថា តើអ្នកជំពាក់ចៅហ្វាយខ្ញុំប៉ុន្មាន ៦ អ្នកនោះឆ្លើយថា ជំពាក់ប្រេង១រយប៉ោត រួចគាត់ប្រាប់អ្នក*
*នោះថា ចូរយកសំបុត្រអ្នក ទៅអង្គុយសរសេរដាក់៥០វិញ ជាប្រញាប់ទៅ ៧ រួចគាត់សួរទៅម្នាក់ទៀត*
*ថា ឯអ្នក តើជំពាក់ប៉ុន្មាន អ្នកនោះឆ្លើយថា ជំពាក់ស្រូវ១រយហាប គាត់ប្រាប់អ្នកនោះថា ចូរយកសំបុត្រ*
*អ្នក ទៅសរសេរដាក់៨០វិញទៅ ៨ ចៅហ្វាយក៏សរសើរអ្នកត្រួតត្រាទុច្ចរិតនោះ ពីព្រោះគាត់បានប្រព្រឹត្ត*
*ដោយឆ្លៀវឆ្លាត ដ្បិតមនុស្សរបស់ផងលោកីយនេះ គេមានប្រាជ្ញាចំពោះជំនាន់គេ ជាជាងមនុស្សរបស់ផង*
*ពន្លឺទៅទៀត ៩ ខ្ញុំក៏ប្រាប់អ្នករាល់គ្នាថា ចូរប្រើទ្រព្យសម្បត្តិលោកីយនេះ ឲ្យបានមិត្រសំឡាញ់ដល់ខ្លួន*
*ដើម្បីកាលណាអ្នករាល់គ្នាខាននៅ នោះនឹងមានគេទទួលអ្នករាល់គ្នា ឲ្យនៅក្នុងទីលំនៅដ៏ស្ថិតស្ថេរអស់*
*កល្បជានិច្ចវិញ ១០ អ្នកណាដែលស្មោះត្រង់ក្នុងការតូចបំផុតនោះក៏ឈ្មោះថា ស្មោះត្រង់ក្នុងការធំ ហើយ*
*អ្នកណាដែលទុច្ចរិតក្នុងការតូចបំផុត នោះក៏ឈ្មោះថាទុច្ចរិតក្នុងការដ៏ធំដែរ ១១ ដូច្នេះ បើអ្នករាល់គ្នាមិន*
*ស្មោះត្រង់ ចំពោះទ្រព្យសម្បត្តិរបស់លោកីយទេ តើអ្នកណាហ៊ានផ្ញើសម្បត្តិដ៏ពិតទុកនឹងអ្នករាល់គ្នាបាន*
*១២ ហើយបើអ្នករាល់គ្នាមិនស្មោះត្រង់នឹងរបស់គេទេ តើអ្នកណានឹងហ៊ានឲ្យរបស់អ្វីដាច់ជារបស់ផងអ្នក*
*បាន ១៣ គ្មានបាវណាដែលបំរើចៅហ្វាយ២បានទេ ពីព្រោះបាវនោះនឹងស្អប់១ ស្រឡាញ់១ ឬនឹងកាន់*
*ខាង១ ហើយមើលងាយ១ ដូច្នេះ អ្នករាល់គ្នាក៏បំរើព្រះផង ទ្រព្យសម្បត្តិផងពុំបានដែរ។*

ព្រះគ្រីស្ទបានចែកចាយរឿងរបស់អ្នកបម្រើមិនស្មោះត្រង់ម្នាក់ដែលបានប្រើប្រាស់ប្រាក់របស់ចៅហ្វាយខុស ដូច្នេះហើយគេនឹងត្រូវគេបណ្តេញចេញ។ ដោយសារតែរឿងនេះអ្នកបម្រើបានរៀបចំផែនការ ដើម្បីផ្គត់ផ្គង់ខ្លួនឯងនៅពេលគាត់បាត់បង់ការងារ។ អ្នកបម្រើបានទៅជិតម្ចាស់បំណុលរបស់ចៅហ្វាយគាត់ ហើយឲ្យពួកគេនូវការបញ្ចុះតម្លៃដោយសង្ឃឹមថាពួកគេនឹងផ្គត់ផ្គង់ឲ្យគាត់នៅពេលគាត់បាត់បង់ការងារ។ វាស្ទើរតែលេចឡើងដូចជាព្រះគ្រីស្ទ គឺកំពុងតែសរសើរភាពមិនស្មោះត្រង់របស់អ្នកបម្រើនេះ ប៉ុន្តែគាត់មិនមែនទេ។ ទ្រង់សរសើរ «ភាពឆ្លាតវៃ» របស់គាត់។ អ្នកបម្រើនេះដឹងថាអនាគតរបស់គាត់មិនប្រាកដប្រជា ហើយបានធ្វើដោយប្រុងប្រយ័ត្ន ដើម្បីរៀបចំសម្រាប់វា។

ព្រះគ្រីស្ទប្រៀបធៀបការនេះជាមួយការរៀបចំរបស់គ្រីស្ទបរិស័ទសម្រាប់ភាពអស់កល្បជានិច្ច។ សំខាន់ទ្រង់បានមានព្រះបន្ទូលក្នុងរបៀបដូចគ្នាដែលពិភពលោកស្វែងរកការផ្គត់ផ្គង់សម្រាប់អនាគតរបស់ពួកគេនៅលើផែនដីនេះ «តាមរយៈការរក្សាទុកប្រាក់ចូលនិវត្តន៍   ការធ្វើជំនួញជាដើម»។ គ្រីស្ទបរិស័ទត្រូវតែប្រើប្រាស់ទ្រព្យសម្បត្តិនៅលោកីយ៍នេះ ដើម្បីទទួលបានមិត្តភក្តិដែលនឹងស្វាគមន៍ពួកគេចូលទៅក្នុងទីលំនៅដ៏អស់កល្បជានិច្ច(ខ ៩) ។

តើទីលំនៅអស់កល្បជានិច្ចមានន័យដូចម្តេច? ជាក់ស្តែងទ្រង់កំពុងសំដៅទៅលើឋានសួគ៌។ ព្រះគ្រីស្ទបានយល់ថា ដើម្បីឲ្យមនុស្សទទួលបានដំណឹងល្អគឺត្រូវការប្រាក់។ សម្រាប់ឲ្យព្រះវិហារដំណើរការបាននិងទៅដល់មនុស្សនៅជិតខាងរបស់ពួកគេ វាត្រូវការប្រាក់។ ដើម្បីបញ្ជូនបេសកជនទៅផ្សព្វផ្សាយដំណឹងល្អនៅឯប្រទេសក្រៅ វាត្រូវចំណាយប្រាក់។ ព័ន្ធកិច្ចដំណើរការបាន គឺត្រូវចំណាយប្រាក់។ ជាក់ស្តែង  ព្រះគម្ពីរបង្រៀនដល់អ្នកទាំងឡាយណាដែល “ផ្សាយដំណឹងល្អគួរតែទទួលបានការរស់នៅ

របស់ពួកគេពីដំណឹងល្អ» (១ កូរិនថូស ៩:១៤) មានន័យថា គ្រូបង្រៀនរបស់យើង គ្រូគង្វាលរបស់យើង និង បេសកជនរបស់យើងគួរតែត្រូវបានសំណងសម្រាប់ការងាររបស់ពួកគេ។

ប៉ុន្តែមិនត្រឹមតែព្រះគ្រីស្ទបានសង្កត់ធ្ងន់លើតម្រូវការរបស់គ្រីស្ទបរិស័ទក្នុងការផ្តល់ប្រាក់ដើម្បីផ្សាយដំណឹងល្អនោះទេ ទ្រង់ថែមទាំងបានផ្តល់ការយល់ដឹងខាងក្នុងចិត្តដល់អ្នកបម្រើដ៏ស្មោះត្រង់ទៅកាន់ឋានសួគ៌។ គ្រីស្ទបរិស័ទដែលលះបង់ប្រាក់របស់ពួកគេ ដើម្បីធ្វើកិច្ចការនៃដំណឹងល្អនឹងត្រូវបានស្វាគមន៍យ៉ាងកក់ក្តៅនៅកាន់ឋានសួគ៌។ ប្រជាជនមកពីប្រទេសដទៃទៀតនឹងព័ទ្ធជុំវិញពួកគេដោយនិយាយថា «តាមរយៈការគាំទ្ររបស់អ្នកពីព័ន្ធកិច្ចនេះខ្ញុំបានទទួលយកព្រះគ្រីស្ទនិងគ្រួសាររបស់ខ្ញុំផងដែរ អរគុណ» ។ វាហាក់បីដូចជានៅស្ថានសួគ៌មនុស្សនឹងមានចំណេះដឹងជ្រៅជ្រះអំពីអ្វីដែលអ្នកដទៃបានធ្វើសម្រាប់នគរព្រះ (ម៉ាថាយ ៥:១៩, វិវរណៈ ៦:៩) ។ នេះមិនមែនជាការភ្ញាក់ផ្អើលនោះទេ ពីព្រោះអ្នកណាដែលធ្វើអ្វីៗដែលអស្ចារ្យនៅលើផែនដីនេះ គឺត្រូវបានផ្តល់កិត្តិយសស្រដៀងគ្នា។ សព្វថ្ងៃនេះត្រូវបានដាក់ឈ្មោះតាមពួកគេ ផ្លូវថ្នល់ អាគារជាដើម ហើយវាហាក់ដូចជាស្រដៀងគ្នានៅស្ថានសួគ៌ដែរ។ អ្នកណាដែលផ្តល់ដោយចិត្តសប្បុរស ដើម្បីលើកស្ទួយនគរព្រះនឹងត្រូវបានស្វាគមន៍និងផ្តល់កិត្តិយសយ៉ាងខ្លាំង។

នេះគួរតែជាបំណងចិត្តរបស់គ្រប់គូស្វាមីភរិយាគ្រិស្ទបរិស័ទ។ ព្រះគ្រីស្ទបានបង្គាប់ដល់គ្រីស្ទបរិស័ទឲ្យធ្វើជាមិត្តសំឡាញ់ដ៏នៅអស់កល្បដោយប្រើ «ទ្រព្យសម្បត្តិខាងឯលោកីយ៍» (ខ ៩) នេះគឺជាការត្រាស់ហៅដល់គូស្វាមីភរិយានៅក្នុងប្រទេសអភិវឌ្ឍន៍ជាពិសេសអាចទទួលបានផលផ្លែដោយសារតែចំនួនធនធានដែលមានសម្រាប់ពួកគេ។

ជាមួយនឹងការនិយាយបែបនេះ សាវ័កប៉ុលបានចែកចាយពីរបៀបដែលពួកជំនុំម៉ាសេដូនទោះបីជាពួកគេក្រីក្រខ្លាំងក៏ដោយក៏បានចូលរួមក្នុងព័ន្ធកិច្ចនេះដែរ។ នៅក្នុង២កូរិនថូស៨:១-៥ គាត់បាននិយាយថាៈ

*១ បងប្អូនអើយ យើងខ្ញុំប្រាប់ឲ្យអ្នករាល់គ្នាដឹង ពីព្រះគុណនៃព្រះ ដែលបានផ្តល់មកពួកជំនុំទាំងប៉ុន្មាន នៅស្រុកម៉ាសេដូនថា ២ កាលមានសេចក្តីទុក្ខលំបាកកំពុងតែល្បងគេជាខ្លាំង នោះសេចក្តីអំណរជាបរិបូរ នឹងសេចក្តីកំសត់ទុគ៌តរបស់គេ បានបណ្តាលឲ្យគេមានចិត្តសទ្ធាដ៏លើសលប់វិញ ៣ ដ្បិតខ្ញុំធ្វើបន្ទាល់ថា គេស្ម័គ្រចិត្តតាមកំឡាំងគេ ហើយហួសកំឡាំងគេផង ៤ ក៏សូមយើងខ្ញុំដោយពាក្យទទូចអង្វរឲ្យយើងខ្ញុំទទួលយកទានរបស់គេនេះ ដែលជាសេចក្តីប្រកបក្នុងការងារសំរាប់ពួកបរិសុទ្ធ ៥ មិនមែនដូចជាយើងខ្ញុំបានសង្ឃឹមតែប៉ុណ្ណោះទេ គឺគេបានប្រគល់ខ្លួនគេទៅព្រះអម្ចាស់ជាមុនដំបូង ហើយដល់យើងខ្ញុំថែមទៀត តាមបំណងព្រះហឫទ័យព្រះ។*

ពិចារណាអំពីទីបន្ទាល់ដ៏អស្ចារ្យរបស់ពួកម៉ាសេដូន។ ដើម្បីលើកទឹកចិត្តដល់បងប្អូននៅទីក្រុងកូរិនថូសក្នុងការថ្វាយដង្វាយ សាវ័កប៉ុលបានប្រាប់ពួកគេអំពីក្រុមជំនុំម៉ាសេដូន និងចិត្តសប្បុរសយ៉ាងជ្រាលជ្រៅរបស់ពួកគេ។ ដំបូងទ្រង់បញ្ជាក់ពីចិត្តសប្បុរសរបស់ពួកគេបានមកពីការងារយ៉ាងពិសេសនៃព្រះគុណរបស់ព្រះជាម្ចាស់(ខ១) ។ ព្រះបានធ្វើកិច្ចការមួយនៅក្នុងដួងចិត្តរបស់ពួកគេដោយបណ្តាលឲ្យពួកគេផ្តល់សេក្តីសប្បុរស សូម្បីតែហួសពីសមត្ថភាពរបស់ពួកគេក៏ដោយ (ខ ៣) ។ ការពិតពួក

គេបានអង្វរដល់សាវ័កប៉ុលសម្រាប់ឯកសិទ្ធិក្នុងការជួយដល់ពួកបរិសុទ្ធដែលកំពុងតស៊ូ (ខ ៤) ។ តើមិនអស្ចារ្យទេឬអី? ពួកគេបានអង្វរសម្រាប់មានឱកាស ដើម្បីថ្វាយ ទោះបីជាពួកគេក្រីក្រខ្លួនឯងក៏ដោយ ហើយនៅក្នុងអត្ថបទនេះពួកគេត្រូវបានគេចងចាំជារៀងរហូតសម្រាប់អំណោយឬការដូរលះបង់របស់ពួកគេ។

នោះជាអ្វីដែលព្រះសព្វព្រះហឫទ័យចំពោះគូស្វាមីភរិយានៅក្នុងអាពាហ៍ពិពាហ៍។ ទ្រង់សព្វព្រះហឫទ័យឲ្យពួកគេលះបង់ថ្វាយ ដើម្បីធ្វើឲ្យនគរព្រះរីកចម្រើនឡើង។ ទោះជាយ៉ាងណាក៏ដោយ នេះអាចធ្វើទៅបានលុះត្រាតែពួកគេថ្វាយខ្លួនដល់ព្រះជាម្ចាស់ជាមុនសិន (ខ ៥) ។ ប្រសិនបើគូស្វាមីភរិយាកាន់ជាប់ជីវិតរបស់ពួកគេ បំណងចិត្ត និងគោលដៅរបស់ពួកគេមកពីព្រះជាម្ចាស់ នោះបន្ទាប់មកពួកគេក៏នឹងកាន់កាបូបរបស់ពួកគេជាប់ដែរ។ នៅពេលយើងថ្វាយខ្លួនយើងដល់ព្រះជាម្ចាស់ យើងនឹងចាប់ផ្ដើមមានលក្ខណៈកាន់តែដូចទ្រង់ ដោយត្រូវបានផ្លាស់ប្ដូរពីសិរីល្អទៅជាសិរីរុងរឿង (២ កូរិនថូស ៣:១៨) ។ វាគឺជាព្រះដែលស្រឡាញ់ពិភពលោកដល់ម្ល៉េះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ (យ៉ូហាន ៣:១៦) ។ ការលះបង់ដ៏ថ្លៃថ្លានៃការថ្វាយគួរតែត្រូវបានគេមើលឃើញនៅក្នុងអ្នកដើរតាមទ្រង់នៅពេលពួកគេស្វែងរកការយល់ព្រមពីទ្រង់នៅក្នុងការគ្រប់គ្រងរបស់ពួកគេ។

គោលការណ៍ដំបូងដែលគូស្វាមីភរិយាត្រូវអនុវត្ត ដើម្បីភាពស្មោះត្រង់ជាមួយហិរញ្ញវត្ថុ គឺត្រូវប្រើប្រាស់ទ្រព្យសម្បត្តិរបស់ពួកគេ ដើម្បីយកឈ្នះព្រលឹងមនុស្សសម្រាប់ថ្វាយដល់ព្រះគ្រីស្ទហើយដើម្បីកសាងនគររបស់ព្រះឡើង។ ចូរយើងអានព្រះបន្ទូលរបស់ព្រះជាម្ចាស់នៃយើងម្ដងទៀតថា«ចូរប្រើទ្រព្យសម្បត្តិលោកីយនេះ ឲ្យបានមិត្រសំឡាញ់ដល់ខ្លួន ដើម្បីកាលណាអ្នករាល់គ្នាខាននៅ នោះនឹងមានគេទទួលអ្នករាល់គ្នាឲ្យនៅក្នុងទីលំនៅដ៏ស្ថិតស្ថេរអស់កល្បជានិច្ចវិញ» (ខ ៩) ។

### ដើម្បីឲ្យមានភាពស្មោះត្រង់ខាងផ្នែកហិរញ្ញវត្ថុ គូស្វាមីភរិយាត្រូវផ្ដោតទៅលើជំនួយរបស់ព្រះជាព្រះពរទៅដល់អ្នកដែលបានថ្វាយ

ក្រោយដែលទ្រង់បានបង្គាប់ដល់ពួកសិស្សរបស់ទ្រង់ឲ្យប្រើប្រាស់ទ្រព្យសម្បត្តិរបស់ពួកគេ ដើម្បីយកឈ្នះព្រលឹងវិញ្ញាណ ព្រះគ្រីស្ទទ្រង់ក៏ប្រទាននូវហេតុផលដែលពួកគេគួរតែអនុវត្តការនេះ ទ្រង់មានព្រះបន្ទូលថា៖

*១០ អ្នកណាដែលស្មោះត្រង់ក្នុងការតូចបំផុតនោះក៏ឈ្មោះថា ស្មោះត្រង់ក្នុងការធំ ហើយអ្នកណាដែលទុច្ចរិតក្នុងការតូចបំផុត នោះក៏ឈ្មោះថាទុច្ចរិតក្នុងការដ៏ធំដែរ ១១ ដូច្នេះ បើអ្នករាល់គ្នាមិនស្មោះត្រង់ ចំពោះទ្រព្យសម្បត្តិរបស់លោកីយទេ តើអ្នកណាហ៊ានផ្ញើសម្បត្តិដ៏ពិតទុកនឹងអ្នករាល់គ្នាបាន ១២ ហើយបើអ្នករាល់គ្នាមិនស្មោះត្រង់នឹងរបស់គេទេ តើអ្នកណានឹងហ៊ានឲ្យរបស់អ្វីដាច់ជារបស់ផងអ្នកបាន (លូកា១៦:១០-១២)។*

ទ្រង់បានមានបន្ទូលយ៉ាងសំខាន់ថា ប្រសិនបើពួកសិស្សស្មោះត្រង់ជាមួយនឹងប្រាក់របស់ពួកគេ នោះព្រះនឹងប្រទានរង្វាន់យ៉ាងបរិបូរណ៍ដល់ពួកគេជាមួយនឹង «ទ្រព្យសម្បត្តិដ៏ពិត» នៅលើផែនដី និងនៅស្ថានសួគ៌ដែរ ប៉ុន្តែប្រសិនបើពួកគេមិនស្មោះត្រង់ ទ្រង់មិនអាចទុកចិត្តពួកគេបានទៀតទេ។ យើងឃើញ

ការនេះជារឿងរាល់ថ្ងៃនៅក្នុងពិភពការងាររបស់យើង។ មនុស្សម្នាក់ចាប់ផ្តើមធ្វើការនៅក្រុមហ៊ុនជាមួយការចូលការងារដែលនៅមានកម្រិត។ គាត់ខិតខំធ្វើការយ៉ាងខ្លាំង ហើយត្រូវបានតំឡើងឋានៈដោយអ្នកគ្រប់គ្រងរបស់គាត់។ អ្នកគ្រប់គ្រងល្អដឹងថា អ្នកណាដែលស្មោះត្រង់នឹងកិច្ចការតូចតាចក៏នឹងស្មោះត្រង់នឹងការងារធំៗដែរ។ ដូច្នេះពួកគេលើកកម្ពស់អ្នកធ្វើការស្មោះត្រង់ហើយផ្តល់ឲ្យពួកគេនូវទំនួលខុសត្រូវបន្ថែមទៀត។ ទោះជាយ៉ាងណាក៏ដោយ អ្នកមិនស្មោះត្រង់តែងតែបាត់បង់ទំនួលខុសត្រូវ ហើយអាចបាត់បង់ការងាររបស់ពួកគេផងដែរ។ ស្រដៀងគ្នានេះដែរ ព្រះដែលជាចៅហ្វាយរបស់យើងតែងតែឃ្លាំមើលពីរបៀបដែលកូនៗរបស់ទ្រង់គ្រប់គ្រងប្រាក់របស់ទ្រង់ ហើយអ្នកណាដែលស្មោះត្រង់ទ្រង់នឹងផ្តល់រង្វាន់ជាទ្រព្យសម្បត្តិដ៏ពិត។

តើអ្វីទៅជា«ទ្រព្យសម្បត្តិដ៏ពិត»ដែលព្រះប្រទានរង្វាន់ដល់អ្នកបម្រើដ៏ស្មោះត្រង់របស់ទ្រង់? ក្នុងផ្នែកមួយប្រហែលជាសំដៅទៅលើទ្រព្យសម្បត្តិនៅឯស្ថានសួគ៌។ នៅក្នុងគម្ពីរម៉ាថាយ ៦:១៩ ព្រះគ្រីស្ទបានត្រាស់បង្គាប់ដល់គ្រីស្ទបរិស័ទឲ្យប្រមូលទ្រព្យសម្បត្តិនៅស្ថានសួគ៌ ដែលដង្កូវនិងច្រែះមិនអាចបំផ្លាញបាន។ ស្រដៀងគ្នានេះដែរ នៅក្នុងរឿងប្រៀបប្រដូចអំពីអ្នកបម្រើស្មោះត្រង់បានទទួលទីក្រុងនានានៅក្នុងនគរខាងមុខនេះចុះ (លូកា ១៩: ១៧, ១៩) ។

ជាមួយនឹងការនិយាយបែបនោះ ទ្រព្យសម្បត្តិដ៏ពិតប្រាកដសំដៅទៅលើអ្វីៗជាច្រើនទៀត វាក៏សំដៅទៅលើភាពជាសាវ័កខាងឯព្រលឹងវិញ្ញាណដែរ។ អ្នកណាដែលស្មោះត្រង់នឹងប្រាក់ក៏អាចទុកចិត្តបានជាមួយការដឹកនាំមនុស្ស បណ្តុះបណ្តាលពួកគេ ថែទាំពួកគេជាដើម។ ល។ នេះជាហេតុផលដែលព្រះជាម្ចាស់តម្រូវឲ្យពួកចាស់ទុំមិនត្រូវស្រឡាញ់ប្រាក់ និងត្រួតត្រាផ្ទះរបស់ខ្លួនដោយស្រួលបួល (១ ធីម៉ូថេ៣:៣-៤)។ ការត្រួតត្រាផ្ទះបានល្អមួយរួមមានភាពស្មោះត្រង់ជាមួយហិរញ្ញវត្ថុ។ ប្រសិនបើមនុស្សម្នាក់មិនស្មោះត្រង់ជាមួយហិរញ្ញវត្ថុ គាត់នឹងក្លាយជាអ្នកបម្រើមិនស្មោះត្រង់របស់មនុស្សដែរ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលមនុស្សម្នាក់ស្មោះត្រង់នឹងហិរញ្ញវត្ថុ ព្រះជាម្ចាស់អាចទុកចិត្តគាត់ដោយផ្តល់នូវឱកាសជាមួយភាពជាសាវ័ក។

ជាងនេះទៅទៀត ទ្រព្យសម្បត្តិដ៏ពិតប្រហែលជាសំដៅទៅលើការយល់ដឹង និងការបង្រៀនព្រះបន្ទូលរបស់ព្រះ។ អ្នកណាដែលជាអ្នកបម្រើស្មោះត្រង់នឹងប្រាក់ នឹងក្លាយជាអ្នកបម្រើស្មោះត្រង់នៃព្រះបន្ទូលរបស់ព្រះដែរ។ ហើយអ្នកណាដែលមិនស្មោះត្រង់នឹងបកស្រាយខុស ហើយប្រើបទគម្ពីរខុសដែរ។

ចុងក្រោយយើងមានការយល់ដឹងកាន់តែច្រើនអំពី «ទ្រព្យសម្បត្តិដ៏ពិត» ដោយពិចារណាការបង្រៀនរបស់សាវ័កប៉ុលអំពីសេក្តីសន្យារបស់ព្រះដល់អ្នកដែលថ្វាយនៅក្នុង (២កូរិនថូស ៩: ៧-៨) គាត់បាននិយាយថា៖

*៧ ចូរឲ្យគ្រប់គ្នាធ្វើតាមដែលសំរេចក្នុងចិត្តចុះ មិនមែនដោយស្តាយ ឬដោយបង្ខំឡើយ ដ្បិតព្រះទ្រង់ស្រឡាញ់ដល់អ្នកណាដែលថ្វាយដោយអំណរ ៨ ហើយព្រះទ្រង់អាចនឹងធ្វើឲ្យគ្រប់ទាំងព្រះគុណបានចំរើនដល់អ្នករាល់គ្នា ប្រយោជន៍ឲ្យមានទាំងអស់គ្រប់គ្រាន់ជានិច្ច ដើម្បីឲ្យបានចំរើនឡើងខាងឯការល្អគ្រប់ជំពូក។*

តើទ្រព្យសម្បត្តិអ្វីទៀតដែលត្រូវបានផ្តល់ដល់អស់អ្នកដែលបានថ្វាយដោយស្មោះត្រង់

ដើម្បីបំពេញនគរព្រះ?

ព្រះទ្រង់សន្យាស្រឡាញ់ដល់អស់អ្នកដែលថ្វាយដោយអំណរ (ខ ៧) ។ គេអាចសួរថា“តើព្រះជាម្ចាស់មិនស្រឡាញ់មនុស្សគ្រប់គ្នាទេឬអី? ”ពិតណាស់ ប៉ុន្តែព្រះជាម្ចាស់ត្រេកអរចំពោះមនុស្សមួយចំនួន (យ៉ាកុប ២:២៣) ។ ទ្រង់ស្រឡាញ់ដល់អស់អ្នកដែលថ្វាយដោយអំណរ អ្នកណាដែលជាមនុស្សដែលសប្បាយចិត្តក្នុងការដែលថ្វាយ។ នៅពេលយើងជាអ្នកដែលថ្វាយដោយសេរី យើងឆ្លុះបញ្ចាំងពីព្រះដែលផ្តល់ឲ្យទ្រង់នូវសេចក្តីរីករាយយ៉ាងខ្លាំង។ នេះគួរតែជាការលើកទឹកចិត្តសម្រាប់គូស្វាមីភរិយា។

ព្រះសន្យាផ្តល់ព្រះគុណ

ដើម្បីបំពេញនូវតម្រូវការទាំងអស់របស់អ្នកថ្វាយដ៏រីករាយឬដោយចិត្តសន្ធា (ខ ៨)។ ព្រះគម្ពីរប្រាប់ថា ព្រះនឹងធ្វើឲ្យ «ព្រះគុណមានពេញបរិបូណ៌» ដូច្នេះពួកគេមាន »ទាំងអស់» ដែលពួកគេត្រូវការ។ អាពាហ៍ពិពាហ៍ជាច្រើនតស៊ូជាមួយភាពខ្វះខាត ពីព្រោះពួកគេមិនមែនជាអ្នកថ្វាយដោយស្មោះត្រង់។ នៅក្នុងម៉ាឡាគី ២:៨-៩ ព្រះនាំមកនូវបណ្តាសាដល់ជនជាតិអ៊ីស្រាអែលដែលជាលទ្ធផលនៃការប្លន់របស់ព្រះអង្គក្នុងមួយភាគដប់និងដង្វាយផ្សេងៗទៀត។ គ្មានអ្វីត្រូវសង្ស័យនោះទេ គូស្វាមីភរិយាជាច្រើនកំពុងស្ថិតក្រោមបណ្តាសាដែលប្លន់របស់ពីព្រះ។

ព្រះសន្យាផ្តល់ព្រះគុណយ៉ាងពេញបរិបូណ៌ក្នុង «រាល់កិច្ចការល្អ» ដល់អស់អ្នកដែលថ្វាយដោយចិត្តរីករាយ។ នៅពេលទ្រង់មានបន្ទូលថា នឹងមានព្រះគុណសម្រាប់ «រាល់កិច្ចការល្អ» ដែលរួមបញ្ចូលនូវអ្វីដែលយើងបានពិចារណារួចហើយ។ ព្រះនឹងប្រណីដល់ពួកគេដោយព្រលឹង ដើម្បីគង្វាលនិងលូតលាស់ខាងឯការយល់ដឹងនៃបទគម្ពីរកាន់តែច្រើន។ ទ្រង់ថែមទាំងផ្តល់ព្រះគុណដល់ពួកគេ ដើម្បីឲ្យមានអាពាហ៍ពិពាហ៍ដែលមានផាសុខភាព។ ប្រាកដណាស់អាពាហ៍ពិពាហ៍គឺជា« ការងារល្អ» ដែលព្រះចង់បង្ហូរនូវព្រះគុណដ៏មានតម្លៃរបស់ទ្រង់ទៅលើពួកគេ។

គូស្វាមីភរិយាដែលប្រើប្រាក់តិចតួចរបស់ពួកគេ ដើម្បីសាងសង់នគររបស់ព្រះនឹងទទួលបានយ៉ាងច្រើន (ទ្រព្យសម្បត្តិដ៏ពិត)។ តាមរយៈការប្រើប្រាស់ហិរញ្ញវត្ថុឲ្យបានត្រឹមត្រូវ គូស្វាមីភរិយាបើកទ្វារទទួលនូវព្រះគុណដ៏លើសលប់ដោយព្រះ ហើយនឹងតាមរយៈអាពាហ៍ពិពាហ៍របស់ពួកគេ។ គោលការណ៍នេះគឺជាទ្វារនៃទ្រព្យសម្បត្តិខាងឯវិញ្ញាណដ៏អស្ចារ្យ ព្រះគុណដ៏អស្ចារ្យ និងការយល់ព្រមពីព្រះលើភាពជាអ្នកដឹកនាំរបស់ប្តីប្រពន្ធ។

**ដើម្បីឲ្យមានភាពស្មោះត្រង់ខាងផ្នែកហិរញ្ញវត្ថុ គូស្វាមីភរិយាមិនត្រូវស្រឡាញ់ប្រាក់នោះទេ**

ដើម្បីស្មោះត្រង់នឹងហិរញ្ញវត្ថុគូស្វាមីភរិយាក៏មិនត្រូវស្រឡាញ់ប្រាក់ដែរ។ ចិត្តប្រាថ្នាចង់បានទ្រព្យសម្បត្តិនិងភាពជោគជ័យអាចទាញមនុស្សឲ្យឃ្លាតឆ្ងាយពីព្រះ ហើយក៏អាចទាញអាពាហ៍ពិពាហ៍ដាច់ចេញពីគ្នាបានដែរ។ បន្ទាប់ពីបង្រៀនពួកសិស្សរបស់ទ្រង់អំពីរបៀបប្រើប្រាស់ប្រាក់របស់ពួកគេ ព្រះគ្រីស្ទបានព្រមានពួកគេដោយមានបន្ទូលថា៖

*គ្មានបាវណាដែលបំរើចៅហ្វាយ២បានទេ ពីព្រោះបាវនោះនឹងស្អប់១ ស្រឡាញ់១ ឬនឹងកាន់ខាង១ ហើយមើលងាយ១ ដូច្នេះអ្នករាល់គ្នាក៏បំរើព្រះផងទ្រព្យសម្បត្តិផងពុំបានដែរ* (លូកា១៦:១៣)។

ព្រះគ្រីស្ទចង់ឲ្យពួកសិស្សដឹងអំពីគ្រោះថ្នាក់នៃការស្រឡាញ់ប្រាក់។ ស្រដៀងគ្នានេះដែរ សាវ័កប៉ុល បានព្រមានធីម៉ូថេដែលជាសិស្សរបស់គាត់។ គាត់បាននិយាយថា៖

*៩ ឯពួកអ្នកដែលចង់ធ្វើជាអ្នកស្តុកស្តម្ភ នោះនឹងធ្លាក់ទៅក្នុងសេចក្តីល្បួង នឹងអន្ទាក់ ហើយក្នុងបំណងជាច្រើន ដែលឆ្កួតផ្តាស ហើយធ្វើទុក្ខដល់ខ្លួន ក៏ពន្លិចមនុស្សទៅក្នុងសេចក្តីហិនវិនាសនឹងសេចក្តីអន្តរធានវិញ១០ ដ្បិតការដែលស្រឡាញ់ប្រាក់ នោះហើយជាមេឫសនៃសេចក្តីអាក្រក់គ្រប់យ៉ាង ដែលអ្នកខ្លះបានឈោងតាម ហើយត្រូវល្បួងលោមឲ្យឃ្លាតចេញពីសេចក្តីជំនឿ ទាំងចាក់ទំលុះខ្លួនគេដោយសេចក្តីព្រួយលំបាកជាច្រើន (១ធីម៉ូថេ ៦:៩-១០) ។*

សាវ័កប៉ុលបានព្រមានដល់ធីម៉ូថេអំពីផលវិបាកនៃការស្រឡាញ់ប្រាក់។ មនុស្សជាច្រើនបានធ្លាក់ខ្លួនចូលទៅក្នុងសេក្តីវិនាស ហើយត្រូវបានបំផ្លាញដោយសារតែវា។ អ្នកខ្លះថែមទាំងវង្វេងចេញពីសេក្តីជំនឿ ហើយបានចាក់ទម្លុះខ្លួនគេដោយទុក្ខសោករាប់មិនអស់។ ជាការពិតណាស់ រឿងនេះបានកើតឡើងចំពោះអាពាហ៍ពិពាហ៍ជាច្រើនផងដែរ។

ដើម្បីធ្វើជាអ្នកបម្រើស្មោះត្រង់នៃហិរញ្ញវត្ថុរបស់ព្រះ គូស្វាមីភរិយាមិនត្រូវស្រឡាញ់ប្រាក់នោះទេ។ សាវ័កយ៉ូហានបាននិយាយថា៖

*១៥ កុំឲ្យស្រឡាញ់លោកីយ ឬរបស់អ្វីដែលនៅក្នុងលោកីយនេះឲ្យសោះ បើអ្នកណាស្រឡាញ់លោកីយ អ្នកនោះគ្មានសេចក្តីស្រឡាញ់របស់ព្រះវរបិតានៅក្នុងខ្លួនឡើយ១៦ ដ្បិតអស់ទាំងសេចក្តីដែលនៅក្នុងលោកីយនេះ គឺជាសេចក្តីប៉ងប្រាថ្នារបស់សាច់ឈាម នឹងសេចក្តីប៉ងប្រាថ្នារបស់ភ្នែក ហើយសេចក្តីអំនួតរបស់ជីវិត នោះមិនកើតមកពីព្រះវរបិតាទេគឺមកតែពីលោកីយនេះវិញ (១យ៉ូហាន ២:១៥-១៦)។*

នេះមិនមែនថា ប្រាក់ឬទ្រព្យសម្បត្តិជាអ្វីដែលអាក្រក់នោះទេ។ ទ្រព្យសម្បត្តិគឺអព្យាក្រឹត ទោះជាយ៉ាងណា ចិត្តរបស់យើងគឺអាក្រក់។ ចិត្តរបស់យើងងាយនឹងភាពលោភលន់ តណ្ហា និងអំនួតដែលទាញយើងឲ្យឃ្លាតចេញពីព្រះ។ ហើយនៅពេលគូស្វាមីភរិយាត្រូវបានទាញចេញពីព្រះ នោះពួកគេក៏នឹងត្រូវបានទាញចេញពីគ្នាដែរ។ វាជាការល្អក្នុងការគិតអំពីអាពាហ៍ពិពាហ៍ដូចជាត្រីកោណ។ ព្រះគឺនៅកំពូលហើយស្វាមីនិងភរិយាគឺស្ថិតនៅជ្រុងទាំងសងខាង។ ស្វាមីនិងភរិយាកាន់តែជិតស្និទ្ធទៅកាន់ព្រះជាម្ចាស់ នោះពួកគេនឹងកាន់តែជិតស្និទ្ធនឹងគ្នាដោយភាពចាំបាច់ជាមួយគ្នាទៅវិញទៅមកដែរ។ ប៉ុន្តែពួកគេនៅកាន់តែឆ្ងាយពីព្រះប៉ុណ្ណា នោះពួកគេនឹងកាន់តែឆ្ងាយពីគ្នាទៅវិញទៅមកដែរ។ ការស្រឡាញ់ប្រាក់ និងទ្រព្យសម្បត្តិមាននិន្នាការអូសទាញគូស្វាមីភរិយាចេញពីព្រះហើយនិងឃ្លាតចេញពីគ្នា។ ព្រះគ្រីស្ទបានមានបន្ទូលយ៉ាងច្បាស់ថា *“អ្នកមិនអាចស្រឡាញ់ទាំងពីរបានទេ អ្នកអាចមានម្ចាស់តែម្នាក់គត់”* ។

ជាអកុសលគូស្វាមីភរិយាជាច្រើនមិនបានធ្វើតាមការព្រមាននេះទេ ដែលនាំឲ្យមានផ្លែរលួយនៅក្នុងអាពាហ៍ពិពាហ៍របស់ពួកគេ។ នៅក្នុងផ្ទះជាច្រើនប្តីធ្វើការច្រើនម៉ោង ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារឲ្យប្រសើរជាងមុន។ ទោះជាយ៉ាងណាក៏ដោយ ការងាររារាំងគាត់ពីការចំណាយពេលប្រកបដោយគុណភាពជាមួយប្រពន្ធនិងកូនៗ ហើយវាក៏រារាំងគាត់ពីការចូលរួមក្នុងព្រះវិហារផងដែរ។

បន្តិចម្តងៗប្រាក់ក្លាយជាព្រះរបស់គាត់ ហើយវាបំផ្លាញទំនាក់ទំនងរបស់គាត់ជាមួយក្រុមគ្រួសារគាត់។ ជាច្រើនដងភរិយាបង្ហាញពីសេក្តីប្រាថ្នាខាងឯតណ្ហាថែមទៀត។ ដើម្បីមានច្រើនថែមទៀតឬរក្សានូវអ្វីដែលពួកគេមាន ទាំងមិត្តរួមការងារធ្វើការច្រើនម៉ោង ហើយកូនត្រូវបានព្រងើយកន្តើយដែលបង្កើតឲ្យមានភាពជូរចត់ ការអាក់អន់ចិត្តនិងកំហឹងនៅក្នុងចិត្តរបស់កូនៗ។ សម្រាប់ហេតុផលនេះ យើងកំពុងចិញ្ចឹមកូនដែលបះបោរជំនាន់មួយដែលមិនយកចិត្តទុកដាក់ចំពោះរឿងខាងឯវិញ្ញាណនិងមិនគោរពសិទ្ធិអំណាច។ ព្រះនៃប្រាក់កំពុងតែបំផ្លាញផ្ទះសម្បែង ហើយទាំងសង្គមផងដែរ។

ហេតុអ្វីការនេះជារឿងធម្មតានៅក្នុងចំណោមគ្រួសារ? វាដោយសារតែទ្រព្យសម្បត្តិមាននិន្នាការបោកបញ្ឆោតយើង។ នៅក្នុងរឿងប្រៀបប្រដូចអំពីអ្នកព្រោះស្រូវ ព្រះគ្រីស្ទបានពិពណ៌នាអំពីគ្រាប់ពូជនៃព្រះបន្ទូលរបស់ព្រះដែលត្រូវបានគេសាបព្រោះទៅលើដីដែលមានបន្លា។ ទ្រង់បានមានបន្ទូលពីការកង្វល់នៃជីវិតនិង «ការភូតភរបោកបញ្ឆោតនៃទ្រព្យសម្បត្តិ» ច្របូកច្របល់ព្រះបន្ទូលហើយធ្វើឲ្យវាមិនអាចបង្កើតផលបាន (ម៉ាថាយ១៣:២២) ។

តើភាពមានបានបោកបញ្ឆោតមនុស្សយ៉ាងដូចម្តេច?

១. ទ្រព្យសម្បត្តិបោកបញ្ឆោតមនុស្សឲ្យគិតតែចង់មានច្រើនជាងនេះនឹងបានស្កប់ចិត្តហើយ។ តើប៉ុន្មានទើបគ្រប់គ្រាន់? ចម្លើយតែងតែថា «បន្តិចទៀត» ។ ហេតុដូច្នេះហើយបានជាមនុស្សចំណាយពេលមួយជីវិតរបស់ពួកគេព្យាយាមរស់នៅ ដើម្បីបានថែមទៀត ហើយទទួលបាននូវការស្កប់ចិត្តចំពោះប្រាក់ និងរបស់របរដែលមានតែធ្វើឲ្យពួកគេមិនស្កប់ចិត្តប៉ុណ្ណោះ។

២. ទ្រព្យសម្បត្តិបោកបញ្ឆោតមនុស្សដោយធ្វើឲ្យពួកគេខ្វាក់ (ម៉ាថាយ ៦: ២១-២៣) និងបំភាន់តម្លៃរបស់ខ្លួន។ មនុស្សចាប់ផ្តើមដាក់ការងារនិងសុវត្ថិភាពរបស់ទ្រព្យសម្បត្តិខ្ពស់ជាងព្រះ គ្រួសារ និងមនុស្ស។ នេះក៏ព្រោះតែពួកគេត្រូវបានខ្វាក់ដោយសារភាពលោភលន់របស់ពួកគេ។ ជាច្រើនដងការនេះនាំឲ្យពួកគេធ្វើអ្វីគ្រប់យ៉ាង ដើម្បីកើនទ្រព្យសម្បត្តិ រួមទាំងការបំពានច្បាប់និងធ្វើឲ្យមនុស្សឈឺចាប់ទៀតផង។

៣. ទ្រព្យសម្បត្តិបោកបញ្ឆោតមនុស្សដោយលើកកម្ពស់ភាពអំនួតនៅក្នុងអ្នកណាដែលមានវានិង អសន្តិសុខចំពោះអ្នកណាដែលមិនមាន។ អ្នកមានទ្រព្យច្រើនទំនោរលើការលើកតម្កើងខ្លួនហើយមើលងាយដល់អ្នកណាដែលមានតិចឬក្រជាង។ ផ្ទុយទៅវិញអ្នកក្រច្រើនតែមានអារម្មណ៍ថាគ្មានសុវត្ថិភាពនិងលើកស្ទួយអ្នកមាន។

ដើម្បីឲ្យគូស្វាមីភរិយាស្មោះត្រង់នឹងហិរញ្ញវត្ថុរបស់ពួកគេ ពួកគេមិនត្រូវស្រឡាញ់ប្រាក់ទេ។ ការស្មុគស្មាញរឿងប្រាក់ គឺជាហេតុផលមួយក្នុងចំណោមហេតុផលខ្ពស់បំផុតសម្រាប់ការលែងលះដោយសារតែវាទំនោរទៅលួចដួងចិត្តរបស់ម្នាក់ឬទាំងពីរនាក់នៅក្នុងអាពាហ៍ពិពាហ៍។ មនុស្សជាច្រើននៅក្នុងក្រុមជំនុំបានដេញតាមប្រាក់ជាជាងព្រះ។ ប្រាក់កំណត់កន្លែងណាដែលត្រូវរស់នៅ កន្លែងណាដែលទៅរៀន កន្លែងណាដែលត្រូវធ្វើការងារ កន្លែងណាដែលត្រូវទៅព្រះវិហារ អ្នកណាដែលគួររៀបការជាមួយឬមានទំនាក់ទំនងជាមួយជាដើម។ យើងមិនអាចបម្រើចៅហ្វាយពីរនាក់បានទេ។ ចៅហ្វាយប្រាក់នឹងបំផ្លាញទំនាក់ទំនងមួយជាមួយព្រះ ដូចនឹងអាពាហ៍ពិពាហ៍របស់ពួកគេដែរ។ ប្រសិនបើ

យើងអនុញ្ញាតឲ្យព្រះធ្វើជាចៅហ្វាយទ្រង់នឹងពង្រឹងនិងបង្កើនទាំងពីរភាពមានបាននិងទំនាក់ទំនង។

តើយើងអាចប្រាប់ដោយរបៀបណាប្រសិនបើប្រាក់ជាម្ចាស់របស់យើង? យើងអាចប្រាប់ដោយពីរបៀបដែលយើងប្រើប្រាក់របស់យើង។ ព្រះគ្រីស្ទបានមានបន្ទូលថា*«ឯទ្រព្យសម្បត្តិរបស់អ្នកនៅកន្លែងណាចិត្តរបស់អ្នកក៏នៅកន្លែងនោះដែរ» (ម៉ាថាយ៦:២១)* ។ កន្លែងណាដែលមនុស្សដាក់ប្រាក់របស់ពួកគេ នោះបង្ហាញពីកន្លែងដែលចិត្តរបស់ពួកគេស្ថិតនៅទីនោះដែរ។ ការវិនិយោគប្រាក់ដោយស្មោះត្រង់ចូលទៅក្នុងនគរព្រះបង្ហាញពីដួងចិត្តសម្រាប់ព្រះជាម្ចាស់។ ប៉ុន្តែអ្នកណាដែលវិនិយោគប្រាក់របស់គេជាចម្បងទៅលើរបស់នៅក្នុងលោកីយ៍នេះ នោះបង្ហាញពីចិត្តលោកីយ៍របស់ពួកគេ។ ដូច្នេះ យើងអាចប្រាប់អ្នកដែលជាចៅហ្វាយរបស់យើង គឺដោយមើលតាមរបាយការណ៍ធនាគាររបស់យើង។

តើអ្វីខ្លះដែលអ្នកប្រើប្រាក់ពណ៌នាអំពីចិត្តរបស់អ្នកនិងទំនាក់ទំនងរបស់អ្នកជាមួយព្រះ? តើអ្នកស្រឡាញ់ព្រះឬទេ? ឬតើអ្នកស្រឡាញ់ប្រាក់និងរបស់នៅលោកីយ៍នេះ? ការស្រឡាញ់ប្រាក់និងរបស់នៅលោកីយ៍នេះនឹងធ្វើឲ្យស្មោចង្រៃដុះនៅក្នុងទំនាក់ទំនងរបស់អ្នកជាមួយព្រះនិងអាពាហ៍ពិពាហ៍របស់អ្នក។

**ដើម្បីឲ្យមានភាពស្មោះត្រង់ខាងផ្នែកហិរញ្ញវត្ថុ គូស្វាមីភរិយាត្រូវតែអនុវត្តវិន័យនៃភាពសាមញ្ញ**

លើសពីនេះទៅទៀត ដើម្បីកុំឲ្យស្រឡាញ់ប្រាក់ គូស្វាមីភរិយាត្រូវតែការពារដួងចិត្តរបស់ពួកគេដោយអនុវត្តវិន័យសាមញ្ញ។ ដោយសារទំនោររបស់យើងក្នុងការស្រឡាញ់ទ្រព្យសម្បត្តិ (ម៉ាថាយ៦:២១) ព្រះគ្រីស្ទបានបញ្ជាដល់អ្នកដើរតាមទ្រង់កុំឲ្យប្រមូលទ្រព្យសម្បត្តិនៅលើផែនដីនេះឡើយ។ ទ្រង់បានមានបន្ទូលថាថា៖

*១៩ កុំឲ្យប្រមូលទ្រព្យសម្បត្តិ ទុកសំរាប់ខ្លួន នៅផែនដី ជាកន្លែងដែលមានកន្លាត នឹងច្រែះស៊ីបំផ្លាញ ហើយចោរទំលុះប្លន់នោះឡើយ២០ ត្រូវប្រមូលទ្រព្យសម្បត្តិ ទុកសំរាប់ខ្លួន នៅឯស្ថានសួគ៌វិញ ដែលជាកន្លែងគ្មានកន្លាតឬច្រែះស៊ីបំផ្លាញឡើយក៏គ្មានចោរទំលុះឬប្លន់ផង» (ម៉ាថាយ ៦:១៩-២០)*។

ដើម្បីកុំឲ្យរក្សាទុកទ្រព្យសម្បត្តិនៅលើផែនដីនេះ គឺត្រូវអនុវត្តវិន័យនៃភាពសាមញ្ញ។ តើរបៀបអនុវត្តនេះនឹងខុសគ្នារវាងគ្រីស្ទបរិស័ទម្នាក់ៗដោយរបៀបណា។ ពួកសិស្សបានលក់អ្វីៗទាំងអស់ក្នុងការដើរតាមព្រះគ្រីស្ទ (លូកា១២:៣២) កន្លែងណាដែលអ្នកផ្សេងទៀតអនុវត្តការគ្រប់គ្រាន់ឬចេះប្រមាណខ្លួន (១ ធីម៉ូថេ ៦: ១៧-១៩)។

ម្តងទៀតមិនមានអ្វីដែលខុសប្លែកពីខាងក្នុងជាមួយទ្រព្យសម្បត្តិនោះទេ ប៉ុន្តែមានអ្វីដែលខាងក្នុងខុសជាមួយដួងចិត្តរបស់យើង។ ហេតុដូច្នេះហើយ ព្រះគ្រីស្ទបានបង្គាប់ដល់គ្រីស្ទបរិស័ទកុំឲ្យ ប្រមូលទ្រព្យសម្បត្តិទុកឬរបស់អ្វីដែលមានតម្លៃ ដើម្បីការពារដួងចិត្តរបស់យើង។

ចុះការសន្សំវិញ? តើការនេះមានន័យថា គ្រីស្ទបរិស័ទមិនគួរសន្សំទេឬ? ពិតជាមិនមែនទេ។ បទគម្ពីរបានបង្រៀនយើងឲ្យចេះសន្សំ ដើម្បីបំពេញសេចក្តីត្រូវការរបស់យើង។ សុភាសិតហៅយើងឲ្យពិចារណាអំពីស្រមោច របៀបដែលវាផ្ទុកនៅរដូវប្រមូលផលនៅរដូវក្តៅសម្រាប់រដូវរងា (៦:៦-៨)។ ដូច្នេះហើយ គ្រីស្ទបរិស័ទក៏គួរតែធ្វើដូច្នោះដែរ។

បន្ទាប់មកតើព្រះគ្រីស្ទចង់មានន័យយ៉ាងដូចម្តេចតាមរយៈបទបញ្ញាមិនឲ្យប្រមូលទ្រព្យសម្បត្តិទុក? តើការអនុវត្តវិន័យខាងឯវិញ្ញាណនៃភាពសាមញ្ញមានន័យដូចម្តេច?

១. ភាពសាមញ្ញមានន័យថា យើងមិនគួរទុកចិត្តលើទ្រព្យសម្បត្តិរបស់យើង ដើម្បីផ្គត់ផ្គង់ដល់យើងនោះទេ (១ ធីម៉ូថេ ៦:១៧)។ ព្រះជាម្ចាស់គឺជាអ្នកផ្គត់ផ្គង់ដល់យើង។ នៅពេលដែលសាតាំងបានល្បួងព្រះគ្រីស្ទឲ្យបង្គាប់ដល់ថ្មឲ្យត្រឡប់ទៅជានំប៉័ង នោះទ្រង់បានឆ្លើយថា*“មនុស្សមិនរស់ដោយសារនំប៉័ងតែប៉ុណ្ណោះទេគឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូលដែលចេញពីព្រះឱស្ឋព្រះមកដែរ” (ម៉ាថាយ ៤: ៤)* ។ ព្រះជាអ្នកបញ្ជាដល់ទ្វារឲ្យបើកសម្រាប់ការងារ អាហារូបករណ៍ ផ្ទះសម្បែងជាដើម ដើម្បីបំពេញសេចក្តីត្រូវការប្រចាំថ្ងៃរបស់យើង។ យើងត្រូវតែទុកចិត្តលើទ្រង់ គួរឲ្យស្តាយណាស់គូស្វាមីភរិយាជាច្រើនមិនតធ្វើតាមព្រះហឫទ័យរបស់ព្រះទេ ពីព្រោះការជឿទុកចិត្តរបស់ពួកគេគឺនៅក្នុងហិរញ្ញវត្ថុរបស់ពួកគេ ការងារឬការចូលនិវត្តន៍របស់ពួកគេ។

២. ភាពសាមញ្ញមានន័យថា យើងគួរតែរីកហាត់ពីភាពសមល្មមឬចេះគ្រប់គ្រាន់នៅក្នុងពេលវេលារបស់យើងដែលត្រូវនឹងទ្រព្យសម្បត្តិនៅលោកីយ៍នេះ។ សាវ័កប៉ុលបាននិយាយថា យើងគួរតែប្រើរបស់នៅលោកីយ៍នេះ តែមិនត្រូវ «ជំពប់ដួល» នៅក្នុងវាឡើយ (១កូរិនថូស ៧:៣១)។ វីដេអូហ្គេម ប្រព័ន្ធផ្សព្វផ្សាយសង្គម អ៊ិនធើណេត និងការបង្កើតផ្សេងទៀត ការលួងលោមចិត្តមានទំនោរ ដើម្បីបំផ្លាស់ចិត្តរបស់មនុស្សដោយបង្កើតឲ្យមានគម្លាតនៅក្នុងទំនាក់ទំនងរបស់ពួកគេជាមួយនឹងព្រះជាម្ចាស់ និងប្តីប្រពន្ធរបស់ពួកគេ។ ការស្កប់ចិត្តត្រូវតែអនុវត្ត។

៣. ភាពសាមញ្ញមានន័យថា យើងគួរតែអនុវត្តនូវការស្កប់ស្កល់ចិត្តក្នុងការប្រមូលទ្រព្យសម្បត្តិនិងរបស់របរនានានៅក្នុងលោកីយ៍នេះ។ យើងគួរតែពិចារណាអំពីរឿងនេះ នៅពេលទិញសម្លៀកបំពាក់ គ្រឿងអេឡិចត្រូនិច ឡាន គ្រឿងសង្ហារិម ផ្ទះជាដើម។ យ៉ាកុបបានស្តីបន្ទោសដល់ពួកជំនុំដំបូងពីការដែលពួកគេមិនស្តាប់បង្គាប់តាមព្រះគ្រីស្ទ។ គាត់បាននិយាយថាទ្រព្យសម្បត្តិដែលពួកគេបានប្រមូលទុកនឹងធ្វើស្មរបន្ទាល់ទាស់នឹងពួកគេនៅថ្ងៃចុងក្រោយ។ បទគម្ពីរយ៉ាកុប ៥:១-៣ ចែងថា៖

*១ ឥឡូវនេះ ពួកអ្នកមានអើយ ចូរយំសោកចុះ ព្រមទាំងស្រែកទ្រហោផង ដោយព្រោះសេចក្តីវេទនា ដែលត្រូវមកលើអ្នករាល់គ្នា ២ ទ្រព្យសម្បត្តិរបស់អ្នករាល់គ្នាបានពុករលួយ ហើយសំលៀកបំពាក់អ្នករាល់គ្នា ត្រូវកន្លាតកាត់អស់ហើយ ៣ មាសប្រាក់របស់អ្នករាល់គ្នាបានដុះស្នឹម ឯស្នឹមនោះ នឹងបានទុកសំរាប់ជាទីបន្ទាល់ ទាស់នឹងអ្នករាល់គ្នា ហើយនឹងស៊ីសាច់អ្នករាល់គ្នាដូចជាភ្លើង ដ្បិតអ្នករាល់គ្នាបានខំប្រមូលបង្គរទ្រព្យសម្បត្តិឡើង នៅជាន់ក្រោយបង្អស់នេះ។*

៤. ភាពសាមញ្ញមានន័យថា ពេលខ្លះយើងត្រូវដកហូតរបស់មានតម្លៃមួយចំនួនរបស់យើង។ ជាមួយបុរសអ្នកមាន សេចក្តីស្រឡាញ់របស់គាត់ចំពោះទ្រព្យសម្បត្តិកំពុងរារាំងគាត់ពីការសង្គ្រោះ (ម៉ាថាយ ១៩:២១-២៣)។ ទ្រព្យសម្បត្តិ គឺជាព្រះរបស់គាត់។ ដូច្នេះ គាត់ត្រូវបានបញ្ជាឲ្យចាកចេញពីទ្រព្យសម្បត្តិរបស់គាត់ ហើយដើរតាមព្រះគ្រីស្ទវិញ។ ស្រដៀងគ្នាដែរ គូស្វាមីភរិយាប្រហែលជាត្រូវធ្វើការសម្រេចចិត្តយ៉ាងម៉ឺងម៉ាត់អំពីប្រាក់ ចំណង់ចំណូលចិត្ត និងអាជីពជាដើម ដើម្បីការពារទំនាក់ទំនងរបស់ពួកគេជាមួយព្រះនិងជាមួយគ្នាទៅវិញទៅមក។

តើអ្វីជារបស់មានតម្លៃរបស់អ្នក? ទាំងនេះមានសក្តានុពលក្នុងការបង្កើតគម្លាតនៃទំនាក់ទំនងជាមួយព្រះនិងដៃគូរបស់អ្នក។ ភរិយាជាច្រើនបានទួញសោកថា ប្តីរបស់ពួកគេចំណាយពេលវេលាច្រើនក្នុងការធ្វើការងារ មើលកីឡា ចំណាយពេលជាមួយអ៊ិនធើណេត ឬលេងវីដេអូហ្គេម។ មានស្វាមីជាច្រើនមានអារម្មណ៍ចូលចិត្តផ្ទះ ការដើរទិញឥវ៉ាន់ ផលិតផលថែរក្សាសម្ផស្សជាដើម ទទួលបានការយកចិត្តទុកដាក់ពីភរិយាច្រើនជាងពួកគេធ្វើ។ ទ្រព្យសម្បត្តិនិងរបស់មានតម្លៃមានកន្លែងសមរម្យសម្រាប់ពួកវា (ធីម៉ូ១ថេ ៦:១៧)។ ដៃគូនីមួយៗត្រូវអធិដ្ឋាន ហើយយល់ដឹងអំពីវិន័យនៃភាពសាមញ្ញនឹងមានលក្ខណៈដូចម្តេចនៅក្នុងអាពាហ៍ពិពាហ៍របស់ពួកគេ។

គូស្វាមីភរិយាខ្លះប្រហែលជាមានអារម្មណ៍ថា ត្រូវបានត្រាស់ហៅឲ្យលក់អ្វីៗទាំងអស់ដែលពួកគេមាន  ដូច្នេះ ពួកគេអាចផ្តោតលើនគរព្រះដូចជាពួកសាវ័កបានធ្វើដែរ (លូកា ១២: ៣២-៣៣)។ អ្នកផ្សេងទៀតប្រហែលជាមានអារម្មណ៍ថា ត្រូវបានត្រាស់ហៅឲ្យលះបង់របស់មានតម្លៃមួយចំនួន (ម៉ាថាយ ១៩:២១) ឬអនុវត្តការចេះស្កប់ចិត្តជាមួយអ្វីគ្រប់យ៉ាង (១ កូរិនថូស ៧:៣១)។ យើងត្រូវតែប្រយ័ត្នកុំថ្កោលទោសអ្នកដទៃចំពោះការជឿជាក់របស់ពួកគេនៅក្នុងផ្នែកនេះ (ម៉ាថាយ ៧:១-២)។ ព្រះគ្រីស្ទបានត្រាស់ហៅពួកសាវ័កទាំងអស់របស់ទ្រង់កុំឲ្យប្រមូលទុក (ម៉ាថាយ ៦:១៩)។ តើព្រះបានត្រាស់ហៅអ្នកឲ្យអនុវត្តវិន័យនៃភាពសាមញ្ញ ដើម្បីការពារដួងចិត្តរបស់អ្នកនៅក្នុងអាពាហ៍ពិពាហ៍យ៉ាងដូចម្តេចខ្លះ?

### ដើម្បីឲ្យមានភាពស្មោះត្រង់ខាងផ្នែកហិរញ្ញវត្ថុ ប្តីប្រពន្ធត្រូវតែអនុវត្តការរស់នៅដោយគ្មានបំណុល

គោលការបន្ទាប់ ប្តីឬប្រពន្ធត្រូវតែអនុវត្តការរស់នៅដោយមិនជាប់បំណុល រ៉ូម១៣:៨ *កុំឲ្យជំពាក់អ្វីដល់អ្នកណាឡើយ ជំពាក់បានតែសេចក្តីស្រឡាញ់ ដល់គ្នាទៅវិញទៅមកប៉ុណ្ណោះ ដ្បិតអ្នកដែលស្រឡាញ់ដល់គេ នោះបានធ្វើសំរេចតាមក្រិត្យវិន័យហើយ (ព្រះគម្ពីរបកប្រែចាស់)*។ ព្រះគម្ពីរបកប្រែថ្មីបកប្រែថា *កុំឲ្យនៅជាប់ដោយបំណុលឡើយ បំណុលដែលអាចបន្តជំពាក់បានគឺជា សេចក្តីស្រលាញ់ចំពោះគ្នាទៅវិញទៅមក*។

វាគួរឲ្យចាប់អារម្មណ៍ខ្លាំងណាស់ក្នុងការពិចារណាពីផលប៉ះពាល់ជាក់ស្តែងនៃខគម្ពីរនេះ។ មនុស្សជាច្រើនចង់ស្រឡាញ់អ្នកដទៃតាមរយៈការឲ្យ ឬថ្វាយដោយសេរីនិងការបម្រើយ៉ាងខ្លាំង ប៉ុន្តែមានអារម្មណ៍ថា ពួកគេមិនអាចធ្វើបានដោយសារតែបំណុល។ ពួកគេមានការបង់ថ្លៃផ្ទះ បង់រំលោះឡាន បង់ថ្លៃមហាវិទ្យាល័យ  ការទូទាត់កាតឥណទានជាដើម ដែលឃុំឃាំងពួកគេពីការបង់ថ្លៃ «ការបន្តជំពាក់បំណុលនៃសេចក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក» របស់ពួកគេ។

ដើម្បីផ្តល់ឬថ្វាយដោយសេរីនិងបម្រើយ៉ាងទូលំទូលាយ គូស្វាមីភរិយាត្រូវសងបំណុលរបស់ពួកគេនិងអនុវត្តការរស់នៅដោយមិនជំពាក់បំណុល។ ការនេះអាចតម្រូវឲ្យមានការផ្លាស់ប្តូរជីវិតដ៏សំខាន់។ សម្រាប់អ្នកណាដែលនៅតែបន្តទៅមហាវិទ្យាល័យ ឬបញ្ចប់ការសិក្សានៅសាលា វាអាចមានន័យថាកំពុងកាត់បន្ថយតម្លៃ ហើយអាចមានកិត្តិនាមតិចជាង ដើម្បីកាត់បន្ថយបំណុល។ វាអាចមានន័យថាបង្កើតធនធានដោយរកវិធី ដើម្បីបន្ថយបំណុលនៅមហាវិទ្យាល័យតាមរយៈការទទួលបានអាហារូបករ

ណ៍ ធ្វើការកំឡុងពេលនៅរៀន ការពន្យារពេលដែលត្រូវចំណាយពេលបញ្ចប់ការរស់នៅដោយមានតម្លៃថោកៗជាដើម ។ល។

សម្រាប់អ្នកដទៃ ការនៅជំពាក់បំណុលអាចមានន័យថា ការទិញឡានប្រើរួចហើយចៀសវាងការបង់ថ្លៃឡាន។ ខ្ញុំបានឮកម្មវិធីទូរទស្សន៍ដ៏ល្បីមួយនិយាយថា «ខ្ញុំមិនដែលទិញឡានថ្មីទេ! វាធ្លាក់ថ្លៃរាប់ពាន់ដុល្លារភ្លាមៗបន្ទាប់ពីបានចេញពីឃ្លាំង។ ខ្ញុំចាំអ្នកផ្សេងទិញវាថ្មី ហើយបន្ទាប់មកខ្ញុំទិញវាតពីគេវាមានតម្លៃថោកជាងជាមួយនឹងចំងាយតិចទៀតផង»។

សម្រាប់អ្នកផ្សេងទៀត វាអាចមានន័យថា ការជួលជំនួសឲ្យការទិញផ្ទះឬមិនទិញ «ផ្ទះក្នុងក្តីសុបិន» របស់ពួកគេ។ វាគួរតែត្រូវបានគេកត់សម្គាល់ថា ទោះបីជាបទដ្ឋាននៅក្នុងសង្គមសព្វថ្ងៃនេះ គឺការមានផ្ទះជារបស់ផ្ទាល់ខ្លួ តែប្រហែលជាវាមិនមែនព្រះបន្ទូលរបស់ព្រះសម្រាប់អ្នកទេ។ អ័ប្រាហាំមិនដែលមានផ្ទះផ្ទាល់ខ្លួនទេ គាត់រស់នៅក្នុងតង់ទោះបីគាត់ជាអ្នកមានម្នាក់ក៏ដោយ (ហេព្រើរ ១១: ៩)។ វាក៏ជារឿងធម្មតាដែរនៅសម័យអ័ប្រាហាំដែលគាត់អាចមានកម្មសិទ្ធផ្ទាល់ខ្លួន ប៉ុន្តែគាត់បានសំរេចចិត្តមិនមែនធ្វើវា ពីព្រោះគាត់បានឃើញខ្លួនគាត់ជាអ្នកធ្វើដំណើរម្នាក់កំពុងរង់ចាំផ្ទះរបស់គាត់នៅឯស្ថានសួគ៌។ ហេព្រើរ ១១:៩-១០ និយាយអំពីគាត់ថា៖

*៩ ដោយសារសេចក្ដីជំនឿ នោះលោកបានស្នាក់នៅក្នុងស្រុក ដែលទ្រង់សន្យាឲ្យ ដូចជានៅប្រទេសដទៃ ក៏នៅតែក្នុងត្រសាល ជាមួយនឹងអ៊ីសាក ហើយនឹងយ៉ាកុប ជាអ្នកគ្រងសេចក្ដីសន្យាដដែលទុកជាមរដកជាមួយគ្នា១០ ពីព្រោះលោករង់ចាំក្រុង១ ដែលមានឫសជញ្ជាំង ដែលព្រះទ្រង់ជាអ្នកគូរ ហើយជាជាងសង់ ។*

ព្រះគ្រីស្ទក៏មិនមានផ្ទះផ្ទាល់ខ្លួនដែរ។ វាប្រហែលជាអាចរារាំងសមត្ថភាពរបស់ទ្រង់ក្នុងការគ្រប់គ្រង។ មានពេលមួយទ្រង់បានប្រកាសថា *«កញ្ជ្រោងមានរូងវាហើយសត្វហើរលើអាកាសក៏មានសំបុកតែកូនមនុស្សគ្មានកន្លែងកើយក្បាលទេ» (លូកា ៩:៥៨)*។ វាជាការអនុវត្តសាមញ្ញមួយនៅក្នុងសតវត្សរ៍ជាច្រើនសម្រាប់អ្នកធ្វើព័ន្ធកិច្ចដែលមិនមានកម្មសិទ្ធិផ្ទាល់ខ្លួន ដើម្បីឲ្យមានច្រើនសម្រាប់គោលបំណងរបស់ព្រះអម្ចាស់។

នៅពេលណាដែលមនុស្សម្នាក់ជំពាក់បំណុល គាត់ជាទាសកររបស់អ្នកឲ្យខ្ចីប្រាក់ (សុភាសិត ២២:៧) ដែលភ្ជាប់មកជាមួយការរឹតត្បិត។ ទោះជាយ៉ាងណាក៏ដោយ បទគម្ពីរបានបញ្ជាឲ្យយើងធ្វើជាទាសកររបស់ព្រះតែមួយប៉ុណ្ណោះ (ម៉ាថាយ ៦:២៤) និងចៀសវាងកុំឲ្យធ្វើជាទាសកររបស់អ្នកដទៃ (១ កូរិនថូស៧:២៣)។ ជារឿយៗ បំណុលនឹងរារាំងភាពស្មោះត្រង់របស់អ្នកពីព្រះ ហើយឃុំឃាំងអ្នកពីការបន្តសងបំណុលរបស់អ្នកចំពោះការស្រឡាញ់ដល់អ្នកដទៃ (រ៉ូម ១៣: ៨)។

តើព្រះជាម្ចាស់កំពុងត្រាស់ហៅអ្នកឲ្យអនុវត្តការរស់នៅដោយគ្មានបំណុលឬ?

## ដើម្បីឲ្យមានភាពស្មោះត្រង់ខាងផ្នែកហិរញ្ញវត្ថុ ប្ដីឬប្រពន្ធត្រូវតែអនុវត្តការបង្កើនការថ្វាយរបស់ ពួកគេដល់កិច្ចការរបស់ព្រះ

គោលការណ៍ចុងក្រោយដែលគូស្វាមីភរិយាត្រូវតែអនុវត្ត ដើម្បីភាពស្មោះត្រង់នឹងហិរញ្ញ

វត្ថុរបស់ពួកគេគឺបន្តស្វែងរកការបង្កើននូវការថ្វាយ។ ជាធម្មតានៅពេលដែលគ្រីស្ទបរិស័ទទទួលបានប្រាក់កាន់តែច្រើនពួកគេឆ្លើយតបដូចជាលោកីយ៍នេះអញ្ចឹងដែរ។ ពួកគេបានដាក់ប្រាក់របស់ពួកគេទៅទិញផ្ទះធំជាងមុន ឡានល្អជាង សម្លៀកបំពាក់ថ្មី ទូរស័ព្ទថ្មីជាងគេបំផុត និងឧបករណ៍អេឡិចត្រូនិកជាដើម។ ទោះជាយ៉ាងណា ព្រះគម្ពីរបង្រៀនថាព្រះប្រទានពរដល់យើង ដូច្នេះ យើងអាចប្រទានពរដល់អ្នកផ្សេងផងដែរ (២ កូរិនថូស៨:១៤-១៥ លោកុប្បត្តិ ១២:២) ហើយថាយើងគួរតែបន្តបង្កើនការឲ្យឬថ្វាយរបស់យើង។ ស្តាប់អ្វីដែលសាវ័កប៉ុលបានប្រាប់ដល់ពួកជំនុំកូរិនថូសអំពីការថ្វាយៈ

*១ ឥឡូវនេះ ខាងឯការរៃប្រាក់សំរាប់ពួកបរិសុទ្ធ នោះចូរឲ្យអ្នករាល់គ្នាធ្វើ ដូចជាខ្ញុំបានផ្តាំទុកក្នុងពួកជំនុំនៅស្រុកកាឡាទីទាំងប៉ុន្មានដែរ ២ គឺរាល់តែអាទិត្យ ក្នុងថ្ងៃដំបូង នោះត្រូវឲ្យអ្នករាល់គ្នាប្រមូលដាក់ទុកនូវអ្វីៗដោយឡែក តាមដែលព្រះបានចំរើនឲ្យដើម្បីកាលណាខ្ញុំមកដល់នោះមិនបាច់នឹងរៃទៀត (១កូរិនថូស១៦:១-២)*។

សាវ័កប៉ុលបានប្រាប់ដល់ពួកអ្នកនៅក្រុងកូរិនថូសឲ្យថ្វាយដូចជាព្រះបានចម្រើនពួកគេឡើងដែរ ឬវាក៏អាចត្រូវបានបកប្រែថា «នៅក្នុងការរក្សាជាមួយប្រាក់ចំណូលរបស់អ្នកដែរ» ។ នៅពេលព្រះចម្រើនគូស្វាមីភរិយា ពួកគេគួរតែបន្ថែមការថ្វាយដែរ។ ជាក់ស្តែង សាវ័កប៉ុលបានបង្រៀនគោលការណ៍ដដែលនេះនៅក្នុង ២កូរិនថូស ៨:៧ ថា *«ដើម្បីឲ្យអ្នករាល់គ្នាបានធ្វើគុណនេះរឹតតែច្រើនឡើង ដូចជាបានចំរើនក្នុងគ្រប់សេចក្តីឯទៀត គឺក្នុងសេចក្តីជំនឿ ពាក្យសំដី ចំណេះ សេចក្តីឧស្សាហ៍គ្រប់ជំពូក ហើយក្នុងសេចក្តីស្រឡាញ់របស់អ្នករាល់គ្នាដល់យើងខ្ញុំដែរ»*។ គាត់បាននិយាយតាមរបៀបដូចគ្នាដែលគ្រីស្ទបរិស័ទបន្តស្វែងរកភាពល្អនៅក្នុងព្រះគុណរបស់ព្រះ នោះពួកគេគួរតែបន្តស្វែងរកភាពល្អនៅក្នុងព្រះគុណនៃការថ្វាយផងដែរ។

នៅពេលគូស្វាមីភរិយារៀបការ វាគួរតែជាគោលដៅរបស់ពួកគេ ដើម្បីរីកចម្រើនក្នុងការថ្វាយរបស់ពួកគេជារៀងរាល់ឆ្នាំ ប្រសិនបើជាព្រះហឫទ័យព្រះជាម្ចាស់។ ពួកគេគួរតែពិនិត្យមើលហិរញ្ញវត្ថុរបស់ពួកគេជាទៀងទាត់ ហើយដឹងថាប្រសិនបើព្រះជាម្ចាស់កំពុងត្រាស់ហៅពួកគេឲ្យបង្កើនតង្វាយរបស់ពួកគេ។ ជាមួយការនិយាយបែបនោះ ព្រឹត្តិការណ៍ដែលមិនបានគ្រោងទុកឬការធ្លាក់ចុះនៃប្រាក់ចំណូលអាចតម្រូវឲ្យមានការថយនៃការថ្វាយដែរ។ ប៉ុន្តែជាទូទៅ បំណងព្រះហឫទ័យរបស់ព្រះគឺសម្រាប់គូស្វាមីភរិយារីកចម្រើនក្នុងការថ្វាយ ។

តើអ្នកកំពុងប្រាថ្នានិងព្យាយាម ដើម្បីឲ្យរីកចម្រើនក្នុងការថ្វាយរបស់អ្នកឬទេ? តើមានការផ្លាស់ប្តូរអ្វីខ្លះដែលត្រូវធ្វើ ដើម្បីឲ្យថ្វាយកាន់តែច្រើន?

## សរុបសេចក្តី

ព្រះដែលជាចៅហ្វាយរបស់យើង គឺកំពុងយាងត្រឡប់មកវិញ ហើយនៅពេលដែលទ្រង់មដល់នោះនឹងមានការប្រកាសពីភាពស្មោះត្រង់ផ្នែកហិរញ្ញវត្ថុរបស់យើង។ តើអ្នកធ្លាប់ជាអ្នកបម្រើស្មោះត្រង់នៃប្រាក់របស់ព្រះជាម្ចាស់ឬទេ? ប្រសិនបើគូស្វាមីភរិយានឹងក្លាយជាអ្នកស្មោះត្រង់ផ្នែកហិរញ្ញវត្ថុ នោះពួកគេត្រូវតែយល់និងអនុវត្តតាមផែនការរបស់ព្រះសម្រាប់ហិរញ្ញវត្ថុរបស់ពួកគេ។

១. ដើម្បីឲ្យមានភាពស្មោះត្រង់ខាងផ្នែកហិរញ្ញវត្ថុ ប្ដីឬប្រពន្ធត្រូវតែប្រើទ្រព្យសម្បត្តិរបស់ពួកគេដើម្បីយកឈ្នះព្រលឹងថ្វាយដល់ព្រះគ្រីស្ទ។

២. ដើម្បីឲ្យមានភាពស្មោះត្រង់ខាងផ្នែកហិរញ្ញវត្ថុ ប្ដីឬប្រពន្ធត្រូវតែផ្ដោតទៅលើព្រះពររបស់ព្រះដល់អ្នកដែលថ្វាយ។

៣. ដើម្បីឲ្យមានភាពស្មោះត្រង់ខាងផ្នែកហិរញ្ញវត្ថុ ប្ដីឬប្រពន្ធមិនត្រូវស្រឡាញ់ប្រាក់ទេ។

៤ដើម្បីឲ្យមានភាពស្មោះត្រង់ខាងផ្នែកហិរញ្ញវត្ថុ ប្ដីឬប្រពន្ធត្រូវតែអនុវត្តការរស់នៅដោយវិន័យនៃភាពសាមញ្ញ។

៥. ដើម្បីឲ្យមានភាពស្មោះត្រង់ខាងផ្នែកហិរញ្ញវត្ថុ ប្ដីឬប្រពន្ធត្រូវតែអនុវត្តការរស់នៅដោយមិនជាប់បំណុល។

៦. ដើម្បីឲ្យមានភាពស្មោះត្រង់ខាងផ្នែកហិរញ្ញវត្ថុ ប្ដីឬប្រពន្ធត្រូវតែអនុវត្តការបង្កើនការថ្វាយដល់កិច្ចការរបស់ព្រះជាម្ចាស់។

**កិច្ចការផ្ទះ**

ឆ្លើយសំនួរ និងពិភាក្សាជាមួយគ្នា

១. តើមានអ្វីថ្មីឬលេចចូលគំនិតរបស់អ្នកនៅក្នុងវគ្គនេះ? តើនៅក្នុងរបៀបណាខ្លះដែលអ្នកទទួលបានការជំរុញឬលើកទឹកចិត្ត? តើមានចំណុច ឬគំនិតណាដែលអ្នកមិនយល់ស្របឬទេ?

២. ជាធម្មតានៅក្នុងអាពាហ៍ពិពាហ៍នីមួយៗ មានអ្នកសន្សំនិងអ្នកចំណាយ។ ការវែកញែកការនេះហើយនិយាយអំពីវាជាមុនអាចជួយការពារអាពាហ៍ពិពាហ៍របស់អ្នកពីស្នាមជាំខ្លះៗ និងស្នាមរបួសនៅតាមផ្លូវដែលដើរជាមួយគ្នា។ តើអ្នកជាធម្មតាប្រើប្រាក់របស់អ្នកយ៉ាងដូចម្ដេច? តើអ្នកចំណាយវាទៅលើអ្វីខ្លះ? តើអ្នកសន្សំបានប៉ុន្មានភាគរយ? តើអ្នកថ្វាយភាគរយដល់ការងាររបស់ព្រះជាម្ចាស់ប៉ុន្មានភាគរយ? ចុះដៃគូរបស់អ្នកវិញ?

៣. តើអ្នកណាដែលអ្នកពិចារណាពីអ្នកចំណាយនិងអ្នកសន្សំនៅក្នុងទំនាក់ទំនង? តើអ្នកមានការព្រួយបារម្ភអំពីទម្លាប់នៃការចំណាយឬការសន្សំរបស់អ្នកឬទេ? តើអ្នកអាចធ្វើឲ្យប្រសើរឡើងនូវការចំណាយនិងសន្សំរបស់អ្នកយ៉ាងដូចម្តេច?

៤. តើអ្នកមានបារម្ភពីការចំណាយរបស់ប្តីឬប្រពន្ធអ្នកឬទម្លាប់នៃការសន្សំឬទេ? តើក្នុងវិធីណាដែលប្តីឬប្រពន្ធរបស់អ្នកអាចអភិវឌ្ឍការចំណាយនិងការសន្សំរបស់គេបាន?

៥. តើអ្វីខ្លះដែលអ្នកនឹងពិចារណាអំពីរបស់មានតម្លៃដែលមានសក្តានុពលអាចលួចយកដួងចិត្តអ្នកពីព្រះនិងដៃគូរបស់អ្នកបាន? នេះអាចជាអ្វីដែលប្រើប្រាស់គំនិតរបស់អ្នកនិងពេលវេលារបស់អ្នកដូចជា៖ ទំនាក់ទំនង អ៊ីនធឺណែត សាលារៀន សម្លៀកបំពាក់ ភាពយន្ត តន្ត្រី វីដេអូហ្គេម ប្រាក់ ការងារ ភាពជោគជ័យជាដើម។ តើអ្នកមានអារម្មណ៍ថា ព្រះកំពុងត្រាស់ហៅអ្នកឲ្យមានវិន័យច្រើនជាងនៅក្នុងផ្នែកទាំងនេះដោយរបៀបណា? ចុះដៃគូរបស់អ្នកវិញ?

៦. សូមស្រមៃថាអ្នកបានទៅជិត ដើម្បីជួយដល់គ្រីស្ទបរិស័ទដែលទទួលការបៀតបៀននៅប្រទេសកូរ៉េខាងជើង។ គ្រីស្ទបរិស័ទនៅទីនោះត្រូវបានគេចាប់រំលោភ សម្លាប់ និងចាប់ដាក់គុកជារៀងរាល់ថ្ងៃ។ ហិរញ្ញវត្ថុត្រូវការជាចាំបាច់ ដើម្បីផ្គត់ផ្គង់ដល់បេសកជននៅផែនដីដើម្បីបង្រៀនព្រះបន្ទូល នាំព្រះគម្ពីរទៅក្នុងប្រទេស ដើម្បីបម្រើដល់អ្នកធ្វើទុក្ខបុកម្នេញនិងត្រូវគេជិះជាន់។ តើអ្នកបានប្តេជ្ញាចិត្តជួយដល់ករណីនេះសម្រាប់រយៈពេលប្រាំឆ្នាំខាងមុខដោយភ្ជាប់ជាមួយការថ្វាយដោយស្មោះត្រង់ដល់ព្រះវិហាររបស់អ្នកដែរទេ?។ តើអ្នកអាចផ្លាស់ប្តូររបៀបរស់នៅបែបណាឥឡូ

វនេះ ដើម្បីរស់នៅកាន់តែសាមញ្ញ ដើម្បីអាចថ្វាយឲ្យកាន់តែច្រើន? តើអ្នកនិងដៃគូរបស់អ្នកអាចសន្សំសំចៃបានយ៉ាងដូចម្តេច? សូមពិចារណាថាអ្នកទាំងពីរកំពុងធ្វើការលើកលែងដោយអ្នកដឹងថាដៃគូរបស់អ្នកមិនមានការងារធ្វើ។

៧. សូមពិចារណាពីលទ្ធភាពដែលអ្នកនិងប្តីឬប្រពន្ធរបស់អ្នកនឹងមានកូនក្នុងរយៈពេលពីរឆ្នាំហើយអ្នកនឹងត្រូវរស់នៅលើប្រាក់ចំណូលតែម្នាក់។ តើអ្នកអាចរស់នៅដោយមានចំណូលតែម្នាក់បានឬទេ? តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីកាត់បន្ថយចំណាយ និងជំរុញការសន្សំកាន់តែច្រើន? តើអ្នកសុខចិត្តរស់នៅក្នុងអាផាតមិនជំនួសឲ្យផ្ទះឬទេ? តើមានបំណុលដែលមានយូរមកហើយដែលវាអាចជាការប្រុងប្រយ័ត្នក្នុងការសងបំណុលឥឡូវនេះទេ? តើមានការបណ្តុះបណ្តាល សាលា ឬការត្រៀមរៀបចំផ្សេងទៀតដែលអ្នកគួរតែបំពេញ ដើម្បីឲ្យមានស្ថេរភាពសេដ្ឋកិច្ចបន្ថែមទៀតនាពេលអនាគតឬទេ? សូមពិចារណាថាវាតែងតែល្អសម្រាប់ការអនុវត្តមួយជីវិតចំពោះការគ្រប់គ្រងប្រាក់ ទោះបីជាអ្នកមានប្រាក់ចំណូលតែម្នាក់ មិនត្រឹមតែសម្រាប់ការមានផ្ទៃពោះទេ តែមានជំងឺ ការបាត់បង់ការងារ បញ្ហាដែលមិនអាចមើលឃើញទុកជាមុនជាដើម។ល។ ចូរសរសេរចុះនូវផែនការដើម្បីត្រៀមរស់នៅលើប្រាក់ចំណូលតែម្នាក់ក្នុងអាពាហ៍ពិពាហ៍ ។

៨. សូមពិចារណាពីលទ្ធភាពនៃការធ្វើជាដៃគូដែលតែងតែចង់បង្កើនការថ្វាយហិរញ្ញវត្ថុរបស់ពួកគេដល់កិច្ចការរបស់នគរព្រះ។ ការអនុវត្តដ៏ឈ្លាសវៃក្នុងការពិចារណាជាមួយនឹងការថ្វាយរបស់អ្នក គឺត្រូវចាប់ផ្តើមដោយការថ្វាយដង្វាយមួយភាគក្នុងដប់ ហើយនៅពេលដែលព្រះចម្រើនដល់អ្នកសូមបង្កើនវាឡើង (១ កូរិនថូស ១៦:២ ២កូរិនថូស៨:៧) ។ សូមអធិស្ឋានហើយសួរដល់ព្រះថា តើភាគរយប៉ុន្មានដែលត្រូវចាប់ផ្តើមជាមួយការថ្វាយរបស់អ្នក ហើយតើភាគរយដែលអ្នកចង់ទទួលបានដោយការរស់នៅសាមញ្ញក្នុងរយៈពេលប្រាំឆ្នាំខាងមុខ?

៩. សុភាសិត ២៧:២៣-២៤ ចែងថា «២៣ ចូរមានចិត្តខ្នះខ្នែងឲ្យស្គាល់សណ្ឋាននៃហ្វូងចៀម ឯង ហើយឲ្យថែមើលហ្វូងគោឯងឲ្យល្អចុះ២៤ ដ្បិតទ្រព្យសម្បត្តិមិនស្ថិតស្ថេរនៅជាដរាបទេ តើមកុដ ស្តេចនៅជាប់អស់ទាំងដំណតទៅឬ»។ វាគឺជាការអនុវត្តដ៏ល្អមួយ ដើម្បីគ្រប់គ្រងប្រាក់ ដូច្នេះអ្នកដឹងពីចំនួនទឹកប្រាក់ដែលអ្នកមានកន្លែងដែលត្រូវចំណាយនិងគោលដៅរយៈពេលខ្លីនិងរយៈពេលវែងរបស់អ្នក សម្រាប់វា។ ប្រសិនបើអ្នកតែងតែមិនដឹងពីស្ថានភាពនៃហ្វូងចៀមរបស់អ្នក ការបាត់បង់ដ៏ធំមួយអាចបង្ក ឲ្យមានភាពតានតឹងដែលមិននឹកស្មានដល់ចំពោះគ្រួសារអ្នក។

ចូរធ្វើការគ្រប់គ្រងថវិកាគំរូមួយដាក់ទៅក្នុងការពិចារណាថា អ្នកបានរៀបការរួចហើយកំពុងរស់នៅក្នុងអាផាតមិនឬផ្ទះ។ រួមបញ្ចូលរបស់របរមួយចំនួនដូចជា៖ មួយភាគដប់និងដង្វាយ ការសន្សំប្រាក់ទូរស័ព្ទចល័ត ការជួលឬការដាក់បញ្ចាំ ហ្គាស អាហារ ធានារ៉ាប់រង ភាពសប្បាយរីករាយជាដើម។ ល។

១០. តើត្រូវចំណាយប៉ុន្មាន ដើម្បីរស់នៅប្រកបដោយផាសុខភាព ការសន្សំនិងថ្វាយដង្វាយដោយសប្បុរសដល់ព្រះជាម្ចាស់? តើមានការព្រួយបារម្ភនិង ឬការកែសំរួលដែលអាចនឹងត្រូវការដែរឬទេ?

១១. បន្ទាប់ពីបញ្ចប់វគ្គនេះតើអ្នកមានអារម្មណ៍ថា ព្រះកំពុងត្រាស់ហៅអ្នកឲ្យអធិស្ឋានសម្រាប់អាពាហ៍ពិពាហ៍របស់អ្នកយ៉ាងដូចម្តេច? សូមចំណាយពេលខ្លះអធិស្ឋាន។

# មូលដ្ឋានគ្រឹះទី៧៖ ភាពស្និទ្ធស្នាលនៅក្នុងអាពាហ៍ពិពាហ៍

តើគូស្វាមីភរិយាអាចអភិវឌ្ឍភាពស្និទ្ធស្នាលក្នុងអាពាហ៍ពិពាហ៍ដោយរបៀបណា?

អាពាហ៍ពិពាហ៍គួរតែជាទំនាក់ទំនងយ៉ាងជិតស្និទ្ធបំផុតដែលអ្នកណាម្នាក់ជួបប្រទះក្នុងជីវិត។ វាគួរតែមានភាពស្និទ្ធស្នាលជាងទំនាក់ទំនងមិត្តភាព ទំនាក់ទំនងរវាងកូនស្រីនិងម្តាយ ទំនាក់ទំនងរវាងឪពុកនិងកូនប្រុស ទំនាក់ទំនងរវាងមិត្តប្រុសនិងមិត្តស្រីជាដើម។ ប៉ុន្តែគួរឲ្យស្តាយដែលគូស្វាមីភរិយាជាច្រើនតែងតែមានអារម្មណ៍ដាច់ឆ្ងាយនិងឯកោនៅក្នុងអាពាហ៍ពិពាហ៍។ពីព្រោះបុរសគឺជារាងកាយ ព្រលឹងនិងវិញ្ញាណ (១ថែស្សាឡូនីចទី៥:២៣, ហេព្រើរ ៤:១២) គូស្វាមីភរិយាត្រូវតែបណ្តុះផ្នែកនីមួយៗនៃខ្លួនរបស់ពួកគេ ដើម្បីអភិវឌ្ឍភាពស្និទ្ធស្នាល។ ពួកគេត្រូវបណ្តុះមិត្តភាព (ព្រលឹង) ភេទរបស់ពួកគេ (រាងកាយ) និងខាងព្រលឹងវិញ្ញាណ (ស្មារតី) ក្នុងអាពាហ៍ពិពាហ៍។ ប្រសិនបើមួយក្នុងចំណោមសាមគ្គីភាពទាំងបីនេះត្រូវបានបាត់ នោះគូស្វាមីភរិយានឹងខ្វះភាពស្និទ្ធស្នាលដែលជាព្រះហឫទ័យរបស់ព្រះ។ ដូច្នេះ សាមគ្គីភាពទាំងបីត្រូវតែបន្តបណ្តុះជាប្រចាំ។

តើគូស្វាមីភរិយាអាចអភិវឌ្ឍចំណុចទាំង៣នៃភាពស្និទ្ធស្នាលនេះដោយរបៀបណា?

**ភាពស្និទ្ធស្នាលនៅក្នុងមិត្តភាព**

នៅពេលដែលយើងពិចារណាអំពីការអភិវឌ្ឍភាពស្និទ្ធស្នាលនៅក្នុងសម្ព័ន្ធភាព យើងត្រូវពិចារណាអំពីសម្ព័ន្ធភាពរវាងព្រះយេស៊ូវគ្រីស្ទជាមួយនឹងពួកជំនុំនៅក្នុង យ៉ូហាន១៥:១៥៖

*ខ្ញុំមិនហៅជាអ្នកបំរើទៀត ពីព្រោះអ្នកបំរើគេមិនដឹងជាចៅហ្វាយធ្វើអ្វីទេ គឺខ្ញុំហៅអ្នករាល់គ្នាថាជាសំឡាញ់វិញ ពីព្រោះខ្ញុំបានឲ្យអ្នករាល់គ្នាដឹងគ្រប់ការទាំងអស់ ដែលខ្ញុំឮពីព្រះវរបិតាខ្ញុំមក។*

តើអ្វីដែលធ្វើឲ្យមានភាពខុសគ្នារវាងការធ្វើជាអ្នកបំរើរបស់ព្រះគ្រីស្ទនិងមិត្តសម្លាញ់របស់ទ្រង់? វាជាការពិតដែលថាព្រះគ្រីស្ទបានចែកចាយអ្វីៗទាំងអស់ជាមួយនឹងសម្លាញ់របស់ទ្រង់។ ក្នុងនាមជាពួកជំនុំយើងទាំងពីរ គឺជាកូនក្រមុំរបស់ព្រះគ្រីស្ទ (អេភេសូ ៥: ២៣-២៧) និងជាសម្លាញ់របស់ទ្រង់។ ទ្រង់បានបង្រៀនយើងនូវអាថ៌កំបាំងរបស់ទ្រង់ ជាអ្វីដែលពិភពលោកនេះនឹងមិនយល់ហើយមិនអាចយល់បាន (១ កូរិនថូស ២:១៤) ។ តាមរយៈព្រះបន្ទូលរបស់ទ្រង់និងព្រះវិញ្ញាណបរិសុទ្ធ ទ្រង់បានបង្រៀនយើងពីសេចក្តីពិតអំពីសេចក្តីសង្គ្រោះ ចិត្តមនុស្សលោក ការបង្កើត ទេវតានិងពួកអារក្សនិងអនាគត។ ក្នុងនាមជាព្រះពួកជំនុំយើងជាសម្លាញ់របស់ព្រះគ្រីស្ទ ហើយរាល់ថ្ងៃយើងមានឯកសិទ្ធិដើម្បីបង្កើនភាពស្និទ្ធស្នាលជាមួយទ្រង់តាមរយៈការសិក្សាព្រះបន្ទូលរបស់ទ្រង់ ហើយនិយាយជាមួយទ្រង់នៅក្នុងសេចក្តីអធិស្ឋាន។

ស្រដៀងគ្នានេះដែរ ការអនុវត្តនៃការប្រាស្រ័យទាក់ទងគ្នាតាមរយៈការចែកចាយអំពីជីវិត គំនិត

ការភ័យខ្លាច និងការព្រួយបារម្ភនឹងបង្កើតឲ្យមានចំណងមិត្តភាពរបស់គូស្វាមីភរិយា ហើយនឹង ភាពស្និទ្ធស្នាលផងដែរ។ ជាការពិត វាចាំបាច់ត្រូវមានវិន័យនៅក្នុងវិស័យនេះ។ នៅពេលដែលជីវិតមមាញឹកនឹងការងារ ការគ្រប់គ្រងគ្រួសារ ការចិញ្ចឹមកូន ព្រះវិហារ ចំណូលចិត្តជាដើម នឹងមានរឿងជាច្រើន (រឿងល្អខ្លះ) ដែលអាចរំខានពីការបណ្តុះមិត្តភាព។

ដូចគ្នានេះដែរ ការនេះច្រើនតែកើតឡើងនៅក្នុងទំនាក់ទំនងរបស់យើងជាមួយព្រះ។ តើចាំរឿងម៉ារីនិងម៉ាថាបានដែរឬទេ? ម៉ាថារវល់បម្រើព្រះយេស៊ូវ រីឯម៉ារីអង្គុយស្ងៀមនៅព្រះបាទារបស់ព្រះយេស៊ូវវិញ។ នៅក្នុងរបៀបដូចគ្នានេះដែរ ជាញឹកញាប់យើងធ្វើឲ្យខ្លួនយើងរវល់នឹងរឿងល្អៗ ដែលអាចធ្វើឲ្យយើងធ្វេសប្រហែសទំនាក់ទំនងរបស់យើងជាមួយព្រះជាម្ចាស់បាន។ រឿងនេះក៏អាចកើតឡើងចំពោះប្តីប្រពន្ធរបស់យើងផងដែរ ដែលមិនត្រឹមតែបណ្តាលឲ្យខ្វះភាពស្និទ្ធស្នាលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កឲ្យមានការមិនចុះសម្រុងគ្នានៅក្នុងអាពាហ៍ពិពាហ៍ផងដែរ។

តើគូស្វាមីភរិយាអាចអនុវត្តវិន័យអ្វីខ្លះ ដើម្បីបង្កើតមិត្តភាព?

### ១. គូស្វាមីគួរតែអនុវត្តការញែកពេលរៀងរាល់ថ្ងៃសម្រាប់ចែកចាយនិងស្តាប់ដើម្បីបណ្តុះមិត្តភាពរបស់ពួកគេ

សកម្មភាពគឺល្អ ប៉ុន្តែការចែករំលែកភាពស្និទ្ធស្នាលគួរតែត្រូវបានពង្រីកជាអតិបរមានៅពេលដែលគូស្វាមីភរិយានៅជាមួយគ្នា។ ភាគច្រើនពេលល្ងាច គឺជាពេលវេលាដ៏ល្អបំផុតសម្រាប់ការនេះ បន្ទាប់ពីការងារនិងធ្វើការផ្សេងទៀតត្រូវបានបញ្ចប់។

រឿងផ្ទាល់ ភរិយាខ្ញុំនិងខ្ញុំតែងតែព្យាយាមចាកចេញពីម៉ោងចុងក្រោយឬច្រើនជាងនេះនៅពេលល្ងាចដើម្បីចែកចាយនិងអធិស្ឋាន។ យើងអាចមានពេលវេលាជួបជុំគ្រួសារមុនពេលដែលយើងញ៉ាំអាហារពេលល្ងាច ជជែកគ្នា មើលកម្មវិធីទូរទស្សន៍ជាមួយកូនស្រីរបស់យើងជាដើម ប៉ុន្តែនៅវេលាចុងក្រោយនៃពេលល្ងាចយើងចង់ផ្តោតលើគ្នាទៅវិញទៅមក។

ក្នុងនាមជាដៃគូមានកូនច្រើន វាពិបាកបែងចែកពេលវេលាសម្រាប់ការចែកចាយភាពជិតស្និទ្ធ ប៉ុន្តែវានៅតែសំខាន់ដដែល។ ខ្ញុំបានលឺប្រពន្ធរបស់គ្រូគង្វាលម្នាក់ដែលមានកូនប្រាំនាក់ចែកចាយថា នៅក្នុងផ្ទះរបស់ពួកគេ ក្មេងៗត្រូវនៅក្នុងបន្ទប់របស់ពួកគេត្រឹមម៉ោង ៨ យប់។ ជាធម្មតាគាត់នឹងប្រាប់កូនៗរបស់ពួកគេបន្ទាប់ពីម៉ោង ៨ យប់ថា «ខ្ញុំមិនមែនជាម៉ាក់ទៀតទេ ប៉ុន្តែជាភរិយារបស់ប្តីខ្ញុំ។ «នោះជារបៀបដែលពួកគេគ្រប់គ្រងភាពរស់នៅផ្ទះហើយនៅតែរក្សាភាពស្និទ្ធស្នាលបានថែមទៀត។ វាក៏បានបង្ហាញដល់ក្មេងៗអំពីអាទិភាពនៃទំនាក់ទំនងអាពាហ៍ពិពាហ៍ដែរ។

### ២. គូស្វាមីភរិយាគួរតែប្រុងប្រយ័ត្នចំពោះឃាតករនៃភាពស្និទ្ធស្នាលក្នុងការផ្តោតទៅលើការបណ្តុះមិត្តភាពរបស់ពួកគេ

ក្នុងការពិចារណាពីសារៈសំខាន់នៃពេលវេលាតែម្នាក់ឯង អ្នកគួរតែដឹងពីឃាតករនៃភាពស្និទ្ធ

ស្គាល។ ទោះបីជាខ្ញុំបានលើកឡើងពីការមើលទូរទស្សន៍ជាមួយប្រពន្ធខ្ញុំ ខ្ញុំក៏ដឹងថារឿងនេះមិនបង្កើតភាពស្និទ្ធស្នាលពិតប្រាកដទេ ប៉ុន្តែជាទូទៅជាការរំខានពីវា។ឬចៀសចេញពីភាពស្និទ្ធស្នាលទៅវិញទេ។ ជារឿយៗការមើលទូរទស្សន៍ ការនៅលេងអ៊ិនធឺណែត ការលេងវីដេអូហ្គេម ការនៅលេងទូរស័ព្ទជាដើម វាអាចក្លាយជាវិធីនៃការបង្វែរអារម្មណ៍ឬជៀសចេញពីភាពស្និទ្ធ ស្នាលផងដែរ។

សៀវភៅប្រឹក្សាយោបល់អំពីអាពាហ៍ពិពាហ៍មួយ ភរិយាខ្ញុំនិងខ្ញុំបានអានតាំងពីដំបូងក្នុងអាពាហ៍ពិពាហ៍បានលើកទឹកចិត្តគូស្វាមីភរិយាកុំឲ្យបើកទូរទស្សន៍សម្រាប់ឆ្នាំដំបូងនៃអាពាហ៍ពិពាហ៍។ ឆ្នាំដំបូងនៃអាពាហ៍ពិពាហ៍គឺជាមូលដ្ឋានគ្រឹះសម្រាប់អាពាហ៍ពិពាហ៍ដែលនៅសល់ទៅមុខទៀត។ នៅក្នុងគម្ពីរសញ្ញាចាស់ ទាហានម្នាក់មិនត្រូវបានអនុញ្ញាតឲ្យធ្វើសង្គ្រាមក្នុងឆ្នាំដំបូងនៃអាពាហ៍ពិពាហ៍នោះទេ។ គាត់ត្រូវនៅផ្ទះហើយនាំសុភមង្គលដល់ភរិយារបស់គាត់ (ចោទិយកថា ២៤: ៥)។ វាគឺនៅក្នុងឆ្នាំដំបូងនៃអាពាហ៍ពិពាហ៍ដែលជាគំរូគឺត្រូវបានបង្កើតឡើងទាំងអ្នកដែលមានសុខភាពល្អនិងមិនល្អ។ ប្រសិនបើប្ដីប្រពន្ធបង្កើតគំរូដំបូងនៃការមើលនិងការធ្វើការផ្សេងៗច្រើនជំនួសឲ្យការចែករំលែកនិងចំណាយពេលជាមួយគ្នា វាអាចមានអ្នកទទួលរងគ្រោះថ្នាក់នៅពេលក្រោយក្នុងអាពាហ៍ពិពាហ៍។ វាមិនមែនជារឿងចម្លែកទេសម្រាប់គូស្វាមីភរិយាដែលនិយាយបន្ទាប់ពីរៀបការហើយរយៈពេលជាច្រើនឆ្នាំ « យើងបានដឹងថាយើងពិតជាមិនស្គាល់គ្នាទេ» ។ វាពិតជាសំខាន់ណាស់ដែលដៃគូទាំងនេះបង្កើតគំរូមិនល្អនៅឆ្នាំដំបូងនៅក្នុងអាពាហ៍ពិពាហ៍នៃការចាប់ផ្ដើមរំខានដោយឃាតករនៃភាពស្និទ្ធស្នាល ដែលឃាំងពួកគេពីការស្គាល់គ្នាយ៉ាងពិតប្រាកដ។

ស្គាល់គ្នាទៅវិញទៅមក វាជាការល្អក្នុងការពិចារណាអំពីអាពាហ៍ពិពាហ៍និងជាពិសេសឆ្នាំដំបូងដែលបង្កើតមូលដ្ឋានគ្រឹះសម្រាប់អាពាហ៍ពិពាហ៍ដែលនៅសល់។ តើអ្នកចង់មានអាពាហ៍ពិពាហ៍ដែលដៃគូរបស់អ្នកត្រលប់មកផ្ទះវិញហើយថើបថ្ពាល់អ្នក ហើយបន្ទាប់មកលេងអ៊ិនធឺណែត មើលទូរទស្សន៍ឬទូរស័ព្ទរយៈពេលបីម៉ោងមុនពេលចូលគេងឬទេ? វាជាការល្អគួរតែប្រយ័ត្នចំពោះទំនោរទាំងនេះដែលអាចធ្វើឲ្យគូស្នេហ៍ឈឺចាប់បាន។ ការពារខ្លួនអ្នកពីអ្នកឃាតករនៃភាពស្និទ្ធស្នាល រារាំងពេលវេលារាល់ថ្ងៃទៅផ្ដោតលើការចែករំលែក ការស្ដាប់ និងនៅជាមួយគ្នា។

**៣. គូស្វាមីភរិយាគួរតែរីករាយនឹងសកម្មភាពនៅជាមួយគ្នា ដើម្បីបណ្ដុះមិត្តភាព**

ជាមួយនឹងអ្វីដែលបាននិយាយ តុល្យភាពគឺចាំបាច់នៅក្នុងអាពាហ៍ពិពាហ៍។ គូស្វាមីភរិយាគ្រាន់តែត្រូវការពេលវេលានៃការចែកចាយ និងស្ដាប់គ្នាទៅវិញទៅមក ប៉ុន្តែពួកគេក៏ត្រូវការរីករាយនឹងសកម្មភាពជាមួយគ្នាផងដែរ ដូចជា៖ ការអាន ការហាត់ប្រាណ ការទៅមើលកុន ការធ្វើដំណើរជាដើម។ គួរឲ្យសោកស្ដាយ គូស្វាមីភរិយាជាច្រើនបានរៀបការដោយគិតថា ពួកគេមានសកម្មភាពជាច្រើនដែលពួកគេចូលចិត្តក្នុងការធ្វើជាមួយគ្នា ប៉ុន្តែបន្ទាប់ពីឆ្នាំដំបូងហើយ ពួកគេរកឃើញថាពួកគេពិតជារីករាយនឹងរឿងផ្សេងៗវិញ។ កាលនៅពេលថែចងដំបូង ស្ត្រីនឹងមើលកីឡាជាមួយមិត្តប្រុសរបស់នាងពីព្រោះនាងសប្បាយចិត្តដែលបាននៅជាមួយគាត់។ ទោះជាយ៉ាងណាក៏ដោយ ក្រោយរៀបការហើយនាងនឹងបដិសេធមើលការប្រកួតបាល់ទាត់ថ្ងៃអាទិត្យទៅធ្វើរឿងផ្ទាល់ខ្លួនរបស់នាងវិញ។ ហើយបុរសក៏ដូចគ្នាដែរ

កាលពេលកំពុងចែចង់បុរសនឹងទៅដើរផ្សារទំនើបជាមួយមិត្តស្រីរបស់គាត់ព្រោះគាត់សប្បាយចិត្តដែលបាននៅក្បែរនាង។ ផ្ទុយទៅវិញនៅក្នុងអាពាហ៍ពិពាហ៍គាត់បានបដិសេធដំណើរកំសាន្តនៅថ្ងៃសៅរ៍ដើម្បីនៅផ្ទះវិញ។ វាមិនមែនជារឿងចម្លែកទេដែលចំណង់ចំណូលចិត្តធ្វើឲ្យព្រិលដល់ការពិតនៃមនុស្សម្នាក់ឈានទៅរកការរៀបការហើយគូស្វាមីភរិយាគួរតែដឹងអំពីរឿងនេះ។

មិនថារឿងនេះកើតឡើងរឺអត់នោះទេ វាជាការសំខាន់សំរាប់គូស្វាមីភរិយាក្នុងការស្វែងរកសកម្មភាពដែលពួកគេរីករាយជាមួយគ្នា ជួយរក្សានិងបង្កើនភាពស្និទ្ធស្នាល។ ព្រះគ្រីស្ទបានទៅគ្រប់ទីកន្លែងជាមួយពួកជំនុំក្មេងខ្ចីរបស់ទ្រង់ ពួកសិស្ស និងចែកចាយអ្វីៗទាំងអស់ជាមួយពួកគេ (ម៉ាថាយ ១៧: ១ យ៉ូហាន ១៥:១៥) ។ ដើម្បីការពារអាពាហ៍ពិពាហ៍របស់យើងនិងជួយពួកគេឲ្យរីកចម្រើនឡើង  វាជាការប្រសើរណាស់ក្នុងការគិតហើយរៀបចំផែនការសម្រាប់សកម្មភាពដែលអាចរីករាយជាមួយគ្នាក៏ដូចជាកំណត់កាលបរិច្ឆេទណាត់ជួបប្រចាំសប្តាហ៍ ឬប្រចាំខែ ដើម្បីចែករំលែករឿងទាំងនេះ។ *“គំនិតរបស់មនុស្សឧស្សាហ៍នោះនាំឲ្យបានបរិបូរឡើងតែម្យ៉ាង តែអស់អ្នកណាដែលមានចិត្តរលះរលាំង នោះនឹងបានតែសេចក្តីខ្វះខាតវិញ” (សុភាសិត ២១: ៥)* ។

ជាការពិតណាស់ ប្តីប្រពន្ធជាច្រើនដងនឹងមិនរីករាយជាមួយសកម្មភាពដូចគ្នាទេ។ នេះគឺជារឿងធម្មតា។ ទោះយ៉ាងណាក៏ដោយ ដោយក្តីស្រឡាញ់ចំពោះប្តីឬប្រពន្ធ ពួកគេគួរតែអនុវត្តនៅក្នុងសកម្មភាពជាច្រើនដែលប្តីប្រពន្ធរបស់ពួកគេពេញចិត្ត។ ភរិយាគួរតែមើលការប្រកួតបាល់ទាត់ម្តងម្កាលហើយស្វាមីគួរតែមើលរឿងកំប្លែងបែបមនោសញ្ចេតនាម្តងម្កាលដែរ។ ដោយក្តីស្រឡាញ់យើងគួរតែបម្រើដៃគូរបស់យើងហើយវិធីដ៏ល្អបំផុតមួយ ដើម្បីធ្វើការនេះបានគឺដោយការធ្វើអ្វីដែលគាត់ពេញចិត្ត។ នេះនឹងបង្កើនចំណងមិត្តភាព។

### ៤. គូស្វាមីភរិយាគួរតែបង្កើតការណាត់ជួបប្រចាំសប្តាហ៍ ដើម្បីបណ្តុះភាពស្និទ្ធស្នាលមិត្តភាពរបស់ពួកគេ

លើសពីនេះទៀត ការអនុវត្តដ៏ឈ្លាសវៃសម្រាប់គូស្វាមីភរិយា គឺបង្កើតឲ្យមានរាត្រីណាត់ជួបប្រចាំសប្តាហ៍។ ជ្រើសរើសរាត្រីដ៏ងាយស្រួលនៃសប្តាហ៍ ដើម្បីចេញទៅខាងក្រៅ ហើយធ្វើអ្វីដែលពិសេសៗ។ ចាប់ផ្តើមពីយប់នេះដោយដកចេញនូវភាពមមាញឹកនៃអាជីវកម្មឬធ្វើជំនួញ ហើយនៅពេលដែលយើងមិនបានព្រៀងវាទុកជាមុន នោះវាមិនអាចកើតឡើងតាមពេលកំណត់បានឡើយ។ រាត្រីណាត់ជួបមិនចាំបាច់មានតម្លៃថ្លៃពេកឬសូម្បីតែចំណាយប្រាក់ ទិដ្ឋភាពដ៏សំខាន់បំផុតរបស់វាគឺការចំណាយពេលវេលាមិនមានការរំខានជាមួយគ្នា។

ការពិតដ៏អស្ចារ្យមួយនៃអាពាហ៍ពិពាហ៍ គឺថាវានឹងចំណាយពេលមួយជីវិត ដើម្បីស្គាល់ដៃគូរបស់អ្នកយ៉ាងច្បាស់ចាប់តាំងពីគាត់ឬនាងតែងតែរីកចម្រើននិងផ្លាស់ប្តូរ។ ហេតុដូច្នេះ  ជាវិន័យមួយដែលគ្រោងទុកដ៏ឈ្លាសវៃ ដើម្បីបណ្តុះភាពស្និទ្ធស្នាលនៃមិត្តភាពក្នុងអាពាហ៍ពិពាហ៍។

**ភាពស្និទ្ធស្នាលក្នុងការរួមភេទ**

ចំណុចបន្ទាប់មកទៀតគូស្វាមីភរិយាត្រូវបណ្តុះភាពស្និទ្ធស្នាលតាមរយៈការរួមភេទ។ ព្រះបានផ្តល់និយមន័យដល់ការរួមភេទក្លាយជាមធ្យោបាយដ៏មានឥទ្ធិពលមួយនៃការបង្កើនភាពស្និទ្ធស្នាលក្នុងអាពាហ៍ពិពាហ៍។ ជាការពិត ជាញឹកញាប់វាត្រូវបានគេហៅ «ការរួមភេទជារបៀបមួយនៃការវាយតម្លៃខាងជាសុខភាព» នៃអាពាហ៍ពិពាហ៍។ គូស្វាមីភរិយាដែលខឹងគ្នា នឹងនៅបរិភោគជាមួយគ្នា ទៅមើលកុនជាមួយគ្នា និងទៅព្រះវិហារជាមួយគ្នា ប៉ុន្តែភាគច្រើនមិនរួមភេទជាមួយគ្នាទេ។ ការរួមភេទគឺជារង្វាស់នៃភាពស្និទ្ធស្នាលសម្រាប់គូស្នេហ៍ ហើយក៏ជារបៀបដែលប្តីប្រពន្ធបង្កើនភាពស្និទ្ធស្នាលជាមួយគ្នាដែរ។

ប្រសិនបើគូស្វាមីភរិយារកឃើញខ្លួនឯងនឹងមានសប្តាហ៍កន្លងទៅដោយគ្មានការរួមភេទ វាអាចជាពេលវេលាដ៏ល្អ ដើម្បីវាយតម្លៃទំនាក់ទំនង។ តើប្តីឬប្រពន្ធខ្ញុំនិងខ្ញុំសុខសប្បាយទេ?» «តើខ្ញុំកំពុងតែជួយបំពេញសេចក្តីត្រូវការរបស់គាត់ហើយឬនៅ?»

ក្នុងការពិចារណាអំពីការរួមភេទ វាក៏សំខាន់ផងដែរក្នុងការពិចារណាពីកលល្បិចរបស់សាតាំងនៅក្នុងផ្នែកខ្លះនៃអាពាហ៍ពិពាហ៍។ ខណៈពេលមិនទាន់រៀបការ ថាមពលរបស់វាផ្តោតលើការល្បួងគូស្វាមីភរិយាឆ្ពោះទៅរកការរួមភេទមុនពេលរៀបការ ប៉ុន្តែនៅក្នុងអាពាហ៍ពិពាហ៍ថាមពលរបស់វាផ្តោតលើការល្បួងពួកគេមិនឲ្យរួមភេទ។ គូស្វាមីភរិយាវ័យក្មេងនឹងជួបប្រទះជាញឹកញាប់នូវភាពចម្លែកនេះតាំងពីការរំជើបរំជួល(តណ្ហា)របស់ពួកគេពិបាកទប់ចិត្តមុនពេលរៀបការ។ ប៉ុន្តែនៅក្នុងអាពាហ៍ពិពាហ៍រួបរួម ភាពស្និទ្ធស្នាលខាងផ្លូវភេទមានទំនោរទៅជាស្ងួតនិងមិនស្កិតស្កេរទេ។ សាតាំងចង់រារាំងភាពស្និទ្ធស្នាលរបស់ប្តីប្រពន្ធតាមរយៈខ្វះការរួមភេទ។ យើងនឹងពិចារណាការងាររបស់សាតាំងបន្ថែមទៀតនៅពេលក្រោយក្នុងវគ្គនេះ។

ឥឡូវនេះសូមពិចារណាអំពីគោលបំណងរបស់ព្រះសម្រាប់ការរួមភេទ។

**១. គោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ការរួមភេទ គឺមានអត្ថន័យនៃការរួបរួមនិងភាពស្និទ្ធស្នាលក្នុងអាពាហ៍ពិពាហ៍**

លោកុប្បត្តិ ២:២៤ចែងថា *«ដោយហេតុនោះ បានជាមនុស្សប្រុសនឹងលាចេញពីឪពុកម្តាយខ្លួន ទៅនៅជាប់នឹងប្រពន្ធវិញ ហើយអ្នកទាំង២នោះនឹងត្រឡប់ជាសាច់តែ១សុទ្ធ»* ។ នៅពេលអ្នកនិពន្ធបាននិយាយថាបុរសនិងស្ត្រីក្លាយជា *«សាច់តែមួយ»* គាត់បានសំដៅយ៉ាងត្រង់ទៅលើការរួមភេទ។ នេះត្រូវបានគាំទ្រដោយការពិតដែលថា កូរិនថូសទី១ ៦:១៦ ចែងថា «បុរសដែលរួមដំណេកជាមួយស្រីរកស៊ីផ្លូវភេទអាចក្លាយជា«សាច់តែ១»ជាមួយនាង»។ ទង្វើផ្លូវភេទនេះមានន័យក្លាយជានិមិត្តរូបនៃសាមគ្គីភាព និងភាពស្និទ្ធស្នាលនៅក្នុងអាពាហ៍ពិពាហ៍នឹងពីរបៀបដែលប្តីប្រពន្ធបណ្តុះវាឡើង។ ជាការពិត ការរួមភេទបានប្រើប្រាស់រូបភាពនៃភាពស្និទ្ធស្នាលរបស់ព្រះជាម្ចាស់និងការតាំងសញ្ញាជាមួយនឹងប្រជាជាតិអ៊ីស្រាអែល អេសេគាល១៦:៨ ចែងថា៖

*«គ្រានោះ កាលអញបានដើរតាមទីនោះមើលឯង នោះឃើញថា ដល់ពេលស្រឡាញ់ហើយ ដូច្នេះអញបានយកជាយអាវអញគ្របលើឯង ព្រមទាំងបិទបាំងសណ្ឋានអាក្រាតរបស់ឯង អើ អញបានស្បថ*

*នឹងឯង ហើយតាំងសញ្ញានឹងឯងផង នោះឯងបានត្រឡប់ជារបស់ផងអញ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា"។*

ព្រះបានយកអ៊ីស្រាអែលធ្វើជាប្រពន្ធរបស់ទ្រង់ ដូចជាស្វាមីយកប្រពន្ធព្រហ្មចារីសម្រាប់ទ្រង់ដែរ។ ព្រះផ្តល់អន្តន័យពីការរួមភេទនៅក្នុងអាពាហ៍ពិពាហ៍ គឺជានិមិត្តរូបនៃទំនាក់ទំនងយ៉ាងជិតស្និទ្ធបំផុតនៅក្នុងពិភពលោក ដែលជាទំនាក់ទំនងរបស់យើងជាមួយទ្រង់។ វាគឺជាការរួបរួមដ៏មានឥទ្ធិពលមួយ។ វាគឺទាំងពីរនិមិត្តរូបនៃសាមគ្គីភាពនិងភាពស្និទ្ធស្នាលហើយជាមធ្យោបាយនៃរបៀបដែលគូស្វាមីភរិយាលូតលាស់នៅក្នុងពួកគេ។

### ២. គោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ការរួមភេទ គឺការបង្កើតពូជ

ដូចដែលបានរៀបរាប់ក្នុងវគ្គ១ ព្រះសព្វព្រះហឫទ័យឲ្យគូស្វាមីភរិយាបង្កើតនិងចិញ្ចឹមពូជដែលព្រះសព្វព្រះហឫទ័យ។ សូមពិចារណាខទាំងនេះ៖

*ដូច្នេះ ទ្រង់ក៏បង្កើតមនុស្សឲ្យដូចរូបអង្គទ្រង់ គឺបានបង្កើតគេឲ្យចំនឹងរូបអង្គទ្រង់នោះឯង ក៏បង្កើតគេឡើងជាប្រុសជាស្រី។ ទ្រង់ប្រទានពរដល់គេ ហើយមានបន្ទូលថា ចូរបង្កើតកូនឲ្យចំរើនជាច្រើនឡើងឲ្យមានពេញពាសលើផែនដីចុះ ត្រូវបង្ក្រាបផែនដី ហើយមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាសនឹងជីវិតផងទាំងឡាយដែលកំពីកនៅផែនដីផង។*

កណ្ឌគម្ពីរលោកុប្បត្តិ ១:២៧-៣៨ ៖ *តើទ្រង់មិនបានបង្កើត ឲ្យមានតែ១ទេឬ ទោះបើទ្រង់មានព្រះវិញ្ញាណសល់នៅក៏ដោយ ហើយហេតុអ្វីបានជាបង្កើតតែមួយដូច្នេះ គឺពីព្រោះទ្រង់ស្វែងរកចង់បានពូជបរិសុទ្ធ ដូច្នេះ ចូរប្រយ័ត ចំពោះវិញ្ញាណរបស់ឯងចុះ កុំឲ្យប្រព្រឹត្តដោយមានចិត្តក្បត់ ចំពោះប្រពន្ធដែលបានគ្នា ពីកាលនៅក្រមុំកំឡោះនោះឡើយ (ម៉ាឡាគី២:១៥)។*

### ៣. បំណងព្រះហឫទ័យរបស់ព្រះអម្ចាស់សម្រាប់ការរួមភេទ គឺការរីករាយនិងសប្បាយចិត្ត

ពិចារណាពីខគម្ពីរទាំងនេះ៖

*១៨ សូមឲ្យរន្ធទឹកឯងបានពរ ចូរឲ្យឯងបានរីករាយចំពោះប្រពន្ធដែលបានគ្នាពីកាលក្រមុំកំឡោះចុះ ១៩ ប្រៀបដូចជាក្តាន់ញីដែលគួរស្រឡាញ់ នឹងប្រើសញីសមសួន ត្រូវឲ្យដោះរបស់នាងបានបំពេញចិត្តឯងជាដរាប ហើយត្រូវឲ្យឯងឈ្លក់ចិត្ត នឹងសេចក្តីស្រឡាញ់របស់នាងជានិច្ចផង (សុភាសិត ៥:១៨-១៩)។*

*៦ ឱមាសសំឡាញ់អើយ ឯងស្រស់បស់ល្អ ហើយប្រិមប្រិយ គួររីករាយណាស់ហ្ន៎ ៧ កំពស់ឯងដូចជាដើមលម៉ើ ហើយដោះឯងដូចជាចង្កោមផ្លែលម៉ើ ៨ អញបានថា អញនឹងឡើងដើមនោះ អញនឹងចាប់ធាងតោងឡើង សូមឲ្យដោះឯងបានដូចជាចង្កោមទំពាំងបាយជូរ ហើយក្លិនខ្យល់ដង្ហើមឯងបានដូចជាផ្លែសារី ៩ នឹងមាត់ឯងក្រអូបដូចជាស្រាទំពាំងបាយជូរយ៉ាងឯក ដែលហូរចុះទៅដោយស្រួលសំរាប់មាសសំឡាញ់អញ ក៏ធ្វើឲ្យបបូរមាត់មនុស្សដេកលក់បាននិយាយឡើង ។ ១០ ខ្ញុំម្ចាស់ជារបស់ផងស្ងួនសំឡាញ់នៃខ្ញុំ ហើយទ្រង់មានសេចក្តីប៉ងប្រាថ្នាចំពោះរូបខ្ញុំម្ចាស់ ១១ ឱស្ងួនសំឡាញ់អើយ សូម*

*មក យើងនឹងចេញទៅឯវាល សូមឲ្យយើងស្នាក់នៅតាមភូមិគេ ១២ យើងនឹងឡើងទៅឯចំការទំពាំងបាយជូរពីព្រលឹម សូមឲ្យយើងទៅមើលបើទំពាំងបាយជូរបានបិុចឡើង ឬមានផ្កាហើយឬនៅ ហើយបើដើមទទឹមកំពុងផ្កាឬទេ នៅទីនោះខ្ញុំម្ចាស់នឹងប្រគល់សេចក្តីស្រឡាញ់ថ្វាយទ្រង់ (បទចម្រៀងសាឡូម៉ូន ៧:៦-១២)។*

គូស្វាមីភរិយាត្រូវមានសេចក្តីរីករាយជាមួយនឹងប្តីឬប្រពន្ធរបស់ពួកគេតាមរយៈការរួមភេទ។ ពិតប្រាកដណាស់ ការរួមភេទគឺជាការអបអរសារទរនៃទំនាក់ទំនង ជាវិធីក្នុងការបង្ហាញសេក្តីរីករាយជាមួយនឹងគ្នា។

**៤. បំណងព្រះហឫទ័យរបស់ព្រះអម្ចាស់នៅក្នុងការរួមភេទ គឺដើម្បីបម្រើដល់ប្តីឬប្រពន្ធ**

នៅក្នុង ១កូរិនថូស៧:៣-៤ សាវ័កប៉ុលបាននិយាយថា៖

*៣ ត្រូវឲ្យប្តីប្រព្រឹត្តនឹងប្រពន្ធដោយចិត្តសប្បុរស ហើយត្រូវឲ្យប្រពន្ធប្រព្រឹត្តនឹងប្តីក៏ដូច្នោះដែរ ៤ ប្រពន្ធមិនមែនជាម្ចាស់លើរូបកាយខ្លួនឯងទេ គឺជាប្តីវិញ ហើយប្តីក៏មិនមែនជាម្ចាស់លើរូបកាយខ្លួនឯងដែរ គឺជាប្រពន្ធវិញ ៥ ដូច្នេះ កុំឲ្យបង្អត់គ្នាឡើយ លើកតែស្រុះចិត្តគ្នាក្នុង១ពេល ដើម្បីឲ្យបានទំនេរនឹងអធិស្ឋាន រួចត្រូវវិលមកនៅជាមួយគ្នាវិញ ក្រែងអារក្សសាតាំងល្បួងលួងអ្នករាល់គ្នា ដោយមិនចេះអត់ទ្រាំ។*

សាវ័កប៉ុលបានបង្រៀនប្រពន្ធត្រូវតែផ្តល់សិទ្ធិជាប្តីដល់ម្ចាស់លើរូបកាយរបស់ខ្លួន ហើយប្តីក៏ត្រូវធ្វើដូចគ្នាដែរ(ខ៤)។ ពួកគេមិនគួរដកហូតការរួមភេទជាអាវុធ ដើម្បីរកផ្លូវឬដាក់ទោសដល់ដៃគូរបស់ខ្លួនឡើយ។ សាវ័កប៉ុលបាននិយាយយ៉ាងចំៗថាកុំ "បង្អត់គ្នា" លើកលែងតែ "យល់ព្រមគ្នា" ជាបណ្តោះអាសន្នដោយហេតុផលខាងវិញ្ញាណប៉ុណ្ណោះ (ខ ៥)។

នៅពេលដែលខ្ញុំរៀបការរួច ខ្ញុំបានទទួលការប្រឹក្សាអំពីការរួមភេទពីបុរសកោតខ្លាចព្រះម្នាក់។ គាត់បាននិយាយថា នៅពេលដែលគាត់រៀបការដំបូងគាត់និងប្រពន្ធរបស់គាត់បានធ្វើកិច្ចព្រមព្រៀងជាមួយគ្នា។ នៅពេលដែលមានម្នាក់ខឹង ឬក៏ម្នាក់ទៀតមិនមានអារម្មណ៍ចង់រួមភេទនោះទេ ម្នាក់ទៀតនឹងនៅតែមានបំណងចិត្តក្នុងការបំពេញចិត្តដល់ដៃគូរបស់ខ្លួន ដូចជាព្រះគម្ពីរបានបង្រៀនដែរ។ គាត់ឬនាងនឹងនិយាយទៅកាន់គ្នាថា *"ទោះបីជាខ្ញុំមិនមានពេលនេះក៏ដោយ ប៉ុន្តែប្រសិនបើអ្នកចង់បានខ្ញុំក៏ចង់បម្រើអ្នកដែរ"* គូស្វាមីភរិយាត្រូវរៀនពីទស្សនៈនៃការរួមភេទដូចជាព័ន្ធកិច្ចចំពោះគ្នាទៅវិញទៅមក ហើយប្តេជ្ញាតែងតែអាចបំពេញសេចក្តីត្រូវការរបស់ដៃគូ។

គួរឲ្យស្តាយ ជាញឹកញាប់ការរួមភេទនៅក្នុងអាពាហ៍ពិពាហ៍ គឺអំពីការបំពេញអារម្មណ៍រំភើប(តណ្ហា) ឬឈានការដល់ចំណុចកំពូលជាជាងការបម្រើ។ ជាលទ្ធផលប្តីឬប្រពន្ធអាចនៅតែមានអារម្មណ៍ស៊ាំ ឬមិនពេញចិត្តជាមួយនឹងការរួមរួមភេទនៅក្នុងអាពាហ៍ពិពាហ៍។ ទោះជាយ៉ាងណាក៏ដោយ នេះមិនមែនជាផែនការរបស់ព្រះជាម្ចាស់នោះឡើយ។ ភីលីព២:៣-៤និយាយថា៖

*៣ កុំឲ្យធ្វើអ្វី ដោយទាស់ទែងគ្នា ឬដោយសេចក្តីអំនួតឥតប្រយោជន៍ឡើយ តែចូររាប់អានគេឲ្យលើសជាងខ្លួនដោយចិត្តសុភាពវិញ៤ កុំឲ្យគ្រប់គ្នាស្វែងរកតែប្រយោជន៍ផ្ទាល់ខ្លួនឡើយ ត្រូវស្វែងរកចំពោះអ្នក*

*ដទៃផង។*

នៅក្នុងការរួមភេទ ក៏ដូចជាគ្រប់ទំនាក់ទំនងទាំងអស់ គ្មានអ្វីធ្វើសម្រេចបានដោយសារចិត្តអាត្មានិយមនោះទេ ប៉ុន្តែគួរតែជាការបម្រើដល់គ្នាទៅវិញទៅមកជាចម្បងវិញ។ នៅក្នុងការរួមភេទ គោលបំណងរបស់ស្វាមីគួរតែជាសេចក្តីសុខរបស់ប្រពន្ធនឹងគោលបំណងរបស់ប្រពន្ធគួរតែជាសេចក្តីសុខរបស់ស្វាមី។

តើការនេះអាចកើតឡើងបានយ៉ាងដូចម្តេចនៅពេលដែលប្តីឬប្រពន្ធគ្មានតម្រេក? នៅក្នុងអាពាហ៍ពិពាហ៍ភាគច្រើន ដៃគូម្ខាងតែងតែមានអារម្មណ៍ជាងដៃគូរបស់ខ្លួន។ ពីព្រោះផែនការរបស់ព្រះសម្រាប់ការរួមភេទនៅក្នុងអាពាហ៍ពិពាហ៍ គឺឲ្យគ្រប់ប្តីឬប្រពន្ធស្វែងរកសេក្តីសុខឲ្យគ្នាទៅវិញទៅមក។ នេះមានន័យថា ប្តីឬប្រពន្ធមួយនឹងមានការរួមភេទលើសពីអារម្មណ៍ ហើយម្នាក់ទៀតនឹងមានអារម្មណ៍តិចជាង។ ម្នាក់ៗគួរតែបន្តស្វែងរកការបម្រើការចាប់អារម្មណ៍ដល់គ្នានៅក្នុងទំនាក់ទំនងរួមភេទជាដៃគូររបស់ខ្លួន។

ជាការពិត មិនគួរឲ្យមាននរណាម្នាក់មានអារម្មណ៍ថា ដូចត្រូវបានគេបង្ខំនោះឡើយ ប៉ុន្តែប្រសិនបើប្តីឬប្រពន្ធកំពុងតែខ្វះអារម្មណ៍ផ្លូវភេទប្តីឬប្រពន្ធបម្រើដល់ដៃគូរបស់ខ្លួននោះ ដៃគូគួរតែអធិស្ឋាននិងសុំព្រះសម្រាប់ប្រទានព្រះគុណដើម្បីបម្រើដល់ដៃគូ។ ជាការពិត ការអនុវត្តដ៏ឈ្លាសវៃសម្រាប់ដៃគូរគឺបន្តអធិស្ឋានទៅបម្រើដល់ដៃគូររបស់ខ្លួនជាជាងសម្ព័ន្ធភាពផ្លូវភេទ។ តាមរយៈការបម្រើដល់ដៃគូ ពួកគេកំពុងតែថ្វាយព្រះកិត្តិយសដល់ព្រះនិងការរចនារបស់ទ្រង់សម្រាប់អាពាហ៍ពិពាហ៍។

លើសពីនេះទៅទៀត គូស្វាមីភរិយាគួរតែបម្រើការរួមភេទគ្នាទៅវិញទៅមកដោយការយល់ថាមានព្រះគុណ (យ៉ាកុប ៤: ៦ កាឡាទី ៥: ២២-២៣ យ៉ូហាន ១៥: ៥) ។ បំណងព្រះហឫទ័យព្រះជាម្ចាស់ផ្តល់ឲ្យគូស្វាមីភរិយានូវព្រះគុណដើម្បីស្រឡាញ់ បម្រើ និងប្រទានពរដល់សម្ព័ន្ធភាពផ្លូវភេទរបស់ពួកគេ ពីព្រោះនេះជាព្រះហឫទ័យរបស់ទ្រង់សម្រាប់អាពាហ៍ពិពាហ៍។ គូស្វាមីភរិយាម្នាក់ៗគួរតែទូលអង្វរព្រះជាទៀងទាត់ចំពោះការចាក់ប្រេងតាំងរបស់ព្រះអង្គលើសម្ព័ន្ធភាពរបស់ពួកគេ។

**៥. បំណងព្រះហឫទ័យរបស់ព្រះសម្រាប់ការរួមភេទ គឺការការពារចេញពីភាពអសីលធម៌ផ្លូវភេទ និងការល្បួងផ្សេងៗ**

១កូរិនថូស ៧:១-២ និយាយថា, «១ ឯសេចក្ដីដែលអ្នករាល់គ្នាបានផ្ញើទៅសួរខ្ញុំ នោះខ្ញុំយល់ឃើញថា បើមនុស្សប្រុសមិនដែលប៉ះពាល់នឹងស្រីសោះ នោះល្អជាជាង២ តែ ដោយព្រោះមានការសហាយស្មន់កើតឡើង បានជាគួរឲ្យគ្រប់គ្នាមានប្រពន្ធជារបស់ផងខ្លួនវិញ ហើយគ្រប់ទាំងស្រីក៏ត្រូវមានប្ដីជារបស់ផងខ្លួនដែរ»

លោកប៉ុលបានបង្រៀនថា អាពាហ៍ពិពាហ៍ហើយនិងការរួមភេទនៅក្នុងអាពាហ៍ពិពាហ៍ គឺដើម្បីការពារគូរស្វាមីភរិយាចេញពីសេចក្តីល្បួងផ្សេងៗដែលនាំទៅរកភាពអសីលធម៌ខាងឯផ្លូវភេទ។ ជាការពិតណាស់ លោកប៉ុលបានបន្ថែមទៀតថា៖ (១កូរិនថូស៧:៥)

*«ដូច្នេះ កុំឲ្យបង្អត់គ្នាឡើយ លើកតែស្រុះចិត្តគ្នាក្នុង១ពេល ដើម្បីឲ្យបានទំនេរនឹងអធិស្ឋាន រួចត្រូវ*

*វិលមកនៅជាមួយគ្នាវិញ ក្រែងអារក្សសាតាំងល្បួងល្បួងអ្នករាល់គ្នា ដោយមិនចេះអត់ទ្រាំ*» ។

នៅពេលដែលគូស្វាមីភរិយាមិនបានអនុវត្តទៀងទាត់ក្នុងការរួមភេទ នោះវាអនុញ្ញាតឲ្យសាតាំងមកល្បួងពួកគេក្នុងវិធីផ្សេងៗ។ នៅក្នុងវិធីណាខ្លះដែលសាតាំងល្បួងគូស្វាមីភរិយាដែលខ្វះភាពស្ថិតស្ថេរនៃការរួមភេទ?

ជាការពិត វាល្បួងពួកគេឲ្យរួមភេទតាមរយៈតណ្ហាភាពអាសអាភាស ការផិតក្បត់ជាដើម។ល។ ប៉ុន្តែមានការល្បួងជាច្រើនទៀត ដូចជាដៃគូម្ខាងរឺទាំងពីរមិនមានអារម្មណ៍ស្រឡាញ់ មិនមានអារម្មណ៍ឬបំណងចិត្ត ការធ្លាក់ទឹកចិត្តនិងឬអសន្តិសុខ។ ខ្ញុំបានយល់ឃើញថាការនេះជារឿងធម្មតាសម្រាប់ភរិយាជាពិសេសបន្ទាប់ពីមានកូនរួច។ នៅពេលដែលសម្ព័ន្ធផ្លូវភេទមិនស្ថិតស្ថេរ ពួកគេត្រូវបានល្បួងឲ្យមានអារម្មណ៍មិនទាក់ទាញ និងមិនស្រឡាញ់។ វាក្លាយជាការបើកទ្វារចំហសម្រាប់សាតាំងដើម្បីជាន់ឈ្លីស្ត្រីនៅក្នុងអាពាហ៍ពិពាហ៍។ ជាមួយប្តី នៅពេលដែលសម្ព័ន្ធផ្លូវភេទមិនស្ថិតស្ថេរ វាហាក់ដូចជាគាត់ងាយធ្លាក់ទៅក្នុងសេចក្តីល្បួងផ្លូវភេទ។ នេះអាចមកពីប្តីធ្វើការច្រើននៅក្រៅផ្ទះជុំវិញសមាជិកភេទផ្ទុយគ្នា។ វាជាការឈ្លាសវៃសម្រាប់ស្វាមីនិងភរិយាក្នុងការចាត់ទុកភាពស្និទ្ធស្នាលខាងផ្លូវភេទជាការការពារចាំបាច់ពីឧបាយកលអាក្រក់របស់សត្រូវ។

ដូចជាឧទាហរណ៍ ខ្ញុំមានមិត្តភក្តិម្នាក់ចែករំលែកថា ពេលគាត់ទើបរៀបការហើយដំបូងសាតាំងបានវាយប្រហារតាមរយៈបន្ទប់គេង។ វាបានក្លាយជាប្រភពនៃអសន្តិសុខ ការភ័យខ្លាច និងការមិនចុះសម្រុងគ្នាយ៉ាងខ្លាំង។ គូស្វាមីភរិយាជាច្រើននឹងនិយាយដូចគ្នា។ ចំពោះហេតុផលនេះ គូស្វាមីភរិយាត្រូវតែអនុវត្តភាពស្មោះត្រង់នៅក្នុងការនេះ ហើយមើលវា មិនត្រឹមតែជាមធ្យោបាយ ដើម្បីបង្កើនអាពាហ៍ពិពាហ៍របស់ពួកគេតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង ដើម្បីការពារអាពាហ៍ពិពាហ៍របស់ពួកគេផងដែរ។ ព្រះវិហារខ្លះក្នុងប៉ុន្មានឆ្នាំថ្មីៗនេះបានអភិវឌ្ឍយុទ្ធនាការរៀបការដែលគូស្វាមីភរិយាប្តេជ្ញាមានការរួមភេទជារៀងរាល់ថ្ងៃរយៈពេលមួយសប្តាហ៍ ឬមួយខែជាវិន័យខាងវិញ្ញាណ ដើម្បីបង្កើនជាសុខភាពនៃអាពាហ៍ពិពាហ៍។ នេះប្រហែលជាមានអ្វីលើសពីនេះទៅទៀត ប៉ុន្តែគោលការណ៍នៅពីក្រោយវាគឺចេញពីព្រះគម្ពីរ។ សម្រាប់ខ្ញុំផ្ទាល់ ខ្ញុំគិតថា វាគឺជាភាពឈ្លាសវៃសម្រាប់ប្តីប្រពន្ធ ដើម្បីបង្កើតផែនការឬកាលវិភាគប្រចាំសប្តាហ៍អនុវត្តន៍ភាពស្និទ្ធស្នាលក្នុងការរួមភេទ។ សាតាំងនឹងប្រើភាពរវល់ ការនឿយហត់ កូនព័ន្ធកិច្ចជាដើម ដើម្បីឃាំងប្តីប្រពន្ធចេញពីព្រះពរនៃការរួមភេទនេះ។

សុភាសិត ២១:៥ ចែងថា «*គំនិតរបស់មនុស្សឧស្សាហ៍ នោះនាំឲ្យបានបរិបូរឡើងតែម្យ៉ាង តែអស់អ្នកណាដែលមានចិត្តលេះរលាំង នោះនឹងបានតែសេចក្តីខ្វះខាតវិញ*» អ្នកណាដែលមានផែនការផែនការនោះដើម្បីជាគជ័យ ហើយអ្នកណាដែលគ្មានផែនការ នោះនឹងត្រូវបរាជ័យ។

ខ្ញុំសូមបន្ថែមការប្រុងប្រយ័ត្ននៅពេលគូស្វាមីភរិយាមានកូន។ កំណើតរបស់កូនៗបន្ថែមបញ្ហាប្រឈមថ្មីៗដល់ភាពស្និទ្ធស្នាលរបស់ប្តីប្រពន្ធ។ ដំណាក់កាលនៃការមានកូនគឺជាព្រះពរដ៏អស្ចារ្យ ប៉ុន្តែវានឹងបើកទ្វារកាន់តែច្រើនសម្រាប់សាតាំង ដើម្បីវាយប្រហារភាពស្និទ្ធស្នាលខាងផ្លូវភេទក្នុងអាពាហ៍ពិពាហ៍។ ជាច្រើនដងកូនៗក្លាយជាចំណុចសំខាន់នៃអាពាហ៍ពិពាហ៍។ នៅក្នុងវប្បធម៌ខ្លះ ភរិយានឹងតែងតែគេងជាមួយកូនច្រើនឆ្នាំ។ នៅពេលខ្លះទៀត គូស្វាមីភរិយានឹងត្រូវតែមានលក្ខណៈជាយុទ្ធ

សាស្ត្រថែមទៀត។ សាតាំងនឹងមិនបញ្ឈប់ការវាយប្រហារអាពាហ៍ពិពាហ៍ដោយសារតែកូនៗនោះទេ។ ជាក់ស្តែង ការវាយប្រហាររបស់វានឹងប្រហែលជាកើនឡើង។ ហេតុដូច្នេះហើយ គ្រីស្ទបរិស័ទត្រូវតែមានប្រាជ្ញានិងយុទ្ធសាស្ត្រក្នុងរបៀបការពារសម្ព័ន្ធភាពផ្លូវភេទ។

ជាមួយនឹងការនិយាយអស់ទាំងនេះ តើក្នុងវិធីណាខ្លះ ដើម្បីឲ្យការរួមភេទនៅក្នុងអាពាហ៍ពិពាហ៍មានការរីកចម្រើន?

- និយាយដោយបើកចំហរអំពីការនេះ
- មានគំរោងផែនការសម្រាប់ការនេះ
- អនុវត្តន៍ភាពផ្អែមល្ហែមពេញមួយថ្ងៃ
- អធិស្ឋានពីការនេះ
- មានគំនិតច្នៃប្រឌិត
- អានឯកសារគ្រីស្ទបរិស័ទជាច្រើនពីការនេះ

អក្សរសិល្ប៍គ្រីស្ទបរិស័ទអាចផ្តល់នូវការយល់ដឹងដោយគ្មានការសាកល្បងនិងមិនទាក់ទង។ ឧទាហរណ៍ ព្រះបានធ្វើឲ្យរាងកាយរបស់ស្ត្រីខុសពីបុរស។ រាងកាយរបស់ស្ត្រីជាធម្មតាចំណាយពេលយូរ ដើម្បីធ្វើឲ្យមានការរំភើប ហើយពួកគេមានអារម្មណ៍រំជួលចិត្តច្រើនជាងបុរស។ ដើម្បីឲ្យស្វាមីបម្រើភរិយា ជាធម្មតាវានឹងចាប់ផ្តើម មុនពេលចូលបន្ទប់គេងតាមរយៈការប៉ះពាល់ ការប្រាស្រ័យទាក់ទងនិងបម្រើប្រកបដោយសេចក្តីស្រឡាញ់។

សរុបសេចក្តីមកការរួមភេទគឺជាការអបអរមួយដែលព្រះបានបង្កើតដើម្បីធ្វើឲ្យ អាពាហ៍ពិពាហ៍មានភាពប្រសើរឡើង។ វាគឺជាកន្លែងដែលភាពស្និទ្ធស្នាលនិងសាមគ្គីភាពត្រូវបានបណ្តុះកន្លែងដែលអព្ភូតហេតុនៃការបង្កើតកូនបានកើតឡើង ហើយជាកន្លែងដែលសេចក្តីអំណរដ៏បរិសុទ្ធត្រូវបានបង្ហូរមក។ ទោះជាយ៉ាងណាក៏ដោយ វាក៏ជាកន្លែងមួយដែលសាតាំងវាយប្រហារជាទូទៅដែរ។ គូស្វាមីភរិយាត្រូវការពារវាហើយបណ្តុះវាដើម្បីបង្កើនភាពស្និទ្ធស្នាលនឹងគ្នា។

### ភាពស្និទ្ធស្នាលខាងឯវិញ្ញាណ

វិធីចុងក្រោយនៃការបង្កើតភាពស្និទ្ធស្នាល គឺតាមរយៈការបណ្តុះភាពស្និទ្ធស្នាលខាងឯវិញ្ញាណ។នេះប្រហែលអាចជាចំណុចដែលគេព្រងើយកន្តើយបំផុតនៃភាពស្និទ្ធស្នាលក្នុងអាពាហ៍ពិពាហ៍។ មនុស្សបណ្តុះគំនិតនិងរាងកាយ ប៉ុន្តែជារឿយៗភ្លេចផ្នែកខាងឯវិញ្ញាណ។ គូស្វាមីភរិយាជាច្រើនក្នុងអាពាហ៍ពិពាហ៍ សូម្បីតែអាពាហ៍ពិពាហ៍មានរយៈពេលយូរជាងម្ភៃឆ្នាំមកហើយដែលជាទូទៅនិយាយទៅកាន់ខ្លួនគេថា «មានអ្វីមួយដែលបាត់» ។ ទិដ្ឋភាពខាងវិញ្ញាណច្រើនតែជាដំណភ្ជាប់ដែលបាត់ទៅនឹងអាពាហ៍ពិពាហ៍ដែលជោគជ័យ។

ទិដ្ឋភាពមួយដែលញែកមនុស្សនិងសត្វគឺជាការពិតដែលថាព្រះជាម្ចាស់បានប្រទានវិញ្ញាណដល់មនុស្សក្នុងការទាក់ទងជាមួយទ្រង់។ វាគឺជាមុខងារខ្ពស់បំផុតរបស់មនុស្សជាតិហើយនៅពេលដែលគេធ្វេសប្រហែស នោះមានន័យថា មនុស្សមានភាពមួយដែលស្រដៀងនឹងសត្វដែរ។ ពួកគេត្រូវបានជំរុញ

ដោយសភាវគតិមូលដ្ឋានរបស់ពួកគេដើម្បីចិញ្ចឹម រួមភេទ សុវត្ថិភាពនិងមានអំណាច។ មនុស្សជាតិមានគោលបំណងចង់មានទំនាក់ទំនងជាមួយព្រះ។ ក្នុងសាច់រឿងនៅគម្ពីរ លោកុប្បត្តិ បានបន្តបង្ហាញពីរបៀបដែលមនុស្សដើរហើយនិយាយជាមួយព្រះ (លោកុប្បត្តិ ២: ១៦-១៧, ៥:២៤, ៦: ៩, ១៣) ។ នៅពេលគូស្វាមីភរិយាបណ្តុះជីវិតខាងវិញ្ញាណជាមួយគ្នា នោះពួកគេកាន់តែបង្កើនភាពស្និទ្ធស្នាលនឹងគ្នាខ្លាំងឡើង។

តើមានវិធីអ្វីខ្លះដែលគូស្វាមីភរិយាបង្កើនភាពស្និទ្ធស្នាលខាងវិញ្ញាណ?

**១. គូស្វាមីភរិយាគួរតែដាក់កាលវិភាគក្នុងការស្វែងរកព្រះជាម្ចាស់តាមរយៈការអធិស្ឋាននិងព្រះបន្ទូលរបស់ព្រះលក្ខណៈជាក្រុមគ្រួសារ (១កូរិនថូស៧:៥)**

ការនេះអាចត្រូវបានធ្វើជារៀងរាល់ពេលយប់ឬពេលព្រឹកម្តងឬពីរដងក្នុងមួយសប្តាហ៍ ឬសូម្បីតែនៅពេលម៉ោងអាហារ។ ជាទូទៅ គូស្វាមីភរិយាគួរតែព្យាយាមបញ្ចូលការអធិស្ឋាននិងអានព្រះគម្ពីរឲ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន នៅពេលចាប់ផ្តើមថ្ងៃរបស់ខ្លួន នៅពេលបើកបរ ពេលញ៉ាំអាហារ ពីមុនពេលទៅព្រះវិហារ មុនពេលដាក់កូនឲ្យគេងជាដើម។ (ចោទិយកថា ៦: ៦-៩) ) ។

**២. គូស្វាមីភរិយាគួរតែថ្វាយបង្គំជាមួយគ្រីស្ទបរិស័ទផ្សេងទៀតជារៀងរាល់អាទិត្យ អ្នកគួរតែក្លាយជាសមាជិកនៃក្រុមជំនុំផ្សព្វផ្សាយព្រះគម្ពីរនិងចូលរួមការបម្រើថ្ងៃអាទិត្យ ក្រុមតូចៗ ការប្រជុំអធិស្ឋានជាដើម។ ល។**

ព្រះគម្ពីរបានបញ្ជាឲ្យយើង «កុំធ្វេសប្រហែស» ការជួបជុំគ្នាទៅវិញទៅមកក្នុងគោលបំណងលើកទឹកចិត្តគ្នា (ហេព្រើរ ១០ : ២៥) ។ ជាមួយការនេះ ជាទូទៅគូស្វាមីភរិយានឹងរកឃើញថា ព្រះគម្ពីរពិតជាជួយអភិវឌ្ឍការតភ្ជាប់គ្នាខាងវិញ្ញាណជាមួយគូស្វាមីភរិយាគ្រីស្ទបរិស័ទដទៃទៀតនៅក្នុងឆាកជីវិតដូចគ្នា ហើយក៏ដូចជាមួយនឹងអស់អ្នកណាដែលអាចជួយណែនាំដល់ពួកគេផងដែរ។

**៣. គូស្វាមីភរិយាគួរតែស្វែងរកវិធីនៃការបម្រើដល់ព្រះជាម្ចាស់និងបម្រើអ្នកដទៃជាមួយគ្នា**

បដិសណ្ឋារកិច្ចគួរតែជាវិធីមួយនៃការបម្រើ។ ហេព្រើរ១៣:១-២ ចែងថា៖ *«១ចូរឲ្យមានសេចក្ដីស្រឡាញ់គ្នា ជាបងប្អូនជានិច្ច២ កុំឲ្យភ្លេចសេចក្ដីចៅរ៉ៅឡើយ ដ្បិតមនុស្សខ្លះបានទទួលទាំងទេវតាឲ្យសំណាក់នៅឥតដឹងផង ដោយមានសេចក្ដីនោះឯង»* គូស្វាមីភរិយាគួរតែបើកទ្វារផ្ទះរបស់ពួកគេដើម្បីប្រទានពរដល់អ្នកដទៃ។ ទោះជាយ៉ាងណាក៏ដោយ ការបម្រើមិនគួរត្រូវបានកំណត់ត្រឹមតែភាពចៅរ៉ាវឬបដិសណ្ឋារកិច្ចនោះទេ។ ព្រះអាចត្រាស់ហៅគូស្វាមីភរិយាមួយចំនួន ដើម្បីចូលរួមក្នុងព័ន្ធកិច្ចក្មេងជំទង់ កុមារ អ្នកជិតខាង អ្នកគ្មានផ្ទះសម្បែង ស្ត្រីមេម៉ាយជាដើម។ ល។

តើអ្នកនឹងបណ្តុះជីវិតខាងវិញ្ញាណជាមួយគ្នានៅក្នុងអាពាហ៍ពិពាហ៍យ៉ាងដូចម្តេច? ពិតណាស់គូស្វាមីភរិយាមិនគួរធ្វេសប្រហែសឬព្រងើយកន្តើយចំពោះការលះបង់ផ្ទាល់ខ្លួន ការថ្វាយបង្គំផ្ទាល់ខ្លួន និងអំណោយទានរៀងៗខ្លួននោះទេ ប៉ុន្តែដើម្បីក្លាយជា« សាច់តែមួយ» ក្នុងអាពាហ៍ពិពាហ៍ (លោកុប្បត្តិ ២:២៤) ពួកគេក៏គួរតែបណ្តុះជីវិតខាងវិញ្ញាណជាមួយគ្នាផងដែរ។

**សរុបសេចក្តី**

ភាពស្និទ្ធស្នាល គឺជាផ្នែកសំខាន់មួយនៃអាពាហ៍ពិពាហ៍។ ព្រះបានបង្កើតមនុស្សឲ្យមានត្រីឯកសាមគ្គីភាពជាមួយនឹងរូបកាយ ព្រលឹង និងវិញ្ញាណ (ថែស្សាឡូនីចទី ១ ៥:២៣, ហេព្រើរ ៤:១២) ហើយគ្រប់សេចក្តីទាំងនេះត្រូវតែបណ្តុះ ដើម្បីអភិវឌ្ឍភាពស្និទ្ធស្នាលក្នុងអាពាហ៍ពិពាហ៍។ គូស្វាមីភរិយាធ្វើបែបនេះដោយបណ្តុះមិត្តភាព (ព្រលឹង) ការរួមភេទ (រាងកាយ) និងខាងវិញ្ញាណ (វិញ្ញាណ) ។ ការអភិវឌ្ឍន៍ផែនការ ដើម្បីបណ្តុះបណ្តាលភាពស្និទ្ធស្នាលទាំងបីនេះនឹងជួយពង្រឹងអាពាហ៍ពិពាហ៍របស់មនុស្សម្នាក់ៗ។

តើព្រះជាម្ចាស់ត្រាស់ហៅអ្នកឲ្យអភិវឌ្ឍយុទ្ធសាស្ត្រនៃភាពស្និទ្ធស្នាលក្នុងអាពាហ៍ពិពាហ៍ដោយរបៀបណា?

**ភាពស្និទ្ធស្នាលក្នុងអាពាហ៍ពិពាហ៍ កិច្ចការផ្ទះ**

ឆ្លើយនឹងសំនួរទាំងនេះ  ហើយពិភាក្សាជាមួយគ្នា

១. តើមានអ្វីថ្មីឬលេចធ្លោមកក្នុងគំនិតអ្នកនៅក្នុងវគ្គនេះ? តើអ្នកត្រូវបានជំរុញឬលើកទឹកចិត្តក្នុងរបៀបណាខ្លះ? តើមានចំណុចឬគំនិតណាដែលអ្នកមិនយល់ស្របឬទេ?

២. តើអ្នកអាចពណ៌នាភាពស្និទ្ធស្នាលនិងសារៈសំខាន់របស់វានៅក្នុងអាពាហ៍ដោយរបៀបណា?

៣. តើមានការប្រែប្រួលអ្វីខ្លះដែលត្រូវបានគេស្គាល់ដែលអ្នកគិតថាអាចធ្វើឲ្យមានការរំខានដល់ពេលវេលាប្រចាំថ្ងៃតែម្នាក់ឯងជាមួយប្តីឬប្រពន្ធរបស់អ្នកនិងការចែករំលែកជិតស្និទ្ធ(ឧទាហរណ៍ ការងារ ចំណង់ចំណូលចិត្ត បុគ្គលិកលក្ខណៈ ការភ័យខ្លាចជាដើម) ឬទេ? តើឃាតករភាពស្និទ្ធស្នាលអ្វីខ្លះដែលអ្នកនិងដៃគូរបស់អ្នកត្រូវប្រុងប្រយ័ត្ន? តើអ្នកនឹងរុករកការទាំងនេះដើម្បីបណ្តុះមិត្តភាពរបស់អ្នកយ៉ាងដូចម្តេច?

៤. ចូរសរសេរចុះនូវសកម្មភាព៧យ៉ាងដែលអ្នកចូលចិត្តធ្វើ ដើម្បីភាពសប្បាយរីករាយ។ សរសេរចុះសកម្មភាព៧យ៉ាងដែលប្ដីប្រពន្ធអ្នកចូលចិត្តធ្វើដើម្បីភាពរីករាយ។ តើសកម្មភាពអ្វីខ្លះដែលអ្នកនិងប្ដីឬប្រពន្ធរបស់អ្នកនឹងធ្វើជាមួយគ្នា? តើសកម្មភាពអ្វីខ្លះដែលអ្នកមានចិត្តចង់រៀនពីរបៀបធ្វើវាឬរីករាយនឹងបង្កើនមិត្តភាពរបស់អ្នកបន្ថែមទៀត?

៥. តើអ្នកនឹងបណ្ដុះទំនាក់ទំនងផ្លូវភេទប្រកបដោយជាសុខភាពដើម្បីការពារអាពាហ៍ពិពាហ៍របស់អ្នកពីការល្បួងរបស់មនុស្សអាក្រក់ (១ កូ ៧: ៥) ដោយរបៀបណា? តើអ្នកនឹងរក្សាជីវិតផ្លូវភេទរបស់អ្នកពីភាពជាប់គាំងយ៉ាងដូចម្ដេច?

៦. តើអ្នកនឹងធ្វើអ្វីខ្លះនៅក្នុងអាពាហ៍ពិពាហ៍នៅពេលដែលអ្នកនិង ឬដៃគូរបស់អ្នកចាប់ផ្ដើមបាត់បង់សេចក្ដីស្រឡាញ់ចំពោះគ្នា? វិវរណៈ២:៤-៥ ផ្ដល់នូវគោលការណ៍ដែលអាចជួយការពារនិងស្ដារសេចក្ដីស្នេហាក្នុងអាពាហ៍ពិពាហ៍។ ព្រះគម្ពីរចែងថា ៤ តែអញប្រកាន់សេចក្ដីនេះនឹងឯង គឺថា ឯងបានបោះបង់ចោលសេចក្ដីស្រឡាញ់ដើមចេញ៥ ដូច្នេះ ចូរនឹកចាំ ដែលឯងបានធ្លាក់ចេញពីសណ្ឋានណានោះ ហើយប្រែចិត្តចុះ រួចប្រព្រឹត្តតាមការដើមដំបូងនោះវិញ ពុំនោះសោត អញនឹងមកឯឯង ហើយនឹងហូតយកជើងចង្កៀងឯងពីកន្លែងចេញ លើកតែឯងប្រែចិត្តឡើងវិញ។

បរិបទនៃខគម្ពីរនេះគឺព្រះយេស៊ូវមានបន្ទូលទៅកាន់ពួកជំនុំអេភេសូរដែលបានបាត់បង់សេចក្ដីស្រឡាញ់ចំពោះទ្រង់។ ក្រុមជំនុំមានភាពអស្ចារ្យនៅក្នុងរឿងជាច្រើន (ខ ១-៣)៖ ការអធិប្បាយ ការបង្រៀន  ការស្អប់គោលលទ្ធិខុសឆ្គង និងសេចក្ដីសុចរិត  ប៉ុន្តែពួកគេបានបាត់បង់អ្វីដែលសំខាន់បំផុតគឺសេចក្ដីស្រឡាញ់ដំបូងរបស់ពួកគេចំពោះព្រះគ្រីស្ទ។

សេចក្ដីស្រឡាញ់គឺជាផ្នែកសំខាន់បំផុតនៃទំនាក់ទំនងរបស់យើងជាមួយព្រះ។ នោះហើយជា

មូលហេតុដែលបញ្ញត្តិដ៏សំខាន់បំផុត គឺត្រូវស្រឡាញ់ព្រះឲ្យអស់ពីចិត្ត អស់ពីគំនិត និងអស់ពីព្រលឹងរបស់យើង ម៉ាថាយ ២២: ៣៦-៣៧ ។ ពីព្រោះពួកជំនុំអេភេសូរបានបាត់បង់ការនេះ ព្រះគ្រីស្ទបានសន្យាថានឹងដាក់វិន័យពួកគេដោយដកហូតជើងចង្កៀងរបស់ពួកគេ ជាពន្លឺរបស់ពួកគេនៅក្នុងសហគមន៍ដែលទីបំផុតនឹងបំផ្លាញព្រះវិហារ។ស្រដៀងគ្នាដែរ សេចក្តីស្រឡាញ់គឺជាផ្នែកសំខាន់បំផុតនៃអាពាហ៍ពិពាហ៍។ ដូច្នេះ ឱវាទដែលព្រះគ្រីស្ទបានប្រទានដល់ក្រុមជំនុំនេះអាចត្រូវបានអនុវត្ត ដើម្បីស្តារសេចក្តីស្រឡាញ់ក្នុងអាពាហ៍ពិពាហ៍ឡើងវិញ។ ព្រះគ្រីស្ទបានត្រាស់ហៅឲ្យព្រះវិហារនេះស្តារសេចក្តីស្រឡាញ់របស់ពួកគេឡើងវិញដោយការប្រែចិត្ត (ការទទួលស្គាល់និងងាកចេញពីអំពើបាប) និងធ្វើអ្វីដែលពួកគេបានធ្វើនៅពេលពួកគេចាប់ផ្តើមស្រឡាញ់ព្រះដំបូង(ប្រហែលជាមានពេលវេលាយ៉ាងទូលំទូលាយនៅក្នុងព្រះបន្ទូលនិងការអធិស្ឋាន ការប្រកបគ្នានៅក្នុងព្រះវិហារ សេវាកម្មជាដើម។ ល។ )។ ការឆ្លើយតបប្រភេទនេះចំពោះការខ្វះសេចក្តីស្រឡាញ់ក៏ត្រូវការនៅក្នុងអាពាហ៍ពិពាហ៍ដើម្បីរក្សាឬស្តារភាពស្និទ្ធស្នាលឡើងវិញ។

តើមានអ្វីខ្លះដែលអ្នកបានធ្វើដំបូងនៅដែលពេលអ្នកស្រឡាញ់ជាមួយប្តីឬប្រពន្ធរបស់អ្នក? តើអ្នកអាចបន្តដាំដុះការទាំងនេះយ៉ាងម៉្តចេ ដើម្បីរក្សាស្នេហាដំបូងរបស់អ្នកឬស្តារវាឡើងវិញដោយរបៀបណា?

៧. បន្ទាប់ពីបញ្ចប់វគ្គនេះតើអ្នកមានអារម្មណ៍ថាព្រះកំពុងត្រាស់ហៅអ្នកឲ្យអធិស្ឋានសម្រាប់អាពាហ៍ពិពាហ៍របស់អ្នកយ៉ាងដូចម្តេច? សូមចំណាយពេលខ្លះអធិស្ឋាន។